ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.



# របាយការណ៍ ប្រចាំឆ្នាំ ២០២៤





# មាតិកា

* * *


**អារម្ភកថា**....................i

**អក្សរកាត់**....................vi

**ខ្លឹមសារសង្ខេប**....................x

**ផ្នែកទី១ - របាយការណ៍ប្រចាំឆ្នាំ២០២៤**

I- **សេដ្ឋកិច្ចពិភពលោកនិងតំបន់**....................១

១- កំណើនសេដ្ឋកិច្ចពិភពលោកនិងតំបន់....................១

២- នយោបាយរូបិយវត្ថុអន្តរជាតិ....................២

៣- លំហូរទុនអន្តរជាតិ....................៤

II- **ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា**....................៥

១- កំណើនសេដ្ឋកិច្ច....................៥

២- ស្ថានភាពអតិផរណា....................១០

៣- អត្រាប្តូរប្រាក់....................១២

៤- ស្ថានភាពជញ្ជីងទូទាត់....................១៤

៥- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ....................១៦

III- **ការគ្រប់គ្រងរូបិយវត្ថុ**....................១៨

១- ការផ្គត់ផ្គង់រូបិយវត្ថុ....................១៨

២- ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់....................១៨

៣- អត្រាប្រាក់បម្រុងកាតព្វកិច្ច....................១៩

៤- មូលបត្រអាចជួញដូរបាន....................២០

៥- ការបោះផ្សាយមូលបត្ររដ្ឋ....................២១

៦- ប្រតិបត្តិការផ្តល់សន្ទនីយភាព....................២៣

IV- **ប្រព័ន្ធធនាគារនៅកម្ពុជា**....................២៥

១- ស្ថានភាពទូទៅ....................២៥

២- ស្ថិរភាពហិរញ្ញវត្ថុ....................២៦

៣- វិស័យធនាគារ....................២៨

៤- វិស័យមីក្រូហិរញ្ញវត្ថុ....................២៩

៥- វិស័យភតិសន្យាហិរញ្ញវត្ថុ....................៣០

៦- គ្រឹះស្ថានឥណទានជនបទ....................៣០

៧- អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន....................៣០

៨- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........................................................ ៣៣
៩- ការអនុវត្តបទប្បញ្ញត្តិ ........................................................ ៣៤
១០- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ........................................................ ៣៥
១១- កិច្ចការពារអតិថិជន ........................................................ ៣៥
១២- កិច្ចការពារប្រាក់បញ្ញើ ........................................................ ៣៦
១៣-ហិរញ្ញវត្ថុប្រកបដោយចីរភាព ........................................................ ៣៦
V- **ការផ្តត់ផ្គង់សេវាធនាគារកណ្តាល** ........................................................ ៣៩
១- ប្រព័ន្ធទូទាត់សងប្រាក់ ........................................................ ៣៩
២- សេវាគ្រប់គ្រងគណនី ........................................................ ៤៩
៣- ការគ្រប់គ្រងចរាចរណ៍ធនបត្រ ........................................................ ៥០
៤- ការងារគ្រប់គ្រងអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត ប្រកបអាជីវកម្មប្តូរប្រាក់ និងអាជ្ញាបណ្ណ ប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ........................................................ ៥៣
VI- **ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** ........................................................ ៥៥
១- ការងារត្រួតពិនិត្យបុគ្គលរាយការណ៍ ........................................................ ៥៥
២- ការងារវិភាគ និងបញ្ជូនរបាយការណ៍ ........................................................ ៥៦
៣- កិច្ចសហប្រតិបត្តិការ ........................................................ ៥៦
៤- ការពង្រឹងសមត្ថភាព ........................................................ ៥៩
VII- **កិច្ចសហប្រតិបត្តិការអន្តរជាតិ** ........................................................ ៦១
១- កិច្ចសហប្រតិបត្តិការពហុភាគី ........................................................ ៦១
២- កិច្ចសហប្រតិបត្តិការទ្វេភាគី ........................................................ ៦៩
VIII- **ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា** ........................................................ ៧៤
១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល ........................................................ ៧៤
២- ការអភិវឌ្ឍធនធានមនុស្ស ........................................................ ៧៥
៣- ការងារសវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ........................................................ ៧៩
៤- សាខាធនាគារជាតិនៃកម្ពុជា ........................................................ ៨១
៥- សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ........................................................ ៨២
៦- សារមន្ទីរព្រះស្រីឦសានវរ្ម័ន ........................................................ ៨៣
IX- **ទំនាក់ទំនងសាធារណៈ** ........................................................ ៨៦
១- ការទំនាក់ទំនង ........................................................ ៨៦
២- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ........................................................ ៨៧
៣- កិច្ចសហការជាមួយសមាគម និងស្ថាប័នផ្សេងៗក្នុងការងារផ្សព្វផ្សាយ ........................................................ ៩១

៤- ការផ្សព្វផ្សាយប្រព័ន្ធបាគង ........ ៩១
៥- ការផ្សព្វផ្សាយពីសារៈសំខាន់នៃប្រាក់រៀល ........ ៩២
៦- ការចូលរួមជាវាគ្មិន និងការទទួលពានរង្វាន់លំដាប់អន្តរជាតិ ........ ៩៥
៧- ការរួមចំណែកក្នុងការងារសង្គម ........ ១០០
**សេចក្តីសន្និដ្ឋាន** ........ ១០៥
**ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារឆ្នាំ២០២៥**
១- ការអនុវត្តនយោបាយរូបិយវត្ថុ ........ ១០៩
២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ........ ១១០
៣- ប្រព័ន្ធទូទាត់សងប្រាក់ ........ ១១០
៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ១១០
៥- ការងារបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ ........ ១១១
៦- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........ ១១១
៧- ការងារប្រតិបត្តិការទីផ្សាររូបិយវត្ថុ ........ ១១២
៨- ការងារសេវាធនាគារ ........ ១១២
៩- ការងារគ្រប់គ្រងសាច់ប្រាក់ ........ ១១៣
១០- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ........ ១១៣
១១- ការគ្រប់គ្រងសាខា ........ ១១៣
១២- ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស ........ ១១៣
១៣-កិច្ចសហប្រតិបត្តិការអន្តរជាតិ ........ ១១៤
១៤- ការងារស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច ........ ១១៤
១៥- ការងារស្ថិតិ ........ ១១៥
១៦- ការងារទំនាក់ទំនង ........ ១១៥
១៧-ការងារសារមន្ទីរ ស.ស.រ. ........ ១១៥
១៨- ការងារវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ ........ ១១៦
**ផ្នែកទី៣ - ឧបសម្ព័ន្ធ**
ឧបសម្ព័ន្ធ ១ តារាង ១ -តារាងជម្រើសសូចនាករសេដ្ឋកិច្ច ........ ១១៧
ឧបសម្ព័ន្ធ ២ តារាង ២ -ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវា ........ ១១៨
ឧបសម្ព័ន្ធ ៣ តារាង ៣ -ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ).. ១១៩
ឧបសម្ព័ន្ធ ៤ ប្រអប់ ១ -អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម និងពិត ........ ១២០
ឧបសម្ព័ន្ធ ៥ តារាង ៤ -ស្ថិតិស្ថានភាពធនាគារកណ្តាល ........ ១២២
ឧបសម្ព័ន្ធ ៦ តារាង ៥ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត ........ ១២៣

ឧបសម្ព័ន្ធ ៧ តារាង ៦ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើ............................. ១២៤
ឧបសម្ព័ន្ធ ៨ តារាង ៧ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ......................... ១២៥
ឧបសម្ព័ន្ធ ៩ តារាង ៨ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុ......................................... ១២៦
ឧបសម្ព័ន្ធ ១០ តារាង ៩ -ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច.................... ១២៧
ឧបសម្ព័ន្ធ ១១ តារាង ១០ -ប្រាក់បញ្ញើនៅគ្រឹះស្ថានធនាគារ......................................... ១២៨
ឧបសម្ព័ន្ធ ១២ តារាង ១១ -ជញ្ជីងទូទាត់ប្រទេសកម្ពុជា............................................... ១២៩
ឧបសម្ព័ន្ធ ១៣ តារាង ១២ -បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
ពីឆ្នាំ២០២០ - ខែកញ្ញា ២០២៤.........................................................១៣០
ឧបសម្ព័ន្ធ ១៤ បញ្ជីលេខទូរសព្ទទំនាក់ទំនងអំពីចម្ងល់និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់
សេវាហិរញ្ញវត្ថុ ........................................................................... ១៣២

# អារម្ភកថា

នាឆ្នាំ២០២៤នេះ សេដ្ឋកិច្ចពិភពលោកត្រូវបានប៉ាន់ស្មានថាមានកំណើន ប្រហាក់ប្រហែលនឹងឆ្នាំកន្លងទៅ ដែលត្រូវបានចាត់ទុកថាមានភាពធន់ ប្រឈមនឹងការកើនឡើងនៃភាពតានតឹងភូមិសាស្ត្រនយោបាយ ការថយចុះល្បឿនកំណើនចិន និងភាពរឹតត្បិតស្ថានភាពហិរញ្ញវត្ថុអន្តរជាតិ។ អតិផរណាពិភពលោកបានថយចុះជាលំដាប់ ពីកម្រិតមួយខ្ពស់កាលពីជាងពីរឆ្នាំមុន ដែលបណ្តាលមកពីការរអាក់រអួលនៃការផ្គត់ផ្គង់ ដោយសារហេតុការណ៍ជាបន្តបន្ទាប់ផ្តើមចេញពីវិបត្តិកូវីដ-១៩ ហើយក្រោយមកពីការអូសបន្លាយសង្គ្រាមនៅរុស្ស៊ីនិងអ៊ុយក្រែន និងជម្លោះប្រដាប់អាវុធនៅតំបន់មជ្ឈិមបូព៌ា។ ក្នុងការប្រឆាំងនឹងអតិផរណា ប្រទេសអភិវឌ្ឍន៍ចម្បងៗបានអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិត តាមរយៈការដំឡើងអត្រាការប្រាក់គោលដើម្បីកាត់បន្ថយតម្រូវការប្រើប្រាស់និងវិនិយោគ។ ក៏ប៉ុន្តែដោយសារអតិផរណាមានប្រភពពីការផ្គត់ផ្គង់ ប្រសិទ្ធភាពនយោបាយរូបិយវត្ថុក្នុងការកាត់បន្ថយអតិផរណាទាមទារពេលវេលាយូរ ដើម្បីឈានទៅសម្រេចតាមគោលដៅ។ ការរក្សាអត្រាការប្រាក់គោលខ្ពស់ក្នុងរយៈពេលវែង បានបង្កផលប៉ះពាល់បន្ថែមដល់សេដ្ឋកិច្ចកំពុងលូតលាស់និងកំពុងអភិវឌ្ឍ តាមរយៈលំហូរចេញនៃមូលធន ដែលធ្វើឱ្យអត្រាការប្រាក់ក្នុងស្រុកកើនឡើង និងតម្លៃរូបិយប័ណ្ណធ្លាក់ចុះ ហើយតម្រូវឱ្យធនាគារកណ្តាលដំឡើងអត្រាការប្រាក់គោលរបស់ខ្លួន ជាមួយនឹងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ទោះបីជាប្រឈមនឹងការកាត់បន្ថយឥណទានដល់សេដ្ឋកិច្ចនិងបាត់បង់ទុនបម្រុងអន្តរជាតិក៏ដោយ។ ការថយចុះនៃអត្រាអតិផរណាទៅរកអត្រាគោលដៅនៅប្រទេសអភិវឌ្ឍន៍ បាននាំឱ្យធនាគារកណ្តាលកាត់បន្ថយអត្រាការប្រាក់គោលសន្សឹមៗ ចាប់តាំងពីដើមឆមាសទី២ ឆ្នាំ២០២៤ មក។

នៅកម្ពុជា សេដ្ឋកិច្ចបានទទួលផលពីកំណើនសេដ្ឋកិច្ចពិភពលោក ប៉ុន្តែក៏រងផលប៉ះពាល់ពីការអនុវត្តនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ផងដែរ ជាពិសេសលើការកើនឡើងនៃអត្រាការប្រាក់និងការប្រែប្រួលនៃអត្រាប្តូរប្រាក់។ កំណើននៅក្នុងសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ដែលជាទីផ្សារនាំចេញរបស់កម្ពុជា បានបង្កើនតម្រូវការផលិតផលកាត់ដេរ កម្មន្តសាលមិនមែនកាត់ដេរថ្មីៗមួយចំនួន និងផលិតផលកសិកម្មពីកម្ពុជា ដែលបន្តផ្តល់ភាពទាក់ទាញដល់ការវិនិយោគនៅក្នុងវិស័យទាំងនេះផងដែរ។ ទន្ទឹមនេះ កំណើនភ្ញៀវអន្តរជាតិ ក៏បានរួមចំណែកជាលំដាប់ក្នុងការទ្រទ្រង់កំណើន បើទោះបីជាវិស័យសំណង់និងអចលនទ្រព្យមានកំណើនទាបក៏ដោយ។ នៅក្នុងស្ថានភាពនេះ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ប្រកបដោយពិលាសដោយបានដាក់ចេញវិធានការគាំទ្រជាបន្តបន្ទាប់ សំដៅបង្កើនល្បឿននៃពិពិធកម្មមូលដ្ឋានកំណើន កំណែទម្រង់ ការប្រើប្រាស់ប្រព័ន្ធឌីជីថល និងការជំរុញវិស័យដែលកំពុងមានបញ្ហាប្រឈម និងមិនទាន់ទទួលបានកំណើនរឹងមាំនៅឡើយ ជាពិសេសវិស័យសំណង់ អចលនទ្រព្យ ទេសចរណ៍និងកសិកម្ម។

ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានរួមចំណែកយ៉ាងសកម្មក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន ដោយរក្សាបានកម្រិតទាបនៃអតិផរណា ស្ថិរភាពអត្រាប្តូរប្រាក់ និងកម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិជាដើម។ ដូចទៅនឹងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍនានាដែរ ធនាគារកណ្តាលក៏ប្រឈមនឹងបញ្ហាជាច្រើនក្នុងការសម្រេចបានលទ្ធផលល្អប្រសើរទាំងនេះ។ ជាក់ស្តែង ក្នុងពេលអតិផរណាបានកើនឡើងខ្ពស់ ដែលបណ្តាលមកពីថ្លៃប្រេងនិងម្ហូបអាហារកាលពីឆ្នាំ២០២២ នយោបាយរូបិយវត្ថុមានឥទ្ធិពលតិចតួច លើការកាត់បន្ថយសម្ពាធថ្លៃ ជាពិសេសស្ថិតក្នុងបរិការណ៍នៃដុល្លារូបនីយកម្មខ្ពស់។ ធនាគារកណ្តាលត្រូវបន្តពឹងផ្អែកលើការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកមួយផ្នែកលើ

ការគ្រប់គ្រងសម្ពាធអតិផរណា ស្របពេលដែលរាជរដ្ឋាភិបាលបានដាក់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមសម្រាប់មុខទំនិញ ដែលជាអាហារមូលដ្ឋាន និងឧបត្ថម្ភធនសម្រាប់ប្រជាជនក្រីក្រ។ ការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់ក៏ជាបញ្ហាប្រឈមធំមួយផងដែរ ដោយសារតែការប្រែប្រួលនៃតម្លៃប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារអន្តរជាតិផង ការបន្ថយល្បឿននៃលំហូរមូលធនចូលកម្ពុជាផង និងភាពទន់ខ្សោយនៃការងើបឡើងនៃវិស័យសេដ្ឋកិច្ចក្នុងស្រុកមួយចំនួនផង។ រូបិយប័ណ្ណនៅប្រទេសជាច្រើនបានថយថ្លៃ ហើយតម្រូវឱ្យធនាគារកណ្តាលធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដើម្បីបន្ថយការប្រែប្រួលខ្លាំង ដែលបាននាំឱ្យទុនបម្រុងអន្តរជាតិថយចុះគួរឱ្យកត់សម្គាល់នៅក្នុងប្រទេសមួយចំនួន។ នៅកម្ពុជា ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ក៏ត្រូវបានអនុវត្តឡើងផងដែរ ជាពិសេសដើម្បីស្រូបយកប្រាក់រៀលពីសេដ្ឋកិច្ចនៅឆ្នាំ២០២៣ ដើម្បីរក្សាស្ថិរភាពប្រាក់រៀល ក៏ប៉ុន្តែនៅឆ្នាំ២០២៤នេះ ការប្រើប្រាស់ឧបករណ៍នយោបាយរូបិយវត្ថុផ្សេងៗ បានជួយរក្សាបរិមាណប្រាក់រៀលក្នុងចរាចរណ៍សមស្រប ដែលឆ្លើយតបបាននឹងតម្រូវការសេដ្ឋកិច្ចក្នុងស្រុក។ កត្តានេះ គួបផ្សំនឹងកំណើនតម្រូវការប្រាក់រៀល ស្របតាមកំណើនសេដ្ឋកិច្ច និងភាពល្អប្រសើរនៃការនាំចេញផលិតផលកសិកម្មទៀតផងនោះ ប្រាក់រៀលបានឡើងថ្លៃ វិលទៅរកគន្លងអត្រាប្តូរប្រាក់ កាលពីមុនវិបត្តិវិញ បន្ទាប់ពីមាននិន្នាការថយថ្លៃអស់រយៈពេលជិត ៤ឆ្នាំកន្លងមក។ ការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់នេះ ក៏ដោយសារតែកម្ពុជាមានទុនបម្រុងអន្តរជាតិខ្ពស់ ដែលអាចប្រើប្រាស់សម្រាប់បម្រើដល់នយោបាយអត្រាប្តូរប្រាក់ប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះ ការគរពូនទុនបម្រុងជាបញ្ហាលំបាកសម្រេចផងដែរ ក្នុងស្ថានភាពដែលទីផ្សារហិរញ្ញវត្ថុអន្តរជាតិមានភាពមិនប្រាកដប្រជា ហើយអត្រាការប្រាក់នៅសហរដ្ឋ-អាមេរិកមានកម្រិតខ្ពស់ក្នុងរយៈពេលយូរ ដែលមានភាពទាក់ទាញប្រាក់ដុល្លារអាមេរិកឱ្យហូរចេញពីសេដ្ឋកិច្ចកំពុងលូតលាស់និងកំពុងអភិវឌ្ឍ។ ទោះយ៉ាងណា ធនាគារជាតិនៃកម្ពុជាបានគ្រប់គ្រងទុនបម្រុងអន្តរជាតិប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងបានគរពូនឱ្យកើនឡើងថែមទៀត ដោយសារជំនឿទុកចិត្តរឹងមាំលើប្រព័ន្ធធនាគារ ក៏ដូចជាសេដ្ឋកិច្ចកម្ពុជា។

ដើម្បីពង្រឹងប្រសិទ្ធភាពនយោបាយរូបិយវត្ថុ ក្របខណ្ឌនយោបាយរូបិយវត្ថុត្រូវបានធ្វើទំនើបកម្ម តាមរយៈការរៀបចំឱ្យមានអត្រាការប្រាក់របស់ធនាគារជាតិនៃកម្ពុជាលើការផ្តល់និងស្រូបយកសន្ទនីយភាពជាប្រាក់រៀលពីប្រព័ន្ធធនាគារ ផ្អែកលើយន្តការទីផ្សារ។ ការកំណត់អត្រាការប្រាក់ទាំងនេះ កំពុងតែផ្តល់ជាអត្រាយោងសម្រាប់ប្រតិបត្តិការអន្តរធនាគារ ដែលនឹងផ្តល់ភាពអំណោយផលដល់ការអភិវឌ្ឍទីផ្សារអន្តរធនាគារនាពេលខាងមុខ ក៏ដូចជាការពង្រឹងការជះឥទ្ធិពលនៃអត្រាការប្រាក់ពីធនាគារកណ្តាលទៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ទោះយ៉ាងណា ការពង្រឹងប្រសិទ្ធភាពនយោបាយរូបិយវត្ថុ ទាមទារឱ្យមានការប្រើប្រាស់ប្រាក់រៀលទូលំទូលាយ ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ហើយក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាប្រចាំ ជាមួយការពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័ននានា ដើម្បីឱ្យការអនុវត្តមានសង្គតិភាពនិងប្រសិទ្ធភាព។

ក្នុងរយៈពេលជាងពីរទសវត្សរ៍មកនេះ ធនាគារជាតិនៃកម្ពុជា ក៏ដូចជាប្រព័ន្ធធនាគារនៅកម្ពុជាបានឆ្លងកាត់កំណែទម្រង់សំខាន់ៗ និងការធ្វើទំនើបកម្មជាបន្តបន្ទាប់ ស្របតាមស្តង់ដាអន្តរជាតិដែលពង្រឹងបានមូលដ្ឋានគ្រឹះនៅក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ គាំទ្រកំណើន និងទប់ទល់បាននឹងការប៉ះទង្គិចនានា។ ជាក់ស្តែង ប្រព័ន្ធធនាគារមានភាពធន់និងវឌ្ឍនភាព ទោះបីជាប្រឈមនឹងវិបត្តិសកលនាពេលកន្លងមកក៏ដោយ ហើយនៅក្នុងស្ថានភាពដែលកំណើនឥណទានមានកម្រិតទាបនារយៈពេល ២ឆ្នាំកន្លងមកនេះ ធនាគារជាតិនៃកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបន្តដាក់ចេញ

នូវវិធានការអនុគ្រោះចាំបាច់មួយចំនួនយ៉ាងប្រុងប្រយ័ត្ន តាមរយៈការបន្ធូរបន្ថយការអនុវត្តពេញលេញនៃទ្រនាប់ដើមទុន និងការរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចក្នុងកម្រិតទាប រហូតដល់ចុងឆ្នាំ២០២៥ ដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសាច់ប្រាក់ខ្ពស់សម្រាប់ផ្តល់ឥណទាន និងរៀបចំឥណទានឡើងវិញសម្រាប់អតិថិជន សម្រាប់គាំទ្រអាជីវកម្ម និងជួយសម្រាលបន្ទុកដល់ប្រជាជនដែលជួបការលំបាកបណ្តោះអាសន្នក្នុងការសងបំណុល។

ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចពិភពលោកកំពុងប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ធនាគារជាតិនៃកម្ពុជាបានពង្រឹងការតាមដាននិងវាយតម្លៃហានិភ័យចំពោះស្ថិរភាពប្រព័ន្ធធនាគារ ក៏ដូចជាការត្រួតពិនិត្យលើភាពរឹងមាំនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ។ ជាមួយគ្នានេះ ការរួមបញ្ចូលនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ត្រូវបានបន្តលើកទឹកចិត្ត ក្នុងគោលដៅពង្រឹងភាពរឹងមាំនៃអាជីវកម្ម។ម្យ៉ាងទៀត កិច្ចពិគ្រោះពិភាក្សាជាមួយភាគីពាក់ព័ន្ធ ក៏ត្រូវបានធ្វើឡើងដើម្បីប្រមូលធាតុចូលគ្រប់ជ្រុងជ្រោយ សំដៅដាក់ចេញវិធានការមីក្រូនិងម៉ាក្រូប្រុងប្រយ័ត្នជាក់លាក់ក្នុងការគ្រប់គ្រងហានិភ័យនិងបង្ការវិបត្តិ។ គួររំលេចថា ការរីកចម្រើននៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើនភាពប្រទាក់ក្រឡារវាងវិស័យរូបវ័ន្តនិងហិរញ្ញវត្ថុ ដែលតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការពង្រឹងយន្តការគ្រប់គ្រងហានិភ័យ បង្ការនិងដោះស្រាយវិបត្តិឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្នុងគោលដៅបន្តពង្រឹងភាពធន់នៃប្រព័ន្ធធនាគារ និងដើម្បីរួមចំណែកក្នុងយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបើកគណនី និងប្រើប្រាស់សេវាទូទាត់សម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) និងបុគ្គលស្វ័យនិយោជន៍។ ទន្ទឹមនេះ ច្រករបៀងតម្លាភាពហិរញ្ញវត្ថុ (FTC) ត្រូវបានអភិវឌ្ឍឡើង ដើម្បីផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល សម្រាប់បង្កើតកិច្ចព្រមព្រៀងជាមុនរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជានិងប្រទេសដៃគូ ក្នុងគោលបំណងសម្រួលដល់ពាណិជ្ជកម្មនិងសេវាហិរញ្ញវត្ថុឆ្លងដែនរបស់ MSMEs។ ច្រករបៀងនេះផ្តល់លទ្ធភាពដល់ MSMEs ក្នុងការផ្គូផ្គងការផ្គត់ផ្គង់និងតម្រូវការ ហើយពង្រីកវិសាលភាពទីផ្សារ ក៏ដូចជាផ្តល់លទ្ធភាពដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការវាយតម្លៃហិរញ្ញប្បទានលើអាជីវកម្មឆ្លងដែនរបស់ MSMEs ដោយប្រើប្រាស់ព័ត៌មានទទួលបានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៃប្រទេសជាដៃគូ។

ជាមួយគ្នានេះ ទំនើបកម្មប្រព័ន្ធទូទាត់បានបង្កើនប្រសិទ្ធភាពក្នុងការទូទាត់ទាំងនៅទីប្រជុំជន និងតំបន់ជនបទ ដែលបានជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ព្រមទាំងបានរួមចំណែកកាត់បន្ថយគម្លាតនៃការអភិវឌ្ឍ ស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។ ធនាគារជាតិនៃកម្ពុជាបានបន្តភ្ជាប់ប្រព័ន្ធទូទាត់ជាមួយប្រទេសក្នុងតំបន់ និងក្រុមហ៊ុនបណ្តាញទូទាត់អន្តរជាតិ ដើម្បីគាំទ្រការបង្កើនប្រតិបត្តិការទូទាត់ឆ្លងដែន សំដៅគាំទ្រវិស័យទេសចរណ៍និងពាណិជ្ជកម្ម។ ម៉្យាងទៀត កម្មវិធីទូទាត់បាគងទេសចរត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីសម្រួលដល់ភ្ញៀវទេសចរក្នុងការទូទាត់និងកាត់បន្ថយការប្រើប្រាស់ក្រដាសប្រាក់ដែលកន្លងមកមានការលំបាកមួយចំនួន។ ការតភ្ជាប់ទាំងនេះ នឹងរួមចំណែកផងដែរលើការប្រើប្រាស់រូបិយវត្ថុជាតិ បង្កើនជម្រើសលើមធ្យោបាយទូទាត់អន្តរជាតិ ដោយប្រសិទ្ធភាព សុវត្ថិភាព និងកាត់បន្ថយការចំណាយថ្លៃប្រតិបត្តិការសម្រាប់គាំទ្រសមាហរណកម្មនិងការកើនឡើងទំនាក់ទំនងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់និងអន្តរជាតិ។

ថ្វីត្បិតតែការពង្រីកសេវាហិរញ្ញវត្ថុ ជាពិសេសតាមប្រព័ន្ធឌីជីថលបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អតិថិជន ក៏បច្ចេកវិទ្យាហិរញ្ញវត្ថុទាំងនេះភ្ជាប់មកជាមួយនូវហានិភ័យផងដែរ ដូចជាការឆបោក និងការឱ្យខ្ចីក្រៅផ្លូវការតាមប្រព័ន្ធអនឡាញ ជាដើម។ ដូច្នេះ ការពង្រឹងបរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ត្រូវបានធ្វើឡើងស្របគ្នា ដើម្បីធានាថាការបង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុ នឹងចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពដល់ការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន។ ជាមួយគ្នានេះ ការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យាក៏ត្រូវពង្រឹងជាប្រចាំ ដើម្បីកាត់បន្ថយហានិភ័យសាយប័រ សំដៅធានានិរន្តរភាពនៃនវានុវត្តន៍ឌីជីថល ជំនឿទុកចិត្តនៃអ្នកប្រើប្រាស់ និងស្ថិរភាពនៃប្រតិបត្តិការធនាគារ។ ទោះយ៉ាងណា ការងារនេះទាមទារការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ទាំងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដើម្បីជួយអប់រំ លើកកម្ពស់ការយល់ដឹង និងចាត់វិធានការទប់ស្កាត់បទល្មើសឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព។

ការគាំទ្រដល់ការអភិវឌ្ឍបៃតង បានក្លាយជាការងារចម្បងមួយទៀត ដែលធនាគារកណ្តាលនានាបានយកចិត្តទុកដាក់ ដោយសារការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់ដល់ស្ថិរភាពថ្លៃ ឬ/និងស្ថិរភាពហិរញ្ញវត្ថុ។ ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជា បានលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើនការយកចិត្តទុកដាក់លើការផ្តល់ហិរញ្ញប្បទានបៃតង។ ជាមួយគ្នានេះ ការសិក្សាស្រាវជ្រាវក៏ត្រូវបាននិងកំពុងធ្វើឡើង ដើម្បីកំណត់ពីវិស័យអាទិភាព ក្នុងការគាំទ្រហិរញ្ញប្បទានបៃតង ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ជំរុញការផ្ទៀងផ្ទាត់ការផ្គត់ផ្គង់និងតម្រូវការ និងបង្កើតក្របខណ្ឌគតិយុត្តគាំទ្រហិរញ្ញវត្ថុបៃតង។

ដោយឡែក ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រកបដោយប្រសិទ្ធភាព គឺមានសារៈសំខាន់ក្នុងការអភិវឌ្ឍនិងសមាហរណកម្មវិស័យហិរញ្ញវត្ថុនៅកម្ពុជា ទៅក្នុងពិភពលោក។ ដើម្បីអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព ការបង្កើនការយល់ដឹងនិងបំពេញកាតព្វកិច្ចរបស់បុគ្គលរាយការណ៍ ការវិភាគ ការត្រួតពិនិត្យ និងកិច្ចសហការជាតិនិងអន្តរជាតិ បន្តជាការងារអាទិភាព។ ទន្ទឹមនេះ ក្របខណ្ឌ និងការអនុវត្តច្បាប់និងបទប្បញ្ញត្តិ ត្រូវបានពង្រឹងជាប្រចាំស្របតាមស្តង់ដាអន្តរជាតិ និងការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យា ក្នុងគោលបំណងទប់ស្កាត់ បទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បន្តដឹកនាំនិងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលជាមូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្រជាតិនាពេលខាងមុខ។

ចំពោះទស្សនវិស័យនៅឆ្នាំ២០២៥ខាងមុខនេះ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងបន្តងើបឡើងថែមទៀត ដែលគាំទ្រជាចម្បងដោយកំណើននៃការនាំចេញ ទេសចរណ៍ និងលំហូរវិនិយោគផ្ទាល់ពីបរទេស ស្របពេលដែលអតិផរណាអាចកើនឡើងបន្តិច ដោយសារការរំពឹងទុកពីការកើនឡើងតម្រូវការក្នុងស្រុកនិងថ្លៃប្រេងអន្តរជាតិ។ កម្រិតទាបនៃអតិផរណា និងការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់នឹងបន្តរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាជំនឿទុកចិត្តមកលើសេដ្ឋកិច្ចកម្ពុជា។ ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏អាចប្រឈមនឹងហានិភ័យក្នុងរយៈពេលខ្លីនិងមធ្យមផងដែរ ដែលអាចនាំឱ្យសេដ្ឋកិច្ចថយចុះ ជាពិសេសពីកត្តាខាងក្រៅ។ ភាពតានតឹងភូមិសាស្ត្រនយោបាយ និងគោលនយោបាយគាំពារនិយមអាចមាននិន្នាការកើនឡើង ដែលនាំឱ្យពាណិជ្ជកម្មអន្តរជាតិថយចុះ អតិផរណាសកលកើនឡើង និងការកាត់បន្ថយអត្រាការប្រាក់គោលនៅប្រទេស

អភិវឌ្ឍន៍ធំៗ អាចមានល្បឿនយឺត។ កត្តាទាំងអស់នេះ នឹងអាចប៉ះពាល់ដល់ការនាំចេញ ការវិនិយោគអតិផរណា និងសម្ពាធមកលើអត្រាប្តូរប្រាក់នៅកម្ពុជា។ ជាមួយគ្នានេះ ការបន្ថយល្បឿននៃសេដ្ឋកិច្ចចិន ដោយសារការអូសបន្លាយនៃវិបត្តិអចលនទ្រព្យ និងភាពទន់ខ្សោយនៃតម្រូវការក្នុងស្រុក អាចបន្ថយលំហូរវិនិយោគ និងទេសចរមកកម្ពុជាផងដែរ។ ដោយឡែក ការចាកចេញពីឋានៈប្រទេសមានការអភិវឌ្ឍន៍តិចតួច ដែលមានរយៈពេលអន្តរកាលរហូតដល់ឆ្នាំ២០២៩ នឹងអាចធ្វើឱ្យកម្ពុជាបាត់បង់នូវភាពអនុគ្រោះមួយចំនួន ដូចជា ជំនួយ ការខ្ចីក្នុងអត្រាការប្រាក់ទាប ឬការដាក់ពន្ធលើការនាំចេញ។ ក្រៅពីនេះ ហានិភ័យក្នុងស្រុកចម្បងៗ រួមមាន ការងើបឡើងយឺតនៃវិស័យសំណង់ និងអចលនទ្រព្យ និងការកើនឡើងឥណទានមិនដំណើរការនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។

ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចនិងការប្រែប្រួលនិម្មាបនកម្មហិរញ្ញវត្ថុអន្តរជាតិ ការពង្រឹងអភិបាលកិច្ច ការការពារហានិភ័យនិងការរក្សានិរន្តរភាពធុរកិច្ច ការអភិវឌ្ឍធនធានមនុស្ស ការលើកកម្ពស់យេនឌ័រ និងការកែសម្រួលរចនាសម្ព័ន្ធផ្ទៃក្នុងមានសារៈសំខាន់ណាស់សម្រាប់បន្តអភិវឌ្ឍធនាគារជាតិនៃកម្ពុជានៅក្នុងរយៈពេលវែង  សំដៅបន្តការរួមចំណែកសម្រេចឱ្យបានបេសកកម្មចម្បងរបស់ខ្លួន ក្នុងការរក្សាស្ថិរភាពថ្លៃ និងក្រោមបាវចនា ប្រាក់រៀល ស្ថិរភាព និងអភិវឌ្ឍន៍។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ផែនការអភិវឌ្ឍន៍ជាតិ ក៏ដូចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនានារបស់រាជរដ្ឋា-ភិបាល សំដៅបន្តសម្រេចឱ្យបានប្រព័ន្ធធនាគារមួយប្រកបដោយសមាហរណកម្ម ភាពធន់ ពិពិធភាព បរិយាបន្ន និងនវានុវត្តន៍។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវការគោរពអរគុណ ដឹងគុណជាអនេក និងចងចាំជានិច្ចចំពោះស្នាដៃមិនអាចកាត់ថ្លៃបានដែល **ឯកឧត្តម ជា ចាន់តូ** អតីតទេសាភិបាល និងជាទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា បានបន្សល់ទុកសម្រាប់ធនាគារជាតិនៃកម្ពុជា ក៏ដូចជាប្រព័ន្ធធនាគារទាំងមូល ឱ្យមានការអភិវឌ្ឍឈរលើមូលដ្ឋានគ្រឹះដ៏រឹងមាំដូចបច្ចុប្បន្ន ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាដែលតែងតែផ្តល់ការគាំទ្រ និងមន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលបានខិតខំបំពេញតួនាទី-ភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមគ្នាកសាងប្រព័ន្ធធនាគារឱ្យមានការអភិវឌ្ឍជឿនលឿន និងប្រកបដោយចីរភាព។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ និងភាគីពាក់ព័ន្ធនានានឹងបន្តគាំទ្រ និងរួមចំណែកសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងប្រព័ន្ធធនាគារ ដែលនឹងបម្រើជាប្រយោជន៍រួមសម្រាប់ជាតិមាតុភូមិនិងប្រជាជនកម្ពុជា។

**ទេសាភិបាល**

**ទេសាភិបាល**

**ជា សិរី**

# អក្សរកាត់

| | | |
|---|---|---|
| គ.ស.ហ. | គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | National Coordination Committee on Anti-Money-Laundering and Combating the Financing of Terrorism and Financing of Proliferation of Weapons of Mass Destruction |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product (GDP) |
| ស.ម.ធ | សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា | |
| ស.ស.រ | សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន | SOSORO – Cambodia's Museum of Economy and Money |
| ស.ហ.ក. | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit (CAFIU) |
| អ.វ.ហ. | អនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | National Risk Assessment Sub-Committee for Combating Money Laundering and Countering Financing Terrorism and Financing of Proliferation |
| ADA | អង្គការទ្រទ្រង់ការអភិវឌ្ឍន៍ស្វ័យភាព | Appui au Développement Autonome |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AFI | សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ | Alliance for Financial Inclusion |
| AI | បញ្ញាសិប្បនិម្មិត | Artificial Intelligence |
| AMRO | អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ | The ASEAN+3 Macroeconomic Research Office |
| APG | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ | Asia/Pacific Group on Money Laundering |
| AREO | របាយការណ៍សេដ្ឋកិច្ចប្រចាំតំបន់អាស៊ាន+៣ | ASEAN+3 Regional Economic Outlook |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| AUSTRAC | មជ្ឈមណ្ឌលវិភាគនិងរបាយការណ៍ប្រតិបត្តិការអូស្ត្រាលី | Australian Transaction Reports and Analysis Centre |
| Bakong LVPS | ប្រព័ន្ធទូទាត់តម្លៃធំបាគង | Bakong Large Value Payment System |
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| BOG | ក្រុមប្រឹក្សាទេសាភិបាល | Board of Governors |
| CBC | ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី | Credit Bureau Cambodia |
| CDOT | ការិយាល័យអភិវឌ្ឍន៍សមត្ថភាពរបស់មូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំប្រទេសថៃ | Capacity Development Office in Thailand |
| CFA | ជំនាញវិភាគហិរញ្ញវត្ថុ | Chartered Financial Analyst |

| | | |
|---|---|---|
| CGCC | សាជីវកម្មធានាឥណទានកម្ពុជា | Credit Guarantee Corporation of Cambodia |
| CIA | ជំនាញសវនកម្មផ្ទៃក្នុង | Certified Internal Audit |
| CMIM | ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ | Chiang Mai Initiative Multilateralization |
| CSS | ប្រព័ន្ធខេមបូឌានស៊ែស្វីច | Cambodian Shared Switch |
| CTR | របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ | Cash Transaction Report |
| CWPD | នារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ | Cambodian Women for Peace and Development |
| e-KYC | ការផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាអេឡិច-ត្រូនិកតាមប្រព័ន្ធបាគង | Electronic Know Your Customer |
| E-Library | បណ្ណាល័យអេឡិចត្រូនិក | Electronic-Library |
| ENEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ | Export-Weighted Nominal Effective Exchange Rate |
| EREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ | Export-Weighted Real Effective Exchange Rate |
| ERIA | វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា | Economic Research Institute for ASEAN and East Asia |
| ESG | បរិស្ថាន សង្គម និងអភិបាលកិច្ច | Environmental, Social, and Governance |
| EXCO | គណៈកម្មាធិការប្រតិបត្តិ | Executive Committee |
| FAST | ប្រព័ន្ធសេវាទូទាត់រហ័ស | Fast System |
| FATF | ក្រុមការងារហិរញ្ញវត្ថុ | Financial Action Task Force |
| FICG | ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ | Financial Intelligence Consultative Group |
| FINTRAC | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកាណាដា | Financial Transactions and Reports Analysis Centre of Canada |
| FSI Connect | កម្មវិធីសិក្សារបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ | Financial Stability Institute Connect |
| FTC | ច្រករបៀងតម្លាភាពហិរញ្ញវត្ថុ | Financial Transparency Corridor |
| IBF | វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ | Institute of Banking and Finance |
| IBS | វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ | Institute for Banking Studies |
| ICI | វិទ្យាស្ថានគ្រាប់ធុញ្ញជាតិអន្តរជាតិ | International Commodity Institute |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ | International Finance Corporation |
| IIF | វិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិ | Institute of International Finance |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |
| INEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល | Import-weighted Nominal Effective Exchange Rate |

| | | |
|---|---|---|
| IREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល | Import-weighted Real Effective Exchange Rate |
| ITRS | ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ | International Transactions Reporting System |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន | Japan International Cooperation Agency |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity-Providing Collateralized Operation |
| MER | របាយការណ៍វាយតម្លៃអញ្ញមញ្ញ | Mutual Evaluation Report |
| MLF | ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី | Marginal Lending Facility |
| MSMEs | សហគ្រាសធុនមីក្រូ តូច និងមធ្យម | Micro, Small and Medium Enterprises |
| NBCP | ថ្នាលធនាគារជាតិនៃកម្ពុជា | National Bank of Cambodia Platform |
| NCD | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposit |
| NCS | ប្រព័ន្ធផាត់ទាត់ជាតិ | National Clearing System |
| NEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមទំហំពាណិជ្ជកម្ម | Nominal Effective Exchange Rate |
| NPL | ឥណទានមិនដំណើរការ | Non-Performing Loan |
| OBS | ប្រព័ន្ធធនាគារអេឡិចត្រូនិក | Online Banking System |
| POS | ម៉ាស៊ីនឆូតកាត | Point of Sale |
| RFF | ឧបករណ៍ផ្តល់ហិរញ្ញប្បទានរហ័ស | Rapid Financing Facility |
| ROA | អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | Return on Asset |
| ROE | អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក | Return on Equity |
| RPPI | សន្ទស្សន៍ថ្លៃលំនៅឋាន | Residential Property Price Indices |
| SEACEN | មជ្ឈមណ្ឌលស៊ាសិន | South East Asian Central Banks |
| SREP | វិធីសាស្ត្រត្រួតពិនិត្យស្រេប | Supervisory Review and Evaluation Process |
| SROC | កម្មវិធីបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យនិងបទប្បញ្ញត្តិ | Supervisory and Regulatory Online Course |
| STR | របាយការណ៍ប្រតិបត្តិការសង្ស័យ | Suspicious Transaction Report |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ | United Nations Development Programme |
| UNESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក | United Nations Economic and Social Commission for Asia and the Pacific |
| UNWTO | អង្គការទេសចរណ៍ពិភពលោក | United Nations World Tourism Organization |
| UTC | គម្រោង Universal Trusted Credentials | Universal Trusted Credentials |

| | | |
|---|---|---|
| WB | ធនាគារពិភពលោក | World Bank |
| WEO | របាយការណ៍សេដ្ឋកិច្ចពិភពលោក | World Economic Outlook |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក | World Trade Organization |

## ខ្លឹមសារសង្ខេប

១. **សេដ្ឋកិច្ចពិភពលោករក្សាបានកំណើនក្នុងអត្រាប្រហាក់ប្រហែលនឹងឆ្នាំមុន ទោះបីជាប្រឈមនឹងភាពតានតឹងភូមិសាស្ត្រនយោបាយ ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច និងការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនក៏ដោយ។** យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០២៤ ត្រូវបានប៉ាន់ស្មានថាសម្រេចបានអត្រា ៣,២% ដែលក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កើនឡើង ១,៧% និងសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍកើនឡើង ៤,២% ហើយសេដ្ឋកិច្ចតំបន់អាស៊ានកើនឡើង ៤,៦%។ អតិផរណាពិភពលោកបានថយចុះពី ៦,៧% នៅឆ្នាំ២០២៣ មក ៥,៧% ដែលបើកលទ្ធភាពឱ្យធនាគារកណ្តាលភាគច្រើនបានចាប់ផ្តើមកាត់បន្ថយអត្រាការប្រាក់គោលជាបណ្តើរៗ។

២. **សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថាសម្រេចបានកំណើនរឹងមាំក្នុងអត្រា ៦% នៅឆ្នាំ២០២៤ ធៀបនឹង ៥% នៅឆ្នាំ២០២៣ ដែលគាំទ្រជាចម្បងដោយកំណើនខ្ពស់នៃវិស័យកម្មន្តសាល និងការបន្តងើបឡើងជាលំដាប់នៃវិស័យទេសចរណ៍។** ជាមួយគ្នានេះ វិស័យកសិកម្មបន្តមានវឌ្ឍនភាពល្អ ដោយផលិតកម្មស្រូវ កៅស៊ូ និងជលផល បានកើនឡើង។ ចំណែកឯវិស័យសំណង់ និងអចលនទ្រព្យមានកំណើនទន់ខ្សោយ ដោយសារការធ្លាក់ចុះតម្រូវការ ស្របពេលតម្លៃអចលនទ្រព្យស្ថិតក្នុងស្ថានភាពកែតម្រូវ។ ចំពោះវិស័យក្រៅប្រទេស សមតុល្យជញ្ជីងទូទាត់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានអតិរេក ៩៣២,៥ លានដុល្លារអាមេរិក ដែលជាចម្បងបណ្តាលមកពីការកើនឡើងទ្រព្យអកម្មបរទេសសុទ្ធនៃគណនីហិរញ្ញវត្ថុ ខណៈអតិរេកគណនីចរន្តនិងដើមទុនបានថយចុះ។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិបានកើនឡើង ១២,៦% ដល់ ២២,៥ ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹងប្រមាណ ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ដែលជាកម្រិតមួយខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍគួរមាន (៣ខែ)។

៣. **អត្រាអតិផរណាមានកម្រិតត្រឹម ០,៨% ដែលជាអត្រាទាបបំផុតក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ ដោយសារការធ្លាក់ថ្លៃប្រេងឥន្ធនៈ ការថមថយកំណើនថ្លៃម្ហូបអាហារ និងកម្រិតទាបនៃអតិផរណាស្នូល។** ស្ថិរភាពថ្លៃនេះក៏ត្រូវបានរួមចំណែកយ៉ាងសំខាន់ផងដែរដោយការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់ ដែលមានកម្រិតជាមធ្យម ៤.០៧១ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានឡើងថ្លៃ ០,៩% (៤.១១០ រៀល នៅឆ្នាំ២០២៣)។ ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយភាពបត់បែននិងប្រុងប្រយ័ត្ន តាមរយៈឧបករណ៍ចម្បងៗ ដើម្បីរក្សាស្ថិរភាពថ្លៃ ព្រមទាំងគាំទ្រសកម្មភាពសេដ្ឋកិច្ច។ ជាក់ស្តែង រូបិយវត្ថុទូទៅ (M2) បានកើនឡើង ១៧,៥% ដែលគាំទ្រដោយកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណ ១៩,៩% ប្រាក់បញ្ញើជារៀល ១២,៥% ខណៈរូបិយវត្ថុក្នុងចរាចរណ៍ថយចុះ -២,៨%។ គួររំលេចថា ដុល្លាវូបនីយកម្មនៅបន្តមានកម្រិតខ្ពស់ ដែលឆ្លុះបញ្ចាំងដោយអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ ៨៥,១%។

៤. **ប្រព័ន្ធធនាគារបន្តរក្សាបានវឌ្ឍនភាព និងមានស្ថិរភាព ដែលបានរួមចំណែកគាំទ្រការងើបឡើងនៃសេដ្ឋកិច្ច។** ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន ៧% (ដល់ ៣៦៩,៤ ទ្រីលានរៀល ស្មើ ៩១,១ ប៊ីលានដុល្លារអាមេរិក)។ ឥណទានបន្តមានកំណើនទាបត្រឹម ៣% (ដល់ ២៤២,៩ ទ្រីលានរៀល ស្មើ ៥៩,៩ ប៊ីលានដុល្លារអាមេរិក) ក្នុងពេលដែលប្រាក់បញ្ញើបានកើនឡើង ១៦,៣%

(ដល់ ២៣០,៩ ទ្រីលានរៀល ស្មើ ៥៧ ប៊ីលានដុល្លារអាមេរិក)។ ស្ថានភាពដើមទុនមានភាពរឹងមាំ ដោយអនុបាតភាពគ្រប់គ្រាន់នៃដើមទុនមានកម្រិត ២២,៥% សម្រាប់វិស័យធនាគារ និង ២៦,២% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ធៀបនឹងកម្រិតកំណត់នៃបទប្បញ្ញត្តិ (១៥%) ស្របពេលដែល ទ្រនាប់ដើមទុនខនស៊ើរវេសិនត្រូវបានអនុវត្តត្រឹម ១,២៥%។ ជាមួយគ្នានេះ សន្ទនីយភាពបន្តមាន កម្រិតខ្ពស់ ដោយអនុបាតគ្របខណ្ឌសន្ទនីយភាពមានអត្រា ១៩២,៤% សម្រាប់វិស័យធនាគារ និង ១៥០,៤% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ធៀបនឹងកម្រិតកំណត់នៃបទប្បញ្ញត្តិ (១០០%)។

៥. **ធនាគារជាតិនៃកម្ពុជាអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញសម្រាប់អតិថិជន ព្រមទាំងបានបន្តពង្រឹងការត្រួតពិនិត្យប្រព័ន្ធធនាគារជាប្រចាំ សំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុ។** ធនាគារជាតិនៃកម្ពុជាបានគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជួយសម្រាលបន្ទុករបស់អាជីវកម្មនិងប្រជាជន ដែលជួបការលំបាកផ្នែកហិរញ្ញវត្ថុបណ្ដោះអាសន្ន តាមរយៈការអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញសម្រាប់អតិថិជន។ ក្នុងស្ថានភាពនេះ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានយកចិត្តទុកដាក់អនុវត្ត ដោយបុរេសកម្ម ផ្អែកលើហានិភ័យនិងទស្សនៈអនាគត ជាមួយនឹងការដាក់ចេញបទប្បញ្ញត្តិ មីក្រូនិងម៉ាក្រូប្រុងប្រយ័ត្នសមស្រប ដើម្បីពង្រឹងភាពធន់ទាំងសន្ទនីយភាពនិងដើមទុន។ ទន្ទឹមនេះ បរិយាបន្នហិរញ្ញវត្ថុត្រូវបានលើកកម្ពស់ជាលំដាប់ ដោយបច្ចុប្បន្ន ចំនួនគណនីប្រាក់បញ្ញើបាន កើនឡើងដល់ ២៣,៣ លានគណនី គណនីឥណទានកើនដល់ ៤ លានគណនី គណនីអ៊ីវ៉ាឡេត កើនដល់ ២០,៧ លានគណនី និងចំនួនពាណិជ្ជករដែលចុះឈ្មោះប្រើប្រាស់ខេអេចឃ្យូអរកូត កើនដល់ ៤,៥ លានគណនី។ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងអភិវឌ្ឍប្រព័ន្ធការពារប្រាក់បញ្ញើ ក្នុងគោលដៅរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងពង្រឹងជំនឿទុកចិត្តលើប្រព័ន្ធធនាគារឱ្យ កាន់តែរឹងមាំថែមទៀត។

៦. **ហិរញ្ញវត្ថុប្រកបដោយចីរភាពត្រូវបាននិងកំពុងយកចិត្តទុកដាក់លើកកម្ពស់ជាប្រចាំ ក្នុងគោលដៅរួមចំណែកការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងកាត់បន្ថយហានិភ័យពីការប្រែប្រួលអាកាសធាតុ។** ធនាគារជាតិនៃកម្ពុជាបានបង្កើនការវិនិយោគលើសញ្ញាបណ្ណបៃតង និងសញ្ញាបណ្ណដែលពាក់ព័ន្ធ នឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលបោះផ្សាយដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ព្រមទាំងបាននិងកំពុងជំរុញការរៀបចំផែនទីមគ្គុទេសក៍ហិរញ្ញវត្ថុបៃតងនៅកម្ពុជា និងប្រព័ន្ធ វដ្តករសាស្ត្រនិងទីផ្សារហិរញ្ញវត្ថុបៃតងនៅកម្ពុជា។ គោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាព កម្ពុជា របស់សមាគមធនាគារនៅកម្ពុជា ត្រូវបានគាំទ្រដាក់ឱ្យអនុវត្ត ដើម្បីជំរុញការចូលរួមគាំទ្រ ពីបណ្ដាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការបង្កើតគោលនយោបាយផ្ដល់ហិរញ្ញប្បទានដែល លើកកម្ពស់ការថែរក្សាបរិស្ថាន វប្បធម៌ និងបរិយាបន្នហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ធនាគារជាតិនៃ កម្ពុជាបានសហការស្រាវជ្រាវលើហិរញ្ញប្បទានបៃតង និងលើកកម្ពស់ការកសាងសមត្ថភាព ពាក់ព័ន្ធនឹងហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជាផងដែរ។

៧. **ស្របតាមនវានុវត្តន៍បច្ចេកវិទ្យា និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញសេដ្ឋកិច្ច និងសង្គមឌីជីថល ប្រព័ន្ធទូទាត់សងប្រាក់ទាំងតម្លៃរាយនិងតម្លៃធំ ត្រូវបានធ្វើទំនើបកម្មជាលំដាប់។** ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ បានសម្រួលដល់ការទូទាត់ពាណិជ្ជកម្ម និងសកម្មភាពសេដ្ឋកិច្ចទាំងក្នុងប្រទេសនិងក្នុងតំបន់ ព្រមទាំងបានរួមចំណែកជំរុញបរិយាបន្ន

ហិរញ្ញវត្ថុទៀតផង។ កម្មវិធីទូទាត់បាគងទេសចរត្រូវបានដាក់ឱ្យដំណើរការ ដើម្បីរួមចំណែកលើកកម្ពស់វិស័យទេសចរណ៍ ដោយអនុញ្ញាតឱ្យភ្ញៀវទេសចរអន្តរជាតិអាចធ្វើប្រតិបត្តិការទូទាត់ទំនិញនិងសេវាតាមឃ្យូអរកូត។ លើសពីនេះ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានតភ្ជាប់ជាមួយបណ្តាប្រទេសជាច្រើនក្នុងតំបន់ និងក្រុមហ៊ុនផ្តល់សេវាទូទាត់អន្តរជាតិនានា ដូចជា ប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី កូរ៉េខាងត្បូង ក្រុមហ៊ុនយូញៀនផេអន្តរជាតិ អាលីផេ និងក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់ម៉ាស្ទ័រកាត ជាដើម ដែលបាននិងកំពុងសម្រួលដល់ការធ្វើពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ឱ្យមានភាពងាយស្រួលឆាប់រហ័ស និងសុវត្ថិភាព។

៨. **ទន្ទឹមនឹងការកើនឡើងនៃការទូទាត់តាមប្រព័ន្ធឌីជីថល តម្រូវការប្រើប្រាស់សាច់ប្រាក់ក៏ត្រូវបានបំពេញបានគ្រប់គ្រាន់ ដែលគាំទ្រដល់ការរីកចម្រើនសេដ្ឋកិច្ចនៅតាមតំបន់នានាទូទាំងប្រទេសជាមួយនឹងការបន្តលើកកម្ពស់គុណភាព និងសោភ័ណភាពក្រដាសប្រាក់រៀលជាប្រចាំ។** ប្រសិទ្ធភាពសេវាធនាគារកណ្តាលត្រូវបានពង្រឹងជាលំដាប់ ដើម្បីគាំទ្រដល់ការគ្រប់គ្រងសាច់ប្រាក់របស់រាជរដ្ឋាភិបាល និងអន្តរការិយកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងសម្រួលដល់ការប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែក ជូនដល់សាធារណជន ក្នុងគោលដៅជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ។ ទន្ទឹមនេះ ដើម្បីអបអរសាទរខួប ២០ឆ្នាំ នៃការគ្រងព្រះបរមរាជសម្បត្តិ **ព្រះករុណាព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យចេញផ្សាយធនប័ត្រអនុស្សាវរីយ៍ប្រភេទ ២០០០០០រៀល។

៩. **ការពង្រឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការផ្សព្វផ្សាយអំពីប្រព័ន្ធបាគង និងការលើកកម្ពស់ប្រាក់រៀលក៏ត្រូវបានយកចិត្តទុកដាក់ជាប្រចាំ តាមរយៈយុទ្ធនាការ ការរៀបចំសិក្ខាសាលា និងការតាំងពិព័រណ៍ផ្សេងៗនៅតាមរាជធានី-ខេត្ត។** យុទ្ធនាការទាំងនេះបានបង្កើនការយល់ដឹងរបស់ប្រជាជនអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ ប្រព័ន្ធទូទាត់ឌីជីថល និងអត្ថប្រយោជន៍នៃការប្រើប្រាស់រូបិយវត្ថុជាតិ។ ជាមួយគ្នានេះ សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីល្បសានវ៉្ឌែ បានរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់ចំណេះដឹងអំពីប្រវត្តិសាស្ត្រសេដ្ឋកិច្ចនិងរូបិយវត្ថុដល់សិស្សានុសិស្ស និងសាធារណជនជាតិនិងអន្តរជាតិ ទាំងនៅរាជធានីភ្នំពេញ និងបណ្តាខេត្ត តាមរយៈការតាំងបង្ហាញ និងការរៀបចំពិព័រណ៍ផ្សេងៗ ហើយចំនួនភ្ញៀវសរុបចូលទស្សនាសារមន្ទីរបានកើនឡើងដល់ប្រមាណ ៥០.០០០ នាក់ នៅឆ្នាំ២០២៤។ ម្យ៉ាងទៀត មណ្ឌលសិក្សាបច្ចេកទេសធនាគារត្រូវបានអភិវឌ្ឍទៅជាវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ ដែលបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍចំណេះដឹងនិងជំនាញក្នុងវិស័យធនាគារសម្រាប់និស្សិត ហើយគ្រោងនឹងចាប់ផ្តើមដំណើរការកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រចាប់ពីឆ្នាំ២០២៥ សំដៅបម្រើដល់វិស័យធនាគារនិងហិរញ្ញវត្ថុ ដែលរីកចម្រើនឥតឈប់ឈរ។

១០. **ការពង្រឹងអភិបាលកិច្ច និងការអភិវឌ្ឍធនធានមនុស្ស ជាការងារអាទិភាពសម្រាប់ការរីកចម្រើនរបស់ធនាគារជាតិនៃកម្ពុជា។** ក្នុងន័យនេះ ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចត្រូវបានយកចិត្ត-ទុកដាក់អនុវត្តជាប្រចាំ ទាំងនៅស្នាក់ការកណ្តាល និងសាខារាជធានី-ខេត្ត ដោយបានលើកកម្ពស់ប្រសិទ្ធភាពការងារ ពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យផ្សេងៗ។ បច្ចុប្បន្ន មន្ត្រី-បុគ្គលិកសរុបរបស់ធនាគារជាតិនៃកម្ពុជាមានចំនួន ២.០៣៨រូប ដែលក្នុងនោះស្ត្រីមានសមាមាត្រ ៤៩%

ស្របពេលដែលសមត្ថភាពជំនាញនិងឯកទេសកម្ម ត្រូវបានយកចិត្តទុកដាក់អភិវឌ្ឍជាលំដាប់តាមរយៈការបណ្តុះបណ្តាលនានា ទាំងនៅក្នុងនិងក្រៅប្រទេស និងការសិក្សាតាមប្រព័ន្ធអនឡាញ។

១១. **អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចូលរួមចំណែកការពារសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ក៏ដូចជាឆ្លើយតបនឹងការរីកចម្រើននៃបច្ចេកវិទ្យា និងនិន្នាការថ្មីៗនៃបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។** ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបាននិងកំពុងពង្រឹងការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការបំពេញមុខងារវិភាគប្រតិបត្តិការ ត្រួតពិនិត្យបុគ្គលរាយការណ៍ សហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិ និងលើកកម្ពស់ការយល់ដឹងក្នុងការចូលរួមអនុវត្តច្បាប់ដល់ក្រសួង-ស្ថាប័ន វិស័យឯកជន និងភាគីពាក់ព័ន្ធ។ ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានបន្តដឹកនាំ និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

១២. **ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី។** ការលើកកម្ពស់ទំនាក់ទំនងល្អជាមួយបណ្តាធនាគារកណ្តាល ស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា បានរួមចំណែកជំរុញសមាហរណកម្មទៅក្នុងតំបន់និងពិភពលោក ពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ ព្រមទាំងបានរួមចំណែកដល់ការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ និងការផ្លាស់ប្តូរចំណេះដឹងនិងបទពិសោធ ស្របតាមការរីកចម្រើននៃប្រព័ន្ធធនាគារនិងនវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុជាសកល។

១៣. **សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថារក្សាបានកំណើន ៣,៣% នៅឆ្នាំ២០២៥ ប៉ុន្តែអាចនឹងមានហានិភ័យមួយចំនួនផងដែរ។** បញ្ហាប្រឈមចម្បងៗចំពោះកំណើនសេដ្ឋកិច្ចពិភពលោក រួមមានភាពមិនច្បាស់លាស់នៃគោលនយោបាយគាំពារនិយមតាមរយៈការដាក់របាំងពាណិជ្ជកម្ម ភាពតានតឹងភូមិសាស្ត្រនយោបាយដែលប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់សាជាថ្មី ការកើនឡើងនៃការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ចដែលមានឥទ្ធិពលដល់លំហូរវិនិយោគ និងពាណិជ្ជកម្មអន្តរជាតិ កំណើនបំណុលសាធារណៈក្នុងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍ កំណើនទាបជាងការរំពឹងទុកនៃប្រទេសចិនដែលអាចប៉ះពាល់បន្តដល់ប្រទេសក្នុងតំបន់ និងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ជាដើម។

១៤. **ចំពោះកម្ពុជា កំណើនសេដ្ឋកិច្ចត្រូវបានរំពឹងនឹងសម្រេចបាន ៦,២% ហើយអតិផរណាត្រូវបានព្យាករថាមានកម្រិតសមស្រប ២,៦% នៅឆ្នាំ២០២៥។** សកម្មភាពសេដ្ឋកិច្ចនឹងបន្តគាំទ្រជាចម្បងដោយកំណើននៃការនាំចេញផលិតផលក្នុងវិស័យកម្មន្តសាលកាត់ដេរ និងការកើនឡើងនៃផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ស្របពេលដែលវិស័យទេសចរណ៍និងកសិកម្មបន្តមានវឌ្ឍនភាពល្អ ទោះជាវិស័យសំណង់និងអចលនទ្រព្យនៅមានភាពទន់ខ្សោយនៅឡើយក៏ដោយ។ ទោះយ៉ាងណា កម្ពុជាក៏អាចប្រឈមនឹងហានិភ័យមួយចំនួន ដែលភាគច្រើនជាហានិភ័យក្រៅប្រទេស រួមមាន ភាពមិនប្រាកដប្រជានៃគោលនយោបាយគាំពារនិយមរបស់សហរដ្ឋអាមេរិក កំណើនទាបជាងការរំពឹងទុកនៃសេដ្ឋកិច្ចតំបន់និងពិភពលោក ភាពមិនច្បាស់លាស់នៃស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ការថយចុះនៃកំណើនសេដ្ឋកិច្ចចិន និងការប្រែប្រួលអាកាសធាតុ ជាដើម។

លើសពីនេះ ការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួចក៏អាចធ្វើឱ្យកម្ពុជាប្រឈមនឹងការបាត់បង់ភាពអនុគ្រោះមួយចំនួនសម្រាប់ការនាំចេញ និងប្រភពហិរញ្ញប្បទានពីបរទេស ដែលអាចដាក់សម្ពាធលើល្បឿនកំណើនសេដ្ឋកិច្ចកម្ពុជាផងដែរ។

១៥. **ប្រព័ន្ធធនាគារនឹងបន្តអភិវឌ្ឍដោយភាពរឹងមាំ ស្របតាមការងើបឡើងនៃសេដ្ឋកិច្ចនៅឆ្នាំ២០២៥ បើទោះបីជាស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅបន្តប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ក៏ដោយ។** ការផ្តល់ឥណទានទៅកាន់វិស័យឯកជនត្រូវបានរំពឹងថាកើនឡើងក្នុងអត្រាមធ្យម ៦% ដែលជួយបង្កើនការវិនិយោគនិងការប្រើប្រាស់។ ជាមួយគ្នានេះ ការបន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់អេឡិចត្រូនិក នឹងរួមចំណែកសម្រួលដល់សកម្មភាពការប្រើប្រាស់ក្នុងស្រុក ជំរុញពាណិជ្ជកម្មឆ្លងដែន ការវិនិយោគ និងទេសចរណ៍ ស្របតាមចក្ខុវិស័យនៃការកសាងសេដ្ឋកិច្ចឌីជីថលនិងនវានុវត្តន៍។ ទោះយ៉ាងណា ប្រព័ន្ធធនាគារក៏ប្រឈមនឹងហានិភ័យមួយចំនួន ដូចជា ការថយចុះគុណភាពឥណទាន និងការថមថយលទ្ធភាពស្វែងរកប្រាក់ចំណេញ ក្នុងពេលដែលការកើនឡើងយឺតនៃវិស័យសំណង់និងអចលនទ្រព្យ ក៏អាចដាក់សម្ពាធមកលើប្រព័ន្ធធនាគារផងដែរ។

# ផ្នែកទី១-របាយការណ៍ប្រចាំឆ្នាំ២០២៤

# I- សេដ្ឋកិច្ចពិភពលោកនិងតំបន់

## ១- កំណើនសេដ្ឋកិច្ចពិភពលោកនិងតំបន់

ភាពតានតឹងភូមិសាស្ត្រនយោបាយ ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច គួបផ្សំនឹងការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន នៅតែជាបញ្ហាប្រឈមចម្បងៗចំពោះកំណើនសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០២៤នេះ។ មូលនិធិរូបិយវត្ថុអន្តរជាតិបានប៉ាន់ស្មានថា សេដ្ឋកិច្ចពិភពលោកមានកំណើន ៣,២% (៣,៣% នៅឆ្នាំ២០២៣)។ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កើន ១,៧% (១,៧% នៅឆ្នាំ២០២៣) ដែលគាំទ្រជាចម្បងដោយកំណើនខ្ពស់នៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក (២,៨%) ដោយសារការកើនឡើងនៃការវិនិយោគនិងតម្រូវការក្នុងស្រុក ខណៈតំបន់អឺរ៉ូ និងជប៉ុនបន្តមានកំណើនយឺត (០,៨% និង -០,២% រៀងគ្នា)។ សេដ្ឋកិច្ចតំបន់អឺរ៉ូមានកំណើនទាបដូចជាប្រទេសបារាំង ១,១% អ៊ីតាលី ០,៦% ហើយប្រទេសអាល្លឺម៉ង់មានកំណើនអវិជ្ជមាន -០,២% លើកលែងប្រទេសអេស្ប៉ាញដែលមានកំណើនខ្ពស់ ៣,១%។ ចំណែកឯសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍកើន ៤,២% (៤,៤% នៅឆ្នាំ២០២៣) ដែលគាំទ្រដោយកំណើនរឹងមាំនៃសេដ្ឋកិច្ចឥណ្ឌា (៦,៥%) ដោយសារការកើនឡើងតម្រូវការក្នុងស្រុក ខណៈប្រទេសចិនបន្តមានកំណើនទាប (៤,៨%) ដែលបណ្តាលមកពីវិបត្តិវិស័យអចលនទ្រព្យ និងការថយចុះការប្រើប្រាស់ក្នុងស្រុក។ សេដ្ឋកិច្ចតំបន់អាស៊ានបន្តងើបឡើង ៤,៦% (៤,១% នៅឆ្នាំ២០២៣) ដែលគាំទ្រជាចម្បងដោយកំណើនតម្រូវការក្នុងស្រុកនិងវិស័យទេសចរណ៍ ដោយក្នុងនោះប្រទេសវៀតណាមកើន ៦,១% (៥% នៅឆ្នាំ២០២៣) និងប្រទេសអាស៊ាន-៥ ដែលរួមមាន ហ្វីលីពីន ៥,៨% (៥,៥% នៅឆ្នាំ២០២៣) ឥណ្ឌូណេស៊ី ៥% (៥% នៅឆ្នាំ២០២៣) ម៉ាឡេស៊ី ៤,៨% (៣,៦% នៅឆ្នាំ២០២៣) ថៃ ២,៨% (១,៩% នៅឆ្នាំ២០២៣) និងសិង្ហបុរី ២,៦% (១,១% នៅឆ្នាំ២០២៣)។

**ក្រាហ្វ ១៖ កំណើនសេដ្ឋកិច្ចពិភពលោក និងតំបន់**

(គិតជាភាគរយ, ឆ្នាំ២០២៣ - ឆ្នាំ២០២៥ព)




ប្រភព៖ របាយការណ៍ WEO និង REO របស់ IMF, សម្គាល់៖ ប = ប៉ាន់ស្មាន, ព = ព្យាករណ៍

**ក្រាហ្វ ២៖ សមាមាត្រ ផ.ស.ស. ពិភពលោក**

(ឆ្នាំ២០២៣)




ប្រភព៖ ធនាគារពិភពលោក

កំណើនសេដ្ឋកិច្ចពិភពលោកក៏ត្រូវបានគាំទ្រដោយកំណើនពាណិជ្ជកម្មនិងទេសចរអន្តរជាតិផងដែរ។ ទំហំពាណិជ្ជកម្មទំនិញអន្តរជាតិបានងើបឡើងវិញក្នុងអត្រា ២,៧% (-១,១% នៅឆ្នាំ ២០២៣) ដែលរួមចំណែកមួយភាគធំដោយកំណើននៃការនាំចេញពីប្រទេសចិននិងឥណ្ឌា។ ទោះយ៉ាងណា លទ្ធភាពនៃការផ្លាស់ប្តូរនយោបាយពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក និងការកើនឡើងនយោបាយគាំពារនិយម អាចបន្ថយល្បឿនកំណើនពាណិជ្ជកម្ម ស្របពេលដែលជម្លោះនៅមជ្ឈិមបូព៌ានៅតែជាបញ្ហាប្រឈមដល់ពាណិជ្ជកម្មអន្តរជាតិ ដោយអាចធ្វើឱ្យប៉ះពាល់ដល់ការផ្គត់ផ្គង់ថាមពល និងការដឹកជញ្ជូន។ ទន្ទឹមនេះ ទេសចរអន្តរជាតិបានកើនឡើងជាលំដាប់ ជិតដល់កម្រិតមុនវិបត្តិកូវីដ-១៩ ជាពិសេសនៅក្នុងតំបន់អឺរ៉ុប និងសហរដ្ឋអាមេរិក ខណៈដែលនៅតំបន់មួយចំនួនដូចជា តំបន់អាហ្វ្រិក និងមជ្ឈិមបូព៌ា ទេសចរអន្តរជាតិមានកំណើនខ្ពស់ជាងកម្រិតមុនវិបត្តិកូវីដ-១៩។

**ក្រាហ្វ ៣៖ កំណើនទំហំពាណិជ្ជកម្មទំនិញអន្តរជាតិ**

(គិតជាភាគរយ, ឆ្នាំ២០១៥ - ឆ្នាំ២០២៥ព)




ប្រភព៖ អង្គការពាណិជ្ជកម្មពិភពលោក (WTO), សម្គាល់៖ ព=ព្យាករណ៍

**ក្រាហ្វ ៤៖ កំណើនទេសចរអន្តរជាតិ**

(ឆ្នាំគោល ២០១៩, ឆ្នាំ២០២២ - ខែកក្កដា ឆ្នាំ២០២៤)




ប្រភព៖ UN World Tourism Organization (UNWTO)

## ២-នយោបាយរូបិយវត្ថុអន្តរជាតិ

ក្រោយវិបត្តិកូវីដ-១៩ និងពេលសង្គ្រាមនៅអ៊ុយក្រែនបានថមថយកម្តៅ ទីផ្សារពលកម្មមានភាពប្រសើរឡើងជាបន្តបន្ទាប់ដែលធ្វើឱ្យការផ្គត់ផ្គង់កើនឡើង។ ប្រការនេះ គួបផ្សំនឹងការរឹតត្បិតនយោបាយរូបិយវត្ថុ ធ្វើឱ្យអតិផរណាពិភពលោកថយចុះ។ អតិផរណាពិភពលោកបានថយចុះមក ៥,៧%[១] នៅឆ្នាំ២០២៤ (៦,៧% នៅឆ្នាំ២០២៣) ដែលក្នុងនោះ អតិផរណានៅប្រទេសអភិវឌ្ឍន៍មានកម្រិត ២,៦% (៤,៦% នៅឆ្នាំ២០២៣) ស្របពេលដែលប្រទេសកំពុង-លូតលាស់និងកំពុងអភិវឌ្ឍមានកម្រិត ៧,៩% (៨,១% នៅឆ្នាំ២០២៣)។

**ក្រាហ្វ ៥៖ អត្រាអតិផរណាពិភពលោក**

(គិតជាភាគរយ, ឆ្នាំ២០២០ - ឆ្នាំ២០២៥ព)




ប្រភព៖ IMF, សម្គាល់៖ ប =ប៉ាន់ស្មាន, ព=ព្យាករណ៍

[១] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក របស់ IMF ចេញផ្សាយខែមករា ឆ្នាំ២០២៥។

រូបិយប័ណ្ណរបស់ប្រទេសអភិវឌ្ឍន៍ធំៗដូចជា ប្រាក់ផោនអង់គ្លេស និងប្រាក់អឺរ៉ូ បានឡើងថ្លៃបន្តិច ខណៈដែលប្រាក់យ៉ន់ចិន បានថយថ្លៃដោយសារភាពទន់ខ្សោយនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក។ ជាមួយគ្នានេះ រូបិយប័ណ្ណរបស់ប្រទេសមួយចំនួនក្នុងតំបន់អាស៊ីបានថយថ្លៃផងដែរ ដូចជា យ៉េនជប៉ុន បាតថៃ និងវ៉ុនកូរ៉េ ខណៈដែលរីងហ្គីតម៉ាឡេស៊ីបានឡើងថ្លៃបន្តិច។ គួររំលេចថា ប្រាក់ដុល្លារអាមេរិកបានថយថ្លៃក្រោយពីការរំពឹងទុកលើការកាត់បន្ថយអត្រាការប្រាក់គោលនៅសហរដ្ឋអាមេរិក ក៏ប៉ុន្តែបានឡើងថ្លៃមកវិញចាប់ពីខែតុលា ឆ្នាំ២០២៤ ដោយសារការរំពឹងទុកពីការកើនឡើងសេដ្ឋកិច្ច និងការបង្កើនពន្ធលើការនាំចូលសហរដ្ឋ-អាមេរិក ក្រោមរដ្ឋាភិបាលអាណត្តិថ្មី។

**ក្រាហ្វ ៦៖ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិក**
(មធ្យម, ឆ្នាំលើឆ្នាំ, ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការថយចុះនៃអត្រាអតិផរណា បើទោះជានៅមានកម្រិតខ្ពស់ជាងកម្រិតគោលដៅ ក៏ធនាគារកណ្តាលមួយចំនួនបានបន្ទាបអត្រាការប្រាក់គោល។ នាឆ្នាំ២០២៤នេះ ធនាគារកណ្តាលអាមេរិកបានបន្ទាបអត្រាការប្រាក់គោលចំនួន៣លើក ពី ៥,៥% មក ៤,៥% ស្របពេលដែលធនាគារកណ្តាលអឺរ៉ុបបានទម្លាក់ចំនួន៤លើក ពី ៤,៥% មក ៣,១៥%។ ធនាគារកណ្តាលអង់គ្លេសនិងចិនបានកាត់បន្ថយពី ៥,២៥% មក ៤,៧៥% និងពី ៣,៤៥% មក ៣,១% រៀងគ្នា។ ផ្ទុយទៅវិញ ធនាគារកណ្តាលជប៉ុនបានដំឡើងអត្រាការប្រាក់គោល២លើកពី -០,១% ដល់ ០,១% និងពី ០,១% ដល់ ០,២៥% ដើម្បីបន្ថយសម្ពាធអតិផរណា។ គួររំលេចថា ធនាគារកណ្តាលជប៉ុនបានរក្សាអត្រាការប្រាក់គោលអវិជ្ជមាន (-០,១%) ចាប់តាំងពីឆ្នាំ២០១៦ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចនិងដោះស្រាយវិបត្តិបរិត្ត-ផរណា។ ចំពោះតំបន់អាស៊ាន ធនាគារកណ្តាលភាគច្រើនក៏បានបន្ទាបអត្រាការប្រាក់គោលផងដែរ ដែលក្នុងនោះ ធនាគារកណ្តាលថៃពី ២,៥% មក ២,២៥% ហ្វីលីពីនពី ៦,៥% មក ៥,៧៥% និងឥណ្ឌូណេស៊ីពី ៦,២៥% មក ៦% រីឯធនាគារកណ្តាល ម៉ាឡេស៊ី និងវៀតណាម បានរក្សាអត្រាការប្រាក់គោលនៅដដែល។

**ក្រាហ្វ ៧៖ អត្រាការប្រាក់គោលនៃប្រទេសអភិវឌ្ឍន៍**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ Trading Economics

**ក្រាហ្វ ៨៖ អត្រាការប្រាក់គោលនៃប្រទេសក្នុងតំបន់អាស៊ី**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ Trading Economics

## ៣- លំហូរទុនអន្តរជាតិ

ប្រទេសកំពុងលូតលាស់បន្តមានលំហូរទុនចេញសុទ្ធ ប៉ុន្តែមានកម្រិតទាបជាងមុន ដោយមានប្រមាណ ១៨០ ប៊ីលានដុល្លារអាមេរិក (២០៦ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០២៣) ដោយសារភាពប្រសើរឡើងនៃសេដ្ឋកិច្ចនៅតំបន់មួយចំនួនដូចជា អាមេរិកឡាទីន អាស៊ីប៉ាស៊ីហ្វិក[២] អាហ្វ្រិក និងមជ្ឈិមបូព៌ា។ ដោយឡែក ប្រទេសចិននៅតែបន្តមានលំហូរទុនចេញសុទ្ធខ្ពស់គួរឱ្យកត់សម្គាល់ ដែលអាចបណ្តាលមកពីកត្តាចម្បងមួយចំនួនដូចជា៖ i/-ភាពទន់ខ្សោយនៃកំណើនសេដ្ឋកិច្ច និងវិបត្តិវិស័យអចលនទ្រព្យ ដែលប៉ះពាល់ដល់ជំនឿទុកចិត្តរបស់វិនិយោគិន ii/-ភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងចិននិងសហរដ្ឋអាមេរិក ដែលធ្វើឱ្យមានភាពមិនប្រាកដប្រជាចំពោះបរិស្ថានវិនិយោគក្នុងប្រទេសចិន និង iii/-ការថយថ្លៃប្រាក់យ៉ន់ចិនដែលជំរុញឱ្យវិនិយោគិនលក់ទ្រព្យសកម្មជាប្រាក់យ៉ន់ និងដកទុនត្រឡប់ទៅប្រទេសអភិវឌ្ឍន៍វិញ។

**តារាង ១៖ ការវិវត្តនៃលំហូរទុនតាមតំបន់នៅប្រទេសកំពុងលូតលាស់**

(គិតជាប៊ីលានដុល្លារអាមេរិក, ឆ្នាំ២០១៣ - ឆ្នាំ២០២៤e)

| ពេល | កំពុងលូតលាស់ | ចិន | អ.ម.ឡាទីន | អាស៊ី/ដកចិន | អាហ្វ្រិក /មជ្ឈិមបូព៌ា |
|---|---|---|---|---|---|
| ២០១៣ | ៥៣៣ | ៣៨៣ | ១៧១ | ៦ | -២៦ |
| ២០១៤ | ៣៦ | -៥១ | ២២០ | -១៣ | -៣០ |
| ២០១៥ | -៣៦៧ | -៨៣២ | ១៩១ | -៣៥ | ២៣ |
| ២០១៦ | -២៧៤ | -៤១១ | ១០៨ | -៦៧ | ៥៦ |
| ២០១៧ | ៣១៣ | ១០៩ | ១១៦ | ៨ | ៩ |
| ២០១៨ | ២២០ | ១៧៩ | ១៥៧ | ២៤ | -៦៣ |
| ២០១៩ | ១២៧ | ១០ | ៧៤ | ៥២ | -៣០ |
| ២០២០ | -១៩៥ | -៥០ | ៥ | -៤ | -៥១ |
| ២០២១ | ១៥៩ | -៤១ | ១៣០ | ៦២ | -៧ |
| ២០២២ | -៤០៨ | -២០៥ | ១១១ | ១១ | -១៥៥ |
| ២០២៣ | -២០៦ | -២៩៦ | ៨៨ | ៣៥ | -៧៨ |
| ២០២៤e | -១៨០ | -៤៧៥ | ១០១ | ៦២ | ១១ |

អវិជ្ជមាន … វិជ្ជមាន

ប្រភព៖ វិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិ (IIF), សម្គាល់៖ អ.ម.ឡាទីន៖ អាមេរិកឡាទីន, អវិជ្ជមាន=លំហូរចេញសុទ្ធ, វិជ្ជមាន=លំហូរចូលសុទ្ធ

ជារួម សេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០២៤នេះ បន្តកើនឡើងជាមួយនឹងការប្រឈមនឹងភាពតានតឹងភូមិសាស្ត្រនយោបាយ ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច និងការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន។ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានគាំទ្រដោយភាពប្រសើរឡើងនៃពាណិជ្ជកម្មអន្តរជាតិ លំហូរទុននិងការវិនិយោគ និងកំណើនក្នុងវិស័យទេសចរណ៍។ ការថយចុះអតិផរណាបាននាំឱ្យមានការធ្វើប្រក្រតីកម្មនយោបាយរូបិយវត្ថុជាលំដាប់ ការបន្ធូរសម្ពាធលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងការប្រែប្រួលខ្លាំងនៃអត្រាប្តូរប្រាក់ផងដែរ។

[២] ទិន្នន័យនេះមិនរាប់បញ្ចូលប្រទេសចិន។

# II- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

## ១- កំណើនសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថាបន្តមានភាពរឹងមាំ ដោយសម្រេចបានកំណើន ៦% ធៀបនឹង ៥% ក្នុងឆ្នាំ២០២៣។ ការកើនឡើងនេះត្រូវបានគាំទ្រជាចម្បងដោយការងើបឡើងវិញយ៉ាងឆាប់រហ័សនៃវិស័យកម្មន្តសាលកាត់ដេរ និងវិស័យទេសចរណ៍ គួបផ្សំនឹងការបន្តមានកំណើននៃវិស័យកសិកម្ម បើទោះបីជាវិស័យសំណង់ និងអចលនទ្រព្យមានភាពទន់ខ្សោយនៅឡើយក៏ដោយ។

**ក្រាហ្វ ៩៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**

(គិតជាភាគរយ, ឆ្នាំ២០១៨-ឆ្នាំ២០២៥ព)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន, ព=ព្យាករណ៍

**វិស័យកម្មន្តសាល៖** វិស័យកម្មន្តសាលបន្តដើរតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា ដែលត្រូវបានប៉ាន់ស្មានថាមានកំណើន ៩,៧% (៣,៦% នៅឆ្នាំ២០២៣)។ ផលិតផលកម្មន្តសាលកាត់ដេរមានកំណើន ៨,៦% ដែលគាំទ្រដោយកំណើនតម្រូវការខាងក្រៅ ជាពិសេសប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជារួមមាន សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ស្របពេលដែលផលិតផលកម្មន្តសាលមិនមែនកាត់ដេរកើន ១០,៩% ដែលរួមចំណែកគាំទ្រដោយកំណើនតម្រូវការខាងក្រៅ ការវិនិយោគ និងគោលនយោបាយពិពិធកម្មរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ ចំនួនរោងចក្រនៅក្នុងវិស័យកម្មន្តសាលបានកើនឡើងដល់ ២.៣១៦ រោងចក្រ[៣] (កើន ២១០ រោងចក្រធៀបនឹងឆ្នាំ២០២៣ និងលុបចេញពីបញ្ជី ១៩) និងអាចផ្តល់ការងារដល់កម្មករប្រមាណ ១,១ លាននាក់។

[៣] ទិន្នន័យជាក់ស្តែងគិតត្រឹមខែតុលា ឆ្នាំ២០២៤។

**ក្រាហ្វ ១០៖ ការរួមចំណែកក្នុងកំណើនវិស័យកម្មន្តសាល**

(គិតជាភាគរយ, ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន

**ក្រាហ្វ ១១៖ ចំនួនរោងចក្រសរុប**

(ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប= ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែតុលា ឆ្នាំ២០២៤)



រូបភាព៖ រោងចក្រផលិតសំបកកង់រថយន្ត ក្រុមហ៊ុន ញូ ប៊ូស្តា ស្ថិតនៅក្នុងតំបន់រដ្ឋបាលសេដ្ឋកិច្ចពិសេស យូប៊ីអ៊ី ស្រុកស្នួល ខេត្តក្រចេះ
ប្រភព៖ គេហទំព័រ AMS



រូបភាព៖ រោងចក្រផលិតម៉ូតូ ហុងដា នៅរាជធានីភ្នំពេញ
ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**វិស័យសេវាកម្ម៖** វិស័យទេសចរណ៍មានកំណើនល្អ ដែលឆ្លុះបញ្ចាំងតាមរយៈការបន្តងើប-ឡើងលឿនជាងការរំពឹងទុកនៃភ្ញៀវអន្តរជាតិនិងទេសចរក្នុងស្រុក។ ភ្ញៀវអន្តរជាតិ[៤] ក្នុងឆ្នាំ២០២៤ បានកើនឡើង ២២,៩% ដល់ប្រមាណ ៦,៧ លាននាក់ (៥,៥ លាននាក់ ក្នុងឆ្នាំ២០២៣) និងខ្ពស់ជាងគ្រាមុនវិបត្តិកូវីដ-១៩ ១,៤% (៦,៦ លាននាក់ នៅឆ្នាំ២០១៩)។ កំណើននេះត្រូវបានចូលរួមគាំទ្រដោយភាពប្រសើរឡើងនៃទេសចរណ៍ក្នុងតំបន់និងសកល ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមមានផ្លូវថ្នល់ និងអាកាសយានដ្ឋានអន្តរជាតិ គួបផ្សំនឹងកំណើននៃការតភ្ជាប់ជើងហោះហើរត្រង់ជាមួយនឹងប្រទេសនានា។ ទោះយ៉ាងណា ចំនួនភ្ញៀវអន្តរជាតិតាមផ្លូវអាកាសបន្តមានកម្រិតទាបនៅឡើយក្នុងសមាមាត្រប្រមាណ ៣៥,៨% នៃទេសចរសរុប ធៀបនឹង ៦៦,៦% នៅគ្រាមុនវិបត្តិកូវីដ-១៩ ដែលធ្វើឱ្យចំណូលពីវិស័យទេសចរណ៍មានកម្រិតទាបធៀបនឹងមុនវិបត្តិកូវីដ-១៩។ ជាមួយគ្នានេះ ទេសចរក្នុងស្រុកបន្តមានកំណើនខ្ពស់ជាងគ្រាមុនវិបត្តិកូវីដ-១៩ ដល់ប្រមាណ ២២,៥ លាននាក់ ក្នុងនោះ រាជធានីភ្នំពេញមានប្រជាប្រិយភាពជាងគេដោយទទួលបានទេសចរ ៤០,៤% នៃទេសចរក្នុងស្រុក

[៤] ក្នុងឆ្នាំ២០២៤ ភ្ញៀវថៃឈរនៅលំដាប់ទី១ (សមាមាត្រ ៣២% នៃភ្ញៀវអន្តរជាតិសរុប) ភ្ញៀវវៀតណាមឈរលំដាប់ទី២ (២០%) និងភ្ញៀវចិនឈរលំដាប់ទី៣ (១២,៧%)។

សរុប ហើយតំបន់ឆ្នេរឈរលំដាប់ទី២ (៣៩,១%) បន្ទាប់មកខេត្តសៀមរាបឈរលំដាប់ទី៣ (៩,៨%) និងតំបន់អេកូទេសចរណ៍ឈរលំដាប់ទី៤ (២,៨%)។

**ក្រាហ្វ ១២៖ ភ្ញៀវអន្តរជាតិ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២៤)




ប្រភព៖ ក្រសួងទេសចរណ៍

**ក្រាហ្វ ១៣៖ ទេសចរក្នុងស្រុក**
(ឆ្នាំ២០១៨ - ឆ្នាំ២០២៤)




ប្រភព៖ ក្រសួងទេសចរណ៍



រូបភាព៖ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក
ប្រភព៖ នាំផ្លូវ- Lead The Way




រូបភាព៖ ប្រាសាទអង្គរវត្តរបស់ប្រទេសកម្ពុជា ជាប់ចំណាត់ថ្នាក់លេខ ១ ជាកន្លែងសម្រាប់ទស្សនាថ្ងៃរះ
ប្រភព៖ គេហទំព័រ Morninglife.co.uk

**វិស័យកសិកម្ម៖** វិស័យកសិកម្មបន្តមានភាពប្រសើរ បើទោះជាសម្រេចបានកំណើនទាបដែលគាំទ្រដោយកំណើនផលដំណាំ និងធនធានជលផល។ ផលស្រូវក្នុងឆ្នាំ២០២៤នេះ បានកើន ១១,១% (ដល់ ១៣,៩ លានតោន) ដែលក្នុងនោះ ផលស្រូវរដូវប្រាំងបានកើន ២២,២% (ដល់ ៣,៨ លានតោន) និងផលស្រូវរដូវវស្សាកើន ៧,៤% (ដល់ ១០ លានតោន)។ ការកើនឡើងនេះរួមចំណែកជាចម្បងដោយកត្តាអាកាសធាតុគួបផ្សំនឹងតម្លៃស្រូវល្អ ដែលជំរុញឱ្យមានការដាំដុះច្រើនជាងមុន។ គួររំលេចផងដែរថា អង្ករក្រអូបប្រណីតកម្ពុជាបានឈ្នះរង្វាន់អង្ករល្អប្រណីតផ្តាច់គេលើពិភពលោក ក្នុងការប្រកួតអង្ករល្អផ្តាច់គេលើពិភពលោក (World Best Rice) នៅក្នុងកម្មវិធី

**ក្រាហ្វ ១៤៖ ផលស្រូវនិងផ្ទៃដីដាំដុះ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២៤)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

"សន្និសីទស្រូវអង្ករពិភពលោកឆ្នាំ២០២៤" នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នាថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ ដែលរៀបចំឡើងដោយ International Commodity Institute (ICI) និង The Rice Trader (TRT) របស់សហរដ្ឋអាមេរិក។ នេះជាលើកទី៦ ដែលអង្ករខ្មែរទទួលពានរង្វាន់ជាអង្ករល្អដាច់គេលើពិភពលោក ដោយលើកទី១ ទទួលបាននៅឆ្នាំ២០១២ ទី២ នៅឆ្នាំ២០១៣ ទី៣ នៅឆ្នាំ២០១៤ ទី៤ នៅឆ្នាំ២០១៨ ទី៥ នៅឆ្នាំ២០២២ និងទី៦ នៅឆ្នាំ២០២៤។

ផលកៅស៊ូបន្តមានកំណើន ៣,៩% ធៀបនឹងគ្រាដូចគ្នាឆ្នាំ២០២៣ (២,៦%) ដល់ ៤០៧ ពាន់តោន។ ចំណែកតម្លៃកៅស៊ូជាមធ្យមកើនឡើងខ្ពស់ ២៤,៧% ពី ១.៣៣៣ ដុល្លារអាមេរិក ក្នុង១តោន នៅឆ្នាំ២០២៣ ដល់ ១.៦៦២ ដុល្លារអាមេរិក ក្នុង១តោន ក្នុងឆ្នាំ២០២៤។

ធនធានជលផលបានកើន ៧% (០,៤% នៅឆ្នាំ២០២៣) ដែលក្នុងនោះផលនេសាទទឹកសាប និងសមុទ្រ កើន ៩,៩% ស្របពេលដែលផលវារីវប្បកម្ម[៩]ក៏បានកើនប្រមាណ ២%។

**ក្រាហ្វ ១៥៖ ផលនិងតម្លៃជ័រកៅស៊ូ**
(ឆ្នាំ២០១៨ -ឆ្នាំ២០២៤)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ក្រាហ្វ ១៦៖ អនុវិស័យជលផល**
(គិតជាភាគរយ, ឆ្នាំ២០១៨ -ឆ្នាំ២០២៤)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




រូបភាព៖ អង្ករក្រអូបប្រណីតកម្ពុជាបានឈ្នះពានរង្វាន់អង្ករល្អប្រណីតដាច់គេលើពិភពលោកលើកទី ៦ ក្នុងឆ្នាំ២០២៤នេះនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
ប្រភព៖ Seasia



រូបភាព៖ ដំណាំកៅស៊ូ
ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**វិស័យសំណង់និងអចលនទ្រព្យ៖** វិស័យសំណង់បន្តមានកំណើនទាបត្រឹម ០,៥% (០,៨% នៅឆ្នាំ២០២៣) ដែលគាំទ្រជាចម្បងដោយគម្រោងសំណង់សាធារណៈសំខាន់ៗដូចជា ផ្លូវ ស្ពាន និង អាកាសយានដ្ឋាន។ ការនាំចូលសម្ភារនិងបរិក្ខារសំណង់បន្តកើនឡើង ៣៣,២% ធៀបនឹងឆ្នាំ២០២៣

[៩] វារីវប្បកម្មសំដៅលើការចិញ្ចឹមត្រី បង្គា បង្កង កង្កែប ។ល។

(៤,៦%)។ តម្លៃគម្រោងសំណង់ទទួលបានការអនុម័តបានកើនឡើង ០,៥%[៦] ដែលក្នុងនោះ តម្លៃសំណង់សាធារណៈកើនឡើង ៦៤% មានសមាមាត្រ ៦,៦% (៤% នៅឆ្នាំ២០២៣) ខណៈតម្លៃសំណង់ឯកជនថយចុះ -៤៤,៧% មានសមាមាត្រ ៩៣,៤% (៩៦% នៅឆ្នាំ២០២៣)។ គួររំលេចថា នៅក្នុងសំណង់ឯកជន តម្លៃសំណង់ឧស្សាហកម្មកើនឡើង ៦១,៣% ធៀបនឹងឆ្នាំ២០២៣ ដែលមានសមាមាត្រ ៣៣,២% (២០,៧% នៅឆ្នាំ២០២៣) ខណៈសំណង់លំនៅឋានថយចុះ -២២,៣% ដែលមានសមាមាត្រ ២៧,៤% (៤៩,៩% នៅឆ្នាំ២០២៣)។

**ក្រាហ្វ ១៧៖ តម្លៃគម្រោងសំណង់**
(ឆ្នាំ២០១៩ - ឆ្នាំ២០២៤ប)




**ក្រាហ្វ ១៨៖ សមាមាត្រគម្រោងសំណង់អនុម័ត**
(ឆ្នាំ២០២៤ប)




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤)

ទន្ទឹមនេះវិស័យអចលនទ្រព្យមានកំណើនបន្តិចត្រឹម ០,២% (-១,៦% នៅឆ្នាំ២០២៣)។ សកម្មភាពលក់ខុនដូបានកើនឡើង ៣៥,៥% ខណៈសកម្មភាពលក់លំនៅឋាន (ផ្ទះល្វែងនិងវីឡាភ្លោះ និងទោល) ថយចុះ -១២,៥%។ ក្នុងឆ្នាំ២០២៤ សន្ទស្សន៍ថ្លៃលំនៅឋានកម្ពុជា (RPPI) ជាមធ្យមថយចុះក្នុងអត្រា -០,២% ធៀបនឹងឆ្នាំ២០២៣ ក្នុងនោះសន្ទស្សន៍ថ្លៃលំនៅឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តជាមធ្យមថយចុះ -១,៨% និង -១,៦% រៀងគ្នា។

**ក្រាហ្វ១៩ ៖សន្ទស្សន៍ថ្លៃលំនៅឋានកម្ពុជា**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០២៣ - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៦] ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ខែធ្នូ។



រូបភាព៖ រូបភាពដំណាក់កាលសាងសង់ ទីស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា, ប្រភព៖ Utracon




រូបភាព៖ ការសាងសង់អាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ
ប្រភព៖ កម្ពុជាថ្មី

## ២- ស្ថានភាពអតិផរណា

អតិផរណាមានកម្រិត ០,៨% ក្នុងឆ្នាំនេះ (២,១% នៅឆ្នាំ២០២៣) ដែលជាអត្រាទាបបំផុតក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ។ អតិផរណាទាបនេះ បណ្តាលមកពីការធ្លាក់ថ្លៃប្រេងឥន្ធនៈ ការថមថយកំណើនថ្លៃម្ហូបអាហារ និងកម្រិតទាបនៃអតិផរណាស្នូល។ ជាមួយគ្នានេះ វិធានការបន្ធូរបន្ថយថ្លៃម្ហូបអាហារនិងប្រេងសាំងរបស់រាជរដ្ឋាភិបាល គួបផ្សំនឹងការឡើងថ្លៃប្រាក់រៀលក៏បានចូលរួមបន្ថយសម្ពាធអតិផរណាផងដែរ។

**ក្រាហ្វ ២០៖ អតិផរណារួម និងអតិផរណាក្រុមទាំងបី**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០២៣ - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

**ក្រាហ្វ ២១៖ ការរួមចំណែកក្នុងអតិផរណារួម**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែកក្កដា ឆ្នាំ២០២៣ - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបន្តថយចុះ -២,១% តែថយខ្សោយជាងនៅឆ្នាំ២០២៣ (-២,៧%) ដោយសារតម្លៃប្រេងនៅពិភពលោកបានបន្តថយចុះ គួបផ្សំនឹងវិធានការបញ្ចុះថ្លៃប្រេងសាំងរបស់រាជរដ្ឋាភិបាល[៧]។ នៅកម្ពុជាថ្លៃប្រេងសាំងបានបន្តធ្លាក់ចុះ -៦,២% (-៥,៦% នៅឆ្នាំ២០២៣) ស្របពេលដែលថ្លៃឥន្ធនៈរឹងថយចុះ -០,៩% (១% នៅឆ្នាំ២០២៣) ហើយថ្លៃឧស្ម័នបន្តមានកំណើនអវិជ្ជមាន -០,៩% (-៤,៧% នៅឆ្នាំ២០២៣)។

**ក្រាហ្វ ២២៖ ការរួមចំណែកក្នុងអតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២៣-ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

អតិផរណាម្ហូបអាហារបានថយចុះជាមធ្យមមកត្រឹម ១,២% (៣,៣% នៅឆ្នាំ២០២៣) ដែលរួមចំណែកជាចម្បងដោយការថយចុះថ្លៃត្រី -០,១% (៤,២% នៅឆ្នាំ២០២៣) និងកំណើនទាបនៃថ្លៃសាច់ជ្រូក ០,១% (២,៦% នៅឆ្នាំ២០២៣) និងសាច់គោ ០,៥%(២,៧%នៅឆ្នាំ២០២៣)ដោយសារការកើនឡើងនៃការផ្គត់ផ្គង់ក្នុងស្រុក គួបផ្សំនឹងការអនុគ្រោះពន្ធរបស់រាជរដ្ឋាភិបាលលើអាហារមូលដ្ឋាន[៨]។ ទោះយ៉ាងណា ថ្លៃបន្លែនិងផ្លែឈើបានរួមចំណែកចម្បងក្នុងកំណើនថ្លៃម្ហូបអាហារនៅឆ្នាំនេះ ដែលកើនឡើង ៤,៤% និង ២,៥% រៀងគ្នា (ប៉ុន្តែទាបជាងឆ្នាំ២០២៣ ៥,១% និង ៤,២% រៀងគ្នា) ដោយសារសម្ពាធអតិផរណាពីប្រទេសដៃគូនាំចូល។

**ក្រាហ្វ ២៣៖ ការរួមចំណែកក្នុងអតិផរណាក្រុមម្ហូបអាហារ**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២៣-ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

---

[៧] រាជរដ្ឋាភិបាលបញ្ចុះតម្លៃប្រេងសាំង ៦,៥ សេនដុល្លារអាមេរិកក្នុងមួយលីត្រចាប់តាំងពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣មក។

[៨] រាជរដ្ឋាភិបាលអនុគ្រោះការយកអាករលើតម្លៃបន្ថែមសម្រាប់អាហារមូលដ្ឋានដូចជាសាច់សត្វចិញ្ចឹម ស៊ុត មច្ឆជាតិ ស្ករ អំបិល ទឹកត្រី និងទឹកស៊ីអ៊ីវ ចាប់តាំងពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤។

អតិផរណាស្នូលថយចុះមក ១% (២% នៅឆ្នាំ២០២៣) ដោយសារកំណើនទាបនៃថ្លៃក្រុមភោជនីយដ្ឋាន ០,៣% (២% នៅឆ្នាំ២០២៣) និងការថែរក្សានិងការជួសជុលជម្រកស្នាក់នៅ ១,៨% (៤,៦% នៅឆ្នាំ២០២៣) ដែលបណ្ដាលមកពីកំណើនទាបនៃឥណទាននិងទេសចរតាមផ្លូវអាកាស គួបផ្សំនឹងឥទ្ធិពលពីការថមថយថ្លៃម្ហូប-អាហារនិងប្រេងឥន្ធនៈ។

**ក្រាហ្វ ២៤៖ ការរួមចំណែកក្នុងអតិផរណាស្នូល**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០២៣-ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

## ៣- អត្រាប្ដូរប្រាក់

អត្រាប្ដូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកនៅឆ្នាំ២០២៤នេះ បន្តមានស្ថិរភាព ហើយប្រាក់រៀលមាននិន្នាការឡើងថ្លៃទៅរកគន្លងមុនវិបត្តិកូវីដ-១៩។ ការឡើងថ្លៃនេះបណ្ដាលមកពីការកើនឡើងតម្រូវការប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់ជាប្រភពទុនក្នុងការផ្ដល់ឥណទាន ការកើនឡើងនៃការស្រូបប្រាក់រៀល គួបផ្សំនឹងការពង្រឹងការគ្រប់គ្រងថវិការដ្ឋាភិបាល។ អត្រាប្ដូរប្រាក់មានកម្រិតជាមធ្យម ៤.០៧១ រៀលក្នុងមួយដុល្លារអាមេរិក ដែលបានឡើងថ្លៃ ០,៩% ធៀបនឹងឆ្នាំ២០២៣ (៤.១១០ រៀល) ប៉ុន្តែថយថ្លៃ ០,៥% ធៀបនឹងឆ្នាំ២០១៦-២០១៨ (៤.០៥២ រៀល)។ ចំណែករូបិយប័ណ្ណប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាមួយចំនួនបានថយថ្លៃធៀបនឹងដុល្លារអាមេរិក ដូចជាយ៉េនជប៉ុន (-៧,១%) យ៉ន់ចិន (-១,២%) ដុងវៀតណាម (-៤,៦%) និងបាតថៃ (-០,៦%) ខណៈដែល ផោនអង់គ្លេស និងប្រាក់អឺរ៉ូ បានកើនថ្លៃ ៣,១% និង ០,៥% រៀងគ្នា។ ជារួម ប្រាក់រៀលបានឡើងថ្លៃធៀបនឹងរូបិយប័ណ្ណដៃគូពាណិជ្ជកម្ម ២,៥%[៩]។

**ក្រាហ្វ ២៥៖ ស្ថានភាពអត្រាប្ដូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**
(គិតជារៀលក្នុងមួយដុល្លារអាមេរិក, ឆ្នាំ២០១៦ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៩] ការថយចុះសន្ទស្សន៍អត្រាប្ដូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមទំហំពាណិជ្ជកម្ម (NEER)។

**ក្រាហ្វ ២៦៖ សន្ទស្សន៍ប្រាក់ដុល្លារអាមេរិក**
(ខែមករា ឆ្នាំ២០២៣ - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២៧៖ អត្រាប្តូរប្រាក់ប្រទេសសំខាន់ៗ និងក្នុងតំបន់ធៀបនឹងដុល្លារអាមេរិក**
(សន្ទស្សន៍មធ្យម,មករា ឆ្នាំ២០១៨=១០០,ខែមករា ឆ្នាំ២០២៣ - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រតិបត្តិការជួញដូរប្រាក់ដុល្លារអាមេរិករវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅលើថ្នាលធនាគារជាតិនៃកម្ពុជា (NBCP) មានចំនួន ២,៧ ប៊ីលានដុល្លារអាមេរិក (១.៩៧១ ប្រតិបត្តិការ) ដែលបានកើន ៤២% ធៀបនឹងឆ្នាំ២០២៣ (១,៨ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ១.៤៨៣ ប្រតិបត្តិការ)។

**ក្រាហ្វ ២៨៖ ការទិញ-លក់ដុល្លារអាមេរិកតាមរយៈ NBCP**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការឡើងថ្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណដៃគូនាំចេញ[១០] ផាត់ទាត់ដោយអតិផរណាកម្ពុជាទាបជាងអតិផរណាដៃគូនាំចេញ[១១]ធ្វើឱ្យសន្ទស្សន៍អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ (EREER) ថយចុះ -១,៩% ដែលបង្ហាញពីភាពអាចប៉ះពាល់ដល់ឧត្តមភាពប្រកួតប្រជែងលើការនាំចេញទំនិញ។ ទោះយ៉ាងណា សម្ពាធអតិផរណាពីការនាំចូលក៏បានថយចុះផងដែរ ដោយសន្ទស្សន៍អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល (IREER)[១២] ថយចុះ -២,៥%[១៣]។

**ក្រាហ្វ ២៩៖ អត្រាប្តូរប្រាក់ប្រសិទ្ធភាពមធ្យម**

(សន្ទស្សន៍ ២០១៥=១០០, ឆ្នាំ២០២០ - ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- ស្ថានភាពជញ្ជីងទូទាត់

សមតុល្យជញ្ជីងទូទាត់កម្ពុជា មានអតិរេក ៤៣២,៥ លានដុល្លារអាមេរិក កើន ៥,៩ដង ធៀបនឹងអតិរេក ៧៣,២ លានដុល្លារអាមេរិក នៅឆ្នាំ២០២៣ ដែលជាចម្បងបណ្តាលមកពីការកើនឡើងទ្រព្យអកម្មបរទេសសុទ្ធនៃគណនីហិរញ្ញវត្ថុ ខណៈដែលអតិរេកគណនីចរន្តនិងដើមទុនបានថយចុះ។

**ក្រាហ្វ ៣០៖ ជញ្ជីងទូទាត់កម្ពុជា**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា,សម្គាល់៖ ប=ប៉ាន់ស្មាន

### - គណនីចរន្តនិងដើមទុន

សមតុល្យគណនីចរន្តនិងដើមទុន មានអតិរេក ០,១% នៃផ.ស.ស. ធៀបនឹងអតិរេក ១,៦% នៃផ.ស.ស. នៅឆ្នាំ២០២៣។ ការថយចុះអតិរេកនេះ ជាចម្បងបណ្តាលមកពីការកើនឡើងឱនភាពពាណិជ្ជកម្មទំនិញ[១៤] និងការថយចុះអតិរេកចំណូលបន្ទាប់បន្សំ[១៥] ខណៈដែលអតិរេកគណនីសេវា[១៦] បានកើនឡើង និងឱនភាពចំណូលបឋម[១៧] បានថយចុះ។

**ក្រាហ្វ ៣១៖ គណនីចរន្ត និងដើមទុន**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

---

[១០] សន្ទស្សន៍ ENEER ថយ -៣,២%។

[១១] អតិផរណាកម្ពុជា ០,៨% អតិផរណាដៃគូនាំចេញថ្លឹងតាមទំហំពាណិជ្ជកម្ម ២,៤%។ ប្រទេសដៃគូនាំចេញរបស់កម្ពុជាជាចម្បងៗរួមមាន៖ ចិន ថៃ សហរដ្ឋ-អាមេរិក វៀតណាម ជប៉ុន អាល្លឺម៉ង់ ចក្រភពអង់គ្លេស ហុងកុង និងកាណាដា។

[១២] ប្រទេសដៃគូនាំចូលមកកម្ពុជាចម្បងៗរួមមាន៖ ចិន ថៃ វៀតណាម តៃវ៉ាន់ សិង្ហបុរី ជប៉ុន ហុងកុង កូរ៉េ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងសហរដ្ឋអាមេរិក។

[១៣] អតិផរណាដៃគូនាំចូលថ្លឹងតាមទំហំពាណិជ្ជកម្ម ១,២% និង សន្ទស្សន៍ INEER ថយ -២,៨%។

[១៤] ឱនភាពពាណិជ្ជកម្មទំនិញបានកើន ១,៥ ប៊ីលានដុល្លារអាមេរិក (៥០,៦%) ធៀបនឹងឱនភាព ៣ ប៊ីលានដុល្លារអាមេរិក ឆ្នាំ២០២៣ ក្នុងនោះ៖ ការនាំចេញកើន ១៣,៥% និងការនាំចូលកើន ១៧,៧%។

[១៥] អតិរេកចំណូលបន្ទាប់បន្សំបានថយចុះ -៧,៨ លានដុល្លារអាមេរិក (-០,២%) ធៀបនឹងអតិរេក ៣,២ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣។

[១៦] អតិរេកសេវាសុទ្ធបានកើន ៤២០,៥ លានដុល្លារអាមេរិក (៣១,៩%) ពីអតិរេក ១,៣ ប៊ីលានដុល្លារអាមេរិក ជាចម្បងដោយសារការកើនឡើងនៃចំណូលពីសេវាធ្វើដំណើរ។

[១៧] ឱនភាពគណនីចំណូលបឋមបានថយចុះ -៤៧៩,៩ លានដុល្លារអាមេរិក (-៥០,៣%) ពីឱនភាព ៩៥៣,៤ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣។

ឱនភាពពាណិជ្ជកម្មទំនិញបានកើនឡើង ៥០,៦% ធៀបនឹងឆ្នាំ២០២៣ (ថយ -៦៦,២%) ដែលជាចម្បងដោយសារការកើនឡើងតម្រូវការក្នុងស្រុក និងការនាំចូលដើម្បីផលិតទំនិញនាំចេញ។ ការនាំចូលកើន ១៧,៧% ធៀបនឹងឆ្នាំ២០២៣ (ថយ -១៧%) ដែលក្នុងនោះ ការនាំចូលយានយន្តកើន ៣៩,១% សម្ភារនិងបរិក្ខារសំណង់កើន ៣៣,២% វត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរកើន ២២,៣% ម្ហូបអាហារនិងភេសជ្ជៈកើន ១៦,៩% និងប្រេងឥន្ធនៈកើន ១០,៦%។ ការនាំចេញកើន ១៣,៥% ក្នុងនោះ ការនាំចេញផលិតផលកាត់ដេរ[១៨] កើន ២៣,៤% (-១៣,២% នៅឆ្នាំ២០២៣) ផលិតផលកសិកម្មកើន ១៦,៥% (៣២,៩% នៅឆ្នាំ២០២៣) ក្នុងនោះ កៅស៊ូកើន ១២,៨% អង្ករកើន ៥% និងផលិតផលកសិកម្មផ្សេងៗកើន ១៩% ខណៈដែលផលិតផលផ្សេងៗថយ -១,៩% (កើន១៥,៤% នៅឆ្នាំ២០២៣) រួមមាន៖ គ្រឿងអេឡិចត្រូនិកថយ -៤២,២% និងទោចក្រយាន -១២,៨% ខណៈដែលសំបកកង់រថយន្ត កើន ១,៣ដង។

អតិរេកគណនីសេវាសុទ្ធបានកើនឡើង ៣១,៩% ធៀបនឹងឆ្នាំ២០២៣ ដែលជាចម្បងបណ្តាលមកពីការងើបឡើងវិញនៃចំនួនទេសចរអន្តរជាតិ (ចំណូលពីសេវាធ្វើដំណើរកើន ១៧,៩%) ស្របពេលដែលឱនភាពគណនីចំណូលបឋមបានថយចុះ -៥០,៣% (ដោយសារការទូទាត់ទៅក្រៅប្រទេស[១៩] ថយ -២៣,៨% ហើយការទូទាត់ចូលក្នុងប្រទេស[២០] កើន ២៧,៩%)។ ទន្ទឹមនេះ អតិរេកគណនីចំណូលបន្ទាប់បន្សំបានថយចុះ -០,២% ដែលក្នុងនោះ ជំនួយរបស់រាជរដ្ឋាភិបាលថយ -៩% ខណៈប្រាក់បង្វែរឯកជនចូលក្នុងប្រទេស[២១] កើន ១,៤%។

**ក្រាហ្វ ៣២៖ ពាណិជ្ជកម្មទំនិញរបស់ប្រទេសកម្ពុជា**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០២៤ប)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន

**ក្រាហ្វ ៣៣៖ ការនាំចេញ**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន

**ក្រាហ្វ ៣៤៖ ការនាំចូល**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា,សម្គាល់៖ ប = ប៉ាន់ស្មាន

---

[១៨] ក្នុងនោះ ការនាំចេញសម្លៀកបំពាក់កើន ២៤,៤% ស្បែកជើង ២៣,១% និងសម្ភារសម្រាប់ធ្វើដំណើរនិងផលិតផលវាយនភ័ណ្ឌផ្សេងទៀត ១៩,៥%។

[១៩] ក្នុងនោះ ការបែងចែកភាគលាភនិងប្រាក់ចំណេញពីការវិនិយោគផ្ទាល់ថយចុះ -៣១,៤% ខណៈចំណាយការប្រាក់របស់រាជរដ្ឋាភិបាល កើន ១៤,៤%។

[២០] ក្នុងនោះ ចំណូលពីការប្រាក់កើន ៣៧,៧%។

[២១] បង្វែរចូលពីក្រៅប្រទេសកើន ០,៤% ក្នុងនោះ ប្រាក់បង្វែរពលករទេសន្តរប្រវេសក៍កើន ១% (ពីថៃកើន ៤,៨% ខណៈដែលពីកូរ៉េថយ -១៤,១% ជប៉ុន -១០,៥% ម៉ាឡេស៊ី -៣,៣%) និងប្រាក់បង្វែរផ្សេងទៀតថយ -៤% ខណៈដែលបង្វែរចេញទៅក្រៅប្រទេសថយ -១២,៥%។

### - គណនីហិរញ្ញវត្ថុ

សមតុល្យគណនីហិរញ្ញវត្ថុបង្ហាញពីការកើនទ្រព្យអកម្មបរទេសសុទ្ធ ៣៧១,៧ លានដុល្លារអាមេរិក ធៀបនឹងទ្រព្យសកម្មបរទេសសុទ្ធ ៦១៨,៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣ ដែលគាំទ្រដោយលំហូរចូលវិនិយោគផ្ទាល់បរទេស ខណៈទ្រព្យសកម្មបរទេសសុទ្ធផ្នែកវិនិយោគផ្សេងទៀត និងវិនិយោគលើផលបត្រកើនឡើង។ លំហូរចូលវិនិយោគផ្ទាល់បរទេសមាន ៤,២ ប៊ីលានដុល្លារអាមេរិក កើន ៤,៩% ដោយសារការកើនឡើងការវិនិយោគលើវិស័យមិនមែនហិរញ្ញវត្ថុ[២២] ១៧,១% ខណៈការវិនិយោគលើវិស័យហិរញ្ញវត្ថុថយ -៣៥,៥%។

វិនិយោគផ្សេងទៀត បង្ហាញពីការកើនឡើងទ្រព្យសកម្មបរទេសសុទ្ធ ៣,២ ប៊ីលានដុល្លារអាមេរិក (កើន ៩,៥% បើធៀបនឹងឆ្នាំ២០២៣) បណ្តាលមកពីការកើនឡើងប្រាក់បញ្ញើ និងការវិនិយោគលើផលបត្រនៅក្រៅប្រទេស គួបផ្សំនឹងការកើនឡើងការទូទាត់បំណុលក្រៅប្រទេសនៃវិស័យហិរញ្ញវត្ថុ ស្របពេលដែលការខ្ចីសុទ្ធរបស់រាជរដ្ឋាភិបាលថយ -១០,២%។

**ក្រាហ្វ ៣៥៖ គណនីហិរញ្ញវត្ថុ**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន

**ក្រាហ្វ ៣៦៖ ការចូលរួមចំណែកក្នុងកំណើនវិនិយោគផ្ទាល់បរទេស**

(គិតជាភាគរយ, ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន

### ៥- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

ទុនបម្រុងអន្តរជាតិបន្តរក្សាបាននៅកម្រិតខ្ពស់ ដែលឆ្លុះបញ្ចាំងពីភាពរឹងមាំនៃលទ្ធភាពសងបំណុលក្រៅប្រទេស ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងប្រព័ន្ធទូទាត់ជាតិ ព្រមទាំងផ្តល់ការការពារគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការសន្ទនីយភាពទប់ទល់នឹងវិបត្តិខាងក្រៅ។ ជាក់ស្តែងទុនបម្រុងអន្តរជាតិបានកើនដល់ ២២,៥ ប៊ីលានដុល្លារអាមេរិក ដែលកើន ១២,៦% ធៀបនឹងឆ្នាំ២០២៣ (២០ ប៊ីលានដុល្លារអាមេរិក) ដែលស្មើនឹង ៧ខែនៃការនាំចូលទំនិញនិងសេវាគ្រា

**ក្រាហ្វ ៣៧៖ ទុនបម្រុងអន្តរជាតិ**

(ឆ្នាំ២០១៨ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[២២] ការវិនិយោគលើវិស័យកម្មន្តសាលកើន ៥៦% (ក្នុងនោះ ការវិនិយោគលើវិស័យកាត់ដេរសម្លៀកបំពាក់កើន ៧៣,៦% ស្បែកជើង ២៧,៥% ផលិតផលធ្វើដំណើរ ៦៣,៤% វេចខ្ចប់ ៦៦,៤% និងផ្សេងៗ ៥៥,៥% ខណៈផលិតកម្មស្ករឡូ ថយ -៣៧,៥%) វិស័យសណ្ឋាគារនិងការកម្សាន្ត ១៩,១% វិស័យកសិកម្ម ១១,៩% វិស័យថាមពល ១,៤% និងវិស័យផ្សេងៗ ៣៣,៩% ខណៈដែលវិស័យអចលនទ្រព្យថយចុះ -២៤,៨% វិស័យសំណង់ -៣២,៤% និងវិស័យអាជីវកម្មរ៉ែ -៦៣,៩%។

បន្ទាប់ដែលជាកម្រិតខ្ពស់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ការកើនឡើងនេះ ជាចម្បងបណ្តាលមកពីការកើនឡើង៖ i/-តម្លៃមាស ii/-ការប្រែប្រួលអត្រាប្តូរប្រាក់ iii/-ចំណូលពីការវិនិយោគក្រៅប្រទេស (ការកើនឡើងនៃអត្រាចំណូល និងការធ្វើពិពិធកម្មទ្រព្យសកម្ម) និង iv/-ប្រាក់បម្រុងកាតព្វកិច្ច។

រចនាសម្ព័ន្ធគ្រប់គ្រងទុនបម្រុងអន្តរជាតិ ត្រូវបានរៀបចំឡើងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីធានាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រុងប្រយ័ត្នខ្ពស់ សំដៅទទួលបានសុវត្ថិភាព សន្ទនីយភាព និងចំណូលសមស្រប។ ក្រុមប្រឹក្សាភិបាល អនុម័តលើគោលនយោបាយវិនិយោគ ដែលជាក្របខ័ណ្ឌរួមសម្រាប់កំណត់ទិសដៅយុទ្ធសាស្ត្រនៃការគ្រប់គ្រងទុនបម្រុង។ គណៈកម្មការវិនិយោគ អនុម័តលើសេចក្តីណែនាំការវិនិយោគ ដែលមានចែងលម្អិតអំពីលក្ខខណ្ឌនៃការវិនិយោគដោយផ្អែកលើគោលនយោបាយវិនិយោគ។ គណៈកម្មការវិនិយោគ ជួបប្រជុំជាប្រចាំរៀងរាល់ខែ ដើម្បីពិនិត្យលទ្ធផលនៃការវិនិយោគរបស់នាយកដ្ឋានទទួលបន្ទុក វិភាគលក្ខខណ្ឌទីផ្សារ និងផ្តល់អនុសាសន៍កែសម្រួលចាំបាច់ដើម្បីធានាថាយុទ្ធសាស្ត្រគ្រប់គ្រងទុនបម្រុងត្រូវបានផ្តោតលើសុវត្ថិភាព សន្ទនីយភាព និងចំណូលសមស្រប។

ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់លើការបង្កើនការវិនិយោគលើសញ្ញាបណ្ណបៃតង (Green bonds) និងសញ្ញាបណ្ណដែលពាក់ព័ន្ធនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលបោះផ្សាយដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ នៅប្រទេសចិន កូរ៉េខាងត្បូង ជប៉ុន និងនៅតំបន់អឺរ៉ុបក្នុងគោលដៅរួមចំណែកលើកកម្ពស់ការអនុវត្តតាមគោលនយោបាយវិនិយោគប្រកបដោយការទទួលខុសត្រូវលើបរិស្ថាន សង្គម និងអភិបាលកិច្ចល្អ ស្របតាមនិន្នាការនៃការវិនិយោគសកល។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏កំពុងស្វែងរកនីតិវិធីក្នុងការបង្វែរការវិនិយោគទុនបម្រុងអន្តរជាតិមកគម្រោងបៃតងនៅកម្ពុជា ស្របតាមការលើកឡើងរបស់លោកជំទាវទេសាភិបាល អំពីដំណោះស្រាយមួយចំនួននៅក្នុងអត្ថបទចេញផ្សាយដោយទស្សនាវដ្តី The Banker រួមមាន ការលើកទឹកចិត្តឱ្យស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបោះផ្សាយជាសញ្ញាបណ្ណបៃតងសម្រាប់គម្រោងវិនិយោគនៅកម្ពុជា និងការធ្វើ Reserve Swap រវាងធនាគារកណ្តាលក្នុងតំបន់ ដើម្បីគាំទ្រគម្រោងបៃតងក្នុងប្រទេសរៀងៗខ្លួន។

ជារួម ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជារក្សាបានស្ថិរភាពល្អ ដែលឆ្លុះបញ្ចាំងតាមរយៈការបន្តងើបឡើងនៃកំណើនសេដ្ឋកិច្ច ជាមួយនឹងកម្រិតទាបនៃអតិផរណា និងស្ថិរភាពអត្រាប្តូរប្រាក់។ សមតុល្យជញ្ជីងទូទាត់កម្ពុជាបន្តមានអតិរេក ស្របពេលដែលទុនបម្រុងអន្តរជាតិមានកម្រិតខ្ពស់គ្រប់គ្រាន់។

# III- ការគ្រប់គ្រងរូបិយវត្ថុ

## ១- ការផ្គត់ផ្គង់រូបិយវត្ថុ

រូបិយវត្ថុទូទៅ (M2) បានបន្តកើនឡើង ១៧,៥% ធៀបនឹងឆ្នាំ២០២៣ បន្ទាប់ពីបានថមថយមកកម្រិតទាបបំផុតនៅឆ្នាំ២០២២ (៨,៣%)។ ការកើនឡើងនេះគឺដោយសារប្រាក់បញ្ញើជារូបិយប័ណ្ណកើន ១៩,៩% និងប្រាក់បញ្ញើជារៀល ១២,៥% ខណៈរូបិយវត្ថុក្នុងចរាចរណ៍បានថយចុះ -២,៨% ក្នុងបរិការណ៍ការរីកចម្រើននៃការទូទាត់អេឡិចត្រូនិក។ ទន្ទឹមនេះ សេដ្ឋកិច្ចកម្ពុជាបន្តមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ដែលឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅស្មើនឹង ៨៥,១% ប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុប ៩០,៩% និងឥណទានជារូបិយប័ណ្ណធៀបនឹងឥណទានសរុប ៨៨,២%។

**ក្រាហ្វ ៣៨៖ ការរួមចំណែកក្នុងកំណើនរូបិយវត្ថុទូទៅ**
(គិតជាភាគរយ, ២០១៧ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៩៖ កំណើនសមាសធាតុរូបិយវត្ថុទូទៅ**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២- ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់

ឆ្លើយតបនឹងកំណើនតម្រូវការប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដោយទិញប្រាក់ដុល្លារអាមេរិកចំនួន ៨០ លានដុល្លារអាមេរិកពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធៀបនឹងការលក់ដុល្លារអាមេរិកចំនួន ១៣៩ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣។ ដោយឡែក ការទិញប្រាក់ដុល្លារអាមេរិកសុទ្ធពីស្ថាប័នរដ្ឋមានចំនួន ៣៦,៩ លានដុល្លារអាមេរិក (ទិញ ៤២,៧ លានដុល្លារអាមេរិក) ធៀបនឹងការទិញសុទ្ធ ១៥,១ លានដុល្លារអាមេរិក (ទិញ ៣០,៤ លានដុល្លារអាមេរិក) កាលពីឆ្នាំ២០២៣។

**ក្រាហ្វ ៤០៖ អន្តរាគមន៍ទិញ-លក់ប្រាក់ដុល្លារអាមេរិក**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤១៖ ការទិញលក់ប្រាក់ដុល្លារអាមេរិកជាមួយស្ថាប័នរដ្ឋ**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣- អត្រាប្រាក់បម្រុងកាតព្វកិច្ច

អត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀល និង ដុល្លារអាមេរិកត្រូវបានបន្តរក្សាឱ្យនៅកម្រិតទាប ត្រឹម ៧%។ ប្រាក់បម្រុងកាតព្វកិច្ចជារៀលមាន ១,៧ ទ្រីលានរៀល ដែលបានកើនឡើង ១០,២% ធៀបនឹងឆ្នាំ២០២៣ ខណៈជាដុល្លារអាមេរិកមាន ៤ ប៊ីលានដុល្លារអាមេរិក (១៦ ទ្រីលានរៀល) ដែលបានថយចុះ -០,៥%។ ការបន្ទាបអត្រានេះ បានផ្តល់សន្ទនីយភាពបន្ថែមប្រមាណ ១,៣ ប៊ីលាន ដុល្លារអាមេរិក ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្រាប់ទ្រទ្រង់ការបន្តងើបឡើងនៃសកម្មភាព សេដ្ឋកិច្ច។

ក្រៅពីប្រាក់បម្រុងកាតព្វកិច្ច គ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ ក៏មានប្រាក់បម្រុងមិនជាប់ កាតព្វកិច្ចផ្សេងទៀតនៅធនាគារជាតិនៃកម្ពុជា ផងដែរ ដែលហៅថា ប្រាក់បម្រុងលើស[២៣]។ ប្រាក់បម្រុងលើសជាដុល្លារអាមេរិកមាន ៤,៩ ប៊ីលាន ដុល្លារអាមេរិក (២៤,៦ ទ្រីលានរៀល) ស្មើនឹង ១,៥ដង នៃប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារ អាមេរិក។ ប្រាក់បម្រុងលើសជារៀលមាន ៥,១ ទ្រីលានរៀល ស្មើនឹង ៣,១ដង នៃប្រាក់បម្រុង កាតព្វកិច្ចជារៀល។ ដោយសារទីផ្សារអន្តរធនាគារ ស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ គ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុបានរក្សាប្រាក់បម្រុងលើស ក្នុងកម្រិតខ្ពស់ ដើម្បីកាត់បន្ថយហានិភ័យសន្ទនីយភាព ដែលការណ៍នេះធ្វើឱ្យប្រសិទ្ធភាពការ អនុវត្តនយោបាយរូបិយវត្ថុ នៅមានកម្រិតផងដែរ។

**ក្រាហ្វ ៤២៖ ទំហំនិងអត្រាប្រាក់បម្រុងកាតព្វកិច្ច**

(ទិន្នន័យចុងគ្រា, ឆ្នាំ១៩៩៣ - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៣៖ ប្រាក់បម្រុងលើស**

(គិតជាទ្រីលានរៀល, ខែមករា ឆ្នាំ២០២៣ - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៤៖ អនុបាតប្រាក់បម្រុងលើសធៀប ប្រាក់បម្រុងកាតព្វកិច្ច**

(គិតជាចំនួនដង, ខែមករា ឆ្នាំ២០២៣ - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[២៣] ប្រាក់បម្រុងលើស = សមតុល្យគណនីចរន្ត + សមតុល្យគណនីទូទាត់ + សមតុល្យគណនីបាគង

## ៤- មូលបត្រអាចជួញដូរបាន

មូលបត្រអាចជួញដូរបាន (NCD) ត្រូវបានប្រើប្រាស់ជាឧបករណ៍នយោបាយរូបិយវត្ថុ ដើម្បីស្រូបយកសន្ទនីយភាពលើសពីប្រព័ន្ធធនាគារ ហើយក៏អាចប្រើប្រាស់ជាវត្ថុធានាសម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពជារៀលរបស់ធនាគារជាតិនៃកម្ពុជា និងទីផ្សារអន្តរធនាគារផងដែរ។ NCD បានស្រូបយកប្រាក់រៀលសរុបមាន ២៦,៨ ទ្រីលានរៀល ដែលបានកើនឡើង ៥៧,៨% ធៀបនឹងឆ្នាំ២០២៣។ គួររំលេចថា ការចេញផ្សាយ NCD មាននិន្នាការថយចុះក្នុងអំឡុងត្រីមាសទី១ ដោយសារកំណើនតម្រូវការប្រាក់រៀលនៅលើទីផ្សារសម្រាប់ការបង់ពន្ធនិងការប្រមូលកសិផល ប៉ុន្តែបានកើនឡើងមកវិញនៅគ្រាបន្ទាប់។ ទន្ទឹមនេះ អត្រាការប្រាក់ NCD ជារៀលជាមធ្យមបានថយចុះពី ០,៩៤% នៅឆ្នាំ២០២៣ មក ០,៩៣% ក្នុងនោះ អត្រាការប្រាក់ NCD ៧ថ្ងៃមានកម្រិត ០,៦៣% (កើនពី ០,៥៦%) និង ៣៦៤ថ្ងៃ ១,៣០% (កើនពី ១,២៣%) ខណៈឥណប្រតិទាន១៤ថ្ងៃមានអត្រា ០,៥៥% (ថយពី ០,៦២%) ២៨ថ្ងៃ ០,៨៤% (ថយពី ០,៨៦%) ៩១ថ្ងៃ ១,២៨% (ថយពី ១,៣៣%) និង ១៨២ថ្ងៃ ០,៩៩% (ថយពី ១,០៣%) ។ នៅចុងឆ្នាំ២០២៤ នេះ អត្រាការប្រាក់ NCD ៧ថ្ងៃ ត្រូវបានបង្កើនពី ០,៧៥% ទៅ ១% ដើម្បីបង្កើនប្រសិទ្ធភាពនៃការស្រូបយកសន្ទនីយភាព។

**ក្រាហ្វ ៤៥៖ ចំនួនទឹកប្រាក់ NCD ជារៀល ដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**

(គិតជាទ្រីលានរៀល, ខែមករា - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៦៖ អត្រាការប្រាក់ NCD ជារៀល**

(គិតជាភាគរយ, ឆ្នាំ២០២៣ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ចំណែកការចេញផ្សាយ NCD ជាដុល្លារអាមេរិកគឺមានស្ថិរភាពពីចន្លោះ ២០០-៥០០ លានដុល្លារអាមេរិកក្នុងមួយខែ។ ការស្រូបយកសន្ទនីយភាពជាដុល្លារអាមេរិកសរុបមាន ៣,៨ ប៊ីលានដុល្លារអាមេរិក ដែលបានថយចុះ -២៦,៣% ធៀបនឹងឆ្នាំ២០២៣។ អត្រាការប្រាក់ NCD ជាដុល្លារអាមេរិកបានថយចុះពី ១,០៧% នៅឆ្នាំ២០២៣ មក ០,៦៩% ជាមធ្យម ដែលក្នុងនោះ អត្រាការប្រាក់ NCD ៧ថ្ងៃ មានកម្រិត ០,២២% (ថយពី ០,៧៤%) ១៤ថ្ងៃ ០,២៧% (ថយពី ០,៧៨%) ២៨ថ្ងៃ ០,៣១% (ថយពី ០,៨៦%) ៩១ថ្ងៃ ១,០៩% (ថយពី ១,២៩%) ១៨២ថ្ងៃ ១,០៨% (ថយពី ១,៣៧%) និង ៣៦៤ថ្ងៃ ១,១៦% (ថយពី ១,៣៩%)។

**ក្រាហ្វ ៤៧៖ ចំនួនទឹកប្រាក់ NCD ជាដុល្លារអាមេរិក ដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**

(គិតជាលានដុល្លារអាមេរិក, ខែមករា - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៨៖ អត្រាការប្រាក់ NCD ជាដុល្លារអាមេរិក**

(គិតជាភាគរយ, ឆ្នាំ២០២៣ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥- ការបោះផ្សាយមូលបត្ររដ្ឋ

នាឆ្នាំ២០២៤នេះ ការបោះផ្សាយមូលបត្ររដ្ឋសរុបមានចំនួន ៣០១,៣ ប៊ីលានរៀល កើនឡើង ៦៣,៣ ប៊ីលានរៀល (២៧%) ធៀបនឹងឆ្នាំ២០២៣ ដែលក្នុងនោះការបោះផ្សាយតាមរយៈការដេញថ្លៃមានចំនួន ១២ លើក ស្មើនឹង ២៨៥,៣ ប៊ីលានរៀល និងតាមរយៈការចរចារមានចំនួន ៣ លើក ស្មើនឹង ១៦ ប៊ីលានរៀល។ ទន្ទឹមនេះ ការទូទាត់គូប៉ុងសរុបមានចំនួន ៣០ លើក ស្មើនឹង ១៤,២ ប៊ីលានរៀល និងការទូទាត់ប្រាក់ដើមមានចំនួន ៤ លើក ស្មើនឹង ៧៦ ប៊ីលានរៀល។

**ក្រាហ្វ ៤៩៖ មូលបត្ររដ្ឋ**

(គិតជាប៊ីលានរៀល, ឆ្នាំ២០២២-ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

| តារាង ២៖ ការបោះផ្សាយមូលបត្ររដ្ឋតាមរយៈការដេញថ្លៃ | | | | | |
|---|---|---|---|---|---|
| លើកទី | កាលបរិច្ឆេទ | ទំហំប្រាក់សរុប (ប៊ីលានរៀល) | ឥណប្រតិទាន | អត្រាគូប៉ុង | អត្រាចំណូល |
| ១ | ២៦-មករា-២៤ | ២២ | ១ឆ្នាំ | ៣,៥០% | ៣,៧៥%-៣,៩៥% |
| ២ | ២៣-កុម្ភៈ-២៤ | ២០ | ២ឆ្នាំ | ៤,០០% | ៤,៧០%-៤,៧៥% |
| ៣ | ២២-មីនា-២៤ | ១៤០ | ៣ឆ្នាំ | ៤,៥០% | ៥,០០%-៥,២៥% |
| ៤ | ២៦-មេសា-២៤ | ១០ | ១ឆ្នាំ | ៣,៥០% | ៣,៩៥% |
| ៥ | ៣១-ឧសភា-២៤ | ២០ | ២ឆ្នាំ | ៤,០០% | ៤,០០% |
| ៦ | ២៨-មិថុនា-២៤ | ៤៣,៣ | ៣ឆ្នាំ | ៤,៥០% | ៤,០០%-៥,២៥% |
| ៧ | ២៧-កក្កដា-២៤ | ១០ | ៥ឆ្នាំ | ៥,០០% | ៥,០០% |
| ៨ | ២១-សីហា-២៤ | ០ | ១០ឆ្នាំ | ៥,២៥% | - |
| ៩ | ១៨-កញ្ញា-២៤ | ២០ | ៣ឆ្នាំ | ៤,៥០% | ៥,០០%-៥,២៥% |
| ១០ | ១៦-តុលា-២៤ | ០ | ៥ឆ្នាំ | ៤,៧៥% | - |
| ១១ | ១៣-វិច្ឆិកា-២៤ | ០ | ៣ឆ្នាំ | ៤,០០% | - |
| ១២ | ១១-ធ្នូ-២៤ | ០ | ៣ឆ្នាំ | ៣,៨០% | - |

មូលបត្ររដ្ឋដែលមានឥណប្រតិទាន ១ឆ្នាំ មានអត្រាគូប៉ុងជាមធ្យម ៣,៥០% និងអត្រាចំណូល ៣,៧៥%-៣,៩៥% ឥណប្រតិទាន ២ឆ្នាំ មានអត្រាគូប៉ុងជាមធ្យម ៤,០០% និងអត្រាចំណូល ៤,០០%-៤,៧៥% ឥណប្រតិទាន ៣ឆ្នាំមានអត្រាគូប៉ុងជាមធ្យម ៤,២៦% និងអត្រាចំណូល ៥,០០%-៥,២៥% ឥណប្រតិទាន ៥ឆ្នាំមានអត្រាគូប៉ុងជាមធ្យម ៤,៥៨% និងអត្រាចំណូល ៤,០០%-៥,០០% ឥណប្រតិទាន ១០ឆ្នាំមានអត្រាគូប៉ុងជាមធ្យម ៤,៥៣% និងអត្រាចំណូល ៣,៨០% និងឥណប្រតិទាន ១៥ឆ្នាំមានអត្រាគូប៉ុងជាមធ្យម ៣,៥០% និងអត្រាចំណូល ៣,៥០%។

**ក្រាហ្វ ៥០៖ អត្រាគូប៉ុង និងអត្រាចំណូលជាមធ្យម**

(គិតជាភាគរយ, ឆ្នាំ២០២២-ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាបានបន្តដើរតួនាទីជាអាណត្តិគាហកសម្រាប់រាជរដ្ឋាភិបាលក្នុងការបោះផ្សាយមូលបត្ររដ្ឋ និងបានចូលរួមចំណែកអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ ស្របតាមក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣-២០២៨។ ក្នុងឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពីការអនុញ្ញាតឱ្យគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ[២៤]ធ្វើប្រតិបត្តិការមូលបត្ររដ្ឋនៅលើថ្នាលធនាគារជាតិនៃកម្ពុជា។

[២៤] គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារសំដៅដល់ (១) ក្រុមហ៊ុនធានាទិញមូលបត្រ (២) ពាណិជ្ជករមូលបត្រ និង (៣) ឈ្មួញជើងសាមូលបត្រ។

## ៦- ប្រតិបត្តិការផ្តល់សន្ទនីយភាព

ការផ្តល់សន្ទនីយភាពជារៀលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈ LPCO មានចំនួន ៤,៣២ ទ្រីលានរៀល (ប្រមាណ ១,០៨ ប៊ីលានដុល្លារអាមេរិក) ដែលបានកើនឡើង ៧៤,០៨% ធៀបនឹងឆ្នាំមុន ក្នុងនោះមានឥណប្រតិទាន៧ថ្ងៃ (២.២៣០ ប៊ីលានរៀល) ៩១ថ្ងៃ (១.២២៦,២ ប៊ីលានរៀល) និង ១៨២ថ្ងៃ (៨៦២,៥ ប៊ីលានរៀល)។ ការផ្តល់សន្ទនីយភាពបានកើនឡើង ជាចម្បងដោយសារការបង្កើនទំហំ LPCO ៧ថ្ងៃ និងការរៀបចំឱ្យមានការដេញថ្លៃរៀងរាល់សប្តាហ៍។ ជាមួយគ្នានេះ អត្រាការប្រាក់ LPCO ៧ថ្ងៃក៏ត្រូវបានបន្ថយពី ៣,៧៥% មក ៣,៥០% ៩១ថ្ងៃ បន្ថយពី ៤% មក ៣,៧៥% និង ១៨២ថ្ងៃ បន្ថយពី ៤,២៥% មក ៤% នៅចុងឆ្នាំ២០២៤ ស្របតាមនិន្នាការនយោបាយរូបិយវត្ថុអន្តរជាតិ និងស្ថានភាពសេដ្ឋកិច្ចកម្ពុជា។

**ក្រាហ្វ ៥១៖ ការផ្តល់សន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការ LPCO ប្រចាំខែ**

(គិតជាប៊ីលានរៀល, ខែមករា - ខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

LPCO មិនទាន់ដល់ឥណប្រតិទានបានថយចុះ -៣៣% ធៀបនឹងឆ្នាំមុន មកត្រឹម ៧០០ ប៊ីលានរៀល ដោយសារការកាត់បន្ថយទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃសម្រាប់ឥណប្រតិទានចាប់ពី ៣ខែ និងបង្កើនទំហំទឹកប្រាក់សម្រាប់ឥណប្រតិទានខ្លីៗ។ អត្រាការប្រាក់ដេញថ្លៃឈ្នះ LPCO ជាមធ្យមសម្រាប់ឥណប្រតិទាន៧ថ្ងៃមានកម្រិត ៣,៧៣% ៩១ថ្ងៃមានកម្រិត ៤,១៣% និង ១៨២ថ្ងៃមានកម្រិត ៤,៣៣%។

**ក្រាហ្វ ៥២៖ ការផ្តល់សន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការ LPCO ប្រចាំឆ្នាំ**

(គិតជាប៊ីលានរៀល, ឆ្នាំ២០១៨ - ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥៣៖ អត្រាការប្រាក់ដេញថ្លៃឈ្នះប្រតិបត្តិការ LPCO ប្រចាំខែ**

(គិតជាភាគរយ, ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) មានចំនួន ៨៩១ ប៊ីលានរៀល ក្នុងអត្រាការប្រាក់ ៦% ស្មើនឹងអត្រាឥណទានវិបារូបន៍ (Overdraft)។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចស្នើសុំបន្តឥណប្រតិទានប្រតិបត្តិការ MLF ជារៀងរាល់ថ្ងៃ ដោយមិនកំណត់ ជាមួយនឹងភាពគ្រប់គ្រាន់នៃវត្ថុធានា។ នាចុងឆ្នាំ២០២៤នេះ អត្រាការប្រាក់ MLF ត្រូវបានកាត់បន្ថយពី ៦% ទៅ ៥,៥% ដែលនឹងរួមចំណែកផ្តល់សន្ទនីយភាពជាប្រាក់រៀលក្នុងអត្រាល្អជាងប្រាក់ដុល្លារអាមេរិក ដែលរក្សាអត្រាឥណទានវិបារូបន៍ ៦% នៅដដែល។

ជារួម ក្នុងឆ្នាំ២០២៤នេះ រូបិយវត្ថុទូទៅបានបន្តដើបឡើង ស្របតាមកំណើនសេដ្ឋកិច្ច ដែលគាំទ្រដោយកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណ។ ធនាគារជាតិនៃកម្ពុជាបន្តរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ តាមរយៈការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ គួបផ្សំនឹងការបង្កើនការស្រូបយកនិងបញ្ចេញសន្ទនីយភាពរយៈពេលខ្លីៗជាជាងជាមួយឥណប្រតិទានចាប់ពី ៣ខែឡើងទៅ។

# IV-ប្រព័ន្ធធនាគារនៅកម្ពុជា

## ១- ស្ថានភាពទូទៅ

ប្រព័ន្ធធនាគារនៅកម្ពុជាមានធនាគារពាណិជ្ជ ៥៩ ធនាគារឯកទេស ៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨៥ គ្រឹះស្ថានឥណទានជនបទ ១១៤ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១៣ អ្នកដំណើរការតតិយភាគី ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៣០ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងធនាគារបរទេស ៥ និងអាជីវកម្មប្តូរប្រាក់ ៣.៣២៧។

ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារ មានកំណើន ៧% ដល់ ៣៦៩,៤ ទ្រីលានរៀល (៩១,១ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះវិស័យធនាគារមានសមាមាត្រ ៩៣,២% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារ វិស័យមីក្រូហិរញ្ញវត្ថុ ៦,៤% និងវិស័យភតិសន្យាហិរញ្ញវត្ថុ ០,៤%។

**ក្រាហ្វ ៥៤៖ ទ្រព្យសកម្មប្រព័ន្ធធនាគារ**

(ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤)

**ក្រាហ្វ ៥៥៖ សមាមាត្រទ្រព្យសកម្មប្រព័ន្ធធនាគារ**

(គិតជាភាគរយ, ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤)

ឥណទានកើនឡើង ៣% ដល់ ២៩២,៩ ទ្រីលានរៀល (៥៩,៩ ប៊ីលានដុល្លារអាមេរិក)។ សម្រាប់ប្រភពមូលនិធិ ប្រាក់បញ្ញើមានកំណើន ១៦,៣% ដល់ ២៣០,៩ ទ្រីលានរៀល (៥៧ ប៊ីលានដុល្លារអាមេរិក) និងដើមទុនមានកំណើន ៥,២% ដល់ ៤០,៥ ទ្រីលានរៀល (១០ ប៊ីលានដុល្លារអាមេរិក)។

**ក្រាហ្វ ៥៦៖ ឥណទានប្រព័ន្ធធនាគារ**

(ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤)

**ក្រាហ្វ ៥៧៖ ប្រាក់បញ្ញើប្រព័ន្ធធនាគារ**

(ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤)

## ២- ស្ថិរភាពហិរញ្ញវត្ថុ



របាយការណ៍ស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០២៣

ជាមួយនឹងភាពមិនប្រាកដប្រជាខ្ពស់នៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកល គួបផ្សំនឹងការងើបឡើងវិញមិនស្មើគ្នានៃវិស័យសេដ្ឋកិច្ចក្នុងស្រុក ប្រព័ន្ធធនាគារបានទទួលរងសម្ពាធ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនយឺតនៃឥណទាន ការថយចុះគុណភាពឥណទាន និងការថមថយលទ្ធភាពស្វែងរកប្រាក់ចំណេញ។ ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាបានបន្តតាមដានស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការពង្រឹងការវិភាគហានិភ័យវិស័យហិរញ្ញវត្ថុ ការវិភាគភាពប្រទាក់ក្រឡារវាងសេដ្ឋកិច្ចវិស័យរូបវន្តនិងវិស័យហិរញ្ញវត្ថុ និងការធ្វើស្ត្រេសតេស្ត។ ជាមួយគ្នានេះ វិធានការអនុគ្រោះបទប្បញ្ញត្តិត្រូវបានដាក់-ចេញ ដើម្បីសម្រាលបន្ទុកដល់អ្នកខ្ចីដែលជួបការលំបាកហិរញ្ញវត្ថុ និងផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចរៀបចំផែនការទប់ទល់នឹងហានិភ័យនិងការខាតបង់ដែលអាចកើតមាន។ ទោះយ៉ាងណា ប្រព័ន្ធធនាគារបន្តរក្សាបានភាពធន់ទាំងផ្នែកដើមទុននិងសន្ទនីយភាព និងអនុវត្តប្រតិបត្តិការសេវាធនាគារប្រកបដោយភាពប្រុងប្រយ័ត្ន ដូចមានបង្ហាញតាមរយៈសូចនាករភាពរឹងមាំហិរញ្ញវត្ថុសំខាន់ៗខាងក្រោម៖

i/- ស្ថានភាពដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបន្តមានភាពគ្រប់គ្រាន់ អនុលោមតាមបទប្បញ្ញត្តិ (១៥%) ដោយអនុបាតភាពគ្រប់គ្រាន់នៃដើមទុនវិស័យធនាគារមានកម្រិតជាមធ្យម ២២,៥% និងវិស័យមីក្រូហិរញ្ញវត្ថុមានកម្រិត ២៦,២%។ ធនាគារជាតិនៃកម្ពុជាក៏បានធ្វើស្ត្រេសតេស្តក្នុងគោលបំណងសាកល្បង ភាពធន់នៃដើមទុនរបស់ធនាគារ តាមរយៈការកំណត់សេណារីយ៉ូស្ត្រេសជាច្រើន និងជាលទ្ធផលបានបង្ហាញថាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅតែអាចរក្សាបានដើមទុនរឹងមាំទប់ទល់នឹងហានិភ័យដែលអាចកើតមាន។

ii/- សន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្តមានកម្រិតខ្ពស់ជាងកម្រិតកំណត់នៃបទប្បញ្ញត្តិ (១០០%) ដោយគ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានអនុបាតក្របខណ្ឌសន្ទនីយភាពជាមធ្យមក្នុងកម្រិត ១៩២,៤% និង ១៥០,៤% រៀងគ្នា ដែលបង្ហាញពីលទ្ធភាពគ្រប់គ្រាន់នៃការសងប្រាក់រយៈពេលខ្លី និងតម្រូវការដកប្រាក់បញ្ញើរបស់អតិថិជន ព្រមទាំងអាចឆ្លើយតបនឹងតម្រូវការឥណទាន។

**ក្រាហ្វ ៥៨៖ អនុបាតភាពគ្រប់គ្រាន់នៃដើមទុន**

(គិតជាភាគរយ, ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤)

**ក្រាហ្វ ៥៩៖ អនុបាតគ្របខណ្ឌសន្ទនីយភាព**

(គិតជាភាគរយ, ឆ្នាំ២០១៨ - ឆ្នាំ២០២៤ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤)

iii/- អនុបាតឥណទានមិនដំណើរការ[២៥]បន្តកើនឡើង ដែលក្នុងនោះវិស័យធនាគារមានកម្រិត ៧,៩% និងវិស័យមីក្រូហិរញ្ញវត្ថុមានកម្រិត ៩% ប៉ុន្តែគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានធ្វើសំវិធានធនគ្រប់គ្រាន់ ដោយសំវិធានធនធៀបនឹងឥណទានមិនដំណើរការមានកម្រិត ៥៥,១%។ ប្រសិនបើដកសំវិធានធនពីឥណទានមិនដំណើរការដុល អនុបាតឥណទានមិនដំណើរការសុទ្ធមានកម្រិតត្រឹម ៣,៥% ដែលជាកម្រិតមួយអាចគ្រប់គ្រងបាន និងបង្ហាញថាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រៀមខ្លួនរួចជាស្រេចក្នុងការបង្ការនិងទប់ទល់ទៅនឹងហានិភ័យឥណទាន។

iv/- លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានថយចុះ ដែលបណ្តាលមកពីការកើនឡើងនៃសំវិធានធនសម្រាប់ឥណទានមិនដំណើរការ គួបផ្សំនឹងកំណើនយឺតនៃឥណទាន។ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក (ROE) របស់វិស័យធនាគារ មានកម្រិត ០,២% និង ១,២% រៀងគ្នា ដែលបានថយចុះធៀបនឹងឆ្នាំ២០២៣ (០,៦% និង ៣,៩%) ខណៈវិស័យមីក្រូហិរញ្ញវត្ថុមានកម្រិត ០,៦% និង ២,៥% រៀងគ្នា ទាបជាងឆ្នាំ២០២៣ (១,៥% និង ៥,៩%)។




សិក្ខាសាលាស្តីពី ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ ឆ្នាំ២០២៣
នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ

[២៥] អនុបាតឥណទានមិនដំណើរការត្រូវបានគណនាដោយយកឥណទានមិនដំណើរការដុល (Gross NPL) ដែលមិនទាន់ដកសំវិធានធនធៀបនឹងឥណទានដុល។

## ៣- វិស័យធនាគារ

ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារបានកើនឡើង ៨,២% ដល់ ៣៤២,៨ ទ្រីលានរៀល (៨៤,៦ ប៊ីលានដុល្លារអាមេរិក) ដោយឥណទានបានកើនឡើង ៣,៣% ដល់ ២២០,១ ទ្រីលានរៀល (៥៤,៣ ប៊ីលានដុល្លារអាមេរិក) និងមានចំនួន ២,៤ លានគណនី។ ឥណទានត្រូវបានផ្តល់ទៅកាន់វិស័យសំខាន់ៗ ក្នុងសេដ្ឋកិច្ច ដូចជា៖ ការជួញដូររាយ ១៦,៩% ការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ១២,៥% ការជួញដូរអចលនទ្រព្យ ១១,៦% ការឱ្យខ្ចីជាបុគ្គល ១០,១% សំណង់ ៩,៧% កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៨,៩% ការជួញដូរដុំ ៨,៨% កម្មន្តសាល ៤,៣% សណ្ឋាគារនិងភោជនីយដ្ឋាន ៤,០% និងផ្សេងៗ ១៣,២%។

**ក្រាហ្វ ៦០៖ ឥណទានគ្រឹះស្ថានធនាគារតាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច**
(ឆ្នាំ២០២៤ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤)

អត្រាការប្រាក់បញ្ញើ ជារៀលនិងដុល្លារអាមេរិករបស់គ្រឹះស្ថានធនាគារជាមធ្យមបានថយចុះមកត្រឹម ៥,៧១% និង ៥,១៨% រៀងគ្នា ទាបជាងអត្រាក្នុងឆ្នាំ២០២៣ (៦,៧៤% និង ៥,៦៤% រៀងគ្នា)។ ដោយឡែក អត្រាការប្រាក់ឥណទានជារៀល និងដុល្លារអាមេរិកជាមធ្យមកើនឡើងដល់ ១២,១១% និង ១០,៣០% រៀងគ្នា ធៀបនឹងឆ្នាំ២០២៣ (១២,០៥% និង ៩,៩២% រៀងគ្នា)។

**ក្រាហ្វ ៦១៖ អត្រាការប្រាក់ជាមធ្យមរបស់គ្រឹះស្ថានធនាគារ**
(គិតជាភាគរយ, ឆ្នាំ២០១៨ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- វិស័យមីក្រូហិរញ្ញវត្ថុ

ទ្រព្យសកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានថយចុះ -៣,៩% មក ២៥,៦ ទ្រីលានរៀល (៦,២ ប៊ីលានដុល្លារអាមេរិក) ដែលក្នុងនោះឥណទានបានកើនឡើង ១,៩% ដល់ ២១,៤ ទ្រីលានរៀល (៥,៣ ប៊ីលានដុល្លារអាមេរិក) ដោយមាន ១,៦ លានគណនី។ ឥណទានទាំងនេះបានផ្តល់ទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច រួមមាន៖ អង្គភាពគ្រួសារ ៣២,៨% កសិកម្ម ២០,៨% ពាណិជ្ជកម្មនិងជំនួញ ២០,១% សេវាកម្ម ១១,៨% សំណង់ ៦,៧% ដឹកជញ្ជូន ២,៧% កម្មន្តសាល ២,៧% និងផ្សេងៗ ២,៤%។

**ក្រាហ្វ ៦២៖ ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យសំខាន់ៗ**

(ឆ្នាំ២០២៤ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤)

អត្រាការប្រាក់បញ្ញើក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជារៀល និងដុល្លារអាមេរិកជាមធ្យម បានថយចុះមកត្រឹម ៦,៤៤% និង ៦,៥១% រៀងគ្នា ធៀបនឹងឆ្នាំ២០២៣ (៧,២៧% និង ៧,៦៥% រៀងគ្នា)។ ទន្ទឹមនេះ អត្រាការប្រាក់ឥណទានជាមធ្យម ជារៀល និងដុល្លារអាមេរិកថយមកត្រឹម ១៦,៦៤% និង ១៤,២៥% រៀងគ្នា ពី ១៦,៩១% និង ១៤,៦៩% នៅឆ្នាំ២០២៣។

**ក្រាហ្វ ៦៣៖ អត្រាការប្រាក់ជាមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

(គិតជាភាគរយ, ឆ្នាំ២០១៨ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥- វិស័យភតិសន្យាហិរញ្ញវត្ថុ

ក្នុងឆ្នាំ២០២៤ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុចំនួន ១ បានក្លាយទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថាន ១ ទៀត បានរួមបញ្ចូលគ្នាជាមួយធនាគារឯកទេស ដែលការណ៍នេះជាកត្តាចម្បង នាំឱ្យទ្រព្យសកម្មរបស់វិស័យនេះថយចុះ -២៥,៦% មក ១,៣ ទ្រីលានរៀល (៣៥៧,៦ លានដុល្លារអាមេរិក)។ ភតិសន្យាហិរញ្ញវត្ថុបានថយចុះ -២១,៧% មក ១,៤ ទ្រីលានរៀល (៣២០,០ លានដុល្លារអាមេរិក) ដោយមាន ៥២.៦៣៧ គណនី និងត្រូវបានផ្តល់ទៅវិស័យផ្សេងៗរួមមាន៖ អង្គភាពគ្រួសារ ៣០,៥% កសិកម្ម ២៩,៨% សេវាកម្ម ១៧,១% ដឹកជញ្ជូន ៤,១% សំណង់ ៣,៤% ពាណិជ្ជកម្មនិងជំនួញ ២,៥% និងវិស័យផ្សេងៗ ១២,៦%។ ប្រភពទុនចម្បងនៃភតិសន្យាហិរញ្ញវត្ថុបានមកពីមូលនិធិភាគទុនិកដែលបានថយចុះ -២៣,៩% មក ៥០៤,៧ ប៊ីលានរៀល (១២៤,៦ លានដុល្លារអាមេរិក)។

## ៦- គ្រឹះស្ថានឥណទានជនបទ

គិតត្រឹមឆ្នាំ២០២៤ គ្រឹះស្ថានឥណទានជនបទចំនួន ១១៥ ដែលទទួលបានវិញ្ញាបនបត្រពីធនាគារជាតិនៃកម្ពុជា បាននិងកំពុងធ្វើប្រតិបត្តិការផ្តល់ឥណទានខ្នាតតូចដល់ប្រជាជនដែលមានប្រាក់ចំណូលទាប នៅតាមទីប្រជុំជននិងជនបទ។

គ្រឹះស្ថានឥណទានជនបទបានផ្តល់ឥណទានសរុប ២០៥,៣ ប៊ីលានរៀល (៥០,៦ លានដុល្លារអាមេរិក) ទៅដល់អតិថិជនចំនួន ៨៤.៥២៣ គណនី ដោយបានបែងចែកទៅកាន់វិស័យចម្បងៗ រួមមាន៖ កសិកម្ម ២៨,៥% អង្គភាពគ្រួសារ ២៦,៥% ពាណិជ្ជកម្ម ២១% សេវាកម្ម ៨,៣% សំណង់ ៥,៥% ដឹកជញ្ជូន ១,២% និងផ្សេងៗ ៩%។ ឥណទានជនបទមានសារៈសំខាន់ក្នុងការរួមចំណែកលើកកម្ពស់ការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដែលមានការគាំពារដោយច្បាប់ បញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញកំណើនសេដ្ឋកិច្ចគ្រួសារប្រកបដោយចីរភាពនិងបរិយាបន្ន។

## ៧- អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ដែលជាអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មានទ្រព្យសកម្មសរុបប្រមាណ ៨៧,៤ ប៊ីលានរៀល (២១,៧ លានដុល្លារអាមេរិក) និងមានគ្រឹះស្ថានជាសមាជិកចំនួន ១៩៩ គ្រឹះស្ថាន។ គិតត្រឹមដំណាច់ឆ្នាំ២០២៤ គ្រឹះស្ថានជាសមាជិកបានបញ្ចូលទិន្នន័យឥណទានទៅក្នុងប្រព័ន្ធចំនួន ៤,៣ លានគណនី (ប្រមាណ ២៣៦,៤ ទ្រីលានរៀល ស្មើនឹង ៥៨,៧ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះ៖ i/- ឯកត្តបុគ្គល ៤,៣ លានគណនី ជាមួយអតិថិជនសរុបចំនួន ៥,១ លាននាក់ (ស្ត្រី ៥៣,១%) និង ii/- ក្រុមហ៊ុន ៦,២ ពាន់គណនី ជាមួយនឹងចំនួន ១.៧៥៣ ក្រុមហ៊ុន។ ជាមួយគ្នានេះដែរ គ្រឹះស្ថានជាសមាជិកបានចូលប្រើប្រាស់របាយការណ៍ឥណទាន សរុបមានចំនួន ៦,៧ លានប្រតិបត្តិការ ក្នុងនោះ ធនាគារ ៤,៤ លានប្រតិបត្តិការ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២,២ លានប្រតិបត្តិការ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ៧៤,១ ពាន់ប្រតិបត្តិការ និងគ្រឹះស្ថានឥណទានជនបទ ៥៦,៥ ពាន់ប្រតិបត្តិការ។ ទន្ទឹមនេះ គ្រឹះស្ថានជាសមាជិកបានបញ្ចូលទិន្នន័យ មូលប្បទានប័ត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីចំនួន ៧.៧២៥ ប្រតិបត្តិការប្រមាណ ២,៦ ទ្រីលានរៀល (៦៥២,១ លានដុល្លារអាមេរិក)។

**ក្រាហ្វ ៦៤៖ ការពិនិត្យរបាយការណ៍ឥណទានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន**

(គិតជាចំនួនពាន់ប្រតិបត្តិការ, ឆ្នាំ២០២០ - ឆ្នាំ២០២៤ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤)

លើសពីនេះ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ត្រូវបានអនុញ្ញាតឱ្យដាក់ដំណើរ-ការសេវាពិនិត្យសុខភាពហិរញ្ញវត្ថុលើកម្មវិធីទូរសព្ទរបស់ ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អេអឹមខេ ព្រមទាំងត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើអនុស្សរណៈ-យោគយល់ ជាមួយនឹងក្រុមហ៊ុន កូរ៉េ ក្រេឌីត ប្យូរ៉ូ ក្នុងការផ្តល់សេវាចែករំលែករបាយការណ៍ព័ត៌មានឥណទានទ្វេភាគីរវាង កម្ពុជានិងកូរ៉េ។ កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធនាគារជាតិនៃកម្ពុជា ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី និងក្រុមហ៊ុន ហ្វាន់ហ្គាយ ឯ.ក បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកិច្ចសហប្រតិបត្តិការប្រើប្រាស់ប្រព័ន្ធកម្មវិធីអន្តរកម្មផ្លាស់ប្តូរទិន្នន័យដើម្បីផ្ទៀងផ្ទាត់អចលនទ្រព្យតាមរយៈគេហទំព័រ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី (CBC) ដោយសហការផ្ទាល់ជាមួយក្រុមហ៊ុនហ្វាន់ហ្គាយ ឯ.ក ក្នុងការប្រើប្រាស់ និងសិទ្ធិប្រត្យក្សទិន្នន័យលើការតភ្ជាប់ប្រព័ន្ធកម្មវិធីអន្តរកម្មនេះ។ ការផ្តល់សេវាផ្ទៀងផ្ទាត់អចលនទ្រព្យ នឹងអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាញយករបាយការណ៍អចលនទ្រព្យ សម្រាប់ជាមូលដ្ឋានមួយក្នុងការវិភាគនិង វាយតម្លៃមុនពេលសម្រេចផ្តល់ឥណទានដល់រូបវន្តបុគ្គល និងនីតិបុគ្គល។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានបំណងស្វែងរកព័ត៌មានអចលនទ្រព្យ អាចទទួលបានរបាយការណ៍បញ្ជាក់ភ្លាមៗ ពីស្ថានភាពអចលនទ្រព្យ អំពីម្ចាស់កម្មសិទ្ធិ ប្រវត្តិជួលអចលនទ្រព្យ និងប្រវត្តិជាប់បន្ទុក តាមប្រព័ន្ធអនឡាញ ដោយមិនចាំបាច់ទៅឆែក ឬផ្ទៀងផ្ទាត់ព័ត៌មានអចលនទ្រព្យនៅមន្ទីរ ឬក្រសួង ដោយផ្ទាល់ឡើយ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ដាក់បញ្ចូលលក្ខខណ្ឌនៃការរក្សាទុក និងបង្ហាញពីប្រវត្តិនៃឥណទានរៀបចំឡើងវិញ រយៈពេល ១ ឆ្នាំ នៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន គិតចាប់ពីថ្ងៃឥណប្រតិទាន ចំពោះតែក្នុងកាលៈទេសៈអនុគ្រោះពិសេសប៉ុណ្ណោះ។





ពិធីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកិច្ចសហប្រតិបត្តិការប្រើប្រាស់ប្រព័ន្ធកម្មវិធីអន្តរកម្មផ្លាស់ប្តូរទិន្នន័យរបស់
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី
នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ

ធនាគារជាតិនៃកម្ពុជានៅតែបន្តតាមដាននិងត្រួតពិនិត្យលើវឌ្ឍនភាពនៃការអនុលោមតាមបទប្បញ្ញត្តិជាធរមានរបស់អ្នកផ្តល់ទិន្នន័យនិងអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន ជាប្រចាំសំដៅធានាគុណភាពទិន្នន័យ និងនិរន្តរភាពនៃដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជា។ ជាមួយគ្នានេះ ដើម្បីលើកកម្ពស់ការប្រើប្រាស់របាយការណ៍ឥណទានឆ្លងប្រទេស ធនាគារជាតិនៃកម្ពុជាតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំគោលការណ៍ និងនីតិវិធីសម្រាប់ការប្រើប្រាស់របាយការណ៍ឥណទានឆ្លងប្រទេស។

## សមតុល្យឥណទាន និងចំនួនអតិថិជន ដែលបែងចែកតាមតំបន់ ក្នុងប្រទេសកម្ពុជា

ការបែងចែកឥណទានតាមតំបន់បង្ហាញថា តំបន់វាលទំនាបទទួលបានឥណទានច្រើនជាងគេ
បន្ទាប់មកគឺ តំបន់ទន្លេសាប និងតំបន់ឆ្នេរសមុទ្រ




ប្រភពរូបភាព៖ ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី

## ៨-ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានបន្តពង្រឹងជាប្រចាំទាំងការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ដោយផ្អែកលើហានិភ័យ និងទស្សនៈអនាគត តាមរយៈវិធីសាស្ត្រស្រេប (SREP) សម្រាប់ការវិភាគស្ថានភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ ទាំងផ្នែកបរិមាណនិងគុណភាព សំដៅកំណត់ឱ្យបានជាមុននូវហានិភ័យនានា និងចាត់វិធានការកែតម្រូវទាន់ពេលវេលា។ ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យលើឯកសារនិងការវិនិច្ឆ័យហ្មត់ចត់ អនុសាសន៍មួយចំនួនត្រូវបានដាក់ចេញ ដោយមានការកំណត់ជាក់លាក់អំពីតម្រូវការដើមទុន សន្ទនីយភាព និងការកំណត់អត្តសញ្ញាណគ្រឹះស្ថានសម្រាប់រៀបចំផែនការចុះត្រួតពិនិត្យដល់ទីកន្លែង។ បន្ថែមពីនេះ ការត្រួតពិនិត្យក៏រួមបញ្ចូលការធ្វើស្ត្រេសតេស្ត និងស្ត្រេសតេស្តត្រឡប់លើអនុបាតភាពគ្រប់គ្រាន់នៃដើមទុន និងការធ្វើស្ត្រេសតេស្តលើអនុបាតក្របខណ្ឌសន្ទនីយភាព ជាដើម ដើម្បីវាយតម្លៃលើស្ថានភាពដើមទុន សន្ទនីយភាព និងភាពធន់របស់គ្រឹះស្ថាននីមួយៗ។

ក្នុងឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែង ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ២៦ ក្នុងនោះ គ្រឹះស្ថានធនាគារពាណិជ្ជចំនួន ៩ គ្រឹះស្ថានធនាគារឯកទេសចំនួន ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន ១០ និងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុចំនួន ៥ ដោយផ្តោតលើ អភិបាលកិច្ច គុណភាពទ្រព្យសកម្ម ការធ្វើចំណាត់ថ្នាក់ឥណទាននិងការធ្វើសំវិធានធនលើអ៊ីមភែរមិន ការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងសន្ទនីយភាព ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ ជាងនេះទៅទៀត ធនាគារជាតិនៃកម្ពុជាក៏បានចុះត្រួតពិនិត្យដល់ទីកន្លែងដោយគ្មានការជូនដំណឹងជាមុនចំពោះគ្រឹះស្ថានធនាគារចំនួន ៨ ដើម្បីពិនិត្យលើប្រសិទ្ធភាពនៃការអនុវត្តសារាចរណែនាំស្តីពីការរៀបចំឥណទានឡើងវិញ។

ជាលទ្ធផល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្តរក្សាបានភាពធន់ទាំងសន្ទនីយភាពនិងដើមទុន មានអភិបាលកិច្ចល្អ មានការពង្រឹងលើការគ្រប់គ្រងហានិភ័យឥណទានដោយបានយកចិត្តទុកដាក់ក្នុងការបញ្ចេញឥណទានប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ។ ទោះយ៉ាងណា គ្រឹះស្ថានមួយចំនួននៅមានចំណុចខ្វះខាតពាក់ព័ន្ធនឹងអភិបាលកិច្ច ការត្រួតពិនិត្យផ្ទៃក្នុងនិងការគ្រប់គ្រងហានិភ័យ ការផ្តល់ឥណទានជារូបិយវត្ថុជាតិ និងការអនុវត្តមិនបានពេញលេញតាមអនុសាសន៍។ ការខ្វះខាតទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំតាមរយៈការតាមដាននិងវាយតម្លៃលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ប្រចាំត្រីមាស ហើយធនាគារជាតិនៃកម្ពុជាក៏បានអនុវត្តវិធានការរដ្ឋបាលមួយចំនួនចំពោះគ្រឹះស្ថានដែលមិនគោរពតាម។





លោកជំទាវបណ្ឌិត ជា សិរី បានចុះត្រួតពិនិត្យដំណើរការអនុវត្តន៍សារាចរណែនាំស្តីពីការរៀបចំឥណទានឡើងវិញ នៅតាមបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤

## ៩- ការអនុវត្តបទប្បញ្ញត្តិ

ប្រកាស និងសេចក្តីណែនាំមួយចំនួន ត្រូវបានដាក់ចេញដើម្បីពង្រឹងភាពធន់ និងធានាវឌ្ឍនភាពនៅក្នុងប្រព័ន្ធធនាគារ ដូចជា៖ i/- ប្រកាសស្តីពី អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ii/- ប្រកាសស្តីពី ប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ iii/- ប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iv/- ប្រកាសស្តីពី អនុបាតសន្ទនីយភាពសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ v/- ប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ vi/-ប្រកាសស្តីពី ហានិភ័យប្រតិបត្តិការសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ vii/- សេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ viii/- សារាចរណែនាំស្តីពី ការប្រគល់ឯកសារសម្គាល់ទ្រព្យធានាជូនអតិថិជនឥណទាន ix/- សារាចរណែនាំស្តីពី ការលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រួលក្នុងការបើកគណនីសន្សំ និងផ្តល់សេវាហិរញ្ញវត្ថុជូនសហគ្រាសធុនមីក្រូតូច និងមធ្យម និងបុគ្គលស្វ័យនិយោជន៍ x/- សេចក្តីជូនដំណឹងស្តីពី ការទប់ស្កាត់ការប្រើប្រាស់ក្រដាសប្រាក់រៀលក្លែងក្លាយ និង xi/- សេចក្តីជូនដំណឹងស្តីពី ការទប់ស្កាត់ការប្រើប្រាស់ក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ។ ដើម្បីលើកកម្ពស់ការយល់ដឹងពីបទប្បញ្ញត្តិដែលបានដាក់ចេញ និងជំរុញការអនុវត្តឱ្យមានសង្គតិភាពនិងប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបានរៀបចំការបណ្តុះបណ្តាលផ្ទៃក្នុង និងជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាបន្តបន្ទាប់។

ដើម្បីផ្តល់លទ្ធភាពបន្ថែមឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការបញ្ចេញឥណទានសំដៅចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាសម្រេច៖ i/- បន្តអនុវត្តអនុបាតទ្រនាប់ដើមទុនខនសើរវេសិន ត្រឹមកម្រិត ១,២៥% រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥ ii/- បន្តអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រឹមកម្រិត ៧% រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥ និង iii/- អនុញ្ញាតឱ្យរៀបចំឥណទានឡើងវិញជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន តាមរយៈការដាក់ចេញនូវសារាចរណែនាំស្តីពី ការរៀបចំឥណទានឡើងវិញ។ ដោយឡែក ការអនុវត្តប្រកាសនិងសេចក្តីណែនាំពាក់ព័ន្ធនឹងក្របខណ្ឌភាពគ្រប់គ្រាន់នៃដើមទុនត្រូវបានពន្យារ រហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ ដើម្បីទុកពេលវេលាបន្ថែមជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា។

ទន្ទឹមនេះ ប្រកាសនិងសេចក្តីណែនាំមួយចំនួនក៏កំពុងត្រូវបានរៀបចំ រួមមាន៖ i/- ប្រកាសពាក់ព័ន្ធនឹងក្របខណ្ឌភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ii/- ប្រកាសស្តីពី វិធានការឆ្លើយតបផ្នែកត្រួតពិនិត្យបុរេសកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ iii/- ប្រកាសស្តីពី ការកំណត់ពិតានអត្រាការប្រាក់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iv/- ប្រកាសស្តីពី ការគួបសរុបផ្នែកបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ v/- ប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ vi/- ប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង vii/- សេចក្តីណែនាំស្តីពី ការវាយតម្លៃទ្រព្យធានាក្នុងគោលបំណងវាយតម្លៃលើអ៊ីមភែរមិន។

## ១០- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ

បរិយាបន្នហិរញ្ញវត្ថុនៅតែជាការងារអាទិភាព ដើម្បីលើកកម្ពស់ការទទួលបាននិងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ទាន់ពេលវេលា មានតម្លៃសមរម្យ និងមានកិច្ចការពារតាមផ្លូវច្បាប់សម្រាប់ប្រជាជនគ្រប់រូប ស្របពេលដែលចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជនត្រូវបានលើកកម្ពស់ជាលំដាប់។ កិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិពាក់ព័ន្ធនានាក៏ត្រូវបានពង្រឹងតាមរយៈការដាក់ចេញនិងអនុវត្តនូវសកម្មភាពយុទ្ធនាការផ្សព្វផ្សាយ កម្មវិធីអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងយន្តការនានា ស្របតាមផែនការសកម្មភាព ក្នុងយុទ្ធសាស្ត្រជាតិ ស្ដីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនចំនួនគណនីប្រាក់បញ្ញើ ២២,៩% ដល់ ២៣,៣ លានគណនី និងគណនីឥណទាន ២,៧% ដល់ ៤ លានគណនី។ ទីស្នាក់-ការកណ្ដាល និងសាខារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំនួន ២.៧០២ ទីតាំង និងមានម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ចំនួន ៥.៨៥៤ ម៉ាស៊ីន ព្រមទាំងម៉ាស៊ីន POS ចំនួន ៩១.៧៩៧ ម៉ាស៊ីន។ លើសពីនេះ ចំនួនគណនីអ៊ីវ៉ាឡេតកើនដល់ប្រមាណ ២០,៧ លានគណនី ហើយចំនួនពាណិជ្ជករដែលចុះឈ្មោះប្រើប្រាស់ខេអេចឃ្យូអរកូតមានប្រមាណ ៤,៥ លានគណនី។

**ក្រាហ្វ ៦៥៖ ចំនួនគណនីប្រាក់បញ្ញើ និងគណនីឥណទាន របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**
(គិតជាលាន, ឆ្នាំ២០២០ - ឆ្នាំ២០២៤ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន, ទិន្នន័យជាក់ស្ដែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤

## ១១- កិច្ចការពារអតិថិជន

### ក. ការពង្រឹងយន្តការសម្របសម្រួលដោះស្រាយបណ្ដឹងអតិថិជន

យន្តការគ្រប់គ្រងនិងដោះស្រាយបណ្ដឹងអតិថិជនត្រូវបានបន្តពង្រឹង តាមរយៈការសម្រប-សម្រួលដោះស្រាយបណ្ដឹងរបស់អតិថិជន ដែលប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈលេខទូរសព្ទហតឡាញ របស់ធនាគារជាតិនៃកម្ពុជា (ទីស្នាក់ការកណ្ដាលចំនួន ៥ ខ្សែ និងសាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្តចំនួន ២១ ខ្សែ) ឱ្យកាន់តែមានប្រសិទ្ធភាព ទាន់ពេលវេលា និងមានសង្គតិភាព ដើម្បីធានាកិច្ចការពារអតិថិជន។ សម្រាប់ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា ទទួលបានបណ្ដឹងចំនួន ៤២៣ ករណី ដែលបណ្ដឹងនៅទីស្នាក់ការកណ្ដាលមានចំនួន ២៥៦ ករណី និងនៅតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តមានចំនួន ១៦៧ ករណី។ បណ្ដឹងទាំងនេះពាក់ព័ន្ធនឹង៖ i/- ការសាកសួរអំពីការដាក់ទ្រព្យធានា ការធានាឥណទាន ការស្នើសុំបង់ផ្ដាច់ឥណទានមុនកាលកំណត់ និងការដកទ្រព្យធានាឥណទាន ii/- ការស្នើសុំរៀបចំឥណទានឡើងវិញ iii/- ការស្នើសុំកែប្រែព័ត៌មានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន iv/- ការស្នើសុំបន្ធូរបន្ថយប្រាក់ពិន័យ v/- ការផ្ទេរប្រាក់មិនបានសម្រេចតាមប្រព័ន្ធឌីជីថល និង vi/- ការប្រើប្រាស់កម្ចីក្រៅផ្លូវការ និងការឆបោកតាមប្រព័ន្ធឌីជីថល។

**ខ. ការបង្កើតស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដានៃកិច្ចសន្យាឥណទាន**

ធនាគារជាតិនៃកម្ពុជា បានផ្តួចផ្តើមនិងសហការជាមួយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ក្នុងការបង្កើតទម្រង់ស្តង់ដាកិច្ចសន្យាឥណទាន និងការកំណត់ខចែងស្តង់ដានៃកិច្ចសន្យាឥណទាន ដើម្បីធានាពីសិទ្ធិនិងអត្ថប្រយោជន៍របស់អតិថិជន និងផ្តល់ការប្រកួតប្រជែងដោយយុត្តិធម៌និងស្មើភាពគ្នា ព្រមទាំងជួយឱ្យអតិថិជនអាចងាយស្រួលយល់ច្បាស់ពីលក្ខខណ្ឌចម្បងៗ។ ស្តង់ដានៃកិច្ចសន្យាឥណទាន និងខចែងស្តង់ដានៃកិច្ចសន្យាឥណទាន នឹងមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រាប់បញ្ចូលទាំងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ដោយបែងចែកជា ៣ ប្រភេទ អាស្រ័យទៅតាមទំហំនៃឥណទាន ឬ ភតិសន្យាហិរញ្ញវត្ថុ ដូចជា៖ i/- ទំហំតូចជាង ឬស្មើ ៥០.០០០ ដុល្លារអាមេរិក គ្រប់គ្រឹះស្ថានត្រូវប្រើប្រាស់ទម្រង់ស្តង់ដានៃកិច្ចសន្យាឥណទានដូចគ្នា ii/- ទំហំចាប់ពី ៥០.០០០ ដុល្លារអាមេរិក រហូតដល់ ១០០.០០០ ដុល្លារអាមេរិក គ្រប់គ្រឹះស្ថានអាចប្រើប្រាស់ទម្រង់កិច្ចសន្យារបស់គ្រឹះស្ថានសាមី ប៉ុន្តែទម្រង់កិច្ចសន្យានោះត្រូវមានបញ្ចូលនូវលក្ខខណ្ឌ និងខចែងស្តង់ដាដែលតម្រូវ និង iii/- ទំហំធំជាង ១០០.០០០ ដុល្លារអាមេរិក គ្រប់គ្រឹះស្ថានអាចប្រើប្រាស់ទម្រង់កិច្ចសន្យារបស់គ្រឹះស្ថានសាមី ដោយពុំតម្រូវឱ្យមានបញ្ចូលនូវលក្ខខណ្ឌ និងខចែងស្តង់ដានោះទេ។

## ១២- កិច្ចការពារប្រាក់បញ្ញើ

ប្រព័ន្ធការពារប្រាក់បញ្ញើគឺជាផ្នែកមួយយ៉ាងសំខាន់ ដើម្បីរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងកសាងជំនឿទុកចិត្តលើប្រព័ន្ធធនាគារ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានសិក្សាលើការរៀបចំប្រព័ន្ធកិច្ចការការពារប្រាក់បញ្ញើអស់រយៈពេលប្រមាណ ១០ ឆ្នាំមកហើយ ដោយផ្អែកលើក្របខណ្ឌច្បាប់ដែលមានស្រាប់ និងបរិបទនៃសេដ្ឋកិច្ចកម្ពុជា។ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងកិច្ចការពារប្រាក់បញ្ញើ ធនាគារជាតិនៃកម្ពុជាបានរៀបចំរចនាសម្ព័ន្ធថ្មី ដោយបង្កើតនាយកដ្ឋានកិច្ចការពារប្រាក់បញ្ញើ ដើម្បីអនុវត្តយន្តការកិច្ចការពារប្រាក់បញ្ញើ និងបុននីតិសម្បទា សំដៅរួមចំណែកការពារសិទ្ធិនិងផលប្រយោជន៍អ្នកដាក់ប្រាក់បញ្ញើ បង្កើនទំនុកចិត្តសាធារណជន និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។ ជាមួយគោលបំណងនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំក្របខណ្ឌបទប្បញ្ញត្តិស្របតាមការវិវត្តនៃគោលការណ៍កិច្ចការពារប្រាក់បញ្ញើ និងឧត្តមានុវត្តន៍អន្តរជាតិ រួមទាំងនីតិវិធីសម្រាប់ប្រតិបត្តិយន្តការកិច្ចការពារប្រាក់បញ្ញើនេះផងដែរ។ ស្របតាមទិសដៅនេះ កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិត្រូវបានពង្រឹងដើម្បីប្រមូលធាតុចូលនានា ព្រមទាំងបទពិសោធនៅតាមបណ្តាប្រទេសមួយចំនួនក្នុងការរៀបចំប្រព័ន្ធការពារប្រាក់បញ្ញើ។

## ១៣- ហិរញ្ញវត្ថុប្រកបដោយចីរភាព

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងយកចិត្តទុកដាក់និងចាត់ទុកកិច្ចការពាក់ព័ន្ធនឹងការជំរុញហិរញ្ញវត្ថុប្រកដោយចីរភាព ជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពផ្សេងៗទៀត តាមរយៈការចូលរួមចំណែកយ៉ាងសកម្មក្នុងដំណើរការនៃការអភិវឌ្ឍគោលនយោបាយនិងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ការរៀបចំគំនិតផ្តួចផ្តើមនិងកិច្ចពិភាក្សានានា ទាំងក្របខណ្ឌជាតិ តំបន់ និងសកល និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ ក្រសួងនិងស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងវិនិយោគិនបៃតង។

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្តសកម្មភាពការងារអាទិភាពដែលពាក់ព័ន្ធមួយចំនួន ដូចជា៖ i/-ការរៀបចំផែនទីមគ្គុទេសក៍ហិរញ្ញវត្ថុបៃតងនៅកម្ពុជា (Cambodian Green Finance Roadmaps) ii/-ការអភិវឌ្ឍប្រព័ន្ធវគ្គីករសាស្ត្រ និងទីផ្សារហិរញ្ញវត្ថុបៃតងនៅកម្ពុជា (Cambodian Green Finance Taxonomy) iii/-ការដាក់បញ្ចូលគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ក្នុងគោលការណ៍ណែនាំស្តីពី ការវិនិយោគទុនបម្រុងអន្តរជាតិ និងវិនិយោគលើសញ្ញាបណ្ណបៃតង iv/-ការចូលរួមវិនិយោគលើសញ្ញាបណ្ណបៃតង ដែលជាផ្នែកមួយនៃការវិនិយោគទុនបម្រុងអន្តរជាតិ របស់ធនាគារជាតិនៃកម្ពុជា v/-ការលើកទឹកចិត្តគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្តល់ហិរញ្ញប្បទានដល់គម្រោងបៃតង តាមរយៈការអនុញ្ញាតឱ្យថ្លឹងកម្រិតហានិភ័យត្រឹម ៨០% vi/-ការរៀបចំក្របខណ្ឌវិភាគនិងវាយតម្លៃហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ (Climate Risk Assessment and Analysis) vii/-ការសិក្សាពីលទ្ធភាពនៃការដាក់ចេញសេចក្តីណែនាំស្តីពី ការដាក់បញ្ជ្រាបហានិភ័យសង្គមនិងបរិស្ថានក្នុងដំណើរការនៃការគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ viii/-ការកសាងសមត្ថភាព និងលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធនឹងហិរញ្ញវត្ថុបៃតង ix/-កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធនានា និង x/-ការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងប្រធានបទនៃហិរញ្ញវត្ថុប្រកបដោយចីរភាពនិងការប្រែប្រួលអាកាសធាតុ ជាដើម។ គួររំលេចផងដែរថា ក្នុងឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា ក៏បានចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុនៅតំបន់អាស៊ាន ដើម្បីរួមគ្នាធ្វើឱ្យតំបន់នេះក្លាយជាគោលដៅវិនិយោគដ៏ទាក់ទាញសម្រាប់វិនិយោគិនបៃតង។ ធនាគារជាតិនៃកម្ពុជា បានស្នើនូវគំនិតផ្តួចផ្តើមថ្មីមួយ សម្រាប់កិច្ចសហប្រតិបត្តិការរវាងធនាគារកណ្តាល និងក្រសួងហិរញ្ញវត្ថុនៃបណ្តាប្រទេសក្នុងតំបន់ ក្នុងការរៀបចំនិងអនុវត្តនូវប្រតិបត្តិការដោះដូរការវិនិយោគមូលបត្របំណុលប្រកបដោយចីរភាព (Sustainability bond investment swap) ដើម្បីវិនិយោគទុនបម្រុងអន្តរជាតិទៅលើគម្រោងវិនិយោគបៃតងប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលគំនិតផ្តួចផ្តើមនេះ ត្រូវបាន លោកជំទាវ ទេសាភិបាល លើកឡើង នៅក្នុងអត្ថបទមតិដែលមានចំណងជើងថា "ការពង្រីកការវិនិយោគទុនបម្រុងអន្តរជាតិរបស់ធនាគារកណ្តាលក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព" ដែលបានចេញផ្សាយនៅក្នុងទស្សនាវដ្តី The Banker កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤។

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តអនុវត្តគំនិតផ្តួចផ្តើមសំខាន់ៗបន្ថែមទៀត រួមមាន៖ i/-បញ្ចប់ផែនទីមគ្គុទ្ទេសក៍ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់កម្ពុជា (Cambodian Sustainable Finance Roadmaps) និងស្នើសុំការអនុម័តពីក្រុមការងារហិរញ្ញវត្ថុបៃតង ព្រមទាំងផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តនូវផែនទីមគ្គុទ្ទេសក៍នេះ ក្នុងឆ្នាំ២០២៥ ii/-បញ្ចប់ការងារពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធវគ្គីករសាស្ត្រ និងទីផ្សារហិរញ្ញវត្ថុបៃតងនៅកម្ពុជា (Cambodia Green Taxonomy and Market) សម្រាប់ដំណាក់កាលទី១ ដែលបានកំណត់រួចជាស្រេចនូវវិស័យអាទិភាពចម្បងចំនួន ៣ សម្រាប់ការដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២៥ និងបន្តអភិវឌ្ឍសម្រាប់ដំណាក់កាលទី២ ដែលនឹងកំណត់វិស័យអាទិភាពចម្បងៗបន្ថែមទៀត iii/-រៀបចំយន្តការស្តីពី ហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីតម្លាភាព និងការទទួលខុសត្រូវ (Reporting and Disclosure Framework) iv/-ពង្រឹងក្របខណ្ឌវាយតម្លៃ និងការពារហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ v/-ការកសាងសមត្ថភាព និងចំណេះដឹង ដល់វិស័យធនាគារនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធ និង vi/-ការសិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនានា គោលដៅរៀបចំនិងដាក់ចេញគោលនយោបាយគាំទ្រហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា ដើម្បីជំរុញការកៀរគរប្រភពទុន សំដៅគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងមានកម្រិតកាបូនទាប។

ជារួម ប្រព័ន្ធធនាគារបន្តរក្សាបានភាពធន់ទាំងដើមទុននិងសន្ទនីយភាពក្នុងការទប់ទល់នឹងហានិភ័យដែលអាចកើតមាន និងអនុវត្តប្រតិបត្តិការសេវាធនាគារប្រកបដោយភាពប្រុងប្រយ័ត្នក្នុងបរិការណ៍ឥណទានមានកំណើនទាប និងឥណទានមិនដំណើរការបន្តកើនឡើង។ ដើម្បីរក្សាបានភាពធន់នេះ ការវិភាគហានិភ័យវិស័យហិរញ្ញវត្ថុទាំងមូលត្រូវបានពង្រឹងជាបន្តបន្ទាប់ ជាពិសេសការវិភាគភាពប្រទាក់ក្រឡារវាងសេដ្ឋកិច្ចវិស័យរូបវន្តនិងវិស័យហិរញ្ញវត្ថុ និងការធ្វើស្ត្រេសតេស្ត។ ទន្ទឹមនេះ ការត្រួតពិនិត្យលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗត្រូវបានអនុវត្តជាប្រចាំតាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត គួបផ្សំនឹងការប្រើប្រាស់វិធីសាស្ត្រស្រេបដើម្បីវាយតម្លៃហានិភ័យចំពោះគ្រឹះស្ថាននីមួយៗ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្តរក្សាបានភាពធន់ មានអភិបាលកិច្ចល្អ មានការពង្រឹងលើការគ្រប់គ្រងហានិភ័យឥណទានដោយបានយកចិត្តទុកដាក់ក្នុងការបញ្ចេញឥណទានប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ  ខណៈគ្រឹះស្ថានមួយចំនួនតូចនៅមានចំណុចខ្វះខាតពាក់ព័ន្ធនឹងអភិបាលកិច្ចការត្រួតពិនិត្យផ្ទៃក្នុងនិងការគ្រប់គ្រងហានិភ័យ ការផ្តល់ឥណទានជារូបិយវត្ថុជាតិ និងការមិនអនុវត្តបានពេញលេញតាមអនុសាសន៍។ ទោះយ៉ាងនេះក្តី ការខ្វះខាតទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំតាមរយៈការតាមដាននិងវាយតម្លៃលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ប្រចាំត្រីមាស ហើយធនាគារជាតិនៃកម្ពុជាក៏បានអនុវត្តវិធានការរដ្ឋបាលមួយចំនួនចំពោះគ្រឹះស្ថានដែលមិនគោរពតាម។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបន្តលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ រួមចំណែកជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាពក្នុងការកាត់បន្ថយហានិភ័យពីការប្រែប្រួលអាកាសធាតុ ព្រមទាំងកំពុងអភិវឌ្ឍប្រព័ន្ធការពារប្រាក់បញ្ញើ ក្នុងគោលដៅរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងពង្រឹងជំនឿទុកចិត្តលើប្រព័ន្ធធនាគារឱ្យកាន់តែរឹងមាំថែមទៀត។

## V- ការផ្ដត់ផ្ដង់សេវាធនាគារកណ្ដាល

### ១- ប្រព័ន្ធទូទាត់សងប្រាក់

#### ក- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់

ការអភិវឌ្ឍនិងធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់គឺជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពផ្សេងទៀតរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីឆ្លើយតបនឹងរបត់ថ្មីនៃការទូទាត់ឌីជីថល និងផ្ដល់នូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាពសម្រាប់សម្រួលដល់សកម្មភាពសេដ្ឋកិច្ចទាំងក្នុងប្រទេសនិងតំបន់ស្របតាមនវានុវត្តន៍បច្ចេកវិទ្យា សេដ្ឋកិច្ច និងសង្គមឌីជីថល។ ដោយពិនិត្យឃើញពីសារៈសំខាន់នេះ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានដាក់ឱ្យដំណើរការជាបន្តបន្ទាប់ ដូចជាប្រព័ន្ធផាត់ទាត់ជាតិ (NCS) ប្រព័ន្ធសេវាទូទាត់រហ័ស (FAST) ប្រព័ន្ធខេមបូខានស៊ែស្វីច (CSS) ប្រព័ន្ធបាគង និងប្រព័ន្ធរីថែលផេ (Retail Pay)។ នវានុវត្តន៍នៃឧបករណ៍ទូទាត់សងប្រាក់ បណ្ដាញទូទាត់ និងសេវាដែលមានសក្ដានុពល បានធ្វើឱ្យសាធារណជន និងសហគ្រាសអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុឌីជីថលបានកាន់តែប្រសើរជាងមុន។ ជាមួយគ្នានេះ ដើម្បីសម្រួលដល់សាធារណជនឱ្យមានភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ប្រាក់អន្តរគ្រឹះស្ថានទាំងតម្លៃរាយនិងតម្លៃធំ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធទូទាត់សងប្រាក់រួម សម្រាប់តភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដែលបានដាក់ឱ្យដំណើរការកន្លងមកជាច្រកទូទាត់តែមួយ នាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤។ បច្ចុប្បន្ននេះមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៤៩ ក្នុងចំណោមគ្រឹះស្ថានចូលរួមចំនួន ៧៣ បានដំណើរការសាកល្បងប្រព័ន្ធនេះ។ ទន្ទឹមគ្នានេះ វិធាននិងនីតិវិធី ព្រមទាំងឯកសារគតិយុត្តផ្សេងៗក៏ត្រូវបាននិងកំពុងរៀបចំក្នុងគោលបំណងគាំទ្រដំណើរការប្រព័ន្ធ និងទុកជាឯកសារចំណងផ្លូវច្បាប់សម្រាប់គ្រប់គ្រឹះស្ថានជាសមាជិក។

ប្រព័ន្ធបាគង | ប្រព័ន្ធខេមបូខានស៊ែស្វីច | ប្រព័ន្ធសេវាទូទាត់រហ័ស | ប្រព័ន្ធផាត់ទាត់ជាតិ | ប្រព័ន្ធធនាគារអេឡិចត្រូនិក | ប្រព័ន្ធរីថែលផេ

#### ខ- សេវាទូទាត់សងប្រាក់

សេវាទូទាត់សងប្រាក់តាមបែបឌីជីថលបន្តចូលរួមយ៉ាងសកម្មក្នុងប្រតិបត្តិការទូទាត់ទំនិញ និងសេវាបានយ៉ាងងាយស្រួល រហ័ស និងមានប្រសិទ្ធភាព។ ដើម្បីធានាបាននូវភាពរឹងមាំរបស់ប្រព័ន្ធទូទាត់សងប្រាក់ សំដៅបម្រើផលប្រយោជន៍របស់អ្នកប្រើប្រាស់កាន់តែប្រសើរ ធនាគារជាតិនៃកម្ពុជាបន្តយកចិត្តទុកដាក់លើការគ្រប់គ្រង និងត្រួតពិនិត្យគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់លើការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានា រួមទាំងការពិនិត្យនិងតាមដានសុខុមាលភាពរបស់គ្រឹះស្ថាន ព្រមទាំងវាយតម្លៃលើសេវាថ្មីៗរបស់គ្រឹះស្ថានមុនដាក់ឱ្យដំណើរការ។

## គ- ការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន

ដើម្បីសម្រួលដល់ពាណិជ្ជកម្ម និងធុរកិច្ចអន្តរជាតិឱ្យកាន់តែរីកចម្រើនបន្ថែមទៀត មធ្យោបាយទូទាត់និងផ្ទេរប្រាក់ឆ្លងដែនក្នុងកម្រៃសមរម្យ បានដើរតួនាទីយ៉ាងសំខាន់ដើម្បីជួយសម្រួលដល់ការដោះដូរ និងសម្រាលបន្ទុករបស់ប្រតិបត្តិករសេដ្ឋកិច្ច ពិសេសពលករទេសន្តរប្រវេសន៍ និងធុរជន។ ក្នុងទិសដៅនេះ កិច្ចសហការលើការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ ប្រតិបត្តិការទូទាត់សងប្រាក់និងផ្ទេរប្រាក់ឆ្លងដែនប្រកបដោយបរិយាបន្ន និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិត្រូវបានបន្តពង្រឹង តាមរយៈការដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី កូរ៉េ ក្រុមហ៊ុនបណ្តាញទូទាត់អន្តរជាតិយូញៀនផេ (រាប់បញ្ចូលទាំងប្រទេសចិន) និងក្រុមហ៊ុនអាលីផេ។ ដោយឡែកនៅក្នុងឆ្នាំ២០២៤នេះ គម្រោងទូទាត់ឆ្លងដែនតាមយន្តអរកូតត្រូវបានដាក់ឱ្យដំណើរការជាមួយប្រទេសកូរ៉េ ម៉ាឡេស៊ី និងក្រុមហ៊ុនអាលីផេ ដែលជាសមិទ្ធផលថ្មីបន្ថែមទៀតនៃចក្ខុវិស័យពង្រីកវិសាលភាពប្រតិបត្តិការទូទាត់ឆ្លងដែន តាមយន្តអរកូតរបស់ប្រព័ន្ធបាគង។




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតីក្នុងពិធីដាក់ឱ្យដំណើរការប្រតិបត្តិការទូទាត់ឆ្លងដែនតាមយន្តអរកូត (QR Code) រវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុន Alipay Connect Pte. Ltd. នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា






លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរ ជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ Mastercard នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ

### ឃ- នវានុវត្តន៍ហិរញ្ញវត្ថុ

ក្រោមក្របខណ្ឌគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុថ្នាក់ជាតិ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយៈ i/-ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំដាក់ចេញ និងផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ និង ii/-គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ដើម្បីពិនិត្យ រៀបចំ និងផ្តល់វឌ្ឍនភាពលើវិធានការគោលនយោបាយនៅក្នុងផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៤-២០២៦ នៃគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។

ប្រព័ន្ធបាគងត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ ដើម្បីពង្រីកមុខងារប្រព័ន្ធ និងជំរុញការទូទាត់ជាអេឡិចត្រូនិកឱ្យកាន់តែមានភាពងាយស្រួលដល់អ្នកប្រើប្រាស់។ មុខងារទាំងនោះមានដូចជាៈ i/- ការអភិវឌ្ឍមុខងារចុះឈ្មោះអតិថិជនជាអេឡិចត្រូនិកតាមប្រព័ន្ធបាគង (e-KYC) ii/- ការអភិវឌ្ឍសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រមុខងារបាគង (Linking Account) iii/- ការអភិវឌ្ឍមុខងារខេអេចឃ្យូអរកូតរូបិយប័ណ្ណតែមួយ iv/- នីតិវិធីដោះស្រាយបណ្តឹងអតិថិជនប្រព័ន្ធបាគង v/- បាគងទេសចរ (Bakong Tourists App) និង vi/- មុខងារបាគងសម្រាប់ការទូទាត់ឆ្លងដែន (Cross-border Bakong API)។ ជាក់ស្តែង កម្មវិធីទូទាត់បាគងទេសចរត្រូវបានដាក់ឱ្យដំណើរការបឋម នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ ដើម្បីរួមចំណែកលើកកម្ពស់វិស័យទេសចរណ៍នៅកម្ពុជា តាមរយៈការផ្តល់ជាមធ្យោបាយទូទាត់តាមអេឡិចត្រូនិក ដែលអាចឱ្យទេសចរអន្តរជាតិមកកម្សាន្តនៅកម្ពុជាធ្វើប្រតិបត្តិការទូទាត់ទំនិញនិងសេវាប្រកបដោយប្រសិទ្ធភាព និងភាពងាយស្រួល។ ជាមួយគ្នានោះ មុខងារ "Link Mastercard" ក្នុងកម្មវិធីបាគងទេសចរ ត្រូវបានដាក់ឱ្យដំណើរការកាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤ ដោយភ្ញៀវទេសចរអាចភ្ជាប់ជាមួយប័ណ្ណទូទាត់ម៉ាស្ទ័រកាត ដើម្បីបញ្ចូលទឹកប្រាក់ក្នុងគណនីបាគងទេសចរ ហើយធ្វើការទូទាត់តាមរយៈការស្កេនខេអេចឃ្យូអរ (KHQR) នៅទីតាំងពាណិជ្ជករប្រមាណ ៤,៥ លានកន្លែងនៅទូទាំងប្រទេសកម្ពុជា។ ចំពោះជំហានបន្ទាប់ កម្មវិធីបាគងទេសចរ អាចភ្ជាប់ជាមួយប័ណ្ណទូទាត់អន្តរជាតិផ្សេងទៀត ដើម្បីដាក់ប្រាក់ក្នុងគណនីបន្ថែមទៀត។

### ង- ហេដ្ឋារចនាសម្ព័ន្ធទូទាត់សាធារណៈឌីជីថល

អភិបាលកិច្ចនៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលគ្របដណ្តប់ទាំងផ្នែកគោលនយោបាយនិងផ្នែកបច្ចេកទេស។ អភិបាលកិច្ចកម្រិតគោលនយោបាយរួមមានបទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាពបណ្តាញ ការទូទាត់សងប្រាក់ កម្រិតនៃការផ្តល់សិទ្ធិ វិធានការប្រឆាំងការសម្អាតប្រាក់ អត្តសញ្ញាណឌីជីថល និងការទទួលបានការអប់រំនិងជំនាញឌីជីថល។ អភិបាលកិច្ចនៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលកម្រិតបច្ចេកទេស ផ្តោតលើសសរស្តម្ភចំនួន៤ រួមមាន អត្តសញ្ញាណឌីជីថល (Digital Identity) ការអនុញ្ញាតនិងការផ្តល់សិទ្ធិ (Authorization and Consent) អន្តរប្រតិបត្តិការប្រព័ន្ធទូទាត់ (Payment Interoperability) និងថ្នាលសម្រាប់ចែករំលែកព័ត៌មាននិងទិន្នន័យ (Data Exchange) ដែលជំរុញនិងសម្រួលដល់ការធ្វើប្រតិបត្តិការប្រកបដោយសុវត្ថិភាព សន្សំសំចៃថ្លៃប្រតិបត្តិការលើកកម្ពស់បរិយាបន្ន និងប្រសិទ្ធភាព។ សារៈសំខាន់នៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល គឺសម្រួលការផ្តល់សេវាសាធារណៈ ជំរុញកំណើនសេដ្ឋកិច្ចឌីជីថលតាមរយៈការផ្តល់ជាការផ្តួចផ្តើមនវានុវត្តន៍ និងកិច្ចសហប្រតិបត្តិការថ្មីៗនៅលើគ្រប់វិស័យ។

- **ប្រព័ន្ធបាគង៖** កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធបាគង ដែលជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលដ៏សំខាន់មួយ ដើរតួនាទីក្នុងការសម្រួលដល់ការទូទាត់ជាឌីជីថលសម្រាប់សាធារណជន។ ប្រព័ន្ធបាគងបានរួមចំណែកក្នុងការលើកកម្ពស់ការធ្វើសមាហរណកម្មក្នុងប្រព័ន្ធហិរញ្ញវត្ថុ តាមរយៈការជំរុញឱ្យមានការធ្វើអន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលការណ៍នេះបានពង្រីកនូវលទ្ធភាពក្នុងការធ្វើប្រតិបត្តិការប្រកបដោយភាពងាយស្រួល និងកាន់តែទូលំទូលាយជាងមុនដល់សាធារណជន។ លើសពីនេះ មុខងារទូទាត់ភ្លាមៗរបស់ប្រព័ន្ធបាគងបានជួយបង្កើនប្រសិទ្ធភាពនិងសម្រួលដល់ដំណើរការទូទាត់របស់រាជរដ្ឋាភិបាលដូចជា ការប្រមូលពន្ធ និងសេវាសាធារណៈផ្សេងទៀតបានកាន់តែប្រសើរ។ ក្នុងន័យនេះ ប្រព័ន្ធបាគងមិនត្រឹមតែជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាប្រព័ន្ធទូទាត់ដ៏សំខាន់ដែលជំរុញ និងសម្រួលដល់ការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចពាណិជ្ជកម្ម សំដៅគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជាផងដែរ។

- **ច្រករបៀងតម្លាភាពហិរញ្ញវត្ថុ (Financial Transparency Corridor-FTC)៖** កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជានិងអាជ្ញាធររូបិយវត្ថុសិង្ហបុរី បានប្រកាសដាក់ឱ្យដំណើរការគម្រោងច្រករបៀងតម្លាភាពហិរញ្ញវត្ថុ (Financial Transparency Corridor-FTC) ដែលជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលសម្រាប់បង្កើតកិច្ចព្រមព្រៀងជាមុន (ការអនុញ្ញាតនិងការផ្តល់សិទ្ធិ) រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិក ដើម្បីសម្រួលដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ក្នុងការធ្វើសកម្មភាពពាណិជ្ជកម្មនិងហិរញ្ញវត្ថុឆ្លងដែន។ តាមរយៈច្រករបៀងនេះ MSMEs អាចមានលទ្ធភាពផ្គូផ្គងតម្រូវការរវាងគ្នាទៅវិញទៅមកបានកាន់តែងាយស្រួល និងអាចពង្រីកវិសាលភាពទីផ្សាររបស់ខ្លួនបានកាន់តែទូលំទូលាយ។ លើសពីនេះ គ្រឹះស្ថានធនាគារនិងហរិញ្ញវត្ថុនៃប្រទេសទាំងពីរ អាចផ្លាស់ប្តូរ និងចែករំលែកព័ត៌មានរវាងគ្រឹះស្ថានជាដៃគូបានយ៉ាងឆាប់រហ័សប្រកបដោយភាពងាយស្រួល ដែលការណ៍នេះនឹងរួមចំណែកសម្រួលដល់ការវាយ-តម្លៃហិរញ្ញប្បទានលើអាជីវកម្មឆ្លងដែនរបស់ MSMEs នៃប្រទេសទាំងពីរ។ ចាប់តាំងពីដាក់ឱ្យដំណើរការច្រករបៀងនេះមានគ្រឹះស្ថានសមាជិកចំនួន ៥ មកពីប្រទេសកម្ពុជារួមមាន៖ ធនាគារអេស៊ីលីដា ស្ថាបនា ហ្វីលីព វីង និងវឌ្ឍនៈអាស៊ីចំកាត់ និងគ្រឹះស្ថានចំនួន ៣ មកពីប្រទេសសិង្ហបុរីរួមមាន៖ ANEXT Bank, Liquid Group និង Sing Investment and Finance។ បច្ចុប្បន្ន គ្រឹះស្ថានសមាជិកកំពុងតភ្ជាប់ប្រព័ន្ធជាមួយក្រុមហ៊ុន Proxtera។




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងលោក Sopnendu Mohanty អគ្គនាយកប្រតិបត្តិបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអាជ្ញាធររូបិយវត្ថុសិង្ហបុរី បានអញ្ជើញជាសាក្សី ក្នុងពិធីចុះហត្ថលេខានិងដោះដូរអនុស្សរណៈយោគយល់ស្តីពី "ការចាប់ផ្តើមគម្រោងច្រករបៀងតម្លាភាពហិរញ្ញវត្ថុរវាងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុសិង្ហបុរី" ដែលប្រព្រឹត្តិទៅនៅក្នុងរបៀបវារៈនៃវេទិកាធុរកិច្ចកម្ពុជា-សិង្ហបុរី នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ នៅប្រទេសសិង្ហបុរី

- **គម្រោង Universal Trusted Credentials (UTC)៖** ធនាគារជាតិនៃកម្ពុជា បានសហការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) អភិវឌ្ឍគម្រោង Universal Trusted Credentials (UTC) សាកល្បង ដើម្បីរៀបចំក្របខណ្ឌទិន្នន័យដែលអាចជឿទុកចិត្តបាន ដោយអនុញ្ញាតឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ កាត់បន្ថយហានិភ័យនៃកិច្ចសន្យាធានាលើសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) និងផ្តល់លទ្ធភាពដល់ MSMEs អាចទទួលបានសេវាហិរញ្ញវត្ថុងាយស្រួល ព្រមទាំងកាត់បន្ថយតម្រូវការនៃវត្ថុធានា។ គម្រោង UTC នេះ មិនត្រឹមតែសម្រួលដល់ដំណើរការនៃការបញ្ជាក់ព័ត៌មាន (Authentication Process) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងទំនុកចិត្តរវាងគ្រឹះស្ថាន ដោយធានាថាការអនុញ្ញាតនិងការផ្តល់សិទ្ធិ (Authorization and Consent) ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល គឺគោរពតាមតម្រូវការរបស់ម្ចាស់ទិន្នន័យនិងព័ត៌មាន។ ភាគីទាំងពីរបានបង្កើតក្រុមការងារដំណើរការសាកល្បងគម្រោងដែលមានសមាសភាពស្នូលដូចជា ធនាគារជាតិនៃកម្ពុជា និង UNDP ជាសហប្រធាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (Techo Start Up) ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ខេមបូឌា (CBC) និងសមាជិកស្ថាប័នប្រឹក្សាយោបល់សម្រាប់វិស័យឯកជន (Private Sector Advisory Bodies) ដែលរួមមាន ធនាគារអេស៊ីលីដា ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ធនាគារកាណាឌីយ៉ា ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ធនាគារស្ថាបនា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអេ អឹម ខេ និងក្រុមហ៊ុន Banhji។ ក្រុមការងារនេះបាន និងកំពុងសិក្សាដើម្បីអភិវឌ្ឍថ្នាលសាកល្បងសម្រាប់ប្រើប្រាស់ក្នុងគម្រោង UTC។




កិច្ចប្រជុំចាប់ផ្តើមគម្រោងសាកល្បង Universal Trusted Credentials (UTC) រវាងធនាគារជាតិនៃកម្ពុជា
អង្គការសហប្រជាជាតិ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤
នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ

## ច- ប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់

ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់អភិវឌ្ឍដោយធនាគារជាតិនៃកម្ពុជាចែកជា ២ ប្រភេទ គឺ ប្រព័ន្ធទូទាត់តម្លៃធំ និងប្រព័ន្ធទូទាត់រាយ៖

❖ **ប្រព័ន្ធទូទាត់តម្លៃធំ**

**i/-ប្រព័ន្ធធនាគារអេឡិចត្រូនិក (OBS)៖** ប្រព័ន្ធ OBS មានសមាជិកចំនួន ៨៥ ក្នុងនោះ ធនាគារពាណិជ្ជ ៥៧ ធនាគារឯកទេស ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៣ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ១៨ និងស្ថាប័នរដ្ឋ ១។ ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS សរុបមាន ៨២,៨ ពាន់ប្រតិបត្តិការ ស្មើនឹង ៥០៧,៦ ទ្រីលានរៀល (កើន ៣០,៨% ធៀបនឹងឆ្នាំ២០២៣) ក្នុងនោះការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាល

ជាប្រាក់រៀលមាន ៥២,៤ ពាន់ប្រតិបត្តិការ ស្មើនឹង ១៣៣,១ ទ្រីលានរៀល (កើន ១៣,៨%) និងជាប្រាក់ដុល្លារអាមេរិកមាន ២៩,៦ ពាន់ប្រតិបត្តិការ ស្មើនឹង ៨៥,៨ ប៊ីលានដុល្លារអាមេរិក (កើន ៣៦,៤%)។ ទន្ទឹមនេះ ការផ្ទេរប្រាក់ជាមួយសាខារាជធានី-ខេត្តជាប្រាក់រៀលមាន ៤១០ ប្រតិបត្តិការ ស្មើនឹង ៦,២ ទ្រីលានរៀល (កើន ៣១%) និងជាប្រាក់ដុល្លារអាមេរិកមាន ៣៦៦ ប្រតិបត្តិការ ស្មើនឹង ៤ ប៊ីលានដុល្លារអាមេរិក (កើន ៨៩,៤%)។

**ក្រាហ្វ ៦៦៖ ការផ្ទេរប្រាក់រៀលតាមប្រព័ន្ធ OBS**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៦៧៖ ការផ្ទេរប្រាក់ដុល្លារអាមេរិកតាមប្រព័ន្ធ OBS**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ii/-ប្រព័ន្ធទូទាត់តម្លៃធំបាគង (Bakong LVPS)៖** ប្រព័ន្ធនេះត្រូវបាននិងកំពុងអភិវឌ្ឍដើម្បីសម្រួលការទូទាត់ ចំពោះប្រតិបត្តិការទូទាត់សងប្រាក់តម្លៃធំអន្តរធនាគារ ប្រតិបត្តិការទូទាត់សមតុល្យសុទ្ធរបស់ប្រព័ន្ធទូទាត់រាយ និងប្រតិបត្តិការទូទាត់ក្នុងទីផ្សារហិរញ្ញវត្ថុ។ ប្រព័ន្ធទូទាត់តម្លៃធំបាគងត្រូវបានដាក់ឱ្យដំណើរការសាកល្បងកាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ហើយបច្ចុប្បន្នមានគ្រឹះស្ថានចំនួន ៣៩ បានដំណើរការប្រព័ន្ធនេះ។

❖ **ប្រព័ន្ធទូទាត់រាយ**

**i/-ប្រព័ន្ធផាត់ទាត់ជាតិ (NCS)៖** ប្រព័ន្ធផាត់ទាត់ជាតិមានសមាជិកចំនួន ៦០ (សមាជិកផ្ទាល់ ៤៨ និងសមាជិកមិនផ្ទាល់ ១២) ហើយដំណើរការជាមួយឧបករណ៍ទូទាត់ពីរប្រភេទគឺ៖ មូលប្បទានប័ត្រ និងបញ្ជាផ្ទេរឥណទាន ដោយត្រូវទូទាត់ជាលក្ខណៈមជ្ឈការនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា និងដោះដូរមូលប្បទានប័ត្រជារូបវន្តនៅស្នាក់ការកណ្តាល និងមណ្ឌលដោះដូរមូលប្បទានប័ត្រដែលមានទីតាំងនៅសាខាធនាគារជាតិនៃកម្ពុជាចំនួន ៧ ខេត្ត (សៀមរាប បាត់ដំបង កំពង់ចាម ព្រះសីហនុ បន្ទាយមានជ័យ ស្វាយរៀង និងកំពង់ធំ)។

- **សេវាទូទាត់មូលប្បទានប័ត្រ៖** ការទូទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលមានចំនួន ៣៣ ពាន់សន្លឹក (ថយ -៤,១% ធៀបនឹងឆ្នាំ២០២៣) និងទំហំប្រាក់ទូទាត់មាន ២១,៦ ទ្រីលានរៀល (ថយ -១,៦%) ខណៈដែលការទូទាត់មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិកមានចំនួន ១,០២ លានសន្លឹក (ថយ -២,៧%) និងទំហំប្រាក់ទូទាត់ ៥៧,៦ ប៊ីលានដុល្លារអាមេរិក (កើន ២៩,៦%)។

**ក្រាហ្វ ៦៨៖ ចំនួន និងទំហំប្រាក់មូលប្បទានប័ត្រ ជាប្រាក់រៀល**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៦៩៖ ចំនួន និងទំហំប្រាក់មូលប្បទានប័ត្រ ជាប្រាក់ដុល្លារអាមេរិក**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**- សេវាបញ្ជាផ្ទេរឥណទាន៖** ការទូទាត់បញ្ជាផ្ទេរឥណទានជាប្រាក់រៀលមានចំនួន ៣៨ ពាន់បញ្ជាផ្ទេរ (កើន ៣៥,១% ធៀបនឹងឆ្នាំ២០២៣) និងទំហំប្រាក់ផ្ទេរមាន ៥,២ ទ្រីលានរៀល (កើន ៦,៧%) ខណៈដែលការទូទាត់បញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិកមានចំនួន ៦១១ ពាន់បញ្ជាផ្ទេរ (ថយ -៣,៣%) និងទំហំប្រាក់ផ្ទេរមាន ១៥,៤ ប៊ីលានដុល្លារអាមេរិក (កើន ១៧,៥%)។

**ក្រាហ្វ ៧០៖ ចំនួន និងទំហំប្រាក់បញ្ជាផ្ទេរឥណទាន ជាប្រាក់រៀល**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧១៖ ចំនួន និងទំហំប្រាក់បញ្ជាផ្ទេរឥណទាន ជាប្រាក់ដុល្លារអាមេរិក**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ii/- ប្រព័ន្ធសេវាទូទាត់រហ័ស (FAST)៖**

ប្រព័ន្ធ FAST ជាប្រព័ន្ធសម្រាប់ផ្ទេរប្រាក់រៀល ដែលមានទំហំប្រាក់អតិបរមា ៨០ លានរៀល ក្នុងមួយប្រតិបត្តិការ។ ប្រព័ន្ធនេះមានសមាជិក ៥៧ គ្រឹះស្ថាន (៣៥ កំពុងដំណើរការជាផ្លូវការ និង ២២ កំពុងស្ថិតក្នុងដំណាក់កាលធ្វើសន្ទានកម្ម) ហើយបានទូទាត់សរុបចំនួន ៣ ពាន់ប្រតិបត្តិការ (ថយ -៨៥% ធៀបនឹងឆ្នាំ២០២៣) និងទំហំប្រាក់ទូទាត់មាន ៧ ប៊ីលានរៀល (ថយ -៩១,៦%)។

**ក្រាហ្វ ៧២៖ ចំនួន និងទំហំប្រាក់សេវាទូទាត់រហ័ស ជាប្រាក់រៀល**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**iii/- ប្រព័ន្ធខេមបូខានស៊ែស្វីច (CSS)៖** ប្រព័ន្ធ CSS មានសមាជិកចំនួន ៦១ គ្រឹះស្ថាន ក្នុងនោះ សមាជិកចំនួន ៤៤ (សមាជិកផ្ទាល់ ៤២ និងសមាជិកមិនផ្ទាល់ ២) កំពុងប្រើប្រាស់ប្រព័ន្ធ CSS និង សមាជិក ១៧ កំពុងធ្វើសន្ទានកម្មប្រព័ន្ធ។ ប្រព័ន្ធ CSS បានដំណើរការទូទាត់ប្រតិបត្តិការជាប្រាក់រៀល មានចំនួន ១៦៤ ពាន់ប្រតិបត្តិការ (ថយ -៤១,៧% ធៀបនឹងឆ្នាំ២០២៣) និងទំហំប្រាក់ទូទាត់ ៣៥,៦ ប៊ីលានរៀល (ថយ -៤៣,៣%) ខណៈដែលប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ៣៤ ពាន់ប្រតិបត្តិការ (ថយ -៣៨,៤%) និងទំហំប្រាក់ទូទាត់ ៤,៥ លានដុល្លារអាមេរិក (ថយ -៤២,៦%)។

**ក្រាហ្វ ៧៣៖ ចំនួន និងទំហំប្រាក់ ប្រព័ន្ធខេមបូខានស៊ែស្វីច ជាប្រាក់រៀល**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧៤៖ ចំនួន និងទំហំប្រាក់ ប្រព័ន្ធខេមបូខានស៊ែស្វីច ជាប្រាក់ដុល្លារអាមេរិក**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**iv/- ប្រព័ន្ធរីថែលផេ (Retail Pay)៖** ប្រព័ន្ធរីថែលផេមានសមាជិកចំនួន ២៣ គ្រឹះស្ថាន ដែលក្នុងនោះ សមាជិកដែលកំពុងដំណើរការផ្លូវការមានចំនួន ១៥ និងសមាជិកដែលមិនទាន់ធ្វើសន្ទានកម្មប្រព័ន្ធមានចំនួន ៨។ ប្រព័ន្ធនេះមានប្រតិបត្តិការទូទាត់ជាប្រាក់រៀលចំនួន ៧ ពាន់ប្រតិបត្តិការ (ថយ -៥៨,១% ធៀបនឹងឆ្នាំ២០២៣) និងទំហំប្រាក់ទូទាត់ ២៣៥,៧ ប៊ីលានរៀល (ថយ -៤៦,៣%) ខណៈដែលប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ១៩ ពាន់ប្រតិបត្តិការ (ថយ -៥៨,៦%) និងទំហំប្រាក់ទូទាត់ ១២៩,៦ លានដុល្លារអាមេរិក (ថយ -៣៨,៨%)។

**ក្រាហ្វ ៧៥៖ ចំនួន និងទំហំប្រាក់ប្រព័ន្ធរីថែលផេ ជាប្រាក់រៀល**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧៦៖ ចំនួន និងទំហំប្រាក់ប្រព័ន្ធរីថែលផេ ជាប្រាក់ដុល្លារអាមេរិក**
(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**v/- ប្រព័ន្ធបាគង៖** ប្រព័ន្ធបាគងមានសមាជិកសរុបចំនួន ៦៩ គ្រឹះស្ថាន ដោយក្នុងនោះ មានគ្រឹះស្ថានចំនួន ៦០ បានដាក់ឱ្យដំណើរការជាផ្លូវការ និងគ្រឹះស្ថានចំនួន ៩ ផ្សេងទៀតបាននិងកំពុងបន្តធ្វើសន្ទានកម្មប្រព័ន្ធ។ ក្នុងឆ្នាំ២០២៤នេះ អតិថិជនចុះឈ្មោះប្រើប្រាស់ប្រព័ន្ធបាគងតាមរយៈកម្មវិធីបាគងមានចំនួន ៦៤២,៥ ពាន់គណនី កើនឡើង ៧% ធៀបនឹងឆ្នាំ២០២៣។ ទន្ទឹមនេះ ចំនួនអតិថិជនដែលមានគណនីធនាគារ/កាបូបអេឡិចត្រូនិកនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហើយអាចធ្វើប្រតិបត្តិការតាមប្រព័ន្ធបាគង (Customer Reached) មានចំនួនប្រមាណ ៣០ លានគណនី ដែលប៉ាន់ប្រមាណស្មើនឹង ១,៦៩ ដង នៃចំនួនប្រជាជនសរុប។ លើសពីនេះ ប្រព័ន្ធបាគងក៏មានមុខងារទូទាត់តាមរយៈខេអេចឃ្យូអរកូត ដែលជាស្តង់ដារឃ្យូអរកូតសម្រាប់ការទូទាត់នៅកម្ពុជាផងដែរ។ គិតត្រឹមដំណាច់ឆ្នាំ២០២៤នេះ គ្រឹះស្ថានធនាគារបានចុះឈ្មោះពាណិជ្ជករទទួលការទូទាត់តាមខេអេចឃ្យូអរកូតមានប្រមាណ ៤,៥ លានគណនី (កើនឡើង ៣៦,៤% ធៀបនឹងចុងឆ្នាំ២០២៣)។

**ក្រាហ្វ ៧៧៖ ចំនួនអ្នកប្រើប្រាស់កម្មវិធីបាគង**

(គិតជាពាន់នាក់, ឆ្នាំ២០២០- ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

រីឯប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ដែលធ្វើឡើងតាមរយៈប្រព័ន្ធបាគងមានចំនួន ៦០៨,៣២ លានប្រតិបត្តិការ ក្នុងនោះប្រតិបត្តិការជាប្រាក់រៀលមានចំនួន ២៩៩,៣២ លានប្រតិបត្តិការ (កើនឡើង ៣៣៤% ធៀបនឹងឆ្នាំ២០២៣) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៣០៨,២០ លានប្រតិបត្តិការ (កើនឡើង ១៣៣% ធៀបនឹងឆ្នាំ២០២៣) និងមានទំហំប្រាក់ជាប្រាក់រៀលប្រមាណ ១៨៣,៧៤ ទ្រីលានរៀល (កើនឡើង ១២៧% ធៀបនឹងឆ្នាំ២០២៣) និងទំហំប្រាក់ជាប្រាក់ដុល្លារអាមេរិកប្រមាណ ១០៤,៨១ ប៊ីលានដុល្លារអាមេរិក (កើនឡើង ៩៥% ធៀបនឹងឆ្នាំ២០២៣) ដែលទំហំប្រាក់សរុបនៅក្នុងឆ្នាំ២០២៤ ស្មើនឹង ៣៣០% នៃផ.ស.ស។ ការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រព័ន្ធបាគងមានការកើនឡើងជាលំដាប់ បន្ទាប់ពីប្រព័ន្ធបាគងត្រូវបានដាក់ឱ្យដំណើរការ។

**ក្រាហ្វ ៧៨៖ ចំនួនប្រតិបត្តិការ និងទំហំទឹកប្រាក់តាមប្រព័ន្ធបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២- សេវាគ្រប់គ្រងគណនី

ធនាគារជាតិនៃកម្ពុជា គ្រប់គ្រងគណនីសរុបចំនួន ២.៨៨៦ ដែលក្នុងនោះ នៅស្នាក់ការកណ្ដាល មាន ២.១៧៦ គណនី និងតាមបណ្ដាសាខារាជធានី-ខេត្ត ៧១០ គណនី បានកើនឡើងចំនួន ៦២[២៦] គណនី (គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៤៧ គណនី និងស្ថាប័នរដ្ឋ ១៥ គណនី) ធៀបនឹងឆ្នាំ២០២៣។

**ក្រាហ្វ ៧៩៖ ចំនួនគណនីតាមប្រភេទគ្រឹះស្ថាន**

(ឆ្នាំ២០២០ - ឆ្នាំ២០២៤)[២៧]




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨០៖ ចំនួនគណនីសរុបនៅស្នាក់ការកណ្ដាល និងតាមបណ្ដាសាខារាជធានី-ខេត្ត**

(ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើរបស់ស្ថាប័នរដ្ឋ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអង្គភាពផ្សេងៗនៅធនាគារជាតិនៃកម្ពុជា ទាំងនៅស្នាក់ការកណ្ដាល និងតាមបណ្ដាសាខារាជធានី-ខេត្ត មានការប្រែប្រួលធៀបនឹងឆ្នាំមុន ក្នុងនោះប្រាក់បញ្ញើជារៀលថយចុះចំនួន ០,២ ទ្រីលានរៀល (ថយ -២,២%) ចំណែកឯប្រាក់បញ្ញើជាដុល្លារអាមេរិកកើនឡើងចំនួន ០,២ ប៊ីលានដុល្លារអាមេរិក (កើន ១,៨% )។

**ក្រាហ្វ ៨១៖ ប្រាក់បញ្ញើជារៀល នៅធនាគារជាតិនៃកម្ពុជា**

(គិតជាទ្រីលានរៀល, ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨២៖ ប្រាក់បញ្ញើជាដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា**

(គិតជាប៊ីលានដុល្លារអាមេរិក, ឆ្នាំ២០២០ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[២៦] បានបើកសរុបចំនួន ២០៥ គណនី និងបិទសរុបចំនួន ១៤៣ គណនី។

[២៧] ចំនួនគណនី ឆ្នាំ២០២០-២០២៤ មានរួមបញ្ចូលទាំងស្នាក់ការកណ្ដាល និងតាមបណ្ដាសាខារាជធានី-ខេត្ត។

## ៣- ការគ្រប់គ្រងចរាចរណ៍ធនបត្រ

### ក- ប្រតិបត្តិការសាច់ប្រាក់របស់បេឡា

ការទទួល និងការបើកប្រាក់រៀលមានចំនួន ១៩,៦ ទ្រីលានរៀល (កើន ១៦,៧%) និង ១៩,២ ទ្រីលានរៀល (កើន ៧,៥%) រៀងគ្នា។ ចំណែកឯ ការទទួល និងការបើកប្រាក់ដុល្លារអាមេរិក មានចំនួន ១៧,១ ប៊ីលានដុល្លារអាមេរិក (កើន ១៩,៣%) និង ៧,១ ប៊ីលានដុល្លារអាមេរិក (កើន ១៧%) រៀងគ្នា។

**ក្រាហ្វ ៨៣៖ ការទទួលនិងបើកប្រាក់រៀល**
(គិតជាប៊ីលានរៀល, ឆ្នាំ២០២០-ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨៤៖ ការទទួលនិងបើកប្រាក់ដុល្លារអាមេរិក**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០២០-ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ខ- ការខារគ្រប់គ្រងសាច់ប្រាក់

ដើម្បីបំពេញតម្រូវការសាធារណជន ធនាគារជាតិនៃកម្ពុជាបានបន្តផ្គត់ផ្គង់ក្រដាសប្រាក់ថ្មីគ្រប់ប្រភេទ និងប្រមូលក្រដាសប្រាក់ចាស់ ទក់ រហែកជាប្រចាំ ព្រមទាំងបានពង្រឹងសោភ័ណភាព និងគុណភាពក្រដាសប្រាក់ ដើម្បីទប់ស្កាត់ការក្លែងបន្លំក្រដាសប្រាក់ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។

ការផ្គត់ផ្គង់ប្រាក់រៀលទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានកើនឡើង ១០,៦% ចំណែកការដឹកជញ្ជូនប្រាក់រៀលចាស់ ទក់ រហែក និងសាច់ប្រាក់លើសពីតម្រូវការមកស្នាក់ការកណ្ដាលវិញបានកើនឡើង ៣៩%។ ទន្ទឹមនេះ ការផ្គត់ផ្គង់ប្រាក់ដុល្លារអាមេរិកទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានកើនឡើង ២៤,៩% និងការដឹកជញ្ជូនប្រាក់ដុល្លារអាមេរិក មកស្នាក់ការកណ្ដាលវិញបានកើនឡើង ៣១% ធៀបនឹងឆ្នាំ២០២៣។

**ក្រាហ្វ ៨៥៖ ប្រាក់រៀលដឹកទៅ-មក សាខាធនាគារជាតិនៃកម្ពុជា**
(គិតជាប៊ីលានរៀល, ឆ្នាំ២០២០-ឆ្នាំ២០២៤)




សប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨៦៖ ប្រាក់ដុល្លារអាមេរិកដឹកទៅ-មក សាខាធនាគារជាតិនៃកម្ពុជា**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០២០-ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការប្តូរក្រដាសប្រាក់ចាស់ ទក់ រហែក ជូនប្រជាពលរដ្ឋតាមរយៈប្រព័ន្ធបាគង បានអនុវត្តប្តូរនៅរាជធានីភ្នំពេញ និងតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ចំនួន ១៩ ធ្វើប្រតិបត្តិការផ្ទេរប្រាក់ចំនួន ៩.៤៧៣ ប្រតិបត្តិការ ដែលមានទឹកប្រាក់ចំនួន ៣,៩ ប៊ីលានរៀល ចូលក្នុងគណនីបាគង និងការទូទាត់តាមរយៈ KHQR ឱ្យកាន់តែទូលំទូលាយជាងមុន ដែលមានប្រជាពលរដ្ឋចូលរួមយ៉ាងច្រើនកុះករ។



ការប្តូរក្រដាសប្រាក់ចាស់ ទក់ រហែក ជូនសាធារណជន តាមប្រព័ន្ធបាគង នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ នៅផ្សារអូឡាំពិក រាជធានីភ្នំពេញ



ក្រដាសប្រាក់សន្សំទុកក្នុងកូនជ្រូក ដែលសាធារណជនយកមកដូរ នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ នៅផ្សារបឹងកេងកង រាជធានីភ្នំពេញ

រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យចេញផ្សាយធនប័ត្រអនុស្សាវរីយ៍ប្រភេទ ២០០.០០០ រៀល ដើម្បីអបអរសាទរខួបលើកទី២០ នៃការគ្រងព្រះបរមរាជសម្បត្តិ ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី និងដាក់ឱ្យចរាចរទូទាំងព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ប័ណ្ណប្រកាស
ធនាគារជាតិ នៃ កម្ពុជា
ធនប័ត្រអនុស្សាវរីយ៍ ប្រភេទ ២០០០០០ រៀល
ផ្ទៃខាងមុខ
ផ្ទៃខាងខ្នង

មន្ត្រីធនាគារជាតិនៃកម្ពុជា បានចូលរួមវគ្គបណ្តុះបណ្តាលក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ ដែលរៀបចំឡើងដោយ៖

- ធនាគារ ស៊ី អាយ អិម ប៊ី នៅប្រទេសសិង្ហបុរី ស្តីពី "ការយល់ដឹងពីប្រាក់ដុល្លារអាមេរិកក្លែងក្លាយ" ក្នុងគោលបំណងកំណត់អត្តសញ្ញាណនៃក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយប្រភេទឆ្នាំ១៩៩៦ ដល់ ឆ្នាំ២០០៤ នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ និង
- ក្រុមហ៊ុនដឹកជញ្ជូនសាច់ប្រាក់ Travelex ស្តីពី "ការពិនិត្យវិនិច្ឆ័យលើក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ" នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ (IBS) និងនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តសៀមរាប នាថ្ងៃទី១៣-១៥ ខែសីហា ឆ្នាំ២០២៤។

អគ្គនាយកដ្ឋានគ្រប់គ្រងសាច់ប្រាក់ បានរៀបចំសិក្ខាសាលាស្តីពី "លក្ខណៈសុវត្ថិភាពក្រដាសប្រាក់រៀល" ដោយមានការចូលរួមពីមន្ត្រីសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤។



សកម្មភាពសិក្ខាកាមរៀនអនុវត្តពិនិត្យមើលលក្ខណៈសុវត្ថិភាពក្រដាសប្រាក់រៀល
ក្នុងពេលធ្វើសិក្ខាសាលាស្តីពី "លក្ខណៈសុវត្ថិភាពក្រដាសប្រាក់រៀល"

## ៤- ការងារគ្រប់គ្រងអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត ប្រកបអាជីវកម្មប្តូរប្រាក់ និងអាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ

### ក. អាជីវកម្មប្តូរប្រាក់ និងលិខិតអនុញ្ញាតប្តូរប្រាក់

បច្ចុប្បន្ន អាជីវកម្មប្តូរប្រាក់ដែលមានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាមានចំនួន ៤៣ (រាជធានីភ្នំពេញចំនួន ៣៨ និងខេត្តចំនួន ៥) និងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ចំនួន ៣.២៨៨ (រាជធានីភ្នំពេញចំនួន ៥១ និងខេត្តចំនួន ៣.២៣៧) ។ ក្នុងឆ្នាំ២០២៤នេះ អាជីវកម្មប្តូរប្រាក់ថ្មីចំនួន ១ ទទួលបានអាជ្ញាបណ្ណ និង ១៩ (រាជធានីភ្នំពេញចំនួន ១ និងខេត្តចំនួន ១៨) ទទួលបានលិខិតអនុញ្ញាត ខណៈដែលអាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់ចំនួន ៥ និងលិខិតអនុញ្ញាត ២៥ ត្រូវបានលុបចោល។

## ខ. អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ

ក្រុមហ៊ុននាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាមានចំនួន១២ ក្រុមហ៊ុន។ ក្នុងឆ្នាំ២០២៤នេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់ប្រតិវេទន៍នាំចេញមាសចំនួន ២១លើក និងនាំចូលមាស ១២លើក។ គួររំលេចថា ការស្នើសុំប្រតិវេទន៍សម្រាប់ការនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ត្រូវអនុវត្តតាមប្រព័ន្ធបញ្ជរតែមួយជាតិ។

ជារួម ប្រសិទ្ធភាពសេវាធនាគារកណ្តាលត្រូវបានពង្រឹងជាប្រចាំ ដើម្បីគាំទ្រដល់អន្តរ-ការិយកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការគ្រប់គ្រងសាច់ប្រាក់របស់រាជរដ្ឋាភិបាល ព្រមទាំងបានសម្រួលដល់ការទូទាត់ទំនិញនិងសេវាកម្មនៅក្នុងសេដ្ឋកិច្ច។ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានបន្តធ្វើទំនើបកម្ម និងពង្រីកការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់ ដែលបានសម្រួលដល់ប្រជាជនកម្ពុជានិងទេសចរអន្តរជាតិក្នុងការទូទាត់ទាំងក្នុងនិងក្រៅប្រទេស។ ចំណែកការគ្រប់គ្រងចរាចរណ៍សាច់ប្រាក់ក៏ត្រូវបានធ្វើឡើងដោយពិលាស ដើម្បីបំពេញតម្រូវការ និងគាំទ្រដល់ការរីកចម្រើនសេដ្ឋកិច្ចនៅទូទាំងប្រទេស។ ក្រដាសប្រាក់រៀលត្រូវបានពង្រឹងជាប្រចាំទាំងសោភ័ណភាព និងគុណភាពក្រដាសប្រាក់ ដើម្បីទប់ស្កាត់ការក្លែងបន្លំក្រដាសប្រាក់ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ទន្ទឹមនេះ អាជីវកម្មប្តូរប្រាក់ និងការនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃត្រូវបានបន្តគ្រប់គ្រងយ៉ាងប្រសើរ។

## VI-ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បាននិងកំពុងអនុវត្តការងារប្រកបដោយការទទួលខុសត្រូវ លើការងារសំខាន់ៗរបស់ខ្លួន មានដូចជា ការងារវិភាគប្រតិបត្តិការ ការត្រួតពិនិត្យបុគ្គលរាយការណ៍ កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ និងការបណ្តុះបណ្តាលនិងផ្សព្វផ្សាយក្នុងការចូលរួមចំណែកអនុវត្តច្បាប់និងបទប្បញ្ញត្តិ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា។

ក្នុងឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានបើកកិច្ចប្រជុំចំនួន ៣ លើក ដើម្បីពិនិត្យពីវឌ្ឍនភាពការងារ និងផ្តល់អនុសាសន៍ល្អៗ ដើម្បីបន្តពង្រឹងប្រសិទ្ធភាពការងារ ជាពិសេសលើការងារវាយតម្លៃហានិភ័យថ្នាក់ជាតិ ដែលត្រូវសម្រេចឱ្យបានឆាប់រហ័ស និងប្រកបដោយគុណភាព។

ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានបន្តដឹកនាំ និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយបានបញ្ចប់ ២ ដំណាក់កាលសំខាន់ៗ។ បច្ចុប្បន្ន ការងារវាយតម្លៃហានិភ័យថ្នាក់ជាតិនេះ កំពុងស្ថិតក្នុងដំណាក់កាលទី៣ ដែលជាការបូកសរុបរបាយការណ៍ និងការរៀបចំរបាយការណ៍សង្ខេប ដើម្បីរាយការណ៍ជូនគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.)។



កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើកទី៥៦ នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ នៅអគារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា



កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើកទី៥៧ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ នៅអគារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

### ១- ការងារត្រួតពិនិត្យបុគ្គលរាយការណ៍

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បន្តពង្រឹងការត្រួតពិនិត្យបុគ្គលរាយការណ៍អំពីការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពី ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការអនុវត្តវិធីសាស្ត្រ ត្រួតពិនិត្យផ្អែកលើហានិភ័យ។ នៅក្នុងឆ្នាំ២០២៤ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានត្រួតពិនិត្យដល់ទីកន្លែងចំពោះបុគ្គលរាយការណ៍សរុបចំនួន ៤២ ដោយបានរកឃើញ មានចំណុចខ្វះខាតមួយចំនួន និងបានផ្តល់អនុសាសន៍កែតម្រូវ។

ការត្រួតពិនិត្យលើឯកសារត្រូវបានអនុវត្តជាប្រចាំ តាមរយៈការតាមដានលទ្ធផល នៃការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម វឌ្ឍនភាពនៃការអនុវត្តតាមអនុសាសន៍ត្រួតពិនិត្យដល់ទីកន្លែង និងលទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុងនិងសវនកម្មផ្ទៃក្នុង។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានយកចិត្តទុកដាក់លើការវាយតម្លៃគុណវុឌ្ឍិរបស់មន្ត្រីប្រតិបត្តិ ដោយបានទទួលស្គាល់មន្ត្រីប្រតិបត្តិចំនួន ៩៨រូប មកពីធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនអចលនវត្ថុ ក្រុមហ៊ុនបរធនបាលកិច្ច ក្រុមហ៊ុនសវនកម្ម និងកាស៊ីណូ។

## ២- ការងារវិភាគ និងបញ្ជូនរបាយការណ៍

ការអនុវត្តកាតព្វកិច្ចរាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការសង្ស័យពីបុគ្គលរាយការណ៍ត្រូវបានតាមដានយ៉ាងយកចិត្តទុកដាក់ស្របតាមមាត្រា ១២ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០២០។ ក្នុងឆ្នាំ២០២៤នេះ ការរាយការណ៍ប្រតិបត្តិការសាច់ប្រាក់ថយចុះ ១៥%[២៨] និងការរាយការណ៍ប្រតិបត្តិការសង្ស័យ ថយចុះ ១៦%[២៩] បើធៀបនឹងឆ្នាំ២០២៣។ ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានរៀបចំកិច្ចប្រជុំជាមួយបុគ្គលរាយការណ៍ ដែលបានស្នើសុំភ្ជាប់ប្រព័ន្ធរាយការណ៍ចំនួន ៨០ ដើម្បីណែនាំបុគ្គលរាយការណ៍ទាំងនោះឱ្យយកចិត្តទុកដាក់អនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាពិសេសការរាយការណ៍ប្រតិបត្តិការឱ្យបានទាន់ពេលវេលា និងមានគុណភាពខ្ពស់។

## ៣- កិច្ចសហប្រតិបត្តិការ

### ក. កិច្ចសហប្រតិបត្តិការក្នុងស្រុក

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានដឹកនាំកិច្ចប្រជុំអនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (អ.វ.ហ.) ចំនួន ៨ លើក ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈមតាមម៉ូឌុលនីមួយៗពាក់ព័ន្ធនឹងការផ្តល់ពិន្ទុ/ចំណាត់ថ្នាក់ភាពងាយរងគ្រោះ ការគំរាមកំហែង និងហានិភ័យ ព្រមទាំងផ្ទៀងផ្ទាត់ជាមួយព័ត៌មានរបស់ស្ថាប័នអន្តរជាតិ ដោយមានសមាសភាពអញ្ជើញមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ២២។ ជាលទ្ធផល ក្រុមការងារទទួលបន្ទុកតាមម៉ូឌុលនីមួយៗបានបញ្ចប់ដំណាក់កាលទី២ និងបានបញ្ជូនមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីរៀបចំរបាយការណ៍គួបសរុបវាយតម្លៃហានិភ័យថ្នាក់ជាតិ។

ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានកែសម្រួល និងចុះអនុស្សរណៈយោគយល់សារជាថ្មីជាមួយអគ្គនាយកដ្ឋានពន្ធដារស្តីពីការផ្លាស់ប្តូរព័ត៌មានសម្រាប់គោលបំណងពន្ធ។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបាននិងកំពុងពិភាក្សាអំពីការចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាមួយនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា និយ័តករធានារ៉ាប់រងកម្ពុជា និងនិយ័តករបរធនបាលកិច្ច។

---

[២៨] ទិន្នន័យព្យាករណ៍ខែធ្នូ ដោយគណនាមធ្យមភាគនៃ CTR ក្នុងរយៈពេល ១១ខែ ឆ្នាំ២០២៤។

[២៩] ទិន្នន័យព្យាករណ៍ខែធ្នូ ដោយគណនាមធ្យមភាគនៃ STR ក្នុងរយៈពេល ១១ខែ ឆ្នាំ២០២៤។

## ខ. កិច្ចសហប្រតិបត្តិការអន្តរជាតិ

**ក្រុមការងារហិរញ្ញវត្ថុ (FATF) និងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG)៖** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានបន្តកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តតាមអនុសាសន៍របស់ APG ដែលមាននៅក្នុងរបាយការណ៍វាយតម្លៃអញ្ញមញ្ញ (Mutual Evaluation Report - MER) កាលពីឆ្នាំ២០១៧ និងបានរៀបចំរបាយការណ៍វឌ្ឍនភាពលើកទី ៦ ស្តីពី ការប្រឆាំងការសម្អាត-ប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ប្រទេសកម្ពុជា ជូនលេខាធិការដ្ឋាន APG ពាក់ព័ន្ធនឹងការអនុវត្តអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ។




មហាសន្និបាត និងវេទិកាជំនួយបច្ចេកទេស ប្រចាំឆ្នាំ២០២៤ របស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ ចាប់ពីថ្ងៃទី២៣-២៧ ខែកញ្ញា ឆ្នាំ២០២៤ នៅទីក្រុងអាប៊ុយដាប៊ី ប្រទេសអេមីរ៉ាតអារ៉ាប់រួម

ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចូលរួមកិច្ចប្រជុំផ្សេងៗរួមមាន៖ i/- កិច្ចប្រជុំគណៈកម្មការវាយតម្លៃអញ្ញមញ្ញ ii/- កិច្ចប្រជុំគណៈកម្មការអភិបាលកិច្ច iii/- កិច្ចប្រជុំគណៈកម្មការប្រតិបត្តិ iv/- កិច្ចប្រជុំក្រុមការងារទំនាក់ទំនងផ្នែកទ្រព្យសកម្មនិម្មិត និងអ្នកផ្តល់សេវាទ្រព្យសកម្មនិម្មិត និង v/- សិក្ខាសាលាគំរូ (Typology Workshop) ប្រចាំឆ្នាំ២០២៤។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក៏បានចូលរួមមហាសន្និបាត និងវគ្គបណ្តុះបណ្តាលផ្សេងៗ ផងដែរ។

ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានពិនិត្យ សិក្សា និងផ្តល់ធាតុចូលមួយចំនួនដល់ ក្រុមលេខាធិការដ្ឋាន APG និង ក្រុមការងារហិរញ្ញវត្ថុ រួមមាន៖ i/- គម្រោងសាកល្បងទំនាក់ទំនងផ្នែកទ្រព្យសកម្មនិម្មិត និងអ្នកផ្តល់សេវាទ្រព្យសកម្មនិម្មិត ii/- សេចក្តីព្រាងនីតិវិធីជុំទី៤ របស់ APG iii/- ការស្ទង់មតិរបស់ក្រុមការងារហិរញ្ញវត្ថុពាក់ព័ន្ធនឹងអនុសាសន៍ទី១៥ (FATF Survey on R.15) iv/- កម្រងសំណួររបស់ក្រុមការងារហិរញ្ញវត្ថុ (FATF Questionnaires) អំពីការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីក-សាយភាយអាវុធមហាប្រល័យ v/- វឌ្ឍនភាពស្តីពីប្រទេសមានហានិភ័យខ្ពស់ដែលតម្រូវឱ្យមានវិធានការប្រឆាំង និងប្រទេសដែលត្រូវបង្កើនការតាមដាន (High-Risk Jurisdictions Questionnaires) និង vi/- សម្របសម្រួលរៀបចំតម្រូវការជំនួយបច្ចេកទេសជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ។

**ក្រុមអ៊ិកម៉ុង (The Egmont Group)៖** ក្នុងនាមជាសមាជិករបស់ក្រុមអ៊ិកម៉ុង អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ ចំនួន ២ គឺ៖ កិច្ចប្រជុំក្រុមការងារនិងក្រុមការងារប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក នៃក្រុមអ៊ិកម៉ុង និងមហាសន្និបាតប្រចាំឆ្នាំលើកទី៣០ របស់ក្រុមអ៊ិកម៉ុង។







កិច្ចប្រជុំក្រុមការងាររបស់ក្រុមអ៊ិកម៉ុង និងក្រុមការងារប្រចាំតំបន់ ប្រចាំឆ្នាំ២០២៤ ចាប់ពីថ្ងៃទី២៩ ខែមករា ដល់ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤ នៅទីក្រុង St. Julian's ប្រទេសម៉ាល់ត៍

មហាសន្និបាតប្រចាំឆ្នាំលើកទី៣០ របស់ក្រុមអ៊ិកម៉ុង ចាប់ពីថ្ងៃទី២-៧ ខែមិថុនា ឆ្នាំ២០២៤ នៅទីក្រុងប៉ារីស ប្រទេសបារាំង

អង្គប្រជុំបានពិភាក្សាលើវឌ្ឍនភាពគម្រោងសិក្សារបស់ក្រុមការងារចំនួន ៤ រួមមាន៖ i/- ក្រុមការងារផ្លាស់ប្តូរព័ត៌មាន ii/- ក្រុមការងារជំនួយបច្ចេកទេសនិងបណ្តុះបណ្តាល iii/- ក្រុមការងារសមាជិកភាព ការគាំទ្រ និងអនុលោមភាព និង iv/- ក្រុមការងារគោលនយោបាយនិងនីតិវិធី ព្រមទាំង បានចែករំលែកចំណេះដឹង និងបទពិសោធពាក់ព័ន្ធនឹងការអភិវឌ្ឍអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុជំនាន់ថ្មី ដោយប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (Artificial Intelligence) និងការពង្រឹងនិងរក្សាធនធានមនុស្សសម្រាប់បំពេញការងារស្នូលផងដែរ។

**ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ (Financial Intelligence Consultative Group – FICG)៖** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចូលរួមកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំ២០២៤ របស់ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ ដែលរៀបចំឡើងក្នុងគោលបំណងពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការ និងពិចារណារួមគ្នាលើគំនិតផ្តួចផ្តើមនិងនវានុវត្តន៍ថ្មីៗដែលជាដំណោះស្រាយលើភាពគំរាមកំហែងក្នុងតំបន់។






មហាសន្និបាតប្រចាំឆ្នាំ២០២៤ របស់ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី២១-២៤ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី

ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សា-យោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ និងបានជួបប្រជុំជាមួយតំណាងមជ្ឈមណ្ឌលវិភាគនិងរបាយការណ៍ប្រតិបត្តិការអូស្ត្រាលី (AUSTRAC) ដើម្បីពិភាក្សានិងចែករំលែកវឌ្ឍនភាពការងាររបស់ប្រទេសជាសមាជិករួមមាន អាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ ព្រមទាំងបច្ចុប្បន្នភាពការងាររបស់គម្រោងសិក្សានានា ដែលរៀបចំដោយក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ។

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក៏បានចូលរួមសហការរៀបចំកម្មវិធីវប្បធម៌ ជាមួយ AUSTRAC ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយបណ្តាប្រទេសក្នុងតំបន់ផងដែរ។

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចូលរួមសិក្ខាសាលាស្តីពីការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ ដែលបានមកពីផលនៃបទល្មើសជួញដូរសត្វព្រៃខុសច្បាប់ដែលសហការរៀបចំដោយក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកាណាដា (FINTRAC) ព្រមទាំងបានផ្តល់ធាតុចូលក្នុងគម្រោងសិក្សាផ្សេងៗរបស់ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ។

ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានសហការរៀបចំសន្និសីទថ្នាក់តំបន់ស្តីពីការប្រឆាំងការសម្អាតប្រាក់ពាក់ព័ន្ធនឹងបទល្មើសជួញដូរវត្ថុបុរាណ និងសម្បត្តិបេតិកភណ្ឌ ជាមួយ EU Global Facilities និងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) នៅខេត្តសៀមរាប។





សន្និសីទថ្នាក់តំបន់ស្តីពីការប្រឆាំងការសម្អាតប្រាក់ពាក់ព័ន្ធនឹងបទល្មើសជួញដូរវត្ថុបុរាណ និងសម្បត្តិបេតិកភណ្ឌ
ចាប់ពីថ្ងៃទី២៧-២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅខេត្តសៀមរាប

## ៤. ការពង្រឹងសមត្ថភាព

មន្ត្រីរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចូលរួមវគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសដែលរៀបចំដោយស្ថាប័នជាតិ និងអន្តរជាតិ តាមរយៈប្រព័ន្ធអនឡាញ និងការចូលរួមផ្ទាល់ ដែលមានប្រធានបទសំខាន់ៗ ដូចជា ការវាយតម្លៃហានិភ័យថ្នាក់ជាតិនៃការរីកសាយភាយអាវុធមហាប្រល័យ ការវិភាគព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុក្នុងតំបន់ទន្លេមេគង្គ ការស៊ើបអង្កេតបទល្មើសហិរញ្ញវត្ថុ សន្តិសុខសាយប័រ ការពង្រឹងការប្រឆាំងឧក្រិដ្ឋកម្មហិរញ្ញវត្ថុ ការត្រួតពិនិត្យតាមស្តង់ដារបស់ក្រុមការងារហិរញ្ញវត្ថុ និងការរៀបចំសំណុំរឿងបទល្មើសជាដើម។

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអន្តរជាតិ និងច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សរុបចំនួន ២៤ លើកជូនមន្ត្រីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងធនាគារជាតិនៃកម្ពុជា និយ័តករ បុគ្គលរាយការណ៍ និងមជ្ឈដ្ឋានសិក្សា។ បន្ថែមលើនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាដែលសហការរៀបចំដោយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករមូលបត្រកម្ពុជា និយ័តករធានារ៉ាប់រងកម្ពុជា និងគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា សរុបចំនួន ២២ លើក។



កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ ច្បាប់ និងបទប្បញ្ញត្តិស្តីពីការ
ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
ជូននិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រង
នាថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤
នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង




វគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអន្តរជាតិ និងច្បាប់និងបទប្បញ្ញត្តិ
ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដល់មន្ត្រី-
បុគ្គលិក ធនាគារជាតិនៃកម្ពុជា
នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤
នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ

ជារួម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានអនុវត្តការងារស្នូលយ៉ាងខ្ជាប់ខ្ជួន និងប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការទទួលរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការសង្ស័យរបស់បុគ្គលរាយការណ៍ ការត្រួតពិនិត្យបុគ្គលរាយការណ៍ ការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងក្នុងនិងក្រៅប្រទេស និងការពង្រឹងសមត្ថភាពមន្ត្រីរបស់អង្គភាព។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានបន្តដឹកនាំ និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធយ៉ាងយកចិត្តទុកដាក់ក្នុងការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

## VII-កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ១- កិច្ចសហប្រតិបត្តិការពហុភាគី

ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្ដាអង្គការ-ស្ថាប័នអន្តរជាតិនានា បន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនសមាហរណកម្ម ពង្រឹងបណ្ដាញសុវត្ថិភាពហិរញ្ញវត្ថុ និងការទទួលបានជំនួយបច្ចេកទេសនិងការអភិវឌ្ឍធនធានមនុស្ស។

**- កិច្ចសហប្រតិបត្តិការអាស៊ាន ៖** ក្រោមមូលបទអាស៊ានឆ្នាំ២០២៤ ស្ដីពី "ការពង្រឹងការតភ្ជាប់ និងភាពធន់អាស៊ាន" ដែលមានឡាវជាប្រធានប្ដូរវេន ធនាគារជាតិនៃកម្ពុជាបានរួមចំណែកគាំទ្រ និងពង្រឹងសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន ដោយសម្រេចបានសមិទ្ធផលសំខាន់ៗ រួមមាន៖ i/-ការអភិវឌ្ឍក្របខណ្ឌការតភ្ជាប់ការទូទាត់ពហុភាគីអាស៊ាន ii/-ការអភិវឌ្ឍនិងផ្សព្វផ្សាយវត្ថិករសាស្ត្រ (Taxonomy) ស្ដីពី ហិរញ្ញប្បទានប្រកបដោយចីរភាពអាស៊ាន កំណែទី៣ iii/-ការអភិវឌ្ឍសេចក្ដីណែនាំសម្រាប់ការពង្រឹងអភិក្រមហិរញ្ញវត្ថុឌីជីថលសម្រាប់អាស៊ាន iv/-ការដាក់ចេញនូវក្របខណ្ឌប្រតិបត្តិការជារូបិយវត្ថុតំបន់អាស៊ាន v/-ការដាក់ចេញគំនិតផ្ដួចផ្ដើមផ្សេងៗ ដើម្បីសម្រេចឱ្យបាននូវការអនុវត្តចក្ខុវិស័យនិងផែនការសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ និងក្រោយឆ្នាំ២០២៥ vi/-ការសម្រេចបានការងារអាទិភាពចំនួន ២១ របស់ក្រុមការងារអាស៊ានសម្រាប់ឆ្នាំ២០២៤ និង vii/-ការលើកកម្ពស់តួនាទីរបស់សហគ្រាសមីក្រូ តូច និងមធ្យម ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចអាស៊ាន។ លើសពីនេះ កិច្ចព្រមព្រៀងអាស៊ានស្វប់ក៏ត្រូវបានពិភាក្សា ដើម្បីពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុអាស៊ាន បន្ថែមលើយន្តការដែលមានស្រាប់ ក្នុងក្របខណ្ឌអាស៊ាន+៣។






ឯកឧត្តម រ័ត្ន សុវណ្ណនរៈ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានដឹកនាំគណៈប្រតិភូចូលរួម
កិច្ចប្រជុំគណៈកម្មាធិការជាន់ខ្ពស់ ស្ដីពី សមាហរណកម្មហិរញ្ញវត្ថុអាស៊ាន លើកទី២៨
ចាប់ពីថ្ងៃទី១៩-២០ ខែកញ្ញា ឆ្នាំ២០២៤ នៅទីក្រុងដាណាង ប្រទេសវៀតណាម

**- កិច្ចសហប្រតិបត្តិការអាស៊ាន+៣៖** ធនាគារជាតិនៃកម្ពុជាបានបន្តចូលរួមក្នុងកិច្ចសហប្រតិបត្តិការអាស៊ាន+៣ ដោយមានប្រទេសឡាវនិងកូរ៉េជាសហប្រធានប្ដូរវេនឆ្នាំ២០២៤។ លទ្ធផលការងារសំខាន់ៗ រួមមាន៖ i/-ការបង្កើតឧបករណ៍ផ្ដល់ហិរញ្ញប្បទានរហ័ស (RFF) ដែលជាឧបករណ៍ហិរញ្ញប្បទានថ្មីសម្រាប់ដោះស្រាយតម្រូវការជញ្ជីងទូទាត់បន្ទាន់ ក្រោមកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្ដួចផ្ដើមឈៀងម៉ៃ (CMIM) ii/-ការធ្វើបច្ចុប្បន្នកម្មគោលការណ៍ប្រតិបត្តិរបស់ CMIM iii/-ការអភិវឌ្ឍរចនាសម្ព័ន្ធអត្រាការប្រាក់រួមតែមួយ (Unified LCY-P Margin Structure) សម្រាប់

ឥណទានជារូបិយវត្ថុក្នុងតំបន់ iv/-ការឯកភាពលើការរៀបចំការសាកល្បង CMIM លើកទី១៥ ដែលផ្តោតសំខាន់លើដំណើរការនៃការសម្រេចចិត្តសម្រាប់យន្តការបង្ការវិបត្តិ v/-ការអនុវត្តទិសដៅយុទ្ធសាស្ត្រឆ្នាំ២០៣០ របស់អង្គភាព AMRO និងការរៀបចំយុទ្ធសាស្ត្រភាពជាដៃគូថ្មីឆ្នាំ២០៣០ vi/-ការពង្រឹងសមត្ថភាពរបស់អង្គភាព AMRO ក្នុងការតាមដានស្ថានភាពសេដ្ឋកិច្ចនិងការពង្រឹងកិច្ចការស្រាវជ្រាវកាន់តែស៊ីជម្រៅ vii/-ការពិនិត្យឡើងវិញទៅលើផែនការការងាររបស់អង្គភាព AMRO និងជ្រើសរើសនាយករងទី៣ ដែលជាតំណែងបង្កើតថ្មី ដើម្បីទទួលបន្ទុកការងារស្រាវជ្រាវនិងតាមដានស្ថានភាពសេដ្ឋកិច្ច viii/-ការអនុវត្តការងារផែនទីមគ្គុទ្ទេសក៍ក្រោមគំនិតផ្តួចផ្តើមទីផ្សារសញ្ញាបណ្ណអាស៊ានរយៈពេលមធ្យម ២០២៣-២០២៦ និង ix/-ការជ្រើសរើសអគ្គលេខាធិការរបស់គំនិតផ្តួចផ្តើមហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយធម្មជាតិ។





លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានដឹកនាំគណៈប្រតិភូធនាគារជាតិនៃកម្ពុជា ចូលរួមកិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីនិងទេសាភិបាលធនាគារកណ្តាលអាស៊ាន+៣ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងប៊ីលីស៊ី ប្រទេសហ្សកហ្ស៊ី

**- មជ្ឈមណ្ឌលស៊ាសិន (SEACEN)៖** ក្នុងឆ្នាំ២០២៤នេះ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់តួនាទីជាប្រធានក្រុមប្រឹក្សាទេសាភិបាល (BOG) និងប្រធានគណៈកម្មាធិការប្រតិបត្តិ (EXCO) នៃមជ្ឈមណ្ឌលស៊ាសិនដោយជោគជ័យ និងប្រគល់តួនាទីជូនធនាគារកណ្តាលឥណ្ឌាជាប្រធានប្តូរវេនបន្ត។ ក្រោយពីលោក Mangal Goswami បានបញ្ចប់អាណត្តិ លោកស្រី Cynyoung Park ត្រូវបានជ្រើសរើសជានាយកប្រតិបត្តិថ្មីរបស់មជ្ឈមណ្ឌលស៊ាសិនសម្រាប់រយៈពេល ៣ ឆ្នាំ។ មជ្ឈមណ្ឌលស៊ាសិនបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់ការបណ្តុះបណ្តាល និងស្រាវជ្រាវលើកិច្ចការធនាគារកណ្តាល ដែលកន្លងមកធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាលលើប្រធានបទនានា រួមមាន ការគ្រប់គ្រងលំហូរមូលធន ការគ្រប់គ្រងហានិភ័យសន្ទនីយភាព នយោបាយរូបិយវត្ថុ និងគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្ន ជាដើម។ ក្នុងនោះដែរ ធនាគារជាតិនៃកម្ពុជាបានចូលរួមរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២ ស្តីពី "ការដឹកនាំប្រកបដោយភាពបត់បែន" និង "ការព្យាករស្ថិរភាពគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុ"។ នៅក្នុងឆ្នាំ២០២៤នេះ មជ្ឈមណ្ឌលស៊ាសិនបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៣២ និងស្រាវជ្រាវចំនួន ២ ព្រមទាំងចែករំលែកចំណេះដឹងលើការគ្រប់គ្រងមូលធន តាមរយៈការស្រាវជ្រាវ និងកិច្ចប្រជុំអនឡាញ។



លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានចូលរួមជាវាគ្មិនក្នុងសន្និសីទថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃបណ្តាប្រទេសជាសមាជិកមជ្ឈមណ្ឌលស៊ាសិន លើកទី៦០ នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ



ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាអធិបតី ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី “ការដឹកនាំប្រកបដោយភាពបត់បែន” នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤ នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ

**- មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)៖** ក្រៅពីការបន្តតាមដាននិងវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិបានបន្តផ្តល់ជំនួយបច្ចេកទេសនិងការកសាងសមត្ថភាពជំនាញជូនមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា។ ក្នុងឆ្នាំ២០២៤នេះ ជំនួយបច្ចេកទេសដែលធនាគារជាតិនៃកម្ពុជាទទួលបានពី IMF រួមមាន៖ i/-ការលើកកម្ពស់ប្រតិបត្តិការរូបិយវត្ថុនិងទីផ្សារប្តូរប្រាក់ ii/-ការកែលម្អសន្ទស្សន៍ថ្លៃលំនៅឋាន និងការធ្វើឱ្យប្រសើរឡើងស្ថិតិវិស័យខាងក្រៅ ជាដើម ស្របពេលដែល IMF បានសហការរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី១១ និងបន្តផ្តល់អាហារូបករណ៍ដល់មន្ត្រីធនាគារជាតិនៃកម្ពុជា ទៅបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមជំនួយរបស់រដ្ឋាភិបាលជប៉ុន។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានបំពេញតួនាទីជាសហប្រធានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាយោបល់នៃការិយាល័យអភិវឌ្ឍន៍សមត្ថភាពរបស់មូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំប្រទេសថៃ (CDOT) ដើម្បីពិនិត្យលទ្ធផលការងារប្រចាំឆ្នាំ ជាពិសេសវឌ្ឍនភាពនៃការអនុវត្តគម្រោងជំនួយបច្ចេកទេសរបស់ប្រទេសជាសមាជិក ក្នុងនោះ ជំនួយដែលបានផ្តល់ជូនធនាគារជាតិនៃកម្ពុជា រួមមាន៖ i/-ការពង្រឹងការចងក្រងស្ថិតិវិស័យក្រៅប្រទេស ii/-ការងារប្រតិបត្តិការរូបិយវត្ថុនិងអត្រាប្តូរប្រាក់ និង iii/-ការអភិវឌ្ឍក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចកម្ពុជា។



លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យក្រុមបេសកកម្មមាត្រា IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដឹកនាំដោយលោក Kenichiro Kashiwase ប្រធានបេសកកម្មថ្មីរបស់ IMF សម្រាប់កម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ

**- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)៖** ធនាគារអភិវឌ្ឍន៍អាស៊ីបានបន្តផ្តល់ជូនធនាគារជាតិនៃកម្ពុជា ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជានូវ៖ i/-ជំនួយបច្ចេកទេសក្នុងការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០ ដែលដឹកនាំដោយធនាគារជាតិនៃកម្ពុជា ហើយគ្រោងនឹងបញ្ចប់ជាស្ថាពរ នាដើមឆ្នាំ២០២៥ និង ii/-គម្រោងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រកបដោយចីរភាព និងបរិយាបន្ន ដែលជាកម្មវិធីហិរញ្ញប្បទានផ្អែកលើគោលនយោបាយ ដោយមាន ៣ អនុកម្មវិធី។ អនុកម្មវិធីទី១ ដែលមានទឹកប្រាក់ប្រមាណ ៥០ លានដុល្លារអាមេរិក នឹងចាប់ផ្តើមអនុវត្តនាឆ្នាំ២០២៥ ខាងមុខ ដែលផ្តោតសំខាន់លើការកែទម្រង់បទប្បញ្ញត្តិបរិស្ថាន ស្ថិរភាពហិរញ្ញវត្ថុ ការអភិវឌ្ឍទីផ្សារ និងកិច្ចការពារអតិថិជន ដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនិងនិយ័តករមូលបត្រកម្ពុជា។



លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុង
កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០
នាថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ

**- ធនាគារពិភពលោក (WB)៖** ធនាគារពិភពលោកបន្តជួយពង្រឹងការងារគ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា ក្រោមកម្មវិធីសហប្រតិបត្តិការប្រឹក្សានិងគ្រប់គ្រងទុនបម្រុង (RAMP Program) ដោយបានជួយកសាងសមត្ថភាពរបស់មន្ត្រីផ្នែកគ្រប់គ្រងទុនបម្រុង និងអភិវឌ្ឍក្របខណ្ឌគ្រប់គ្រងអភិបាលកិច្ចនិងហានិភ័យ សំដៅធ្វើយ៉ាងណាឱ្យការកំណត់គោលដៅចំណូលមានតុល្យភាពជាមួយនឹងហានិភ័យ។ ទន្ទឹមនេះ ជំនួយបច្ចេកទេសក៏ត្រូវបានផ្តល់ផងដែរលើ "ការគាំទ្រស្ថិរភាពនិងបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា" រយៈពេល២ឆ្នាំបន្ថែម។

**- ក្រុមប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន)៖** ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងកិច្ចសហការជាមួយប្រទេសហ្វ្រង់កូហ្វូន ដែលមានចំនួនសរុប ៨៤ ប្រទេស (សមាជិកពេញសិទ្ធិ ៥៤ សមាជិកមិនទាន់ពេញសិទ្ធិ ៤ និងអង្កេតការ ១) តាមរយៈការចូលរួមក្នុងកិច្ចប្រជុំថ្នាក់ទេសាភិបាលរបស់ធនាគារកណ្តាលនៃប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) នៅទីក្រុងព្រុចសែល ប្រទេសបែលហ្ស៊ិក ស្តីពី ការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។ នាឱកាសនេះ ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ត្រូវបានអញ្ជើញចែករំលែកបទពិសោធពីហិរញ្ញវត្ថុបៃតង ការអនុវត្តគោលការណ៍គាំទ្រការផ្តល់ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅក្នុងប្រព័ន្ធធនាគារ និងការវិនិយោគទុនបម្រុងអន្តរជាតិលើសញ្ញាបណ្ណបៃតង ជាដើម។ ក្នុងកិច្ចប្រជុំនោះ ធនាគារជាតិនៃកម្ពុជាក៏បានគាំទ្រក្នុងការជំរុញឱ្យមានការចូលរួមបន្ថែមទៀតរបស់មូលនិធិនិងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ក៏ដូចជាប្រទេសអភិវឌ្ឍន៍

ក្នុងការគាំទ្រផ្តល់ហិរញ្ញប្បទានបៃតង ព្រមទាំងពង្រឹងកិច្ចសហការនិងសាមគ្គីភាពលើការគាំទ្រគម្រោងវិនិយោគបៃតង ដោយការទិញសញ្ញាបណ្ណបៃតងទៅវិញទៅមកជាដើម។ នាឆ្នាំ២០២៦ ខាងមុខ ធនាគារជាតិនៃកម្ពុជាទទួលបានការទុកចិត្តឱ្យធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំប្រ៊្វង់កូហ្វូនជាលើកទី៣ ដែលលើកទី២ ធ្វើឡើងក្នុងឆ្នាំ២០១១ និងលើកទី១ នៅឆ្នាំ២០០២។



លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំថ្នាក់ទេសាភិបាល ធនាគារកណ្តាលនៃប្រទេសនិយាយភាសាបារាំង (ប្រ៊្វង់កូហ្វូន) លើកទី៣០ ចាប់ពីថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងព្រុចសែល ប្រទេសបែលហ្ស៊ិក

**ប្រអប់១៖ កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិ**

➢ **ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)៖** ធនាគារជាតិនៃកម្ពុជាបានបន្តកិច្ចសហការអនុវត្តគម្រោង ការលើកកម្ពស់សមត្ថភាពក្នុងការស្រាវជ្រាវ វិភាគសេដ្ឋកិច្ច និងប្រតិបត្តិការនយោបាយរូបិយវត្ថុ។ ក្រោមគម្រោងនេះ JICA បានបញ្ជូនជំនាញការថ្មី ១រូបបន្ថែមទៀត ព្រមទាំងបានរៀបចំវគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន ស្តីពី "ការអង្កេតរបស់ធនាគារកណ្តាល" និងវគ្គបណ្តុះបណ្តាលនៅខេត្តសៀមរាបស្តីពី "ការពង្រឹងការគ្រប់គ្រងទិន្នន័យ និងការវិភាគសេដ្ឋកិច្ចដោយប្រើប្រាស់ Dashboard" ដល់មន្ត្រីជំនាញរបស់ធនាគារជាតិនៃកម្ពុជាផងដែរ។ ជំនាញការរបស់ JICA បានបំពេញបេសកកម្មចំនួន ៣ លើក នៅធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងវាយតម្លៃគ្រប់ជ្រុងជ្រោយពីបរិវត្តកម្មឌីជីថលនៅកម្ពុជា។



ជំនួបប្រជុំរវាងលោកបណ្ឌិត យូ វុណ្ណី អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ ជាមួយលោក Tabata Hidetaka ប្រធានការិយាល័យសហប្រតិបត្តិការអន្តរជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជប៉ុន ដើម្បីពិភាក្សាពីស្ថានភាពសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងធនាគារ នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា

➢ **សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI)៖** ធនាគារជាតិនៃកម្ពុជា បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ និងវេទិកាគោលនយោបាយសកលរបស់ AFI ដែលត្រូវបានរៀបចំឡើងនៅប្រទេសអែលសាល់វ៉ាឌ័រ ដើម្បីពិភាក្សាអំពីការរក្សានិរន្តរភាពប្រតិបត្តិការ ការបន្តគាំទ្រជំនួយបច្ចេកទេសដល់ប្រទេសជាសមាជិក ការបង្កើតការិយាល័យតំណាង និងការប្រែក្លាយជាអង្គការអន្តររដ្ឋាភិបាល ក៏ដូចជាពិភាក្សាលើប្រធានបទស្តីពី "នវានុវត្តន៍សម្រាប់បរិយាបន្នជាសកល" ដោយផ្តោតលើគោលនយោបាយនិងវិធានការចំពោះបញ្ហាប្រឈមនានាក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការរក្សាស្ថិរភាពហិរញ្ញវត្ថុ ការលើកកម្ពស់សិទ្ធិអតិថិជន និងការអនុវត្តទីផ្សារ ការផ្តល់ហិរញ្ញប្បទានបៃតងនិងបរិយាបន្ន និងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ជាដើម។ ទន្ទឹមនេះ AFI បានបន្តផ្តល់ជំនួយលើការធ្វើបច្ចុប្បន្នកម្មផែនទីមគ្គុទ្ទេសក៍ស្តីពី "ចំណេះដឹងផ្នែកហិរញ្ញវត្ថុឆ្នាំ២០២៣-២០២៨" ក្នុងគោលបំណងកំណត់ក្របខណ្ឌលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងហិរញ្ញវត្ថុឌីជីថល។ លើសពីនេះ ភាគីទាំងពីរក៏បានសហការអភិវឌ្ឍក្របខណ្ឌប្រមូលទិន្នន័យបរិយាបន្នហិរញ្ញវត្ថុបែងចែកតាមភេទ ក្នុងគោលដៅកំណត់ចន្លោះខ្វះខាតនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុបែងចែកតាមភេទឱ្យកាន់តែមានប្រសិទ្ធភាព។ ជាលទ្ធផល ទម្រង់របាយការណ៍នេះត្រូវបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត និងរាយការណ៍មកធនាគារជាតិនៃកម្ពុជា ជារៀងរាល់ត្រីមាស គិតចាប់តាំងពីត្រីមាសទី៣ ឆ្នាំ២០២៤ នេះតទៅ។



ឯកឧត្តម រ័ត្ន សុវណ្ណនរៈ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនិងវេទិកាគោលនយោបាយសកលរបស់ AFI ចាប់ពីថ្ងៃទី២-៥ ខែកញ្ញា ឆ្នាំ២០២៤ នៅប្រទេសអែលសាល់វ៉ាឌ័រ

➢ **កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)៖** គម្រោង Universal Trusted Credentials (UTC) ក្រោមគំនិតផ្តួចផ្តើមរបស់ UNDP និងភាគីពាក់ព័ន្ធផ្សេងទៀត នឹងត្រូវបានដាក់ឱ្យអនុវត្តនៅកម្ពុជា ក្នុងគោលបំណងបង្កើតនូវប្រព័ន្ធទិន្នន័យមួយដែលមានភាពរឹងមាំ សំដៅជួយសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ដោះស្រាយបញ្ហាប្រឈមនានា ជាពិសេសការទទួលបានហិរញ្ញវត្ថុផ្លូវការពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលនឹងអាចលើកកម្ពស់សមត្ថភាពក្នុងការនាំចេញផលិតផលរបស់ MSMEs ទៅកាន់ប្រទេសជាដៃគូ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា និង UNDP បានសហការរៀបចំសិក្ខាសាលាស្តីពី "ការទប់ស្កាត់ការឆបោកតាមប្រព័ន្ធឌីជីថលនៅកម្ពុជា" ក្នុងគោលបំណង i/- ផ្តល់ការយល់ដឹងរួមអំពីនិន្នាការ និងផលប៉ះពាល់ នៃការបោកប្រាស់តាមរយៈ



សិក្ខាសាលាស្តីពី
"ការទប់ស្កាត់ការឆបោកតាមប្រព័ន្ធឌីជីថលនៅកម្ពុជា"
នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា

ប្រព័ន្ធឌីជីថលទូទាំងពិភពលោក និងនៅក្នុងប្រទេសកម្ពុជា ii/- ពិនិត្យឡើងវិញនូវគំនិតផ្តួចផ្តើមសាធារណៈ ឯកជន និងសហគមន៍ក្នុងការប្រឆាំងនឹងការបោកប្រាស់ ដើម្បីកំណត់គម្លាត និងបង្កើនឱកាសសម្រាប់កិច្ចសហការរួមគ្នាឱ្យប្រសើរឡើងវិញ និង iii/- កំណត់សកម្មភាពនៅជំហានបន្ទាប់ រួមមានការតភ្ជាប់ទំនាក់ទំនងទៅស្ថាប័នពាក់ព័ន្ធជាសកល និងរៀបចំករណីសិក្សាស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។

➢ **គណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ (UNESCAP)៖** ភាគីទាំងពីរបានសហការរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់សហគ្រិនជាស្ត្រីក្នុងខេត្តកំពង់ចាម និងខេត្តក្រចេះ ក្នុងគោលបំណងផ្តល់ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថលដល់សហគ្រិនស្ត្រី និងនិស្សិតជាស្ត្រី។ លើសពីនេះ UNESCAP បានជួបពិភាក្សាពីកិច្ចសហប្រតិបត្តិការ ក្នុងការគាំទ្រនិងលើកកម្ពស់សហគ្រិនស្ត្រី ព្រមទាំងការរៀបចំផែនការចង្អុលទិសហិរញ្ញប្បទានប្រកបដោយចីរភាពនៅកម្ពុជា។



ជំនួបរវាងលោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងលោកជំទាវបណ្ឌិតអាមីដា សាល់សៃអាលីហ្សាបាណា អគ្គលេខាធិការរង នៃអង្គការសហប្រជាជាតិ និងជាលេខាធិការប្រតិបត្តិអង្គការ UNESCAP នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ

➢ **សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)៖** ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា បានចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី "ហិរញ្ញប្បទានបៃតងនៅកម្ពុជា" ដែលរៀបចំដោយសមាគមធនាគារនៅកម្ពុជា និង IFC ដើម្បីចែករំលែកចំណេះដឹងជូនសិក្ខាកាមអំពីទស្សនទានសំខាន់ៗពាក់ព័ន្ធនឹងហិរញ្ញប្បទានបៃតង និងឱកាសក្នុងការកៀរគរហិរញ្ញវត្ថុបៃតងសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ ជាមួយគ្នានេះ IFC បានសហការក្នុងការអភិវឌ្ឍទីផ្សារខ្សែច្រវ៉ាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងទំនុកចិត្ត ដើម្បីពង្រឹងលទ្ធភាពដល់ការទទួលបានហិរញ្ញប្បទានសម្រាប់អាជីវកម្មនៅកម្ពុជា ជាពិសេសសហគ្រាសធុនតូច និងមធ្យម ដោយបានរៀបចំវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ដល់មន្ត្រីធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីធ្វើការសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ពីសេវា Factoring ការផ្តល់ហិរញ្ញប្បទានដែលធានាដោយចលនវត្ថុ និងការអភិវឌ្ឍទីផ្សារខ្សែច្រវ៉ាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុ ជាដើម។ បន្ថែមពីនេះ IFC បាននិងកំពុងគាំទ្រដល់ធនាគារជាតិនៃកម្ពុជាក្នុងការពង្រឹងកិច្ចការពារអតិថិជនដែលប្រើប្រាស់សេវាហិរញ្ញវត្ថុ តាមរយៈ៖ i/-ការផ្តល់ជំនួយបច្ចេកទេសក្នុងការរៀបចំបទប្បញ្ញត្តិ និងការត្រួតពិនិត្យពាក់ព័ន្ធនឹងកិច្ចការពារអតិថិជន ii/-ការសហការជាមួយ



ឯកឧត្តម យឹម លាត ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាអធិបតី ក្នុងសិក្ខាសាលា ស្តីពី "ហិរញ្ញប្បទានបៃតងនៅកម្ពុជា" នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ នៅសណ្ឋាគារហាយ៉ាត់ រីជិនស៊ី ភ្នំពេញ

សមាគម ភាគីពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការបង្កើនសមត្ថភាពបុគ្គលិក និងពង្រឹងស្វ័យនិយ័តកម្ម iii/-ការជំរុញឱ្យមានយន្តការឯករាជ្យក្នុងការដោះស្រាយបណ្តឹងនិងវិវាទក្នុងវិស័យធនាគារ ឬមជ្ឈមណ្ឌលសម្រាប់អតិថិជនហិរញ្ញវត្ថុ (Financial Consumer Center) និង iv/- ការគាំទ្រដល់ការងារពាក់ព័ន្ធនឹងកិច្ចការពារអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាដើម។

➢ **វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA)៖** ធនាគារជាតិនៃកម្ពុជា និង ERIA បានចុះអនុស្សរណៈយោគយល់ស្តីពី "កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជា" ក្នុងគោលបំណងបង្កើតជាក្របខណ្ឌកសាងសមត្ថភាព តាមរយៈការរៀបចំសិក្ខាសាលាដើម្បីពិភាក្សា ក៏ដូចជាពិគ្រោះយោបល់ទាក់ទងនឹងបរិវត្តកម្មបៃតង និងនវានុវត្តន៍ឌីជីថល និងស្វែងរកឱកាសក្នុងដំណើរអភិវឌ្ឍន៍គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) និងហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជា ព្រមទាំងអនុញ្ញាតឱ្យមានការអនុវត្តគម្រោងស្រាវជ្រាវរួមគ្នាជុំវិញទិដ្ឋភាពហិរញ្ញប្បទានឌីជីថលបៃតង។ ជាមួយគ្នានេះ ភាគីទាំងពីរបានសហការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជា" ក្នុងគោលបំណងផ្តល់ជាវេទិកាពិភាក្សាអំពីការអនុវត្ត និងបញ្ហាប្រឈមនានា ក្នុងការផ្តល់ឥណទានបៃតងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធដើរតួជាជំហានដ៏សំខាន់ក្នុងការប្រមូលរាល់បញ្ហាពាក់ព័ន្ធសម្រាប់ការសិក្សាស្រាវជ្រាវ និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីជាដំណោះស្រាយជំរុញការផ្តល់ហិរញ្ញប្បទានបៃតង។



ឯកឧត្តម យឹម លាត ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា និង លោកបណ្ឌិត Aladdin D.Rillo នាយកគ្រប់គ្រងរៀបចំគោលនយោបាយនិងប្រតិបត្តិការនៃវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) បានអញ្ជើញជាអធិបតី ក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជា" នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ នៅខេត្តសៀមរាប

## ២- កិច្ចសហប្រតិបត្តិការទ្វេភាគី

ធនាគារជាតិនៃកម្ពុជាបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្ដាធនាគារកណ្ដាល និងអាជ្ញាធររូបិយវត្ថុនានានៅក្នុងតំបន់និងពិភពលោក ដោយលទ្ធផលសំខាន់ៗសម្រេចបានរួមមាន៖

- **ធនាគារកណ្ដាលម៉ាឡេស៊ី៖** ធនាគារកណ្ដាលទាំងពីរបានជួបប្រជុំទ្វេភាគី ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការវិស័យធនាគារ និងពិនិត្យលើវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការនាពេលកន្លងមក ព្រមទាំងបានចុះអនុស្សរណៈយោគយល់ស្ដីពី កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុនិងប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីលើកកម្ពស់ការទូទាត់ឆ្លងដែនជារូបិយវត្ថុក្នុងស្រុកប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។



ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្ដីពី កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី

- **ធនាគារជាតិនៃហ្សកហ្ស៊ី៖** ធនាគារកណ្ដាលទាំងពីរបានចុះអនុស្សរណៈយោគយល់និងជួបប្រជុំទ្វេភាគី ដើម្បីពិភាក្សាផ្លាស់ប្ដូរទស្សនៈលើស្ថានភាពសេដ្ឋកិច្ច ដំណើរនៃការអភិវឌ្ឍវិស័យធនាគារ នយោបាយរូបិយវត្ថុនិងស្ថិរភាពហិរញ្ញវត្ថុ ចីរភាពហិរញ្ញវត្ថុ នៅទីក្រុងប៊ីលីស៊ី ប្រទេសហ្សកហ្ស៊ី។




កិច្ចប្រជុំទ្វេភាគី និងពិធីចុះអនុស្សរណៈយោគយល់
នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងប៊ីលីស៊ី ប្រទេសហ្សកហ្ស៊ី

- **ធនាគារកណ្ដាលឡាវ៖** មន្ត្រីជំនាញធនាគារកណ្ដាលឡាវបានធ្វើទស្សនកិច្ចនៅធនាគារជាតិនៃកម្ពុជា ដើម្បីដកស្រង់បទពិសោធលើប្រធានបទ៖ i/-ការបោះពុម្ពធនបត្រតម្លៃធំ ii/-រដ្ឋបាល និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យលក្ខណៈមជ្ឈការប្រកបដោយសុវត្ថិភាព iii/-ការគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុធនាគារកណ្ដាល iv/-ក្របខណ្ឌនយោបាយរូបិយវត្ថុ v/-ការគ្រប់គ្រងការប្ដូរប្រាក់ vi/-នីតិវិធីនៃការផ្ដល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង vii/- ការគ្រប់គ្រងនិងអភិវឌ្ឍប្រព័ន្ធទូទាត់របស់ធនាគារកណ្ដាល។ ជាមួយគ្នានេះ មន្ត្រីជំនាញធនាគារជាតិនៃកម្ពុជាបាន

ធ្វើទស្សនកិច្ចនៅធនាគារកណ្តាលឡាវដើម្បីចែករំលែកបទពិសោធលើប្រធានបទ៖ i/-បទពិសោធនៃការធ្វើបដិដុល្លារូបនីយកម្ម ii/-ការត្រួតពិនិត្យប្រព័ន្ធទូទាត់ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការដោះដូរទ្រព្យគ្រីបតូ iii/-ក្របខណ្ឌបទប្បញ្ញត្តិ និងការត្រួតពិនិត្យក្រុមហ៊ុនភតិសន្យា iv/-ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់និងការបោះផ្សាយមូលបត្ររដ្ឋនិងធនាគារកណ្តាល និង v/-ការសហការធ្វើការត្រួតពិនិត្យដល់ទីកន្លែងលើសាខាធនាគារពាណិជ្ជរបស់ប្រទេសកម្ពុជាដែលធ្វើប្រតិបត្តិការនៅប្រទេសឡាវ។



ទស្សនកិច្ចសិក្សារបស់មន្ត្រីជំនាញធនាគារកណ្តាលឡាវ
ចាប់ពីថ្ងៃទី១៧-២០ ខែមករា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា



ទស្សនកិច្ចសិក្សារបស់មន្ត្រីជំនាញធនាគារជាតិនៃកម្ពុជា
ចាប់ពីថ្ងៃទី១១-១៣ ខែកញ្ញា ឆ្នាំ២០២៤ នៅធនាគារកណ្តាលឡាវ

**- អាជ្ញាធររូបិយវត្ថុនៃព្រះរាជាណាចក្រប៊ូតង់៖** គណៈប្រតិភូនៃអាជ្ញាធររូបិយវត្ថុនៃព្រះរាជាណាចក្រប៊ូតង់បានមកបំពេញទស្សនកិច្ចសិក្សានៅធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងស្វែងយល់ពីបទពិសោធលើ៖ i/-ការអនុវត្តនយោបាយអត្រាប្តូរប្រាក់ ii/-នយោបាយរូបិយវត្ថុ iii/-ការគ្រប់គ្រងសន្ទនីយភាព និង iv/-តួនាទីនៃការធ្វើសមាហរណកម្មហិរញ្ញវត្ថុអាស៊ានរបស់ធនាគារជាតិនៃកម្ពុជា។

**- អាជ្ញាធររូបិយវត្ថុសិង្ហបុរី៖** កម្ពុជានិងសិង្ហបុរីបានដាក់ឱ្យដំណើរការគម្រោងថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុ (FTC) នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ នៅវិមានរដ្ឋាភិបាល Istana នៃប្រទេសសិង្ហបុរី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម ឡរ៉េន វ៉ុង នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី ក្នុងដំណើរបំពេញទស្សនកិច្ចផ្លូវការរបស់សម្តេចធិបតី ទៅកាន់សាធារណរដ្ឋសិង្ហបុរី។ គម្រោងថ្នាល FTC នេះ ជាហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់បង្កើតកិច្ចព្រមព្រៀងជាមុនរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជានិងសិង្ហបុរី ដើម្បីមានលទ្ធភាពប្រើប្រាស់ទិន្នន័យសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសទាំងពីរក្នុងការវាយតម្លៃឥណទានឱ្យបានប្រសើរជាងមុន សំដៅជំរុញសកម្មភាពពាណិជ្ជកម្ម និងប្រើប្រាស់សេវាហិរញ្ញវត្ថុឆ្លងដែនទ្វេភាគី។



ពិធីប្រកាសដាក់ឱ្យដំណើរការគម្រោងថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុ (Financial Transparency Corridor-FTC) រវាងកម្ពុជា និងសិង្ហបុរី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ នៅវិមានរដ្ឋាភិបាល Istana នៃប្រទេសសិង្ហបុរី

**- ធនាគារកណ្តាលទីម័រខាងកើត៖** ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលទីម័រខាងកើតបានចុះអនុស្សរណៈយោគយល់ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកទេសឱ្យបានកាន់តែរឹងមាំ តាមរយៈការចែករំលែកព័ត៌មាននិងបទពិសោធនិងពង្រឹងសមត្ថភាពរបស់មន្ត្រីជំនាញនៃធនាគារទាំងពីរ។




ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ រវាងធនាគារកណ្តាលទីម័រខាងកើត និងធនាគារជាតិនៃកម្ពុជា នាថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា

**- ធនាគារកណ្តាលហ្វីលីពីន៖** អនុស្សរណៈយោគយល់ស្តីពី ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលហ្វីលីពីន ត្រូវបានចុះហត្ថលេខានៅខេត្តសៀមរាប ក្នុងគោលបំណងពង្រឹងនិងពង្រីកទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការទ្វេភាគីលើផ្នែក៖ i/-ប្រតិបត្តិការធនាគារកណ្តាល ii/-ការតភ្ជាប់និងនវានុវត្តន៍ប្រព័ន្ធទូទាត់ iii/-នវានុវត្តន៍ហិរញ្ញវត្ថុឌីជីថល iv/-ការត្រួតពិនិត្យធនាគារ និង v/-ការអភិវឌ្ឍធនធានមនុស្ស ជាដើម។




ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការរវាងធនាគារកណ្តាលទាំងពីរ នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ នៅខេត្តសៀមរាប

**- ធនាគារជាតិរវ៉ាន់ដា៖** តបតាមការអញ្ជើញរបស់ទេសាភិបាល ធនាគារជាតិរវ៉ាន់ដា ធនាគារជាតិនៃកម្ពុជាបានចូលរួមខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតធនាគារជាតិរវ៉ាន់ដា និងបានធ្វើជាវាគ្មិនក្នុងកិច្ចពិភាក្សាលើប្រធានបទ "ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រកបដោយចីរភាព" ដោយបានចែករំលែកបទពិសោធទាក់ទងនឹងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់បាគង គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចឃ្យូអរកូត (KHQR) និងប្រព័ន្ធទូទាត់ឆ្លងដែន ជាដើម។




ឯកឧត្តម រ័ត្ន សុវណ្ណនរៈ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាលើប្រធានបទ "ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រកបដោយចីរភាព" នាថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៤ នៅទីក្រុងគីហ្គាលី ប្រទេសរវ៉ាន់ដា

**- ធនាគារកណ្តាលឡេសូតូ៖** គណៈប្រតិភូធនាគារកណ្តាលនៃប្រទេសឡេសូតូ បានធ្វើទស្សនកិច្ចសិក្សានៅធនាគារជាតិនៃកម្ពុជា ដើម្បីសិក្សាស្វែងយល់ពីដំណើរនៃការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ដោយផ្តោតលើបច្ចេកវិទ្យា និងក្របខណ្ឌគតិយុត្តក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ និងលំហូរប្រតិបត្តិការដែលជំរុញឱ្យប្រតិបត្តិការទូទាត់អន្តរគ្រឹះស្ថានកាន់តែរីកចម្រើននិងប្រកបដោយបរិយាបន្ន។



ទស្សនកិច្ចសិក្សារបស់គណៈប្រតិភូធនាគារកណ្តាលនៃប្រទេសឡេសូតូ ស្តីពីដំណើរអភិវឌ្ឍន៍ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ចាប់ពីថ្ងៃទី៣០ ខែតុលា ដល់ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ

**- ធនាគារកណ្តាលបេឡារុស៖** ក្រុមប្រឹក្សាភិបាលនៃធនាគារកណ្តាលបេឡារុស បានមកទស្សនកិច្ចនិងពិភាក្សានៅធនាគារជាតិនៃកម្ពុជា ដោយបានស្នើសុំពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមតាមរយៈការអនុវត្តអនុស្សរណៈយោគយល់ក្នុងការផ្លាស់ប្តូរព័ត៌មាននិងទស្សនកិច្ចសិក្សា ដើម្បីចែករំលែកចំណេះដឹង និងពង្រឹងសមត្ថភាពមន្ត្រីជំនាញក្នុងការងារធនាគារកណ្តាល។

**- ធនាគារកណ្តាលវៀតណាម៖** កិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ២០២៤នេះ ត្រូវបានធ្វើឡើងនៅទីក្រុងហាណូយ ប្រទេសវៀតណាម ក្នុងគោលបំណងស្វែងយល់ពីវឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារនៃប្រទេសទាំងពីរ និងការដាក់ចេញទិសដៅក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីនាពេលខាងមុខ។



កិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ធនាគារកណ្តាលវៀតណាម នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅទីក្រុងហាណូយ ប្រទេសវៀតណាម

**- ធនាគារកណ្តាលឥណ្ឌូណេស៊ី៖** ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលឥណ្ឌូណេស៊ី បានចុះអនុស្សរណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងគោលបំណងបង្កើតក្របខណ្ឌ៖ i/-សម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធផ្សេងៗ និង ii/-កិច្ចសហប្រតិបត្តិការអភិវឌ្ឍប្រព័ន្ធទូទាត់ឆ្លងដែននៃប្រទេសទាំងពីរ ដើម្បីលើកកម្ពស់ប្រតិបត្តិការទូទាត់ឆ្លងដែនប្រកបដោយប្រសិទ្ធភាពនិងកាន់តែមានសុវត្ថិភាព ក៏ដូចជាជំរុញនវានុវត្តន៍ហិរញ្ញវត្ថុឌីជីថល។

**- ធនាគារកណ្តាលកូរ៉េ៖** ធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលកូរ៉េបានបន្តកិច្ចសហការស្រាវជ្រាវរួមគ្នា ក្រោមកម្មវិធី "ដៃគូចំណេះដឹង" ដោយក្នុងឆ្នាំ២០២៤នេះ ធនាគារកណ្តាលទាំងពីរបានបញ្ចប់កិច្ចសហការស្រាវជ្រាវរួមគ្នាលើប្រធានបទស្តីពី "ការវាយតម្លៃ និងធ្វើឱ្យប្រសើរឡើងឧបករណ៍គោលនយោបាយម៉ាក្រូប្រុងប្រយ័ត្ន" ជាស្ថាពរនិងដោយជោគជ័យ ព្រមទាំងបានរៀបចំសិក្ខាសាលាដើម្បីចែករំលែកនិងផ្សព្វផ្សាយនូវលទ្ធផលស្រាវជ្រាវ។






លោក ឃួ វុណ្ណី អគ្គនាយកគោលនយោបាយ និងសហប្រតិបត្តិការអន្តរជាតិ បានចូលរួមក្នុងសិក្ខាសាលា ស្តីពី "ការវាយតម្លៃ និងធ្វើឱ្យប្រសើរឡើងឧបករណ៍គោលនយោបាយម៉ាក្រូប្រុងប្រយ័ត្ន" ក្រោមកម្មវិធី "ដៃគូចំណេះដឹង" ជាមួយធនាគារកណ្តាលកូរ៉េ នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤ នៅទីក្រុង Incheon សាធារណរដ្ឋកូរ៉េ

ជារួម កិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីរបស់ធនាគារជាតិនៃកម្ពុជាជាមួយធនាគារកណ្តាល ស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា កាន់តែមានភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងបានតាមរយៈការចុះអនុស្សរណៈយោគយល់ ការផ្លាស់ប្តូរចំណេះដឹងនិងបទពិសោធ ការសិក្សាស្រាវជ្រាវរួមគ្នា ការចូលរួមតាមដាននិងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការអនុវត្តគម្រោងជំនួយបច្ចេកទេសជាដើម។ កិច្ចសហប្រតិបត្តិការនេះបានផ្តល់អត្ថប្រយោជន៍ជាច្រើន ជាពិសេសការលើកកម្ពស់សមត្ថភាពមន្ត្រីជំនាញនិងស្ថាប័នក្នុងការបំពេញតួនាទីជាធនាគារកណ្តាលស្របតាមនិន្នាការនិងការវិវឌ្ឍរីកចម្រើននៃវិស័យហិរញ្ញវត្ថុនិងបច្ចេកវិទ្យាជាសកល ព្រមទាំងបានរួមចំណែកក្នុងការពង្រីកទំនាក់ទំនងនិងការតភ្ជាប់ និងជាពិសេសពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុរបស់កម្ពុជាផងដែរ។

# VIII-ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

## ១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល

**សមាសភាពក្រុមប្រឹក្សាភិបាល**



**លោកជំទាវ ជា សិរី**
អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
ជាប្រធាន



**ឯកឧត្តម ស៊ុំ សន្និសិទ្ធ**
ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា
ជាសមាជិក



**ឯកឧត្តម ហួត ពុំ**
តំណាងប្រមុខរាជរដ្ឋាភិបាល
ជាសមាជិក



**ឯកឧត្តម រស់ សីលវ៉ា**
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ជាសមាជិក



**លោកស្រី អេង នេត្រា**
តំណាងមជ្ឈដ្ឋានឧត្តមសិក្សា
ជាសមាជិក



**លោក ឡាយ ម៉េងស៊ុន**
តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច
ជាសមាជិក



**លោក មុំ ដារ៉ែត**
តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា
ជាសមាជិក

ក្នុងឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានជួបប្រជុំចំនួន ៦លើក មានដូចតទៅ៖

- លើកទី១៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦២ នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២៣ និងសំណើសុំបង្កើតសាខាធនាគារជាតិនៃកម្ពុជាខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ និងខេត្តត្បូងឃ្មុំ។

- លើកទី២៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦៣ នាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០២៣ និងផែនការឆ្នាំ២០២៤ និងសេចក្តីព្រាងគោលនយោបាយវិនិយោគសម្រាប់ការគ្រប់គ្រងទុនបម្រុងវិនិយោគ។

- លើកទី៣៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦៤ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា។

- លើកទី៤៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦៥ នាថ្ងៃទី២ ខែសីហា ឆ្នាំ២០២៤ ដើម្បីពិភាក្សាលើរបាយការណ៍ស្តីពី ស្ថានភាពឥណទានរៀបចំឡើងវិញនិងឥណទានចំពោះវិស័យអចលនទ្រព្យនៅក្នុងប្រព័ន្ធធនាគារកម្ពុជា និងការសម្របសម្រួលចរាចរណ៍ក្រដាសប្រាក់ដុល្លារអាមេរិកជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅខេត្តសៀមរាប។

-លើកទី៥៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦៦ នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងប្រកាសស្តីពីរចនាសម្ព័ន្ធ និងមុខងារ-ភារកិច្ចរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ និងអគ្គបេឡា។

-លើកទី៦៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦៧ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥។

## ២- ការអភិវឌ្ឍធនធានមនុស្ស

ធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា មានការអភិវឌ្ឍនិងរីកចម្រើនជាបន្តបន្ទាប់ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃចំនួនមន្ត្រី-បុគ្គលិកប្រកបដោយគុណវុឌ្ឍិ រចនាសម្ព័ន្ធការងាររឹងមាំ និងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ន ការគ្រប់គ្រងធនធានមនុស្សត្រូវបានអភិវឌ្ឍស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា និងតម្រូវការនៃសមាហរណកម្មនៅក្នុងតំបន់និងពិភពលោក ព្រមទាំងគោលការណ៍នៃស្ថិរភាព និងប្រសិទ្ធភាពការងារ។

### ក- ស្ថិតិមន្ត្រី-បុគ្គលិក

គិតត្រឹមចុងឆ្នាំ២០២៤នេះ មន្ត្រី-បុគ្គលិកក្នុងក្របខណ្ឌធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសមានចំនួន ២.០៣៨រូប (ប្រុស ១.០៣៧រូប ស្រី ១.០០១រូប) ក្នុងនោះទីស្នាក់ការកណ្តាលមានចំនួន ១.៥១៦រូប (ប្រុស ៧៩៨រូប ស្រី៧១៨រូប) និងសាខារាជធានី-ខេត្ត មានចំនួន ៥២២រូប (ប្រុស២៣៩រូប ស្រី២៨៣រូប)។ ក្នុងរយៈពេល មួយឆ្នាំនេះ ក្របខណ្ឌមន្ត្រី-បុគ្គលិកនៅទីស្នាក់ការកណ្តាលបានកើនឡើងចំនួន ១០៣រូប (ចូលថ្មី ១២៤រូប ផ្ទេរចូល ១រូប ផ្ទេរចេញ ២រូប ចូលនិវត្តន៍ ៧រូប លាឈប់ ៧រូប និងមរណភាព ៦រូប) ខណៈនៅសាខាកើនឡើងចំនួន ៧រូប (ចូលថ្មី ១១រូប ផ្ទេរចូល ១រូប ផ្ទេរចេញ ១រូប ចូលនិវត្តន៍ ៣រូប និងបញ្ឈប់ពីការងារ ១រូប)។

## ក្រាហ្វ ៨៧៖ ស្ថិតិមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា តាមកម្រិតវប្បធម៌

(ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ខ- ការងារបណ្តុះបណ្តាល

**- ការងារបណ្តុះបណ្តាលក្នុងប្រទេស**

សមត្ថភាពមន្ត្រី-បុគ្គលិកត្រូវបានបន្តអភិវឌ្ឍជាប្រចាំ តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជា ក៏ដូចជាតាមការអញ្ជើញរបស់ក្រសួង-ស្ថាប័ននានាដែល រួមមានសិក្ខាសាលាចំនួន ៤០លើក (សិក្ខាកាមចូលរួម ១.៧៥០រូប) វគ្គសិក្សា ២៥លើក (សិក្ខាកាម ១.២៥០រូប) និងកិច្ចប្រជុំ ៣៥លើក (មន្ត្រី-បុគ្គលិកចូលរួម ១.១៤០រូប)។ លើសពីនេះ កម្មវិធីចុះកម្ម-សិក្សានៅធនាគារជាតិនៃកម្ពុជាជូនសិស្ស-និស្សិតមកពីបណ្តាគ្រឹះស្ថានឧត្តមសិក្សាក៏ត្រូវបានរៀបចំ ចំនួន ១៥លើក (សិស្ស-និស្សិតចូលរួម ២៣០រូប)។ ក្រៅពីការចូលរួមវគ្គបណ្តុះបណ្តាលផ្ទាល់ដល់ ទីកន្លែង វគ្គសិក្សាតាមប្រព័ន្ធអនឡាញ ក៏ត្រូវបានរៀបចំឡើងចំនួន ៣វគ្គគឺ៖

១/- វគ្គ NBC FSI Connect ជំនាញត្រួតពិនិត្យធនាគារ ក្រោមកម្មវិធីរបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុនៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) មាន ៨ជំនាន់ ដែលមានសិក្ខាកាមចូលរួម សិក្សាសរុប ៣៨១រូប ក្នុងនោះមានសិក្ខាកាមអាហារូបករណ៍មាន ២៥រូប និងបានរៀបចំឱ្យប្រឡង អនឡាញជាផ្លូវការ ដើម្បីវាយតម្លៃគុណភាពសិក្សាជាបន្តបន្ទាប់មកដល់លើកទី៥៤ ដោយមានមន្ត្រី បុគ្គលិកប្រឡងបញ្ចប់កម្រិតបឋមមាន ១២៣រូប កម្រិតមធ្យម ៧១រូប និងកម្រិតខ្ពស់ ១៣៦រូប

២/- កម្មវិធីបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យនិងបទប្បញ្ញត្តិ សម្រាប់មន្ត្រីត្រួតពិនិត្យធនាគារ (SROC) ក្រោមកម្មវិធីរបស់ BIS-IMF មាន ៨ជំនាន់ ដែលមានសិក្ខាកាមសរុប ៣៥រូប ដោយមាន មន្ត្រី-បុគ្គលិកកំពុងសិក្សាចំនួន ៥រូប និង

៣/- កម្មវិធីសិក្សាកម្រិត Micro-Master មានសិក្ខាកាមកំពុងសិក្សាចំនួន ៦រូប។





ការប្រឡងតាមប្រព័ន្ធ Online កម្មវិធីបណ្តុះបណ្តាល NBC-FSI-Connect លើកទី៥៣ នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤

**- ការងារបណ្តុះបណ្តាលក្រៅប្រទេស**

មន្ត្រី-បុគ្គលិកត្រូវបានចាត់បញ្ជូនឱ្យចូលរួម៖ i/-កិច្ចប្រជុំផ្ទាល់និងតាមប្រព័ន្ធអនឡាញចំនួន ១៨២លើក ដោយមានមន្ត្រី-បុគ្គលិកចូលរួម ៥៧៨រូប ii/-វគ្គសិក្សារយៈពេលខ្លីផ្ទាល់និងតាមប្រព័ន្ធអនឡាញ ២០១លើក មានមន្ត្រី-បុគ្គលិកចូលរួម ចំនួន ៨១១រូប និង iii/-វគ្គសិក្សារយៈពេលវែងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មានមន្ត្រី-បុគ្គលិកចូលរួម ២៧រូប។

**- វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ**

បន្ទាប់ពីទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល តាមរយៈអនុក្រឹត្យលេខ ២២៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤ ស្តីពី ការទទួលស្គាល់ការប្រែក្លាយមណ្ឌលសិក្សាបច្ចេកទេសធនាគារទៅជាវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រគ្រោងនឹងចាប់ផ្តើមដំណើរការជាផ្លូវការចាប់ពីឆ្នាំ២០២៥នេះតទៅ។ ទន្ទឹមនេះ វិទ្យាស្ថានបានបង្កើតប្រព័ន្ធអនឡាញសម្រាប់សម្រួលដល់ការចុះឈ្មោះចូលរៀនរបស់និស្សិតឱ្យស្របតាមការអភិវឌ្ឍនៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន។

បច្ចុប្បន្ន និស្សិតកំពុងសិក្សាថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារសរុបចំនួន ២៦៨រូប (ស្រី ១៨៩រូប) ក្នុងនោះនិស្សិតជំនាន់ទី៣២មានចំនួន ១៣៩រូប (ស្រី ៩៧រូប) កំពុងសិក្សាឆ្នាំទី២ ឆមាសទី២ ហើយត្រៀមចុះកម្មសិក្សានៅតាមនាយកដ្ឋានជំនាញរបស់ធនាគារជាតិនៃកម្ពុជា ក្រោយប្រឡងបញ្ចប់ និងជំនាន់ទី៣៣មាន ១២៩រូប (ស្រី ៩២រូប) កំពុងសិក្សាឆ្នាំទី១ ឆមាសទី២។

មន្ត្រី-បុគ្គលិកសរុបមានចំនួន ១១២រូប ក្នុងនោះសាស្ត្រាចារ្យមាន ៦៥រូប (ស្រី ១៣រូប) ដែលសាស្ត្រាចារ្យក្នុងប្រព័ន្ធធនាគារជាតិនៃកម្ពុជាមាន ៥២រូប (ស្រី ៨រូប) និងក្រៅប្រព័ន្ធធនាគារជាតិនៃកម្ពុជាមានចំនួន ១៣រូប (ស្រី ៥រូប)។

**ក្រាហ្វ ៨៨៖ ស្ថិតិសាស្ត្រាចារ្យ**

(ឆ្នាំ២០២៤)





ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទន្ទឹមនេះ វិទ្យាស្ថានបានបន្តសហការជាមួយដៃគូយុទ្ធសាស្ត្រទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិនានា ក្រសួងអប់រំ យុវជន និង កីឡា សាលាមធ្យមវិចិត្រសិល្បៈ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារកណ្ដាល និងអាជ្ញាធររូបិយវត្ថុ និងដៃគូសហការមួយចំនួនទៀត ដើម្បីវាយតម្លៃលក្ខណៈបច្ចេកទេសលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់វិទ្យាស្ថាន ធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សា ផ្លាស់ប្តូរបទពិសោធពាក់ព័ន្ធនឹងការរៀបចំកម្មវិធីសិក្សាបណ្តុះបណ្តាលនិស្សិតនិងការកែទម្រង់កម្មវិធីសិក្សា ក៏ដូចជារៀបចំសិក្ខាសាលានិងកិច្ចប្រជុំនានាសរុបប្រមាណ ៨០ កម្មវិធីដែលមានអ្នកចូលរួមជាង ១៦.៥០០រូប។



ដំណើរទស្សនកិច្ចរបស់ឯកឧត្តម Hélder Lopes ទេសាភិបាល
និងគណៈប្រតិភូធនាគារកណ្ដាលទីម័រខាងកើត
នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤
នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ




ដំណើរទស្សនកិច្ចរបស់ឯកឧត្តម Jacques PELLET
ឯកអគ្គរដ្ឋទូតបារាំង និងគណៈប្រតិភូ នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤
នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ



ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការ
រវាង វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ (IBS)
និងវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (IBF)
នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤



ការទស្សនាទស្សនីយភាពរឿង "ទេពហត្ថា"
ដឹកនាំដោយលោក Xavier de Lauzanne
នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ នាថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៤






ពិធីសម្ពោធជាផ្លូវការនៃការប្រែក្លាយមណ្ឌលសិក្សាបច្ចេកទេសធនាគារ ទៅជា វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ នៃធនាគារជាតិនៃកម្ពុជា នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤

សៀវភៅថ្មីៗពាក់ព័ន្ធនឹងចំណេះដឹងផ្នែកធនាគារ ហិរញ្ញវត្ថុ សេដ្ឋកិច្ច និងប្រវត្តិសាស្ត្រនានា ត្រូវបានបន្តរៀបចំដាក់បញ្ចូលក្នុងបណ្ណាល័យ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវរបស់និស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ។ លើសពីនេះ បណ្ណាល័យអេឡិចត្រូនិក (E-Library) បាននិងកំពុងអភិវឌ្ឍដោយតភ្ជាប់ជាមួយបណ្ណាល័យអេឡិចត្រូនិករបស់ស្ថាប័នអន្តរជាតិ ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងមហាវិទ្យាល័យនានាទាំងក្នុងនិងក្រៅប្រទេស។

ក្រៅពីមុខវិជ្ជាស្នូលវិទ្យាស្ថានក៏បានរៀបចំសកម្មភាពនិងកម្មវិធីសិក្សាបន្ថែម ដូចជាការទស្សនាភាពយន្ត ដំណើរទស្សនកិច្ចសិក្សា ថ្នាក់កីឡាតៃក្វាន់ដូ និងការអានរឿងខ្លីបែបប្រឌិតដោយអ្នកនិពន្ធបរទេស ទាំងជាភាសាអង់គ្លេស និងភាសាខ្មែរផងដែរ។

## ៣- ការងារសវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

សវនកម្មផ្ទៃក្នុង និងអធិការកិច្ចត្រូវបានកំណត់វិសាលភាពស្របតាមការវិវត្តនៃសកម្មភាពការងាររបស់ធនាគារជាតិនៃកម្ពុជា និងត្រូវបានអនុវត្តដោយឯករាជ្យនិងមិនលំអៀង និងមានមុខងារជួយផ្តល់ប្រឹក្សាយោបល់ ដែលជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងការងារអភិបាលកិច្ច ការត្រួតពិនិត្យផ្ទៃក្នុង ការប្រតិបត្តិតាមបទប្បញ្ញត្តិនិងសេចក្តីណែនាំ និងការគ្រប់គ្រងហានិភ័យ ។

នៅក្នុងឆ្នាំ២០២៤ ការងារសវនកម្មផ្ទៃក្នុងត្រូវបានអនុវត្តលើការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ការគ្រប់គ្រងមន្ត្រីបុគ្គលិកនិងបណ្តុះបណ្តាល ការគ្រប់គ្រងសាច់ប្រាក់ និងដំណើរការនៃប្រតិបត្តិការរបស់នាយកដ្ឋាន និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ចំនួន ៩ខេត្ត ដោយបានពិនិត្យនិងវាយតម្លៃទៅលើសកម្មភាពការងារនិងប្រតិបត្តិការ ដែលអាចកើតមានហានិភ័យរួមទាំង ការចុះបញ្ជីប្រតិបត្តិការតាមប្រព័ន្ធធនាគារស្នូល សកម្មភាពវិនិយោគទុនបម្រុងអន្តរជាតិ និងការគ្រប់គ្រងទ្រព្យសកម្ម ជាដើម។ ចំណែកឯ ការងារអធិការកិច្ចត្រូវបានអនុវត្តលើការងារគ្រប់គ្រងសាច់ប្រាក់នៅតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តទាំង១៩ និងការពិនិត្យលើការងារកាត់កម្ទេចនិងដុតបំផ្លាញក្រដាសប្រាក់ចាស់ ទក់ រហែក នៅស្នាក់ការកណ្តាល ដើម្បីធានានូវសុវត្ថិភាពនិងការគ្រប់គ្រងសាច់ប្រាក់ក្នុងឃ្លាំង និងការប្រតិបត្តិតាម ស្របតាមគោលការណ៍ណែនាំ។

លើសពីនេះ ការតាមដានការអនុវត្តតាមអនុសាសន៍នៅនាយកដ្ឋានគ្រប់គ្រងទុនបម្រុង នាយកដ្ឋានបេឡាប្រតិបត្តិការ នាយកដ្ឋានសេវាធនាគារ និងសាខាធនាគារជាតិនៃកម្ពុជាចំនួន ៦ខេត្ត បង្ហាញថា សវនដ្ឋានបានប្រតិបត្តិតាមអនុសាសន៍ ៩០%។ ការអនុវត្តតាមអនុសាសន៍ នឹងជួយពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងបង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ចនៅក្នុងការងារប្រចាំថ្ងៃ ក៏ដូចជា លំហូរប្រតិបត្តិការ នៅធនាគារជាតិនៃកម្ពុជា។



កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងរបាយការណ៍សវនកម្ម
នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤
នៅសាខាធនាគារជាតិនៃកម្ពុជា ខេត្តស្ទឹងត្រែង



កិច្ចប្រជុំការងារអធិការកិច្ច នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៤
នៅសាខាធនាគារជាតិនៃកម្ពុជា ខេត្តព្រះសីហនុ

ជាមួយនឹងការកើនឡើងនៃសកម្មភាពការងារនិងប្រតិបត្តិការ រួមទាំងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់កាន់តែខ្លាំងលើការគ្រប់គ្រងហានិភ័យនៅគ្រប់ផ្នែកទាំងអស់។ ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំផែនការរក្សានិរន្តរភាពធុរកិច្ចសម្រាប់ប្រព័ន្ធធនាគារស្នូលនិងការងារគ្រប់គ្រងទុនបម្រុងអន្តរជាតិ  កំណត់ហានិភ័យសំខាន់ៗនៅគ្រប់អគ្គនាយកដ្ឋាន ជាពិសេសនៅផ្នែកប្រតិបត្តិការ និងពង្រីកការយល់ដឹងអំពីវប្បធម៌ហានិភ័យ ដើម្បីពង្រឹងនិងតាមដានការគ្រប់គ្រងហានិភ័យ។

នៅក្នុងឆ្នាំ២០២៤ គណៈកម្មការគ្រប់គ្រងហានិភ័យនៃប្រព័ន្ធធនាគារស្នូលបានប្រជុំចំនួន៥លើក ដោយបានពិភាក្សាលើបញ្ហាពាក់ព័ន្ធនឹងដំណើរការធ្វើបច្ចុប្បន្នកម្ម និងការដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធធនាគារស្នូល ១៤.៧ និងពិនិត្យលើការរៀបចំផែនការបន្តនិរន្តរភាពធុរកិច្ចរបស់នាយកដ្ឋានគ្រប់គ្រងទុនបម្រុង។



កិច្ចប្រជុំគណៈកម្មការគ្រប់គ្រងហានិភ័យនៃប្រព័ន្ធធនាគារស្នូល លើកទី៦៦
នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា

ក្នុងគោលដៅពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ធនាគារជាតិនៃកម្ពុជាបានអញ្ជើញមន្ត្រីជំនាញធនាគារកណ្តាលម៉ាឡេស៊ីដើម្បីចែករំលែកចំណេះដឹងនិងបទពិសោធលើការគ្រប់គ្រងហានិភ័យស្ថាប័ន និងសវនកម្មផ្ទៃក្នុង ជូនមន្ត្រី-បុគ្គលិកនៃនាយកដ្ឋានពាក់ព័ន្ធ។ ក្នុងក្របខណ្ឌធនាគារកណ្តាលអាស៊ាន មន្ត្រីធនាគារជាតិនៃកម្ពុជាចំនួន ៣រូប បានចូលរួមកិច្ចប្រជុំលើកទី ៩ ថ្នាក់ប្រធានសវនកម្មផ្ទៃក្នុងនៃធនាគារកណ្តាលប្រទេសសមាជិកអាស៊ាន (The 9th ASEAN Central Bank Heads of Internal Audit Network Meeting) ដែលរៀបចំដោយធនាគារកណ្តាលវៀតណាម ចាប់ពីថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០២៤ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។




សិក្ខាសាលា ស្តីពី ការគ្រប់គ្រងហានិភ័យស្ថាប័ន និងសវនកម្មផ្ទៃក្នុង ចាប់ពីថ្ងៃទី៩-១០ ខែមិថុនា ឆ្នាំ២០២៤ នៅវិទ្យាស្ថានបច្ចេកទេសធនាគារ ធនាគារជាតិនៃកម្ពុជា




កិច្ចប្រជុំលើកទី៩ ថ្នាក់ប្រធានសវនកម្មផ្ទៃក្នុងនៃធនាគារកណ្តាលប្រទេសសមាជិកអាស៊ាន ចាប់ពីថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០២៤ នៅទីក្រុងហាណូយ ប្រទេសវៀតណាម

## ៤- សាខាធនាគារជាតិនៃកម្ពុជា

ប្រតិបត្តិការនៅតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តត្រូវបានបន្តពង្រឹង និងពង្រីកជាប្រចាំ សំដៅគ្រប់គ្រងការធ្វើចរាចរសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារឱ្យបានកាន់តែទូលំទូលាយតាមរយៈការផ្តល់សេវា (គ្រប់គ្រងគណនីប្រាក់បញ្ញើ ទទួល-បើកសាច់ប្រាក់ និងសេវាផ្ទេរប្រាក់) ជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រសួងនិងមន្ទីរ-អង្គភាពរបស់រាជរដ្ឋាភិបាលឱ្យកាន់តែមានគុណភាពនិងប្រសិទ្ធភាពខ្ពស់ថែមទៀត។ នៅឆ្នាំ២០២៤នេះ ចំណូលប្រតិបត្តិការជាប្រាក់រៀលសរុបរបស់សាខាមានចំនួន ១១,៣៤ ទ្រីលានរៀល និងជាប្រាក់ដុល្លារអាមេរិកមាន ៦,៤៣ ប៊ីលានដុល្លារអាមេរិក និងចំណាយជាសាច់ប្រាក់ជាប្រាក់រៀល ៨,៨៣ ទ្រីលានរៀល និងជាដុល្លារអាមេរិក ២,៣២ ប៊ីលានដុល្លារអាមេរិក។ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានបន្តចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល និងចូលរួមតាមដានស្ថានភាពសេដ្ឋកិច្ចតាមបណ្តារាជធានី-ខេត្តដូចជា ការប្រែប្រួលថ្លៃទំនិញនិងសេវា អត្រាប្តូរប្រាក់ និងសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗដទៃទៀត ដែលរួមចំណែកក្នុងការតាមដានស្ថានភាពសេដ្ឋកិច្ចជារួម និងការអនុវត្តនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

ទន្ទឹមនេះ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ក៏បានផ្តល់សេវាបង់ប្រាក់ បើកប្រាក់ជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអង្គភាពរដ្ឋ ប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែកជូនសាធារណជនក្នុងគោលបំណងជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយថែមទៀត។

**ក្រាហ្វ ៨៩៖ ស្ថិតិមន្ត្រី-បុគ្គលិកសាខារាជធានី-ខេត្ត**
(ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា



ការប្តូរក្រដាសប្រាក់ចាស់ ទក់ រហែក ជូនសាធារណជន តាមប្រព័ន្ធបាគង នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ នៅផ្សារកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង



ការប្តូរក្រដាសប្រាក់ចាស់ ទក់ រហែក ជូនសាធារណជនតាមប្រព័ន្ធបាគង នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ នៅវិទ្យាល័យជប់វ៉ារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ៥- សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា

គិតត្រឹមចុងឆ្នាំ២០២៤ សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា (ស.ម.ធ) មានសមាជិកសរុប ២.៤៨៣រូប ក្នុងនោះនៅស្នាក់ការកណ្តាលចំនួន ១.៧៨០រូប (និវត្តជន ១៤៣រូប) និងនៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តចំនួន ៧០៣រូប (និវត្តជន ១២២រូប)។

ក្នុងឆ្នាំ២០២៤ គណៈកម្មាធិការ ស.ម.ធ អាណត្តិទី១០ បានប្រជុំចំនួន ៣លើក ដោយបានពិនិត្យនិងពិភាក្សាលើការបែងចែកភារកិច្ចដល់សមាជិកគណៈកម្មាធិការ របាយការណ៍សកម្មភាពការងារក្នុងឆ្នាំ២០២៤ និងការកែសម្រួលប្រការ៧ នៃលក្ខន្តិកៈមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ដើម្បីឱ្យបុគ្គលិកអណ្តែតនិងកិច្ចសន្យាដែលកំពុងបម្រើការងារនៅធនាគារជាតិនៃកម្ពុជាអាចសុំចូលជាសមាជិក ស.ម.ធ។ ទន្ទឹមនេះ ស.ម.ធ បានចេញសេចក្តីសម្រេចទទួលសមាជិកថ្មីចំនួន ២៧៦រូប និងលុបឈ្មោះសមាជិកចំនួន ១២រូប ដែលបានលាឈប់ពីការងារនិងទទួលមរណភាព។ អនុលោមតាមគោលការណ៍ ស.ម.ធ បានប្រើប្រាស់ថវិកាឧបត្ថម្ភជូនសមាជិកនិងសហព័ទ្ធសមាជិកចំនួន ១៩៥ ករណី ក្នុងនោះ សមាជិកនិងសហព័ទ្ធសមាជិកសម្រាលកូនចំនួន ១១០រូប គ្រោះថ្នាក់ ១៨រូប ជំងឺធ្ងន់ធ្ងរ ៦២រូប និង មរណភាព ៩រូប។ លើសពីនេះ ស.ម.ធ ក៏បានចុះសួរសុខទុក្ខសមាជិកមានជំងឺនិងគ្រោះថ្នាក់ដល់គេហដ្ឋាននិងមន្ទីរពេទ្យ និងចូលរួមពិធីបុណ្យសពសមាជិកនិងសហព័ទ្ធសមាជិកផងដែរ។

**ក្រាហ្វ ៩០៖ ចំណាយឧបត្ថម្ភរបស់ ស.ម.ធ**

(ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា



កិច្ចប្រជុំគណៈកម្មាធិការ ស.ម.ធ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍ការងារ
នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ

## ៦- សារមន្ទីរព្រះស្រីវល្លសានវរ្ម័ន

ភ្ញៀវដែលអញ្ជើញមកទស្សនាសារមន្ទីរព្រះស្រីវល្លសានវរ្ម័ន (ស.ស.រ.) មានចំនួនជាង ១០០.០០០នាក់ គិតចាប់ពីថ្ងៃបើកសម្ពោធសារមន្ទីរ នាថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ដល់បច្ចុប្បន្ន ហើយក្នុងនោះ មានប្រមាណ ៨៥% ជាភ្ញៀវជនជាតិខ្មែរ។ ដោយឡែកនៅឆ្នាំ២០២៤ ចំនួនភ្ញៀវចូលទស្សនាបានកើនឡើងគួរឱ្យកត់សម្គាល់ដល់ ៤៩.០០០នាក់ ធៀបនឹង ៣៦.៩៧៦នាក់ នៅឆ្នាំ២០២៣។ ដើម្បីចូលរួមផ្សព្វផ្សាយពីប្រវត្តិសាស្ត្រកម្ពុជា សារមន្ទីរបានរៀបចំ និងសម្ពោធពិព័រណ៍ចំនួន ៤ រួមមាន៖ i/- ពិព័រណ៍អចិន្ត្រៃយ៍សាលទី៥និងទី៦ឡើងវិញ អំពីសម័យឯករាជ្យ សម័យសាធារណរដ្ឋខ្មែរ និងសម័យ ប៉ុល ពត នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤ ii/- ពិព័រណ៍មិនអចិន្ត្រៃយ៍ក្រោមប្រធានបទ "ពណ៌ពីអតីតកាល៖ ទិដ្ឋភាពប្រទេសកម្ពុជាក្នុងគំនូរតាមវត្តអារាម (១៨៩០-១៩៧០)" នាថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ ដែលមានអ្នកចូលទស្សនាប្រមាណ ១៦.៨០០នាក់ និង iii/- សហការរៀបចំពិព័រណ៍ជាមួយសម្ព័ន្ធគំនូរពណ៌ទឹកកម្ពុជា រយៈពេល ៥ថ្ងៃ ចាប់ពីថ្ងៃទី៦-១០ ខែវិច្ឆិកា ឆ្នាំ២០២៤ និង iv/- ពិព័រណ៍រូបថតសម័យសង្គ្រាមជាមួយមូលនិធិសមាគមរូបថតភ្នំពេញក្នុងកម្មវិធីមហោស្រពរូបថតភ្នំពេញ។

សារមន្ទីរបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ជាមួយសមាគមធនាគារនៅកម្ពុជា និងក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ខេមបូឌា ដើម្បីឧបត្ថម្ភដល់ទស្សនកិច្ចរបស់សិស្សនៃគ្រឹះស្ថានសិក្សារដ្ឋ។ ជាលទ្ធផល ចំនួនសិស្សមកពីគ្រឹះស្ថានសិក្សារដ្ឋបានមកទស្សនាសារមន្ទីរមានការកើនឡើងជាលំដាប់ រហូតដល់ជិត ៩.៣០០នាក់។



កម្មវិធីសម្ពោធសាលពិព័រណ៌មិនអចិន្ត្រៃយ៍នៃសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីល្បសានវរ្ម័ន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចក្រុមព្រះ នរោត្តម ច័ក្រពង្ស ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤



សកម្មភាពសិស្សានុសិស្សចូលទស្សនា សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីល្បសានវរ្ម័ន





សកម្មភាពសិស្សានុសិស្សមកពីខេត្តកំពង់ធំចូលទស្សនានៅសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីល្បសានវរ្ម័ន

**ក្រាហ្វ ៩១៖ ចំនួនភ្ញៀវទស្សនាសរុប**

(ឆ្នាំ២០១៩ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្នុងឆ្នាំ២០២៤នេះ សារមន្ទីរ ស.ស.រ. បាត់ដំបងបានបន្តរៀបចំ និងបញ្ចប់ការដ្ឋានជួសជុល និងសំណង់។ សម្រាប់ឆ្នាំ២០២៥ខាងមុខ គម្រោងនេះនឹងបន្តការងារផលិត និងដំឡើងពិព័រណ៍អចិន្ត្រៃយ៍នៃសារមន្ទីរ។



អគារសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ខេត្តបាត់ដំបង





លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញពិនិត្យការដ្ឋានសារមន្ទីរ ស.ស.រ. បាត់ដំបង
នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤

ជារួម ការបន្តអភិវឌ្ឍធនធានមនុស្ស និងអភិបាលកិច្ច គឺជាការងារអាទិភាពសម្រាប់ធនាគារជាតិនៃកម្ពុជា ដែលបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃចំនួន និងសមត្ថភាពរបស់មន្ត្រី-បុគ្គលិក។ ការងារសវនកម្ម និងអធិការកិច្ចត្រូវបានបន្តយកចិត្តទុកដាក់ ដើម្បីធានាបាននូវ អភិបាលកិច្ចល្អ។ លើសពីនេះ វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ បានបន្តដើរតួនាទីជាគ្រឹះស្ថានអប់រំដ៏សំខាន់សម្រាប់ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។

## IX- ទំនាក់ទំនងសាធារណៈ

### ១- ការទំនាក់ទំនង

ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់លើការងារអភិវឌ្ឍទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ បណ្តាញសារព័ត៌មាន និងសាធារណជនតាមរយៈបណ្តាញសង្គម និងបណ្តាញទំនាក់ទំនងផ្សេងៗសំដៅផ្សព្វផ្សាយអំពីសកម្មភាពសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តនយោបាយរូបិយវត្ថុ និងការងារពាក់ព័ន្ធនឹងធនាគារជាតិនៃកម្ពុជា ក៏ដូចជាវិស័យនានានៅកម្ពុជា។ បណ្តាញសង្គមផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា មានដូចជាហ្វេសប៊ុក Linkedin Instagram X និង Tiktok បានផ្សព្វផ្សាយមាតិកាចំនួន ៣៨៥ ដែលមានចំនួនទស្សនាសរុប ៧,៤ លាន។ គិតត្រឹមចុងឆ្នាំ២០២៤ បណ្តាញសង្គមផ្លូវការធនាគារជាតិនៃកម្ពុជាមានអ្នកតាមដានសរុបចំនួន ៣៦២.៣០០ គណនី កើនឡើង ៣៣.០០០ គណនី ធៀបនឹងគ្រាដូចគ្នាឆ្នាំ២០២៣។ សារទទួលបាននិងឆ្លើយតបទៅសាធារណជនមាន ១.០៧៨ និងបានសម្របសម្រួលជាមួយបណ្តាញសារព័ត៌មានថ្នាក់ជាតិ និងអន្តរជាតិតាមរយៈអ៊ីម៉ែលសម្រាប់បទសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ និងការចេញផ្សាយអត្ថបទដែលទាក់ទងនឹងធនាគារជាតិនៃកម្ពុជា។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាតែងតែធ្វើការផ្សព្វផ្សាយឱ្យសាធារណជនបានយល់ដឹងនិងបង្កើនការប្រុងប្រយ័ត្នខ្ពស់ចំពោះល្បិចកលឆបោករបស់ជនទុច្ចរិតមួយចំនួនដែលបានបង្កើតឆាណែល ឬគណនីតេលេក្រាម (Telegram) ដោយក្លែងបន្លំប្រើឈ្មោះនិងនិមិត្តសញ្ញារបស់ធនាគារជាតិនៃកម្ពុជា ក្រសួង-ស្ថាប័នសាធារណៈ ក៏ដូចជារូបភាពរបស់ថ្នាក់ដឹកនាំ ដើម្បីផ្សព្វផ្សាយទាក់ទាញសាធារណជនឱ្យចូលរួមក្នុងគម្រោងវិនិយោគ ឬប្រតិបត្តិការជួញដូរផលិត-ផលហិរញ្ញវត្ថុក្រៅផ្លូវការ ដូចជា ហាងឆេងមាស អត្រាប្តូរប្រាក់ ឬទ្រព្យឌីជីថល ជាដើម ដែលនាំឱ្យមានការខាតបង់ប្រាក់កាស និងទ្រព្យសម្បត្តិផ្សេងៗផងដែរ។ ជាមួយគ្នានេះ សន្និសីទសារព័ត៌មានក៏ត្រូវបានរៀបចំចំនួន ៦លើក ដើម្បីបញ្ជ្រាបការយល់ដឹងរបស់សាធារណជនឱ្យបានកាន់តែទូលំទូលាយទៅលើប្រធានបទដូចជា៖ i/- សមិទ្ធផលការងារប្រចាំឆមាសទី១ និងការបកស្រាយពីខ្លឹមសារបច្ចេកទេសផ្នែកសេដ្ឋកិច្ចនិងប្រព័ន្ធធនាគារ ii/- ដំណើរការកម្មវិធីបាគងទេសចរ iii/- ការបិទ/បើកគណនីជាប្រាក់រៀលជូនដល់អតិថិជនរបស់គ្រឹះស្ថានហិរញ្ញវត្ថុ iv/- ការរៀបចំឥណទានឡើងវិញ v/- ឥណទានក្រៅផ្លូវការ និង vi/- រូបិយប័ណ្ណគ្រីបតូ។







លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ក្នុងសន្និសីទសារព័ត៌មានស្តីពីដំណើរការប្រព័ន្ធបាគងទេសចរ (Bakong Tourists App) នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ នៅភោជនីយដ្ឋាន Seri Garden

លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ក្នុងសន្និសីទសារព័ត៌មានស្តីពី ការបិទ/បើកគណនីជាប្រាក់រៀលជូនដល់អតិថិជនរបស់គ្រឹះស្ថានហិរញ្ញវត្ថុ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ នៅភោជនីយដ្ឋាន Seri Garden



លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អមដោយប្រធានសមាគមធនាគារនៅកម្ពុជា ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងភាគីពាក់ព័ន្ធ ក្នុងសន្និសីទសារព័ត៌មានពន្យល់ពីខ្លឹមសារបច្ចេកទេសស្តីពីការរៀបចំឥណទានឡើងវិញ និងហានិភ័យនៃកម្ចីក្រៅផ្លូវការ នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤ នៅសណ្ឋាគារ ហៃយ៉ាត់ រីជិន ស៊ី ភ្នំពេញ

## ២- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជាបន្តយកចិត្តទុកដាក់ក្នុងការជំរុញកម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ដើម្បីលើកកម្ពស់ការទទួលបាននិងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការទាន់ពេលវេលា តម្លៃសមរម្យ និងមានកិច្ចការពារតាមផ្លូវច្បាប់ តាមរយៈការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការពង្រឹងកិច្ចការពារអតិថិជន។ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នរដ្ឋ និងដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិពាក់ព័ន្ធនានា ក្នុងការដាក់ចេញនិងអនុវត្តនូវសកម្មភាពយុទ្ធនាការផ្សព្វផ្សាយ កម្មវិធីអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងយន្តការនានា ស្របតាមផែនការសកម្មភាពដែលកំណត់ក្នុងយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។

### - ការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ

គម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០១៧មក។ ជាលទ្ធផល ការងារបញ្ជ្រាបចំណេះដឹងដំណាក់កាលទី១ និងដំណាក់កាលទី២ត្រូវបានបញ្ចប់ជាស្ថាពរ ហើយគម្រោងសម្រាប់ដំណាក់កាលទី៣ក៏បាននិងកំពុងអនុវត្ត ដែលក្នុងនោះរួមមានផែនការដូចជា៖ i/-ការរៀបចំសៀវភៅសម្រាប់សិស្សថ្នាក់ទី៧ ដល់ទី១១ លើមុខវិជ្ជា គណិតវិទ្យា និងសីលធម៌-ពលរដ្ឋវិជ្ជា ii/-ការរៀបចំសៀវភៅណែនាំសម្រាប់គ្រូថ្នាក់ទី៧ ដល់ទី១១ លើមុខវិជ្ជា គណិតវិទ្យា និងសីលធម៌-ពលរដ្ឋវិជ្ជាសម្រាប់ជាឯកសារជំនួយស្មារតីដល់គ្រូក្នុងការបង្រៀនសិស្ស iii/-ការរៀបចំសៀវភៅលំហាត់សម្រាប់សិស្ស ដើម្បីសិស្សអាចស្វ័យសិក្សា និងបង្កើនចំណេះដឹង ក្រៅម៉ោងសិក្សាគោល iv/-ការរៀបចំវីដេអូណែនាំសម្រាប់សិស្សដែលរៀនមិនទាន់ ឬខកខានមិនបានមក v/-ការបង្រៀនសាកល្បងលើឯកសារនិងសម្ភារៈសិក្សាដែលបានរៀបចំ នៅសាលារៀនគោលដៅចំនួន ១០ និង vi/-ការវាយតម្លៃនៅពេលបញ្ចប់ឆ្នាំសិក្សា ដែលការវាយតម្លៃនេះត្រូវតែស្របតាមការធ្វើតេស្តស្តង់ដា។



កិច្ចប្រជុំស្តីពី វឌ្ឍនភាពការងារបញ្ជ្រាបចំណេះដឹងហិរញ្ញវត្ថុក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ ដំណាក់កាលទី៣
នាថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ

### - ការងារលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រីនិងសហគ្រិនភាពស្ត្រី

ធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី បានបន្តរួមគ្នាអនុវត្តការងារលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី ដោយបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពី "ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី" ក្នុងគោលបំណងបង្កើតក្របខណ្ឌកិច្ចសហប្រតិបត្តិការ ដែលមានរយៈពេលអនុវត្ត ៥ ឆ្នាំ សំដៅលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រីតាមរយៈការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងហិរញ្ញវត្ថុឌីជីថល ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច និងការពង្រីកភាពជាដៃគូក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី។ អនុស្សរណៈយោគយល់នេះក៏នឹងអនុញ្ញាតឱ្យភាគីទាំងពីរ បន្តរួមគ្នាសម្រេចនូវគោលដៅកំណត់ក្នុងយុទ្ធសាស្រ្តជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ និងយុទ្ធសាស្រ្តនារីរតនៈទី៦ ឆ្នាំ២០២៤-២០២៨ ផងដែរ។

- **យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ!និយាយពីលុយៈតក់ៗពេញបំពង់"**

ក្នុងដំណាក់កាលទី២ ជំហានទី២ យុទ្ធនាការ "តោះ! និយាយពីលុយៈ តក់ៗពេញបំពង់" ដែលជាកិច្ចសហការរវាងធនាគារជាតិនៃកម្ពុជា និងអង្គការ Good Return ត្រូវបានរៀបចំជាកម្រង រឿងអប់រំខ្លីពាក់ព័ន្ធនឹងចំណេះដឹងក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ក្រោមខ្លឹមសារអប់រំទាក់ទងនឹង លក្ខខណ្ឌនៃកិច្ចសន្យាឥណទានក្នុងការបង់ផ្ដាច់ឥណទានមុនកាលកំណត់ និងហានិភ័យនៃ ការប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ។ ជាមួយគ្នានេះ កូនសៀវភៅ (Comic Book) ដែលមាន ចំណងជើងថា "គិតមុនគូរ" និង "គួរពិចារណា" ក៏ត្រូវបានរៀបចំរួចរាល់និងកំពុងធ្វើតេស្តសាកល្បង ជាមួយសាធារណជនទូទៅ ដើម្បីទទួលបានមតិយោបល់ និងកែសម្រួល មុននឹងផ្សព្វផ្សាយជា សាធារណៈ។ លើសពីនេះ វគ្គបណ្តុះបណ្តាលសម្រាប់កម្មករ-កម្មការិនីរោងចក្រក៏ត្រូវបានរៀបចំឡើង នៅតាមបណ្តារាជធានី-ខេត្តចំនួន១៦លើក និងមានកម្មករ-កម្មការនីចូលរួមសរុបប្រមាណ ១.០០០ នាក់ ដោយមានគ្រូបង្គោលមកពីសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (CWPD) ដើម្បីផ្សព្វផ្សាយលើប្រធានបទ៖ i/- ការលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុឌីជីថល លើការការពារ ព័ត៌មានផ្ទាល់ខ្លួនក្នុងការប្រើប្រាស់សេវាឌីជីថលនិងការប្រើប្រាស់កម្មវិធីទូរស័ព្ទ "បញ្ជីលុយខ្ញុំ"សម្រាប់ គ្រប់គ្រង និងកត់ត្រារាល់ចំណូល-ចំណាយ ii/- ការសន្សំ iii/- ការជំរុញការពិភាក្សា និងសម្រេចចិត្ត ផ្នែកហិរញ្ញវត្ថុរវាងបុរសនិងស្ត្រីនៅក្នុងគ្រួសារ និង iv/- ការលើកកម្ពស់ចំណេះដឹងនិងទំនុកចិត្ត មកលើសេវាហិរញ្ញវត្ថុផ្លូវការ ជាដើម។

- **គម្រោងការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍**

ក្រោមកិច្ចសហការពីសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សមាគមធនាគារនៅកម្ពុជា អង្គការ CFRISE+SPTF អង្គការ ADA និង ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធី គម្រោង "ការពង្រឹង សុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍" ត្រូវបានរៀបចំឡើងក្នុងគោលដៅពង្រឹងសុវត្ថិភាពក្នុងការប្រើប្រាស់ សេវាហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ និងជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការនៅតាមសហគមន៍ ដែលស្របតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងដំណាក់កាល ដំបូង គម្រោងនេះត្រូវបានអនុវត្តចំពោះឃុំចំនួន ៤ គឺ ឃុំត្បូងក្រពើក្នុងស្រុកសន្ទុកនៃខេត្តកំពង់ធំ ឃុំស្នំក្រពើក្នុងស្រុកគងពិសីនៃខេត្តកំពង់ស្ពឺ ឃុំពោធិរាជក្នុងស្រុកស្វាយជ្រំនៃខេត្តស្វាយរៀង និង ឃុំវត្តតាមិមក្នុងស្រុកសង្កែនៃខេត្តបាត់ដំបង ដោយផ្តោតសំខាន់លើការលើកកម្ពស់ចំណេះដឹងផ្នែក ហិរញ្ញវត្ថុ បង្កើនភាពអង់អាចរបស់អ្នកប្រើប្រាស់ និងពង្រឹងកិច្ចការពារអតិថិជន។ សមិទ្ធផលជាច្រើន ដែលសម្រេចបានមានដូចជា៖ i/-ការជ្រើសរើសជនបង្គោលនិងអ្នកសម្របសម្រួលតាមសហគមន៍ ii/-ការរៀបចំសៀវភៅមេរៀនសម្រាប់ការបណ្តុះបណ្តាលមានចំនួន ៥ មេរៀន iii/-ការរៀបចំវគ្គបណ្តុះ-បណ្តាលជូនជនបង្គោល និងអ្នកសម្របសម្រួលតាមសហគមន៍ iv/-ការរៀបចំនិងបោះពុម្ពខិត្តប័ណ្ណ ស្តីពី យន្តការបណ្តឹងតវ៉ាសម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុ ហើយបានផ្សព្វផ្សាយនៅតាមសហគមន៍ ឃុំគោលដៅ v/-ការរៀបចំនិងបោះពុម្ពផ្ទាំងបញ្ជីឈ្មោះ និងលក្ខណៈផលិតផលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្លូវការ ដែលមានប្រតិបត្តិការក្នុងឃុំគោលដៅនីមួយៗ ព្រមទាំងបានបិទផ្សព្វផ្សាយនៅ តាមសាលាឃុំ និងច្រកចេញ-ចូលតែមួយរបស់ឃុំ និង vi/-ការរៀបចំវគ្គបណ្តុះបណ្តាលបន្តដោយ ជនបង្គោលនិងអ្នកសម្របសម្រួលតាមសហគមន៍នៅតាមឃុំគោលដៅនីមួយៗ។




សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយលទ្ធផលគម្រោងការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍"
នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ

### - សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា"

សិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ត្រូវបានបន្តរៀបចំនៅតាមបណ្តាខេត្ត និងក្រុង/ស្រុកនានា សរុបចំនួន ៥ លើក ដែលក្នុងនោះសិក្ខាសាលាថ្នាក់ខេត្តមាន ២ លើក និងថ្នាក់ស្រុក ៣ លើក ដោយមានអ្នកចូលរួមសរុបប្រមាណ ១.៥០០ នាក់។ សិក្ខាសាលាទាំងនេះមានគោលបំណងពង្រឹងចំណេះដឹងពាក់ព័ន្ធនឹងវិស័យធនាគារនិងហិរញ្ញវត្ថុ ជូនដល់អាជ្ញាធរមូលដ្ឋានក្នុងគោលដៅលើកកម្ពស់ការយល់ដឹងក្នុងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុនៅតាមតំបន់មូលដ្ឋាន ព្រមទាំងការរីកចម្រើននៃវិស័យធនាគារនិងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ស្ថិរភាព តម្លាភាព និងកិច្ចការពារអត្ថប្រយោជន៍សម្រាប់អ្នកប្រើប្រាស់។ បន្ថែមពីនេះ ក្នុងបរិការណ៍នៃការស្តារសេដ្ឋកិច្ច សិក្ខាសាលាទាំងនេះបានផ្តល់ជាវេទិកាសាធារណ: សម្រាប់អាជ្ញាធរមូលដ្ឋាននិងប្រជាពលរដ្ឋអាចលើកឡើងនូវសំណូមពរ និងបញ្ហាប្រឈមនានាដែលបាននិងកំពុងជួបប្រទះពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ព្រមទាំងផ្តល់ឱកាសដល់ធនាគារជាតិនៃកម្ពុជា ផ្សព្វផ្សាយពីវិធានការនានាដែលបានដាក់ចេញ ដើម្បីសម្រួលដល់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុដែលកំពុងរងផលប៉ះពាល់នៃការធ្លាក់ចុះនៃប្រាក់ចំណូលផងដែរ។ ជាលទ្ធផល ធនាគារជាតិនៃកម្ពុជា ក៏បានប្រមូលជាធាតុចូលសំខាន់ៗជាច្រើនដែលជាប្រយោជន៍សម្រាប់បន្តអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ ជំរុញបរិយាបន្នហិរញ្ញវត្ថុ លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងពង្រឹងកិច្ចការពារអតិថិជន។




សិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា"
នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ នៅខេត្តឧត្តរមានជ័យ

## ៣- កិច្ចសហការជាមួយសមាគម និងស្ថាប័នផ្សេងៗក្នុងការងារផ្សព្វផ្សាយ

សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា នៅតែបន្តចូលរួមចំណែកជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការជំរុញកម្រិតបរិយាបន្នហិរញ្ញវត្ថុ លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងពង្រឹងកិច្ចការពារអតិថិជន ដើម្បីបង្កើនការយល់ដឹង ការទទួលបាន និងការប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព បរិយាបន្នហិរញ្ញវត្ថុ និងចីរភាព តាមរយៈការរៀបចំសិក្ខាសាលា យុទ្ធនាការ និងកម្មវិធីផ្សព្វផ្សាយនានារបស់សមាគមទាំងពីរ និងគ្រឹះស្ថាន។ បន្ទាប់ពីបានចេញសេចក្តីថ្លែងការណ៍រួមកាលពីឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ បន្តសហការបង្ក្រាបសកម្មភាពផ្សព្វផ្សាយនិងផ្តល់ឥណទានដោយខុសច្បាប់ សំដៅចូលរួមទប់ស្កាត់បទល្មើសនានាឱ្យទាន់ពេលវេលា ដែលអាចបង្កហានិភ័យចំពោះគ្រឹះស្ថាន អតិថិជន និងវិស័យធនាគារទាំងមូលផងដែរ។





សកម្មភាពឆបោក ផ្សព្វផ្សាយនិងផ្តល់ឥណទានដោយខុសច្បាប់

## ៤- ការផ្សព្វផ្សាយប្រព័ន្ធបាគង

ដើម្បីបង្កើនការប្រើប្រាស់ប្រព័ន្ធបាគងឱ្យកាន់តែទូលំទូលាយថែមទៀត ក្នុងឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបាន i/-ផលិតវីដេអូចំនួន ១៥ និងផ្សព្វផ្សាយជាសាធារណៈជាប្រចាំលើគេហទំព័រហ្វេសប៊ុកផ្លូវការរបស់ "បាគង" ដើម្បីលើកកម្ពស់ចំណេះដឹងទូទៅ អត្ថប្រយោជន៍ និងការប្រើប្រាស់ប្រព័ន្ធបាគង និង KHQR ដោយមានចំនួនទស្សនាសរុបជាង ១.៥០០.០០០ ដង។ វីដេអូទាំងនេះបង្ហាញពីរបៀបប្រើប្រាស់ និងអត្ថប្រយោជន៍នៃប្រព័ន្ធបាគង និង KHQR ក្នុងជីវិតប្រចាំថ្ងៃ ស្របតាមគោលដៅលើកកម្ពស់ការទូទាត់តាមឌីជីថល ដែលអាចជួយកាត់បន្ថយការពឹងផ្អែកលើសាច់ប្រាក់ និងជួយជំរុញកំណើនសេដ្ឋកិច្ច។ ii/-រៀបចំកម្មវិធីប្រកួតវីដេអូលើកកម្ពស់ការប្រើប្រាស់បាគង KHQR និងបញ្ជ្រាបចំណេះដឹងហិរញ្ញវត្ថុ ដោយទទួលបានវីដេអូប្រកួតប្រជែងចំនួន ៩៩ ពីបេក្ខជន-បេក្ខនារីដែលជាអ្នកមានឥទ្ធិពលលើបណ្តាញសង្គម (Influencers) និងអ្នកផលិតមាតិកាលើបណ្តាញសង្គមតិកតុក (TikTok) ព្រមទាំងទទួលបានចំនួនទស្សនាសរុបជាង ៥.០០០.០០០ ដង។ កម្មវិធីប្រកួតប្រជែងមានគោលបំណងបង្កើនការយល់ដឹង ក្នុងចំណោម

យូអរកូដ សម្រាប់ស្កេនចូលទៅទស្សនាវីដេអូផ្សព្វផ្សាយរបស់ "បាគង"

សាធារណៈជនឱ្យកាន់តែទូលំទូលាយ ទាក់ទងនឹងការប្រើប្រាស់ មុខងារ និងអត្ថប្រយោជន៍នៃប្រព័ន្ធបាគង និង KHQR ឈានទៅជំរុញការប្រើប្រាស់នូវប្រព័ន្ធបាគង និង KHQR សម្រាប់បុគ្គល និងអាជីវកម្ម។ កម្មវិធីនេះក៏បានលើកកម្ពស់នវានុវត្តន៍ និងគំនិតច្នៃប្រឌិតថ្មីពីសាធារណជន និងលើកកម្ពស់មុខមាត់ និងកេរ្តិ៍ឈ្មោះរបស់ធនាគារជាតិនៃកម្ពុជា និងកសាងទំនុកចិត្តលើប្រព័ន្ធធនាគារបន្ថែមមួយកម្រិតទៀតផងដែរ។ iii/- បានរៀបចំកម្មវិធីផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹងបាគង KHQR និងចំណេះដឹងហិរញ្ញវត្ថុ នៅតាមគ្រឹះស្ថានឧត្តមសិក្សា និងមធ្យមសិក្សាក្នុងរាជធានីភ្នំពេញចំនួនសរុប ៨ គ្រឹះស្ថានសិក្សា ដោយមានអ្នកចូលរួមសរុបជាង ២.០០០នាក់។

## ៥- ការផ្សព្វផ្សាយពីសារៈសំខាន់នៃប្រាក់រៀល

យុទ្ធនាការផ្សព្វផ្សាយជាសាធារណៈស្ដីពី "ប្រាក់រៀល និងប្រព័ន្ធបាគង" ត្រូវបានរៀបចំនៅរាជធានី-ខេត្តចំនួន ៧ រួមមាន៖ រាជធានីភ្នំពេញ ស្វាយរៀង ព្រៃវែង បន្ទាយមានជ័យ សៀមរាប មណ្ឌលគិរី និងរតនគិរី ដោយមានពិព័រណ៍ស្ដីពីប្រវត្តិរូបិយវត្ថុកម្ពុជា កម្មវិធីប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែក យកក្រដាសប្រាក់រៀលថ្មី កម្មវិធីតាំងបង្ហាញប្រព័ន្ធទូទាត់បាគង កម្មវិធីប្រកួតប្រជែងផលិតមាតិកាវីដេអូខ្លីក្រោមប្រធានបទ "តើប្រាក់ ១០.០០០រៀលអាចទិញអ្វីបានខ្លះ?" និងកម្មវិធីប្រកួតប្រជែងធ្វើបទបង្ហាញជាច្រើនទៀតអំពីសារៈសំខាន់នៃប្រាក់រៀល។ កម្មវិធីនេះមានអ្នកចូលរួមទស្សនាដោយផ្ទាល់ប្រមាណ ២៦ ពាន់នាក់ និងតាមបណ្ដាញសង្គមជាង ៨០ ពាន់នាក់។ នាឱកាសនោះសាធារណជនក៏បានយកក្រដាសប្រាក់រៀល ចាស់ ទក់ រហែក មកប្តូរក្រដាសប្រាក់ថ្មីដោយឥតគិតថ្លៃសរុបជិត ២,៤ ប៊ីលានរៀល។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានផ្សព្វផ្សាយនូវអត្ថបទដែលមានខ្លឹមសារ ពាក់ព័ន្ធនឹងសារៈសំខាន់នៃប្រាក់រៀល នៅតាមសារព័ត៌មាននានាផងដែរ។ គួររំលេចថាតាមរយៈកម្មវិធីប្រកួតប្រជែងផលិតវីដេអូ "តើប្រាក់ ១០.០០០រៀល អាចទិញអ្វីបានខ្លះ?" ត្រូវបានសង្កេតឃើញថាផ្តល់អត្ថប្រយោជន៍បន្ថែមដូចជា៖ i/-បង្កើនវិសាលភាពក្នុងការផ្សព្វផ្សាយពីប្រាក់រៀលបានកាន់តែទូលំទូលាយ ដោយបានទាក់ទាញវីដេអូប្រកួតប្រជែងចំនួន ១៣០ វីដេអូ និងចំនួនចូលទស្សនាសរុបជាង ២,៥ លានដង និង ii/-បំផុសគំនិតសាធារណជនជាពិសេសយុវជនឱ្យយល់ដឹងបន្ថែមទៀតពីសារៈសំខាន់នៃការប្រើប្រាស់ប្រាក់រៀលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ព្រមទាំង ស្ថានភាពអតិផរណា និងអំណាចទិញរបស់ប្រាក់រៀល ជាដើម។

សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ដំណើរឆ្ពោះទៅមុខនៃប្រាក់រៀល និងប្រព័ន្ធបាគង" ត្រូវបានរៀបចំនៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ ក្នុងឱកាសអបអរសាទរខួបលើកទី៤៤ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ដោយមានការចូលរួមដោយផ្ទាល់ពីថ្នាក់ដឹកនាំជាតំណាងមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងនិស្សិតប្រមាណ ៤៥០នាក់ ព្រមទាំងមានអ្នកចូលទស្សនាតាមទំព័រហ្វេសប៊ុកផ្លូវការប្រមាណ ៥១ ពាន់នាក់។ ទន្ទឹមនេះ ដើម្បីជំរុញ និងលើកទឹកចិត្តសាធារណជនឱ្យប្រើប្រាស់ប្រាក់រៀលកាន់តែច្រើន និងទូលំទូលាយ យុទ្ធនាការប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែកត្រូវបានបន្តអនុវត្តនៅតាមបណ្ដាខេត្តទូទាំងប្រទេស។




សិក្ខាសាលាស្តីពី "ដំណើរឆ្ពោះទៅមុខនៃប្រាក់រៀល និងប្រព័ន្ធបាគង"
ក្នុងឱកាសអបអរសាទរខួបលើកទី៤៤ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ
នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ រាជធានីភ្នំពេញ




យុទ្ធនាការផ្សព្វផ្សាយជាសាធារណៈស្តីពី "ប្រាក់រៀល និងប្រព័ន្ធបាគង"
នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៤ នៅផ្សារទំនើបខេម៉ល វេងស្រេង




កម្មវិធីផ្សព្វផ្សាយ ស្តីពី "ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ"
នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤ នៅខេត្តស្វាយរៀង




កម្មវិធីផ្សព្វផ្សាយ ស្តីពី "ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ"
នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ នៅខេត្តព្រៃវែង




កម្មវិធីផ្សព្វផ្សាយ ស្តីពី "ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ"
នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅខេត្តបន្ទាយមានជ័យ




កម្មវិធីផ្សព្វផ្សាយ ស្តីពី "ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ"
នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤ នៅខេត្តរតនគិរី




កម្មវិធីផ្សព្វផ្សាយ ស្តីពី "ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ"
នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ នៅខេត្តមណ្ឌលគិរី

## ៦- ការចូលរួមជាវាគ្មិន និងការទទួលពានរង្វាន់លំដាប់អន្តរជាតិ

ដោយបានទទួលស្គាល់ និងវាយតម្លៃខ្ពស់លើប្រសិទ្ធភាពនៃការងារក្នុងការគ្រប់គ្រងអតិផរណា អត្រាប្តូរប្រាក់ និងការអភិវឌ្ឍប្រព័ន្ធធនាគារ លោកជំទាវ ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ត្រូវបានទស្សនាវដ្តីអន្តរជាតិ Global Finance ផ្តល់ចំណាត់ថ្នាក់ A- ជាអ្នកដឹកនាំធនាគារកណ្តាលមានប្រសិទ្ធភាពនៅលើពិភពលោក។ មិនត្រឹមតែប៉ុណ្ណោះ លោកជំទាវ ទេសាភិបាល ក៏បានទទួលពានរង្វាន់អតីតនិស្សិតអន្តរជាតិឆ្នើមពីសាកលវិទ្យាល័យ Adelaide (The University of Adelaide) នៃប្រទេសអូស្ត្រាលី ដែលបញ្ជាក់ពីសមិទ្ធផលការងារលេចធ្លោរបស់លោកជំទាវ ក្នុងការប្រើប្រាស់ចំណេះជំនាញពីការសិក្សា ដើម្បីចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

បន្ថែមលើនេះ ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ក៏បានអញ្ជើញចូលរួមជាវាគ្មិនចែករំលែកបទពិសោធគន្លឹះ នៅក្នុងព្រឹត្តិការណ៍អន្តរជាតិនានា ដូចជា៖ i/- ព្រឹត្តិការណ៍ G20 នៅទីស្នាក់ការកណ្តាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ii/- វេទិកាសេដ្ឋកិច្ចពិភពលោក ឆ្នាំ២០២៤ នៅទីក្រុងដាវូស ប្រទេសស្វីស iii/- វេទិកាពិភាក្សារបស់ស្ថាប័នសារព័ត៌មានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលំដាប់ពិភពលោក Bloomberg នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក iv/- កម្មវិធី Nikkei Forum ឆ្នាំ២០២៤ នៅជប៉ុន v/- កិច្ចប្រជុំកំពូលបច្ចេកវិទ្យាហិរញ្ញវត្ថុឌុយបៃ នៅអេមីរ៉ាតអារ៉ាប់រួម vi/- ពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុជប៉ុន ឆ្នាំ២០២៤ នៅប្រទេសជប៉ុន vii/- ពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុ ឆ្នាំ២០២៤ នៅប្រទេសសិង្ហបុរី viii/- កិច្ចពិភាក្សាក្នុងវេទិកានិយ័តករហិរញ្ញវត្ថុកម្រិតខ្ពស់ប្រចាំតំបន់អាស៊ី នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ix/- កិច្ចពិភាក្សាក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតធនាគារជាតិរវ៉ាន់ដា នៅប្រទេសរវ៉ាន់ដា x/- កិច្ចពិភាក្សាស្តីពី "អន្តរកាលហិរញ្ញវត្ថុក្នុងការត្រួតពិនិត្យធនាគារ" ក្នុងវេទិកានិយ័តករហិរញ្ញវត្ថុកម្រិតខ្ពស់ប្រចាំតំបន់អាស៊ី នៅទីក្រុងតូក្យូ ប្រទេសជប៉ុន និង xi/- ពិព័រណ៍ផលិតផលបច្ចេកវិទ្យា FrancoTech 2024 នៅទីក្រុងប៉ារីស ប្រទេសបារាំង ជាដើម។

ប្រធានបទសំខាន់ៗដែលបានចែករំលែកក្នុងព្រឹត្តិការណ៍អន្តរជាតិខាងលើ មានដូចជា ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការប្រើប្រាស់ប្រព័ន្ធទូទាត់បាគង ការប្រើប្រាស់ប្រព័ន្ធទូទាត់ឆ្លងដែនតាមយូអរកូត ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការអនុវត្តគោលការណ៍គាំទ្រការផ្តល់ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅក្នុងប្រព័ន្ធធនាគារ ការវិនិយោគទុនបម្រុងអន្តរជាតិលើសញ្ញាបណ្ណបៃតង ការគិតគូរពីបរិស្ថានក្នុងប្រព័ន្ធហិរញ្ញវត្ថុ និងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនិងនវានុវត្តន៍ ជាដើម។

បន្ថែមលើពានរង្វាន់ពីរខាងលើ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ត្រូវបានស្ថាប័នលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ (The Money Awareness and Inclusion Awards - MAIAs) ចាត់ចូលក្នុងបញ្ជីឥស្សរជនឆ្នើម ៥០រូប "MAIA Money Changers" ឆ្នាំ២០២៤ ដែលជាការទទួលស្គាល់សមិទ្ធផលការងាររបស់លោកជំទាវ ក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងបរិយាបន្នហិរញ្ញវត្ថុ។







លោកជំទាវបណ្ឌិត ជា សិរី ស្ថិតក្នុងបញ្ជីឥស្សរជនឆ្នើម MAIA Money Changers 2024 របស់ស្ថាប័ន MAIA

បន្ថែមលើនេះ ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ក៏បានអញ្ជើញចូលរួមជាវាគ្មិនចែករំលែកបទពិសោធគន្លឹះ នៅក្នុងព្រឹត្តិការណ៍អន្តរជាតិនានា ដូចជា៖ i/- ព្រឹត្តិការណ៍ G20 នៅទីស្នាក់ការកណ្ដាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ii/- វេទិកាសេដ្ឋកិច្ចពិភពលោក ឆ្នាំ២០២៤ នៅទីក្រុងដាវូស ប្រទេសស្វីស iii/- វេទិកាពិភាក្សារបស់ស្ថាប័នសារព័ត៌មានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលំដាប់ពិភពលោក Bloomberg នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក iv/- កម្មវិធី Nikkei Forum ឆ្នាំ២០២៤ នៅជប៉ុន v/- កិច្ចប្រជុំកំពូលបច្ចេកវិទ្យាហិរញ្ញវត្ថុឌុយបៃ នៅអេមីរ៉ាតអារ៉ាប់រួម vi/- ពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុជប៉ុន ឆ្នាំ២០២៤ នៅប្រទេសជប៉ុន vii/- ពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុឆ្នាំ២០២៤ នៅប្រទេសសិង្ហបុរី viii/- កិច្ចពិភាក្សាក្នុងវេទិកានិយ័តករហិរញ្ញវត្ថុកម្រិតខ្ពស់ប្រចាំតំបន់អាស៊ី នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ix/- កិច្ចពិភាក្សាក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦០ នៃ

ការបង្កើតធនាគារជាតិវ៉ាន់ដា នៅប្រទេសវ៉ាន់ដា x/- កិច្ចពិភាក្សាស្ដីពី "អន្តរកាលហិរញ្ញវត្ថុក្នុងការត្រួតពិនិត្យធនាគារ" ក្នុងវេទិកានិយ័តករហិរញ្ញវត្ថុកម្រិតខ្ពស់ប្រចាំតំបន់អាស៊ី នៅទីក្រុងតូក្យូ ប្រទេសជប៉ុន និង xi/- ពិព័រណ៍ផលិតផលបច្ចេកវិទ្យា FrancoTech 2024 នៅទីក្រុងប៉ារីស ប្រទេសបារាំង ជាដើម។

ប្រធានបទសំខាន់ៗដែលបានចែករំលែកក្នុងព្រឹត្តិការណ៍អន្តរជាតិខាងលើ មានដូចជា ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការប្រើប្រាស់ប្រព័ន្ធទូទាត់បាគង ការប្រើប្រាស់ប្រព័ន្ធទូទាត់ឆ្លងដែនតាមឃ្យូអរកូត ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការអនុវត្តគោលការណ៍គាំទ្រការផ្តល់ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅក្នុងប្រព័ន្ធធនាគារ ការវិនិយោគទុនបម្រុងអន្តរជាតិលើសញ្ញាបណ្ណបៃតង ការគិតគូរពីបរិស្ថានក្នុងប្រព័ន្ធហិរញ្ញវត្ថុ និងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនិងនវានុវត្តន៍ ជាដើម។




លោកជំទាវបណ្ឌិត ជា សិរី បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងវេទិកាពិភាក្សាស្ដីពី "ការបង្កើតអនាគតបច្ចេកវិទ្យាហិរញ្ញវត្ថុ៖ កិច្ចពិភាក្សាកម្រិតគោលនយោបាយអំពីបញ្ញាសិប្បនិម្មិត (AI)" ក្នុងកម្មវិធីពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុជប៉ុន នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤ នៅប្រទេសជប៉ុន




លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងវេទិកាពិភាក្សា នៃកិច្ចប្រជុំកំពូលបច្ចេកវិទ្យាហិរញ្ញវត្ថុឌុយបៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះអង្គម្ចាស់ Sheikh Maktoum bin Mohammed bin Rashid Al Maktoum (ជួរមុខ ទី៥ពីឆ្វេង) នាថ្ងៃទី៦ ឧសភា ឆ្នាំ២០២៤ នៅទីក្រុងឌុយបៃ ប្រទេសអេមីរ៉ាតអារ៉ាប់រួម



លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សា ក្នុងកម្មវិធី Nikkei Forum លើកទី២៩ ជាមួយលោកសាស្ត្រាចារ្យ Tetsuya Watanabe ប្រធានវិទ្យាស្ថានស្រាវជ្រាវ សេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ស្ដាំ) និងឯកឧត្តម Arifin Tasrif រដ្ឋមន្ត្រីក្រសួងថាមពល និងធនធានរ៉ែ ប្រទេសឥណ្ឌូណេស៊ី (ទី២ពីស្ដាំ) ក្រោមកិច្ចសម្របសម្រួលដោយលោក Kiyoshi Ando ការីនិពន្ធជាន់ខ្ពស់ នៃសារព័ត៌មាន Nikkei Asia (ឆ្វេង) នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន




ឯកឧត្តម រ័ត្ន សុវណ្ណនរៈ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមសន្និសីទកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ និងការអភិវឌ្ឍ ចិន-អាស៊ានឆ្នាំ២០២៤ ចាប់ពីថ្ងៃទី២៣-២៥ ខែកញ្ញា ឆ្នាំ២០២៤ នៅទីក្រុងណាននីង ខេត្តក្វាងស៊ីនៃសាធារណរដ្ឋប្រជាមានិតចិន







ឯកឧត្តម រ័ត្ន សុវណ្ណនរៈ បានអញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាលើប្រធានបទ "ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រកបដោយចីរភាព" ក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតធនាគារជាតិរវ៉ាន់ដា នាថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៤ នៅទីក្រុងគីហ្គាលី ប្រទេសរវ៉ាន់ដា




លោកជំទាវបណ្ឌិត ជា សិរី បានអញ្ជើញចូលរួមចែករំលែកទស្សនទានក្នុងកិច្ចពិភាក្សាស្តីពី "អន្តរកាលហិរញ្ញវត្ថុក្នុងការត្រួតពិនិត្យធនាគារ" ក្នុងវេទិកានិយ័តករហិរញ្ញវត្ថុកម្រិតខ្ពស់ប្រចាំតំបន់អាស៊ី នាថ្ងៃទី២ ខែតុលា ឆ្នាំ២០២៤ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន




ឯកឧត្តម យឹម លាត ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សា នៃពិព័រណ៍ផលិតផលបច្ចេកវិទ្យា FrancoTech 2024 ដែលជាព្រឹត្តិការណ៍អមកិច្ចប្រជុំកំពូលប្រហ្វង់កូហ្វូនឆ្នាំ២០២៤ ចាប់ពីថ្ងៃទី៣-៤ ខែតុលា ឆ្នាំ២០២៤ នៅទីក្រុងប៉ារីស ប្រទេសបារាំង




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាស្តីពីប្រធានបទ "អនាគតនៃប្រតិបត្តិការទូទាត់ឆ្លងដែន៖ កាន់តែលឿន កាន់តែសុវត្ថិភាព និងកិច្ចសហប្រតិបត្តិការល្អ" នៅក្នុងព្រឹត្តិការណ៍ G20 (G20 Event) រៀបចំឡើងដោយធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ នៅទីស្នាក់ការកណ្តាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក




លោកជំទាវបណ្ឌិត ជា សិរី បានអញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាស្តីពី "ក្តីសង្ឃឹមឆ្ពោះទៅរកកំណើនខ្ពស់ឡើងវិញ៖ ការជំរុញកំណើនសេដ្ឋកិច្ច ការគ្រប់គ្រងហានិភ័យ និងការរៀបចំគោលនយោបាយសម្រាប់អនាគត" ដែលជាកម្មវិធីពិភាក្សាដំបូងគេក្នុងវេទិកានិយ័តកម្មសាកលឆ្នាំ២០២៤ (Global Regulatory Forum 2024) រៀបចំឡើងដោយស្ថាប័នសារព័ត៌មានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលំដាប់ពិភពលោក Bloomberg នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក




លោកជំទាវបណ្ឌិត ជា សិរី បានអញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាស្តីពី "កិច្ចគាំពារឆ្អឹងខ្នងនៃសេដ្ឋកិច្ច៖ ការជំរុញកំណើនសហគ្រាសធុនតូចនិងមធ្យមជាសកល តាមរយៈនវានុវត្តន៍ឌីជីថល" ក្នុងពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី (Singapore Fintech Festival) នាថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅប្រទេសសឹង្ហបុរី




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ឯកឧត្តមបណ្ឌិត P. Nandalal Weerasinghe ទេសាភិបាល ធនាគារកណ្តាលស្រីលង្កា ឯកឧត្តមបណ្ឌិត Sethaput Suthiwartnarueput ទេសាភិបាល ធនាគារកណ្តាលថៃ ឯកឧត្តម Abdul Rasheed Ghaffour ទេសាភិបាល ធនាគារកណ្តាលម៉ាឡេស៊ី និងលោក Pierre-Olivier Gourinchas សេដ្ឋវិទូជាន់ខ្ពស់ មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងវេទិកាពិភាក្សានៃសន្និសីទថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃបណ្តាប្រទេសជាសមាជិកមជ្ឈមណ្ឌលស៊ាសិន លើកទី៦០ នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ នៅទីក្រុងសេអ៊ូល សាធាណរដ្ឋកូរ៉េ (ពីស្តាំទៅឆ្វេង)

## ៧- ការរួមចំណែកក្នុងការងារសង្គម

ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទធនាគារជាតិនៃកម្ពុជា បានចូលរួមក្នុងសកម្មភាពសង្គមសប្បុរសធម៌ ជាពិសេសក្នុងវិស័យអប់រំ សុខាភិបាល និងសាសនារួមមាន៖ i/- សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការសាលាមត្តេយ្យសហគមន៍ "រក្សាកុមារ" នៅក្នុងភូមិកាលមេឃ ឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ ii/- ផ្តល់រង្វាន់លើកទឹកចិត្តលោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស វិទ្យាល័យតាអោក និងវិទ្យាល័យកំពង់ឈើទាល ក្នុងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលបានប្រឡងជាប់ជាស្ថាពរ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០២៣-២០២៤ iii/- សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសសិង្ហបុរី មូលនិធិចក្ខុខ្មែរ និងអង្គការផ្តល់នូវក្តីសង្ឃឹមកម្ពុជា ជួយពិនិត្យនិងព្យាបាលភ្នែក-ត្រចៀក ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ក្នុងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ iv/- សម្ពោធឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលផ្សេងៗទៀត ស្ថិតនៅក្នុងវត្តល្អក់ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ v/- សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអាគារសិក្សាចំនួន ៣ខ្នង នៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ និងកម្មវិធីបញ្ចុះបឋមសិលាកសាងអាគារសិក្សា ចំនួន ១ខ្នង ស្ថិតនៅក្នុងស្រុកប្រាសាទ-បល្ល័ង្គ ខេត្តកំពង់ធំ vi/- ចុះសួរសុខទុក្ខ និងនាំយកនូវអំណោយជាសម្ភារៈនិងស្បៀងអាហារមួយចំនួនចែកជូនប្រជាពលរដ្ឋដែលជួបការលំបាកក្នុងជីវភាពរស់នៅ ស្ថិតក្នុងស្រុកប្រាសាទសំបូរ និងស្រុកសន្ទុក vii/- សម្ពោធខ្លោងទ្វារវត្ត និងសមិទ្ធផលនានា ក្នុងវត្តពោធិព្រឹក្សាខារាម (ហៅវត្តតូប) នៅស្រុកទឹកឈូ ខេត្តកំពត viii/- ចុះជួបសំណេះសំណាលសួរសុខទុក្ខនិងចែកអំណោយជាស្បៀងអាហារ ព្រមទាំងថវិកាមួយចំនួនជូនប្រជាពលរដ្ឋ ៣០០ គ្រួសារដែលមានជីវភាពខ្វះខាត និងរងផលប៉ះពាល់ដោយសារទឹកជំនន់ នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ix/- រៀបចំសិក្ខាសាលាស្តីពី ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា សិស្សថ្នាក់ទី១២ នៅស្រុកសន្ទុក ខេត្តកំពង់ធំ x/- ចុះសួរសុខទុក្ខនិងចែកអំណោយជូនគ្រួសារក្រីក្រចំនួន ២០០គ្រួសារ នៅស្រុកសន្ទុក ខេត្តកំពង់ធំ និង

xi/- សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការបន្ទប់កំព្យូទ័រ Lab ពីរបន្ទប់នៅវិទ្យាល័យនៃឃុំតាំងក្រសាំង និង ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានកំព្យូទ័រចំនួន ៥០ គ្រឿង និង LCD Projector ចំនួន ២។





លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតី និងកាត់ខ្សែបូសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សាលាមត្តេយ្យសហគមន៍ "រក្សាកុមារ" ដែលស្ថិតក្នុងភូមិកាលមេឃ ឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤





លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញសំណេះសំណាល និងផ្តល់រង្វាន់លើកទឹកចិត្តលោកគ្រូ-អ្នកគ្រូ និងសិស្សវិទ្យាល័យតាអោក និងវិទ្យាល័យកំពង់ឈើទាល ក្នុងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលបានប្រឡងជាប់ជាស្ពាពរសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា២០២៣-២០២៤ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤





លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចុះសួរសុខទុក្ខ និងចែកអំណោយជូនគ្រួសារក្រីក្រចំនួន ២០០គ្រួសារ នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៤ នៅស្រុកសន្ទុក ខេត្តកំពង់ធំ




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមក្នុងពិធីបើកសិក្ខាសាលាស្ដីពី “ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា” សម្រាប់សិស្សានុសិស្សថ្នាក់ទី១២ នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៤ នៅស្រុកសន្ទុក ខេត្តកំពង់ធំ




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខ និងចែកអំណោយជាស្បៀងអាហារ នាថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤ នៅសាលាស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាអធិបតីសម្ពោធខ្លោងទ្វារវត្ត និងសមិទ្ធផលនានាក្នុងវត្តពោធិព្រឹក្សារាម (ហៅវត្តតូប) នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤ នៅភូមិត្រពាំងព្រីងខាងជើង ឃុំត្រពាំងព្រីង ស្រុកទឹកឈូ ខេត្តកំពត




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអាគារសិក្សា នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៤ នៅវិទ្យាល័យតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញសួរសុខទុក្ខប្រជាជនដែលបានចូលរួម
កម្មវិធីពិនិត្យភ្នែក និងត្រចៀកដោយឥតគិតថ្លៃ នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៤ នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សាមួយខ្នង
ដែលបានជួយកែលម្អរួចរាល់ នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ នៅសាលាបឋមសិក្សាភូមិបន្ទាយយោមរាជ ឃុំប្រាសាទ ស្រុកសន្ទុក ខេត្តកំពង់ធំ




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងក្រុមការងារ បានអញ្ជើញជាអធិបតី និងកាត់ខ្សែបូ
ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការបន្ទប់កុំព្យូទ័រ Labs មួយបន្ទប់នៅវិទ្យាល័យ ហ៊ុន សែន ភ្នំសន្ទុក ក្នុងភូមិជីមាយ
ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤





លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាអធិបតីថ្លែងមតិសំណេះសំណាល ក្នុងពិធីសម្ពោធ ដាក់ឱ្យប្រើប្រាស់អគារពុទ្ធិកសិក្សារាជបូណ៌ ដែលស្ថិតនៅក្នុងវត្តរាជបូណ៌ ឬវត្តបូណ៌ ខេត្តសៀមរាប នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤

សរុបមក ទំនាក់ទំនងសាធារណៈជាផ្នែកមួយយ៉ាងសំខាន់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនជំនឿទុកចិត្តរបស់សាធារណជននិងស្ថាប័នពាក់ព័ន្ធមកលើធនាគារជាតិនៃកម្ពុជា ជាពិសេសការអនុវត្តគោលនយោបាយ និងវិធានការនានាដែលត្រូវបានដាក់ចេញ។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាបានបន្តរៀបចំនិងពង្រឹងជាប្រចាំនូវកម្មវិធីផ្សព្វផ្សាយទូលំទូលាយ សិក្ខាសាលា និងពិព័រណ៍ពាក់ព័ន្ធនឹងសកម្មភាពលើកកម្ពស់ប្រាក់រៀល ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងប្រព័ន្ធបាគង ទាំងនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត។

## សេចក្តីសន្និដ្ឋាន

នាឆ្នាំ២០២៤នេះ សេដ្ឋកិច្ចកម្ពុជាបន្តងើបឡើងជាលំដាប់ និងរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរ បើទោះជាសេដ្ឋកិច្ចពិភពលោកប្រឈមនឹងភាពមិនច្បាស់លាស់ដែលបណ្តាលមកពីភាពតានតឹងភូមិសាស្ត្រនយោបាយក៏ដោយ។ អត្រាអតិផរណាបានបន្តថយចុះមកកម្រិតទាប ក្នុងពេលដែលអត្រាប្តូរប្រាក់រៀលបានឡើងថ្លៃបន្តិចធៀបនឹងឆ្នាំ២០២៣។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិបានកើនឡើងនិងមានកម្រិតខ្ពស់គ្រប់គ្រាន់ សម្រាប់គាំទ្រដល់ការអនុវត្តនយោបាយរូបិយវត្ថុនិងពង្រឹងជំនឿទុកចិត្តវិនិយោគិនមកលើសេដ្ឋកិច្ចកម្ពុជា។

ប្រព័ន្ធធនាគារបន្តមានវឌ្ឍនភាព និងរក្សាបានភាពធន់ទាំងផ្នែកដើមទុននិងសន្ទនីយភាព ដែលបានរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច។ វិធានការមីក្រូនិងម៉ាក្រូប្រុងប្រយ័ត្ន ត្រូវបានអនុវត្តប្រកបដោយបុរេសកម្ម ស្របតាមស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរួមចំណែកដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជួយដល់ប្រជាជនដែលជួបការលំបាក និងរក្សានិរន្តរភាពសកម្មភាពអាជីវកម្ម។ ទន្ទឹមនេះ បរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ត្រូវបានលើកកម្ពស់ជាប្រចាំ ដែលបានបង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការប្រកបដោយប្រសិទ្ធភាព។

ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានធ្វើទំនើបកម្ម ដោយបានគាំទ្រដល់កំណើនសកម្មភាពពាណិជ្ជកម្ម បង្កើនបរិយាបន្នហិរញ្ញវត្ថុ ជំរុញសេដ្ឋកិច្ចឌីជីថល និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ លើសពីនេះ កម្មវិធីទូទាត់បាគងទេសចរត្រូវបានដាក់ឱ្យដំណើរការ ស្របពេលដែលការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ជាមួយបណ្តាប្រទេសជាច្រើនក្នុងតំបន់ និងក្រុមហ៊ុនផ្តល់សេវាទូទាត់អន្តរជាតិនានា ត្រូវបានពង្រីកជាលំដាប់ ដែលបានសម្រួលដល់ការធ្វើពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងការផ្ទេរប្រាក់ឆ្លងដែនឱ្យមានភាពងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាព។

ដោយឡែក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអាជ្ញាធរត្រួតពិនិត្យបានរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹង តម្លាភាព និងជំនឿទុកចិត្តនៃវិស័យហិរញ្ញវត្ថុ តាមរយៈការពង្រឹងការអនុវត្តច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដោយបានបន្តអនុវត្តជាប្រចាំនូវការវិភាគប្រតិបត្តិការ ការត្រួតពិនិត្យបុគ្គលរាយការណ៍ ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្រុក និងអន្តរជាតិ និងការបណ្តុះបណ្តាលនិងផ្សព្វផ្សាយនានា ព្រមទាំងបានបន្តដឹកនាំ និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ យ៉ាងយកចិត្តទុកដាក់ក្នុងការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

ម្យ៉ាងទៀត កិច្ចសហប្រតិបត្តិការអន្តរជាតិទាំងក្នុងក្របខណ្ឌទ្វេភាគីនិងពហុភាគី ត្រូវបានលើកកម្ពស់ជាប្រចាំ ដែលបានរួមចំណែកជំរុញសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅក្នុងតំបន់និងពិភពលោក និងពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ បរិយាបន្ន និងចីរភាព។ ធនាគារជាតិនៃកម្ពុជាក៏បានបន្តអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងពង្រឹងអភិបាលកិច្ច ដែលបានលើកកម្ពស់ប្រសិទ្ធភាពការងារ និងគុណភាពនៃការផ្តល់សេវាធនាគារកណ្តាលជូនដល់ក្រសួង-ស្ថាប័នសាធារណៈ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

# ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារ ឆ្នាំ២០២៥

## ទស្សនវិស័យ និងទិសដៅការងារ ឆ្នាំ២០២៥

សេដ្ឋកិច្ចពិភពលោកឆ្នាំ២០២៥ ត្រូវបានព្យាករថាមានកំណើន ៣,៣% ខ្ពស់ជាងកំណើនឆ្នាំ២០២៤ (៣,២%) ដែលក្នុងនោះ ប្រទេសអភិវឌ្ឍន៍នឹងរក្សាកំណើន ១,៩% ប្រទេសកំពុងលូតលាស់ និងកំពុងអភិវឌ្ឍ ៤,២% និងប្រទេសអាស៊ានបង្កើនល្បឿនកំណើន ៤,៧% ខណៈដែលកំណើនប្រទេសចិនអាចថយល្បឿនបន្តិចថែមទៀត ក្នុងអត្រា ៤,៦%។ ទន្ទឹមនេះ កំណើនសេដ្ឋកិច្ចពិភពលោកអាចនឹងប្រឈមបញ្ហាចម្បងៗមួយចំនួន រួមមាន៖ i/-ភាពមិនច្បាស់លាស់នៃគោលនយោបាយគាំពារនិយម តាមរយៈការដាក់របាំងពាណិជ្ជកម្ម ii/-ស្ថានការណ៍កាន់តែធ្ងន់ធ្ងរនៃភាពតានតឹងភូមិសាស្ត្រនយោបាយ ដែលប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់សារជាថ្មី iii/-ការកើនឡើងនៃការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ចដែលមានឥទ្ធិពលដល់លំហូរវិនិយោគ និងពាណិជ្ជកម្មអន្តរជាតិ iv/-កំណើនបំណុលសាធារណៈក្នុងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍ v/-កំណើនទាបជាងការរំពឹងទុកនៃប្រទេសចិនដែលអាចប៉ះពាល់បន្តដល់ប្រទេសក្នុងតំបន់ និង vi/-ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ជាដើម។

**ហានិភ័យនិងបញ្ហាប្រឈមនៃសេដ្ឋកិច្ចពិភពលោក**



### កំណើនសេដ្ឋកិច្ចពិភពលោក តំបន់ និងបណ្តាប្រទេសមួយចំនួន[១]



| | ពិភពលោក | ប្រទេសអភិវឌ្ឍន៍ | ប្រទេសកំ. លូតលាស់ និងអភិ. | អាមេរិក | តំបន់អឺរ៉ូ | ចក្រភពអង់គ្លេស | ចិន[២] | អាស៊ាន[៣] |
|---|---|---|---|---|---|---|---|---|
| ២០២៥ | ៣,៣ | ១,៩▲ | ៤,២ | ២,៧ ▼ | ១,0 ▲ | ១,៦▲ | ៤,៦ ▼ | ៤,៧▲ |
| ២០២៤ | ៣,២ | ១,៧ | ៤,២ | ២,៨ | 0,៨ | 0,៩ | ៤,៨ | ៤,៦ |

សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានកំណើន ៦,២% នៅឆ្នាំ២០២៥ ដែលគាំទ្រជាចម្បងដោយកំណើននៃការនាំចេញផលិតផលក្នុងវិស័យកម្មន្តសាលកាត់ដេរ និងការបន្តកើនឡើងនៃផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ស្របពេលដែលវិស័យទេសចរណ៍និងកសិកម្មបន្តមានវឌ្ឍនភាពល្អ ទោះជាវិស័យសំណង់និងអចលនទ្រព្យបន្តមានភាពទន់ខ្សោយនៅឡើយក៏ដោយ។ ក្នុងវិស័យឧស្សាហកម្ម កំណើនតម្រូវការខាងក្រៅ ជាពិសេសប្រទេសដៃគូពាណិជ្ជកម្មធំៗរបស់កម្ពុជា ដូចជា សហរដ្ឋអាមេរិក និងតំបន់អឺរ៉ូ នឹងទ្រទ្រង់ដល់ការបន្តងើបឡើងនៃវិស័យកាត់ដេរដែលរំពឹងថាសម្រេចបានកំណើន ៩,៤% ស្របពេលដែលវិស័យកម្មន្តសាលមិនមែនកាត់ដេរនឹងកើនឡើងក្នុងអត្រា ៨,១% ដែលគាំទ្រដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលកម្ពុជាទទួលបានកន្លងមក និងការបន្តធ្វើពិពិធកម្មដៃគូពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា។ ចំពោះវិស័យសេវា ភាពប្រសើរឡើងនៃស្ថានភាពទេសចរណ៍ក្នុងតំបន់ និងការដាក់ចេញវិធានការគាំទ្រជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលនឹងជួយទ្រទ្រង់ដល់ការបន្តងើបឡើងវិញនៃវិស័យទេសចរណ៍ក្នុងអត្រា ១៦,៣%។ ទន្ទឹមនេះ ការជួញដូរដុំនិងរាយក៏ត្រូវបានរំពឹងថាបន្តងើបឡើងក្នុងរង្វង់ ៩,៨% ដែលគាំទ្រដោយតម្រូវការប្រើប្រាស់ក្នុងស្រុក និងកំណើននៃចំនួនភ្ញៀវអន្តរជាតិ។ វិស័យកសិកម្មរំពឹងថានឹងមានកំណើន ១,១% ដោយសារភាពអំណោយ-ផលនៃកត្តាអាកាសធាតុ និងភាពប្រសើរឡើងនៃប្រព័ន្ធធារាសាស្ត្រ ស្របពេលដែលវិស័យសំណង់និងអចលនទ្រព្យត្រូវបានរំពឹងថានឹងកើន ១,៨% និង ១,២% រៀងគ្នា ដែលគាំទ្រជាចម្បងដោយគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈរបស់រាជរដ្ឋាភិបាល។

ប្រព័ន្ធធនាគារនឹងបន្តអភិវឌ្ឍដោយរឹងមាំ និងបន្តដើរតួនាទីយ៉ាងសកម្មក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ច តាមរយៈការផ្តល់ឥណទានទៅកាន់វិស័យឯកជន ដែលរំពឹងថាកើនឡើងក្នុងអត្រាមធ្យម ៦% ដែលជួយបង្កើនការវិនិយោគនិងការប្រើប្រាស់។ ជាមួយគ្នានេះ ការបន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់អេឡិចត្រូនិក នឹងរួមចំណែកសម្រួលដល់សកម្មភាពប្រើប្រាស់ក្នុងស្រុក ជំរុញពាណិជ្ជកម្មឆ្លងដែន ការវិនិយោគ និងទេសចរណ៍ ស្របតាមចក្ខុវិស័យនៃការកសាងសេដ្ឋកិច្ចឌីជីថលនិងនវានុវត្តន៍។

---

[១] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក, IMF, ខែមករា ឆ្នាំ២០២៥។

[២] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក, IMF, ខែមករា ឆ្នាំ២០២៥។

[៣] អាស៊ាន រួមមាន ប្រទេសព្រុយណេ កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។

## អតិផរណាព្យាករណ៍[៤]

អតិផរណាជាមធ្យមនៅឆ្នាំ២០២៥ ត្រូវបានព្យាករថាមានកម្រិតសមស្រប ២,៦% ខ្ពស់ជាងឆ្នាំ២០២៤ (០,៨%)។ ការព្យាករនេះត្រូវបានធ្វើឡើង ក្រោមការសន្មតថា៖ i/-តម្រូវការខាងក្រៅនិងក្នុងស្រុកនឹងកើនឡើង ដោយសារសេដ្ឋកិច្ចពិភពលោកបន្តរក្សាកំណើន ស្របពេលដែលសេដ្ឋកិច្ចកម្ពុជាបន្តងើបឡើងថែមទៀត ii/-ប្រាក់ដុល្លារអាមេរិកនឹងមិនថយថ្លៃគួរឱ្យកត់សម្គាល់ទេ ថ្វីបើអត្រាការប្រាក់គោលអាចត្រូវកាត់បន្ថយថែមទៀតក៏ដោយ ដោយសារទំនុកចិត្តលើរដ្ឋាភិបាលថ្មីរបស់សហរដ្ឋអាមេរិក និង iii/-ការប្រែប្រួលអាកាសធាតុ ដែលកត្តាទាំងនេះបង្កើនសម្ពាធអតិផរណារបស់កម្ពុជា ខណៈដែល iv/-ភាពតានតឹងភូមិសាស្ត្រនយោបាយនឹងមិនបណ្តាលឱ្យថ្លៃប្រេងនិងម្ហូបអាហារពិភពលោកកើនឡើងវិញជាគំហុកទេ។

**ក្រាហ្វ ៩២៖ អតិផរណាព្យាករណ៍**

(គិតជាភាគរយ, ឆ្នាំ២០២៥ព)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា *ព=ព្យាករណ៍

### តារាង ៣៖ ការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជា ដោយរាជរដ្ឋាភិបាលនិងស្ថាប័នអន្តរជាតិនានា

| | ឆ្នាំ២០២៤ប | ឆ្នាំ២០២៥ព |
|---|---|---|
| រាជរដ្ឋាភិបាល | ៦,០% | ៦,៣% |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | ៥,៥% | ៥,៨% |
| ធនាគារពិភពលោក (WB) | ៥,៣% | ៥,៥% |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ៥,៨% | ៦,០% |
| អង្គភាព AMRO | ៥,៦% | ៥,៩% |

*សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

[៤] ការព្យាករត្រូវបានធ្វើឡើងដោយបញ្ចូលគ្នា តាមរយៈវិធាន Bayes រវាង ១/-ការវិនិច្ឆ័យលើគន្លងអតិផរណានាពេលអនាគត និង ២/-ការព្យាករដោយប្រើម៉ូដែល ARIMA (p,d,q) ព្យាករសន្ទស្សន៍ថ្លៃក្រុមទាំង ១២ នៅក្នុងកន្ត្រកទំនិញប្រើប្រាស់។

ជាមួយនឹងសុទិដ្ឋិនិយមនៃកំណើនសេដ្ឋកិច្ច កម្ពុជាក៏ប្រឈមនឹងហានិភ័យមួយចំនួន ដែលភាគច្រើនជាហានិភ័យក្រៅប្រទេស រួមមាន៖ i/-កំណើនទាបជាងការរំពឹងទុកនៃសេដ្ឋកិច្ចពិភពលោក និងតំបន់ ជាពិសេសប្រទេសដៃគូសំខាន់ៗ ដូចជា សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ii/-ភាពមិនច្បាស់លាស់នៃលំហូរទុន និងការរឹតត្បិតស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិ iii/-ការថយចុះនៃសេដ្ឋកិច្ចចិន ដែលនាំឱ្យការវិនិយោគនិងចំនួនទេសចរចិនថយចុះ និង iv/-ការប្រែប្រួលអាកាសធាតុ ដែលអាចបន្ថយកំណើនក្នុងវិស័យកសិកម្មជាដើម ខណៈដែលបញ្ហាប្រឈមជារចនាសម្ព័ន្ធមួយចំនួននឹងបន្តដាក់សម្ពាធលើល្បឿនកំណើនសេដ្ឋកិច្ចកម្ពុជា។

**កត្តាអំណោយផល ហានិភ័យ និងបញ្ហាប្រឈមចំពោះកំណើនសេដ្ឋកិច្ចកម្ពុជា**

**កត្តាអំណោយផល**

+ការកើនឡើងវិញនៃការវិនិយោគក្នុងតំបន់
+មានទីតាំងភូមិសាស្ត្រនៅចំកណ្តាលអាស៊ាន
+ការកើនឡើងការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម
+លទ្ធភាពខ្ពស់នៃវិស័យធនាគារក្នុងការឆ្លើយតបនឹងតម្រូវការហិរញ្ញប្បទានក្នុងពេលមានវិបត្តិ
+សេដ្ឋកិច្ចមានភាពបើកទូលាយ និងសមាហរណកម្មខ្ពស់
+ស្ថិរភាពនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
+កត្តាភាគលាភប្រជាសាស្ត្រ

**ហានិភ័យ**

-កំណើនទាបជាងការរំពឹងទុកនៃសេដ្ឋកិច្ចពិភពលោក និងតំបន់ ជាពិសេសសហរដ្ឋអាមេរិក និងអឺរ៉ុប
-កំណើនទន់ខ្សោយនៃវិស័យសំណង់និងអចលនទ្រព្យ
-ការកើនឡើងនៃឥណទានមិនដំណើរការ
-ការប្រែប្រួលអាកាសធាតុដែលអាចបន្ថយកំណើនក្នុងវិស័យកសិកម្ម
-ឧក្រិដ្ឋកម្មសាយប័រ
-ភាពតានតឹងភូមិសាស្ត្រនយោបាយ
-ការបែកចែកភូមិសាស្ត្រសេដ្ឋកិច្ច

ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ច និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបន្តអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានកំណត់ទិសដៅការងារសំខាន់ៗសម្រាប់ឆ្នាំ២០២៥ ដូចខាងក្រោម៖

## ១- ការអនុវត្តនយោបាយរូបិយវត្ថុ

- គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប
- រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដោយតាមដាននិងធ្វើអន្តរាគមន៍តាមការចាំបាច់ ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជនលើរូបិយវត្ថុជាតិ
- លើកកម្ពស់ការប្រើប្រាស់និងចំណេះដឹងពីប្រាក់រៀល
- កែលំអ និងពង្រឹងប្រសិទ្ធភាពឧបករណ៍នយោបាយរូបិយវត្ថុដែលមាន និងអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុថ្មីៗ
- អភិវឌ្ឍក្របខណ្ឌក្លីដ័រអត្រាការប្រាក់ និង

- លើកកម្ពស់ការយល់ដឹងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្ដីពី ក្របខណ្ឌនិងឧបករណ៍នយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

## ២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

- រៀបចំសេចក្ដីណែនាំការវិនិយោគសម្រាប់ឆ្នាំ២០២៥
- ធ្វើបច្ចុប្បន្នកម្មក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនៅក្នុងនាយកដ្ឋានគ្រប់គ្រងទុនបម្រុងឱ្យស្របតាមស្តង់ដារអន្តរជាតិ
- បន្តតាមដានស្ថានភាពទីផ្សារហិរញ្ញវត្ថុសកល បណ្ដាប្រទេសអភិវឌ្ឍន៍ និងប្រទេសទីផ្សារកំពុងលូតលាស់ ដើម្បីត្រៀមរៀបចំយុទ្ធសាស្ត្រវិនិយោគដែលមានភាពបត់បែនប្រកបដោយសុវត្ថិភាព សន្ទនីយភាព និងស្វែងរកចំណូលសមស្រប
- បន្តសិក្សារៀបចំសេចក្ដីណែនាំការវិនិយោគសម្រាប់គ្រប់គ្រងមូលនិធិសោធន ដោយរៀនសូត្រពីបទពិសោធរបស់បណ្ដាធនាគារកណ្ដាលផ្សេងៗលើការគ្រប់គ្រងមូលនិធិសោធន
- ស្វែងរកឱកាសវិនិយោគទាំងក្នុង និងក្រៅប្រទេសសម្រាប់ទុនមូលនិធិសោធន
- បន្តសិក្សាស្រាវជ្រាវលើឧបករណ៍វិនិយោគថ្មីៗ ដើម្បីសម្រេចបានពិពិធកម្មហានិភ័យ និងបង្កើនចំណូល និង
- បន្តសិក្សាពីឱកាស និងលទ្ធភាពពង្រីកការវិនិយោគក្រោមក្របខណ្ឌការវិនិយោគប្រកបដោយការទទួលខុសត្រូវលើបរិស្ថាន សង្គម និងអភិបាលកិច្ចល្អ។

## ៣- ប្រព័ន្ធទូទាត់សងប្រាក់

- បន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ក្នុងនោះរួមមានប្រព័ន្ធទូទាត់រាយ និងប្រព័ន្ធទូទាត់តម្លៃធំ
- បន្តអនុវត្តគម្រោងទូទាត់ និងផ្ទេរប្រាក់ឆ្លងដែនជាមួយប្រទេសក្នុងតំបន់ និងប្រទេសដៃគូ
- បន្តលើកកម្ពស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ស្របតាមផែនទីមគ្គុទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ២០២០-២០២៥ និងបន្តរៀបចំវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា
- បន្តលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល និងការប្រើប្រាស់ប្រព័ន្ធបាគងឱ្យកាន់តែទូលំទូលាយ និងបន្តការអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ជំហានបន្ទាប់ និង
- បន្តតាមដាន និងត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

## ៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- តាមដានជាប្រចាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈការត្រួតពិនិត្យលើឯកសារ ការចុះត្រួតពិនិត្យដល់ទីកន្លែង និងការធ្វើស្ត្រេសតេស្ត ព្រមទាំងការតាមដានការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- ពិនិត្យឡើងវិញលើសេណារីយ៉ូនៃការធ្វើស្ត្រេសតេស្តចំពោះអនុបាតភាពគ្រប់គ្រាន់នៃដើមទុន អនុបាតឥណទានមិនដំណើរការ និងអនុបាតក្របខណ្ឌសន្ទនីយភាព និង
- ធ្វើបច្ចុប្បន្នកម្មវិធីសាស្ត្រត្រួតពិនិត្យ ស្របតាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។

## ៥- ការងារបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ

- បញ្ចប់គម្រោងរៀបចំសេចក្ដីព្រាងប្រកាសទាក់ទងនឹងសាធនភាព និងសន្ទនីយភាព សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។
- ពង្រឹងកិច្ចការពារអតិថិជន និងការដោះស្រាយបណ្ដឹង តាមរយៈការបណ្ដុះបណ្ដាលមន្ត្រីទទួលបន្ទុកដោះស្រាយបណ្ដឹងអតិថិជន និងផ្សព្វផ្សាយនូវកម្រងឯកសារថ្មីៗបន្ថែមទៀត
- ធ្វើបច្ចុប្បន្នភាពលើប្រកាសស្ដីពី ការដោះស្រាយបណ្ដឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងសិក្សាលើវិធីសាស្ត្រក្នុងការដាក់ចេញនូវបទប្បញ្ញត្តិនៃកិច្ចការពារអតិថិជន (រួមទាំងការត្រួតពិនិត្យការអនុវត្តទីផ្សារ) សម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុ
- ចុះផ្សព្វផ្សាយសិក្ខាសាលា ស្ដីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ដើម្បីលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុជូនដល់ប្រជាជន និងអាជ្ញាធរតាមមូលដ្ឋាន
- បញ្ចប់ការរៀបចំផែនទីចង្អុលផ្លូវស្ដីពីចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងអនុវត្តការប្រមូលនិងការវិភាគទិន្នន័យបរិយាបន្នហិរញ្ញវត្ថុបែងចែកតាមភេទ
- វាយតម្លៃ និងត្រួតពិនិត្យឡើងវិញលើយុទ្ធសាស្ត្រជាតិ ស្ដីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥
- រៀបចំបទប្បញ្ញត្តិនិងឯកសារគតិយុត្តនានាសម្រាប់អនុវត្តយន្តការកិច្ចការពារប្រាក់បញ្ញើ
- ពិនិត្យ និងចាប់ផ្ដើមគម្រោងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ និង
- បន្តពិនិត្យ និងធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្របតាមការវិវត្តនៃស្តង់ដាអន្តរជាតិ និងប្រព័ន្ធធនាគារនៅកម្ពុជា។

## ៦- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- បន្តរៀបចំនិងសម្របសម្រួលការវាយតម្លៃហានិភ័យថ្នាក់ជាតិស្ដីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២
- បន្តតាមដានការអនុវត្តកាតព្វកិច្ចរបស់បុគ្គលរាយការណ៍ ស្របតាមច្បាប់និងបទប្បញ្ញត្តិស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បន្តអនុវត្តការចុះត្រួតពិនិត្យដល់ទីកន្លែង ចំពោះបុគ្គលរាយការណ៍ដែលស្ថិតក្នុងវិស័យធនាគារ មូលបត្រ ធានារ៉ាប់រង បរធនបាលកិច្ច អចលនវត្ថុ និងកាស៊ីណូ
- អភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីសម្រួលដល់ការងារវិភាគ
- បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិតាមរយៈការបន្តចុះអនុស្សរណៈយោគយល់ជាមួយក្រសួង-ស្ថាប័នជាតិ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអន្តរជាតិ
- បន្តពង្រឹងសមត្ថភាពមន្ត្រីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ទាក់ទងនឹងការត្រួតពិនិត្យ និងវិភាគប្រតិបត្តិការហិរញ្ញវត្ថុ តាមរយៈការចូលរួមសិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលនានា និង
- សហការជាមួយក្រសួង-ស្ថាប័នក្នុងស្រុក និងដៃគូអន្តរជាតិ ដើម្បីរៀបចំវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលា ក្នុងគោលដៅបន្តពង្រឹងចំណេះដឹងដល់បុគ្គលរាយការណ៍ និងភាគីពាក់ព័ន្ធ។

## ៧- ការងារប្រតិបត្តិការទីផ្សាររូបិយវត្ថុ

- បន្តរៀបចំការដេញថ្លៃប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា (LPCO) និងមូលបត្រអាចជួញដូរបាន (NCD) តាមកាលវិភាគដែលបានកំណត់
- បន្តអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF)
- បន្តអភិវឌ្ឍទីផ្សារអន្តរធនាគារតាមរយៈការជំរុញសកម្មភាពប្រតិបត្តិការជួញដូរនៅលើថ្នាលធនាគារជាតិនៃកម្ពុជា (NBCP) និង
- បង្កើនកិច្ចសហការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីជំរុញប្រសិទ្ធភាពឧបករណ៍នយោបាយរូបិយវត្ថុ។

## ៨- ការងារសេវាធនាគារ

- បន្តការបណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធដល់សមាជិកសភាផាត់ទាត់ជាតិនៅទីស្នាក់ការកណ្តាល និងនៅតាមបណ្តាមណ្ឌលដោះដូរមូលប្បទានប័ត្រ សាខាធនាគារជាតិនៃកម្ពុជាខេត្ត
- សហការជាមួយក្រុមការងាររៀបចំសេចក្តីព្រាងវិធាន និងនីតិវិធីប្រព័ន្ធទូទាត់សងប្រាក់រួម
- បន្តជួយគាំទ្រសមាជិកសភាផាត់ទាត់ជាតិក្នុងការធ្វើសន្ទានកម្មប្រព័ន្ធផាត់ទាត់ជាតិ (NCS) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS)
- បន្តគាំទ្រ ជំរុញ និងពង្រីកសេវាប្រព័ន្ធ Bakong និងប្រព័ន្ធធនាគារអនឡាញ (OBS)
- បន្តបង្កើនប្រសិទ្ធភាពការងារផ្តល់សេវាគ្រប់គ្រងគណនី
- សម្របសម្រួលដល់ការបោះផ្សាយមូលបត្ររដ្ឋឱ្យសម្រេចបានតាមផែនការនៃការបោះផ្សាយមូលបត្ររដ្ឋឆ្នាំ២០២៥
- សហការ និងសម្របសម្រួលពាក់ព័ន្ធនឹងការអនុញ្ញាតឱ្យគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារធ្វើប្រតិបត្តិការមូលបត្ររដ្ឋនៅលើថ្នាលធនាគារជាតិនៃកម្ពុជា (NBCP) ទាំងទីផ្សារដំបូង និងទីផ្សារបន្ទាប់
- ចូលរួមសហការជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាក់ទងនឹងគម្រោងជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ីលើការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋនៅកម្ពុជា
- ចូលរួមសិក្សាលើការបង្កើតខ្សែកោងអត្រាទិន្នផល/ខ្សែកោងអត្រាចំណូលរបស់វិនិយោគិនមូលបត្ររដ្ឋ
- បន្តផ្សព្វផ្សាយជាទៀងទាត់នូវផែនការបោះផ្សាយមូលបត្ររដ្ឋ
- បន្តរៀបចំយន្តការជួញដូរមូលបត្ររដ្ឋក្នុងទីផ្សារបន្ទាប់តាមរយៈថ្នាលធនាគារជាតិនៃកម្ពុជា (NBCP) សំដៅបង្កើតឱ្យបាននូវទីផ្សារបន្ទាប់ដែលមានលក្ខណៈពេញលេញ សន្ទនីយភាពខ្ពស់ ថ្លៃប្រតិបត្តិការនិងហានិភ័យទាប និង
- សហការរៀបចំកិច្ចពិគ្រោះយោបល់ ដើម្បីស្ទាបស្ទង់ទីផ្សារជាមួយវិនិយោគិនមូលបត្ររដ្ឋជាប្រចាំ។

## ៩- ការងារគ្រប់គ្រងសាច់ប្រាក់

- បន្តពង្រឹងសេវាបង់ និងបើកសាច់ប្រាក់ឱ្យកាន់តែល្អប្រសើរ
- ពង្រឹងការអនុវត្តការងារដឹកជញ្ជូនធនបត្រឱ្យកាន់តែមានសុវត្ថិភាព
- បង្កើនលទ្ធភាពការរាប់ស្រាស់ជ្រើសក្រដាសប្រាក់ឱ្យបានទាន់ពេលវេលា
- បន្តលើកកម្ពស់ការងារគ្រប់គ្រងសាច់ប្រាក់ និងការថែរក្សាសុវត្ថិភាពឃ្លាំងប្រាក់ និង
- បន្តពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ការចរាចរក្រដាសប្រាក់ក្លែងក្លាយ ។

## ១០- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

- អនុវត្តការងារសវនកម្មនិងអធិការកិច្ច ស្របតាមផែនការឆ្នាំ២០២៥ និងតាមការចាំបាច់
- ចូលរួមត្រួតពិនិត្យការកាត់កម្ទេចនិងដុតបំផ្លាញក្រដាសប្រាក់ចាស់ ទក់ និងរហែក
- ពិនិត្យនិងតាមដានការងារគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធធនាគារស្នូលរបស់ធនាគារជាតិនៃកម្ពុជា
- ពិនិត្យឡើងវិញលើមុខងារ-ភារកិច្ចរបស់អគ្គាធិការដ្ឋាន ឱ្យស្របតាមរចនាសម្ព័ន្ធថ្មីរបស់អគ្គនាយកដ្ឋាននានា
- សិក្សាលទ្ធភាពបង្កើតអង្គភាពគ្រប់គ្រងហានិភ័យនៅធនាគារជាតិនៃកម្ពុជា ដើម្បីឈានទៅបង្កើតក្របខណ្ឌគ្រប់គ្រងហានិភ័យ ឱ្យស្របតាមស្តង់ដាឧត្តមានុវត្ត និង
- លើកកម្ពស់សមត្ថភាពមន្ត្រី ដើម្បីបង្កើនគុណភាពការងារសវនកម្មនិងអធិការកិច្ច និងពង្រឹងការគ្រប់គ្រងហានិភ័យ ឱ្យស្របតាមនិន្នាការបច្ចុប្បន្ន។

## ១១- ការគ្រប់គ្រងសាខា

- បន្តផ្សព្វផ្សាយសេចក្តីសម្រេច ឬការណែនាំរបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ដល់បណ្តាសាខាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់
- ចូលរួមសម្របសម្រួល និងដោះស្រាយរាល់ករណីមិនប្រក្រតីទាំងឡាយ ក្នុងដំណើរការការងាររបស់សាខា
- បន្តតាមដាន និងរាយការណ៍ពីការវិវត្តនៃសកម្មភាពការងារ និងបញ្ហាប្រឈមទាំងឡាយជូនថ្នាក់ដឹកនាំ និង
- ចូលរួមសម្របសម្រួលការងាររវាងនាយកដ្ឋានជំនាញនៅទីស្នាក់ការកណ្តាល និងបណ្តាសាខាធនាគារជាតិនៃកម្ពុជា រាជធានីខេត្ត។

## ១២- ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស

- បន្តកែលំអកម្មវិធីបណ្តុះបណ្តាល និងបើកវគ្គប្រតិបត្តិការធនាគារកណ្តាល វគ្គត្រួតពិនិត្យធនាគារ វគ្គភាពជាអ្នកដឹកនាំ និងរៀបចំកិច្ចប្រជុំផ្សេងៗនៅធនាគារជាតិនៃកម្ពុជា
- បន្តរៀបចំនិងកែលំអគោលនយោបាយគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ដើម្បីធានាឱ្យបាននូវនិរន្តរភាព សុវត្ថិភាព និងប្រសិទ្ធភាពការងារ
- បន្តរៀបចំគោលនយោបាយលើកទឹកចិត្តមន្ត្រីបុគ្គលិក ដើម្បីពង្រឹងឯកទេសកម្មជំនាញត្រួតពិនិត្យធនាគារ ជំនាញវិភាគហិរញ្ញវត្ថុ(CFA) ជំនាញគណនេយ្យ(CPA/ACCA) និង

សវនកម្មផ្ទៃក្នុង(CIA)
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមប្រព័ន្ធ Online ដើម្បីឱ្យស្របតាមការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិ និង
- ពង្រឹងការងារចាត់តាំងមន្ត្រីបុគ្គលិក ស្របតាមគោលនយោបាយយុទ្ធសាស្ត្រ និងតម្រូវការការងារជាក់ស្តែង របស់ធនាគារជាតិនៃកម្ពុជា។

**១៣- កិច្ចសហប្រតិបត្តិការអន្តរជាតិ**

- សហការជាមួយមជ្ឈមណ្ឌល SEACEN និងគណៈកម្មាធិការកសាងសមត្ថភាពអាស៊ានក្រោមក្របខណ្ឌសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន រៀបចំសិក្ខាសាលាស្តីពី "គោលនយោបាយនិងសេរីភាវូបនីយកម្មគណនីមូលធន ក្រោមស្ថានភាពនៃការប្រែប្រួលលំហូរមូលធននិងហិរញ្ញប្បទាន ប្រកបដោយចីរភាពក្នុងបរិបទដុល្លារូបនីយកម្ម"
- រៀបចំចុះអនុស្សរណៈយោគយល់ជាមួយធនាគារកណ្តាលព្រុយណេ
- ពង្រីកកិច្ចសហការទ្វេភាគីជាមួយធនាគារកណ្តាលជាដៃគូក្នុងតំបន់
- ពង្រឹងបន្ថែមការធ្វើសមាហរណកម្មហិរញ្ញវត្ថុទៅក្នុងអាស៊ាន និងតំបន់ផ្សេងៗ និង
- ពង្រឹងកិច្ចសន្ទនាជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងដៃគូអភិវឌ្ឍន៍។

**១៤- ការងារស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច**

- រៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី១២ របស់ធនាគារជាតិនៃកម្ពុជា
- បន្តធ្វើអង្កេតស្តីពីទំនុកចិត្តធុរកិច្ចនៅកម្ពុជា (Business Confidence Survey) នៅតាមបណ្តារាជធានី-ខេត្ត ដើម្បីចងក្រងជាសន្ទស្សន៍ទំនុកចិត្តធុរកិច្ច (Business Confidence Index) ប្រចាំគ្រាសម្រាប់រួមចំណែកតាមដាននិងវាយតម្លៃស្ថានភាពសេដ្ឋកិច្ច
- អភិវឌ្ឍម៉ូដែលវិភាគស្ថានភាពសេដ្ឋកិច្ចដោយផ្អែកលើផ្នែកតម្រូវការ
- បន្តធ្វើបច្ចុប្បន្នភាពសូចនាករគន្លឹះ វាយតម្លៃស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងព្យាករអំពីការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លីខាងមុខ (Nowcasting and Near-term Forecasting) សម្រាប់ឆ្នាំ២០២៥ និង២០២៦
- ពង្រឹង និងអភិវឌ្ឍម៉ូដែលថ្មីៗ ដើម្បីធ្វើឱ្យការវិភាគ វាយតម្លៃ និងព្យាករស្ថានភាពសេដ្ឋកិច្ចកាន់តែប្រសើរ
- បន្តរៀបចំនិងចងក្រងព្រឹត្តិបត្រប្រចាំខែស្តីពី ស្ថានភាពសេដ្ឋកិច្ចនិងធនាគារ
- សហការជាមួយ JICA ក្នុងការសិក្សាស្រាវជ្រាវស្តីពី៖ i/-យន្តការចម្លងនយោបាយរូបិយវត្ថុ ii/-ការប៉ាន់ស្មានបរិមាណរូបិយប័ណ្ណ (ដុល្លារអាមេរិក) ក្នុងចរាចរណ៍ និង iii/-ឥទ្ធិពលនៃឌីជីថលូបនីយកម្មទៅលើប្រព័ន្ធរូបិយវត្ថុ
- សហការជាមួយ UNDP ប្រចាំកម្ពុជាដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃការសិក្សា៖ i/-ផលប៉ះពាល់នៃដុល្លារូបនីយកម្មលើវិស័យកាត់ដេរ ផលិតស្បែកជើង ទំនិញធ្វើដំណើរ និងកាបូបកម្ពុជា ii/-ការបង្កើនឱ្យដល់កម្រិតអតិបរមានៃលំហូរការផ្ទេរប្រាក់ពីប្រទេសថៃមកកម្ពុជា៖ ឧបសគ្គនិងអនុសាសន៍ដើម្បីជំរុញការផ្ទេរប្រាក់តាមរយៈប្រព័ន្ធឌីជីថល

- សហការជាមួយវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាននិងអាស៊ីបូព៌ា (ERIA) ដើម្បីរៀបចំសិក្ខាសាលានិងសិក្សាស្រាវជ្រាវស្តីពី៖ ការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជា
- ជ្រើសរើសអត្ថបទសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយក្នុងកម្រងអត្ថបទស្រាវជ្រាវរបស់ធនាគារជាតិនៃកម្ពុជា (NBC Working Paper Series) និង
- ពង្រឹងគុណភាពសិក្សាស្រាវជ្រាវឱ្យស្របតាមស្តង់ដាអន្តរជាតិ ដោយសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិ។

## ១៥- ការងារស្ថិតិ

- ដាក់ឱ្យប្រើប្រាស់ទិន្នន័យសន្ទស្សន៍ថ្លៃលំនៅដ្ឋាន (RPPI) ផ្អែកតាមវិធីសាស្ត្រកាត់បន្ថយកំហុស ដែលផ្តល់អនុសាសន៍ដោយ IMF
- រៀបចំកិច្ចប្រជុំពិភាក្សា ជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីពង្រឹងគុណភាពការរាយការណ៍ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) និងសន្ទស្សន៍ថ្លៃលំនៅដ្ឋាន (RPPI)
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយទស្សនាទានស្តីពីស្ថិតិចំណូលសេវាធ្វើដំណើរជូនអ្នកប្រើប្រាស់និងស្ថាប័នពាក់ព័ន្ធដែលជាប្រភពទិន្នន័យ ដើម្បីធ្វើឱ្យប្រសើរឡើងវិធីសាស្ត្រចងក្រងស្ថិតិចំណូលសេវាធ្វើដំណើរ
- ប្តូរការចងក្រងទិន្នន័យសូចនាករភាពរឹងមាំហិរញ្ញវត្ថុ (FSIs) ពីប្រចាំត្រីមាសទៅជាប្រចាំខែដោយប្រើប្លង់គណនីថ្មី របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង
- ដាក់ឱ្យប្រើប្រាស់ទិន្នន័យសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមបណ្តារាជធានី-ខេត្ត ដែលបានប្រមូលប្រព័ន្ធមូលដ្ឋានទិន្នន័យថ្មី ជាមួយនឹងមុខទំនិញចំនួន ៨០មុខ។

## ១៦- ការងារទំនាក់ទំនង

- សហការក្រសួងអប់រំ យុវជន និងកីឡា រៀបចំកម្មវិធីផ្សព្វផ្សាយស្តីពី "ប្រាក់រៀល និងប្រព័ន្ធបាគង" នៅតាមបណ្តារាជធានី-ខេត្ត
- រៀបចំជំនួបជាមួយនឹងអ្នកសារព័ត៌មានដើម្បីពង្រឹងការយល់ដឹងពីវិស័យសេដ្ឋកិច្ចនិងធនាគារ
- បង្កើតវីដេអូដែលមានលក្ខណៈជាសារព័ត៌មានអំពីសមិទ្ធផលថ្មីៗរបស់ធនាគារជាតិនៃកម្ពុជា និង
- ផលិតមាតិកាផ្សព្វផ្សាយ អំពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជា និងផ្សព្វផ្សាយលើបណ្តាញសង្គមផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ចំនួន ២ ដងក្នុង១សប្តាហ៍។

## ១៧- ការងារសារមន្ទីរ ស.ស.រ.

- ធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីអំពីការចូលរួមចំណែកពីវិស័យនីមួយៗក្នុងកំណើនសេដ្ឋកិច្ចកម្ពុជានៅម៉ូឌុលទី៨
- បន្តការងាររៀបចំសារមន្ទីរបាត់ដំបង និងមជ្ឈមណ្ឌលតាំងពិព័រណ៍ខេត្តកំពត
- ត្រៀមការងាររៀបចំពិព័រណ៍ក្រោមកិច្ចសហការជាមួយមូលនិធិជប៉ុនក្នុងការដាក់តាំងកម្រងរូបថតប្រវត្តិសាស្ត្រនៃទីក្រុងតូក្យូ (Tokyo Before/After)
- បង្ហើយការងារបោះពុម្ពសៀវភៅ រួមមានសៀវភៅកាតាឡុកស្តីអំពីពិព័រណ៍មិនអចិន្ត្រៃយ៍

សៀវភៅកំពុងសហការរៀបចំជាមួយគ្រឹះស្ថានបោះពុម្ពស៊ីប៉ាអំពីប្រវត្តិសេដ្ឋកិច្ច និងសារមន្ទីរ ស.ស.រ. និងសៀវភៅមគ្គុទេសក៍សម្រាប់កុមារដែលមកទស្សនាសារមន្ទីរ
- ជ្រើសរើសបុគ្គលិកសម្រាប់បម្រើការងារនៅសារមន្ទីរ ស.ស.រ. និងសារមន្ទីរបាត់ដំបង និង
- រៀបចំផែនការសម្រាប់ប្រើប្រាស់អគារធនាគារឥណ្ឌូចិន។

**១៨- ការងារវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ**

- រៀបចំដំណើរការថ្នាក់បរិញ្ញាបត្រជំនាញធនាគារ ជាមួយកម្មវិធីសិក្សាឆ្នាំទី៣ នៅដើមឆ្នាំ២០២៥
- រៀបចំផ្លាស់ប្តូរឯកសណ្ឋាននិស្សិតនៃវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ
- រៀបចំគេហទំព័រសម្រាប់វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ
- បន្តរៀបចំបង្កើនកម្រិតសិក្សាថ្នាក់អនុបណ្ឌិត ឬថ្នាក់សមមូល
- បន្តរៀបចំអភិវឌ្ឍបណ្ណាល័យទាំងបណ្ណាល័យជារូបវន្ត និងបណ្ណាល័យអេឡិចត្រូនិក
